**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**


## សារណាបញ្ចប់ការសិក្សា

# ប្រៀបធៀបការបញ្ចាំចលនវត្ថុ និងប្រាតិភោគដោយអនុប្បទាន

ស្រាវជ្រាវពីថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **ហូ ធារី**

កញ្ញា **ញ៉ូ ដាលីន**

សាស្ត្រាចារ្យណែនាំ

លោកស្រី **ប៊ួយ ធីតា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២២ (និស្សិតអាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំ **ហូ ឆារី** និងនាងខ្ញុំ **ញ៉ៅ ដាលីន** សូមសម្តែងនូវការគោរព និងរលឹកដឹងគុណដ៏ខ្ពង់ខ្ពស់ជូនចំពោះ៖

១. លោកឪពុក អ្នកម្តាយ ដែលបានចិញ្ចឹមបីបាច់ថែរក្សា ប្រៀនប្រដៅយើងខ្ញុំប្រកបដោយព្រហ្មវិហារធម៌។ លោកបានជួយផ្គត់ផ្គង់ទំនុកបម្រុង ផ្តល់ឱកាសសិក្សារៀនសូត្រតាំងពីបឋមវ័យ និងលើកទឹកចិត្តយើងខ្ញុំគ្រប់ពេលវេលារហូតដល់បានបញ្ចប់បរិញ្ញាបត្រថ្នាក់នីតិសាស្ត្រ។

២. ឯកឧត្តមសកលវិទ្យាធិការ និងគណៈគ្រប់គ្រងសាកលវិទ្យាល័យ លោក លោកស្រីដែលជាសាស្ត្រាចារ្យ និងបុគ្គលិកនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានជួយសម្របសម្រួល ផ្តល់ភាពងាយស្រួលដល់ការសិក្សាក្រេបជញ្ជក់យកចំណេះដឹងផ្នែកនីតិសាស្ត្រ និងបំណិនជីវិតផ្សេងៗក្នុងរយៈពេលបួនឆ្នាំនៃការសិក្សាថ្នាក់បរិញ្ញាបត្ររបស់យើងខ្ញុំ។

៣. លោកស្រី **ម៉ួយ ធីតា** ព្រឹទ្ធបុរសរងមហាវិទ្យាល័យនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងជាសាស្ត្រាចារ្យណែនាំសារណាមួយនេះដែលលោកស្រីសាស្ត្រាចារ្យបានចំណាយពេលវេលាយ៉ាងច្រើនក្នុងការផ្តល់ជាមតិយោបល់ និងបានជួយពិនិត្យណែនាំលើកិច្ចការស្រាវជ្រាវរបស់យើងខ្ញុំរហូតទទួលបានសមិទ្ធិផលមួយនេះ។

ជាចុងបញ្ចប់ យើងខ្ញុំសូមឱនកាយគោរពដោយសេចក្តីដឹងគុណដល់អ្នកមានគុណដែលបានរៀបរាប់ខាងលើ សូមអោយលោកជួបតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ការបញ្ចាំពុំមែនជាសញ្ញាណថ្មីនោះឡើយសម្រាប់ប្រទេសកម្ពុជា ប៉ុន្តែសញ្ញាណដែលទើបតែកកើតនោះគឺរបបគតិយុត្តនៃប្រាតិភោគដោយអនុប្បទាន។ មូលហេតុដែលបណ្តាលអោយយើងខ្ញុំសម្រេចយកប្រធានបទ **"ការប្រៀបធៀបការបញ្ចាំចលនវត្ថុ និងប្រាតិភោគដោយអនុប្បទាន"** នេះមកធ្វើការបកស្រាយ បណ្តាលមកពីការមើលឃើញនូវការភ័ន្តច្រលំនៃការអនុវត្តរវាងប្រតិបត្តិការទាំងពីរនេះ និងមានបំណងញែកអោយដាច់ពីគ្នាដើម្បីជាពុទ្ធិដល់អ្នកសិក្សា និងចូលចិត្តស្រាវជ្រាវស្វែងយល់ ឬជាកម្មវត្ថុនៃការស្រាវជ្រាវរបស់ពួកគេ។ សញ្ញាណទាំងពីរនេះបានចរាចរយ៉ាងមមាញឹកនៅគ្រប់តំបន់ទីប្រជុំជនបច្ចុប្បន្ន ដែលជាការសម្រួលនូវសេដ្ឋកិច្ចគ្រួសារប្រជាពលរដ្ឋកម្ពុជាបានមួយចំណែកធំ។

អំឡុងពេលនៃការតាក់តែងអត្ថបទនេះឡើង យើងខ្ញុំពិតជាមានភាពលំបាកដោយសារតែសញ្ញាណនៃរបបគតិយុត្តនីមួយៗ មានលក្ខណៈប្រហាក់ប្រហែលគ្នាខ្លាំង។ ការតាក់តែងត្រូវពឹងផ្អែកទាំងស្រុងទៅលើអត្ថបទនានាជាជំនួយស្មារតីស្ទើរតែទាំងស្រុង ដែលឯកសារទាំងនោះមានដូចជានៅបណ្ណាល័យ នៅកន្លែងលក់សៀវភៅ បណ្ណាគារ គ្រឹស្ថានបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ព្រមទាំងនៅតាមបណ្តាញអ៊ីនធឺណែតផងដែរ។ ការសិក្សាទៅលើប្រធានបទនេះ។ ការសរសេរចេញនូវអត្ថបទមួយនេះ យើងខ្ញុំបានប្រឹងអស់ពីកំលាំងកាយចិត្តទំរាំសម្រេចចេញជារូបរាង និងអាចញែកសញ្ញាណទាំងពីរអោយដាច់ពីគ្នាបាន ដោយហេតុថាការអនុវត្តសព្វថ្ងៃគឺវានៅជាមួយគ្នាតែម្តង។ ការខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត និងស្មារតីនេះ ទីបំផុតចេញជារូបរាងឡើងក្រោយពីការស្វាធ្យាយស្រាវជ្រាវអស់រយៈពេលប៉ុន្មានខែមកនេះ។

ជាចុងបញ្ចប់យើងខ្ញុំសង្ឃឹមថាស្នាដៃដ៏តូចមួយនេះ នឹងក្លាយជាប្រយោជន៍ដល់ការអនុវត្តសិទ្ធិលើការបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ព្រមទាំងរួមចំណែកដល់ការសិក្សាលើប្រាតិភោគចលនវត្ថុ។ យើងខ្ញុំក៏សូមមេត្តាខន្តីអភ័យទោសចំពោះរាល់កំហុសឆ្គងក្នុងការតាក់តែងនេះ ហើយក៏សូមទទួលស្វាគមន៍នូវរាល់ការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់អ្នកស្រាវជ្រាវគ្រប់រូបដើម្បីជាបច្ច័យក្នុងការកែលម្អសមិទ្ធផលមួយនេះអោយកាន់តែប្រសើរឡើងថែមមួយកម្រិតទៀត។

# មាតិកា

**ទំព័រ**


**សេចក្តីផ្តើម** ........ **១**

**ជំពូកទី១ សញ្ញាណទូទៅ** ........ **៤**

**១.១. ការវិវត្តន៍** ........ **៤**

**១.២ និដ្ឋភាពគតិយុត្ត** ........ **៦**

**១.៣ និយមន័យ** ........ **៨**

**១.៤ កម្មវត្ថុនៃកិច្ចសន្យាបញ្ចាំ** ........ **៩**

**១.៥ កម្មវត្ថុនៃកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន** ........ **១០**

**ជំពូកទី២ ការបង្កើត និងអានុភាព នៃកិច្ចសន្យាបញ្ចាំចលនវត្ថុ និងប្រាតិភោគដោយអនុប្បទាន** ........ **១២**

**២.១ ការបង្កើតកិច្ចសន្យា** ........ **១២**

២.១.១ លក្ខខណ្ឌសុពលភាព ........ ១៤

២.១.២ ទំហំនៃសិទ្ធិលើបំណុលដែលត្រូវធានា ........ ១៥

**២.២ អានុភាពនៃការបញ្ចាំចលនវត្ថុ និងប្រាតិភោគដោយអនុប្បទាន** ........ **១៦**

២.២.១ ការបញ្ចាំចលនវត្ថុ ........ ១៧

២.២.១.១ លក្ខខណ្ឌតតាំងចាំបាច់នៃសិទ្ធិលើការបញ្ចាំ ........ ១៧

ក. ការបញ្ចាំចលនវត្ថុ ........ ១៧

ខ. ការបញ្ចាំអចលនវត្ថុ ........ ១៨

គ. ការបញ្ចាំសិទ្ធិ ........ ១៩

២.២.១.២ អានុភាពចំពោះផលពីទ្រព្យបញ្ចាំ ........ ១៩

២.២.១.៣ ការប្រើប្រាស់ និងអាស្រ័យផលចំពោះការបញ្ចាំចលនវត្ថុ ........ ២០

២.២.១.៤ ការបញ្ចាំបន្ត ........ ២១

ក. ការបញ្ចាំបន្ត ដោយមានការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ........ ២១

ខ. ការបញ្ចាំបន្តក្រោមការទទួលខុសត្រូវរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ ........ ២១

២.២.១.៥ ឧបាទេសកម្មលើវត្ថុបញ្ចាំ ........ ២២

២.២.១.៦ ការហាមឃាត់ចំពោះកិច្ចសន្យាបញ្ចាំផ្តាច់ ........ ២៣

២.២.១.៧ អានុភាពលើវត្ថុភ្ជាប់នឹងវត្ថុបញ្ចាំ ....................................................................២៤
ក. សមាសភាគនៃវត្ថុ....................................................................................................២៤
ខ. វត្ថុចំណុះ និងវត្ថុចម្រុង...........................................................................................២៤
២.២.២ ប្រាតិភោគដោយអនុប្បទាន ....................................................................................២៥
២.២.២.១ លក្ខខណ្ឌតតាំងនៃកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន .........................២៥
២.២.២.២ អានុភាពចំពោះផលដែលកើតចេញពីទ្រព្យធានា ...........................................២៧
២.២.២.៣ ការចាត់ចែងវត្ថុធានា .............................................................................................៣១
២.២.២.៤ ឧបាទេសកម្មលើវត្ថុនៃកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន .......................៣១
២.២.២.៥ ប្រាតិភោគដោយអនុប្បទានធៀបនឹងការបញ្ចាំផ្តាច់........................................ ៣២
២.២.២.៦ អានុភាពលើវត្ថុដែលភ្ជាប់នឹងវត្ថុធានាប្រាតិភោគដោយ អនុប្បទាន ............. ៣៣
ក. សមាសភាគនៃវត្ថុ.................................................................................................... ៣៣
ខ. វត្ថុចំណុះ និងវត្ថុចម្រុង........................................................................................... ៣៣
២.២.៣ លក្ខណៈរួម និងបញ្ញត្តិអនុវត្តដូចគ្នា ................................................................... ៣៤
២.២.៣.១ ប្រភេទនៃសិទ្ធិប្រាតិភោគប្រត្រក្ស.......................................................................... ៣៤
២.២.៣.២ ប្រាតិភោគចលនវត្ថុ ............................................................................................. ៣៥
២.២.៣.៣ បញ្ញត្តិអនុវត្តដូចគ្នា ................................................................................................ ៣៥
ក. អានុភាពនៃការឃាត់ទុក ......................................................................................... ៣៥
ខ. តំហែរក្សាវត្ថុ............................................................................................................ ៣៦
គ. សិទ្ធិទាមទារអោយសងសោហ៊ុយរបស់ម្ចាស់សិទ្ធិ ................................................ ៣៧
**ជំពូកទី៣ នីតិវិធីអនុវត្តសិទ្ធិលើការបញ្ចាំចលនវត្ថុ និងប្រាតិភោគដោយអនុប្បទាន៣៩**
**៣.១ ការអនុវត្តសិទ្ធិរបស់ម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុ..........................................៣៩**
៣.១.១ បណ្តឹងទាមទារអោយប្រគល់វត្ថុ................................................................................ ៣៩
៣.១.២ ការអនុវត្តជាក់ស្តែងចំពោះការបញ្ចាំចលនវត្ថុ នៅមុនពេល និងក្រោយពេលក្រមរដ្ឋប្បវេណីចូលជាធរមាន ..................................................................................................................៤០
៣.១.៣ នីតិវិធីអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប...........................................................៤០
៣.១.៤ លំដាប់នៃសិទ្ធិលើការបញ្ចាំចលនវត្ថុ .......................................................................៤១
**៣.២ ការអនុវត្តសិទ្ធិរបស់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន.............................៤២**
៣.២.១ ករណីវត្ថុនៅក្នុងដៃម្ចាស់សិទ្ធិ..................................................................................៤៣

៣.២.២ ករណីវត្ថុនៅក្នុងដៃអ្នកបង្កើត ..................................................................... ៥៤
៣.២.៣ ករណីយកិច្ចសងប្រាក់ជម្រះ និងសិទ្ធិទទួលយកមកវិញរបស់អ្នកបង្កើត .............. ៥៥
៣.២.៤ លំដាប់នៃសិទ្ធិករណីមានម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានទី២ .................... ៥៧
**សេចក្តីសន្និដ្ឋាន** ............................................................................................ **៥៨**
**អនុសាសន៍** .................................................................................................... **៥២**
**ឯកសារយោង**
**បញ្ជីឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៩៣ ជាបទដ្ឋានគតិយុត្តមួយដ៏រឹងមាំមួយដែលអនុញ្ញាតអោយប្រទេសកម្ពុជាប្រកាន់នូវសេដ្ឋកិច្ចទីផ្សារសេរីដែលនាំអោយប្រជាពលរដ្ឋ មានសិទ្ធិក្នុងការប្រកបរបររកស៊ីចិញ្ចឹមជីវិតទៅតាមសម្ថភាព[1]។ ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរីនេះ បានផ្តល់ឱកាសអោយប្រជាពលរដ្ឋបង្កើតអាជីវកម្ម រៀងៗខ្លួនកាន់តែរីកដុះដាល និងចរាចរយ៉ាងពេញទំហឹង ប្រកបដោយការប្រកួតប្រជែងនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន។ ពុំនោះទៀតសោតនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃនេះ គ្រួសារនីមួយៗតែងមានប្រភពចំណូលរៀងខ្លួន។ សមាជិកគ្រួសារម្នាក់ៗតែងគិតគូរឿងសមតុល្យចំណូលចំណាយក្នុងគោលបំណងអោយជីវភាពមានភាពរុងរឿងប្រសើរ។ ពួកគេតែងមានតម្រូវការឥតឈប់ឈរ មិនថាតម្រូវការចាំបាច់ ឬតម្រូវការបន្ទាប់បន្សំនោះទេ ទាំងនេះជាហេតុដែលនាំអោយ ការរស់នៅរបស់បុគ្គលទាំងនេះ គឺមិនចេះគ្រប់គ្រាន់នោះឡើយ ជាកត្តានាំអោយមាននូវកង្វះខាតជាម្តងម្កាលទៅតាមចំណង់តម្រូវការ ឬក្នុងការងាររបររកស៊ីរបស់ខ្លួន ទោះបីជាគ្រួសារនោះមានចំណូលទាបក្តី ឬខ្ពស់ក្តី។ កង្វះខាតម្តងម្កាល ដែលអាចស្ថិតនៅក្នុងរូបភាពនៃការចង់ពង្រីកអាជីវកម្ម កង្វះទុនបង្វិល ឬករណីប្រធានសក្តិដែលកើតឡើងភ្លាមៗក្នុងគ្រួសារនេះហើយដែលនាំអោយពួកគេត្រូវទៅខ្ចីប្រាក់ពីបុគ្គលផ្សេងទៀតដើម្បីដោះស្រាយនូវតម្រូវការនោះ ដែលនាំអោយកើតមាននូវកម្ចី ដែលចងបុគ្គល និងបុគ្គលនោះដោយកិច្ចសន្យាខ្ចីបរិភោគ (កិច្ចសន្យាខ្ចីប្រាក់)។ បុគ្គលអោយខ្ចីត្រូវបានហៅថាម្ចាស់បំណុល ដែលអាចជាធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនានា កុងស៊ីផ្សេងៗឬបុគ្គលដែលមានទ្រព្យធនច្រើន។ ហានិភ័យដែលអាចនឹងកើតឡើងគឺម្ចាស់បំណុលទាំងនោះធ្លាប់បានទទួលរងនូវបញ្ហាច្រើនដែលកើតពីកូនបំណុល (អ្នកខ្ចី) មិនមានលទ្ធភាពសង ជាហេតុនាំអោយពួកគេទាមទារនូវវត្ថុផ្សេងមកធានាទៅលើប្រាក់កម្ចីនោះ ដើម្បីធានានូវការអនុវត្តកាតព្វកិច្ចរបស់កូនបំណុល បង្កើតបានជាកិច្ចសន្យាដែលភ្ជាប់នឹងការធានាកាតព្វកិច្ច។

ក្នុងករណីខាងលើនេះ កម្មសិទ្ធករនៃទ្រព្យ មានសិទ្ធិចាត់ចែងទ្រព្យរបស់ខ្លួនបានដោយសេរីទៅតាមច្បាប់ បុគ្គលជាកម្មសិទ្ធិករនៃទ្រព្យ អាចយកទ្រព្យដែលខ្លួនមាននោះទៅលក់ ដើម្បីបំពេញទៅតាមតម្រូវការរបស់ខ្លួន ប៉ុន្តែប្រសិនគេយកទ្រព្យនោះទៅលក់ គេនឹងបាត់បង់ទ្រព្យនោះ ប្តូរនឹងទឹកប្រាក់មួយចំនួន ឬថ្នូរផ្សេងៗ ហើយអាចខាត់បង់ដោយសារការលក់បន្ទាន់ ឬខាត់បង់អត្ថប្រយោជន៍ទៅថ្ងៃអនាគត។ ហេតុនេះលទ្ធភាពនៃការប្រើប្រាស់ទ្រព្យដើម្បីធានាបំណុល ដែលជាលក្ខខណ្ឌតម្រូវក្នុងការទទួលបានប្រាក់កម្ចី ពិតជាដើរតួយ៉ាងសំខាន់នៅក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី។

[1] មាត្រា ៥៦ រដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣

តាមរយៈតថភាពខាងលើយើងឃើញថារូបភាពនៃការធានាបំណុល ឬធានានូវការអនុវត្តកាតព្វកិច្ចរបស់កូនបំណុល មានលក្ខណៈផ្សេងៗពីគ្នា អាស្រ័យទៅតាមការព្រមព្រៀងរបស់គូភាគីដើម្បីជ្រើសរើសយកនូវទម្រង់របបគតិយុត្តណាមួយយកមកអនុវត្ត។ ដោយយោងតាមក្រមរដ្ឋប្បវេណីថ្មីឆ្នាំ ២០០៧ ដែលបានប្រកាសអោយអនុវត្តដោយព្រះរាជក្រមលេខ នស/រកម/០៥/១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដោយបានចែងអំពីការធានាបំណុល ដែលអាចជាការប្រគល់ទ្រព្យទៅអោយម្ចាស់បំណុលកាន់កាប់ ដែលយើងហៅថា ការបញ្ចាំ ឬការធានាកាតព្វកិច្ចដែលអាចប្តូរលក្ខណៈនៃការកាន់កាប់បាន ដែលហៅថា ប្រាតិភោគដោយអនុប្បទាន។

តាមការពិតប្រតិបត្តិការដែលភ្ជាប់ទៅនឹងការធានាកាតព្វកិច្ចដែលក្រមរដ្ឋប្បវេណីបញ្ញត្តិទទួលស្គាល់មានច្រើនជាអាទិ៍ ការបញ្ចាំ ប្រាតិភោគដោយអនុប្បទាន ហ៊ីប៉ូតែក ប្រតិបត្តិការដែលមានកិច្ចធានាជាដើម ប៉ុន្តែយើងខ្ញុំបានសង្កេតឃើញថាសកម្មភាពនៃការបញ្ចាំ និងប្រាតិភោគដោយអនុប្បទាននាពេលបច្ចុប្បន្នមានសកម្មភាពរស់រវើក និងចរាចរណ៍យ៉ាងមមាញឹកជាងគេពីមួយថ្ងៃទៅមួយថ្ងៃ មួយវិញទៀតមានការភាន់ច្រលំជាច្រើនចំពោះការអនុវត្តសញ្ញាណនៃការបញ្ចាំចលនវត្ថុ និងប្រាតិភោគដោយអនុប្បទាននេះ ជាហេតុនាំអោយយើងខ្ញុំសម្រេចចិត្តធ្វើការស្រាវជ្រាវទៅលើប្រធានបទ "ប្រៀបធៀបការបញ្ចាំចលនវត្ថុ និងប្រាតិភោគដោយអនុប្បទាន"។ ហេតុនេះសំណួរគតិយុត្តមួយសួរថា *តើការបញ្ចាំ និងប្រាតិភោគដោយអនុប្បទាននេះជាអ្វី? តើសញ្ញាណនៃការបញ្ចាំ និងប្រាតិភោគដោយអនុប្បទានត្រូវបានស្គាល់យ៉ាងទូលំទូលាយពីសំណាក់ប្រជាពលរដ្ឋទូទៅក៏ដូចជាមន្ត្រីអនុវត្តហើយឬនៅ? តើប្រាតិភោគទាំងពីរប្រភេទនេះមានលក្ខណៈខុសគ្នាយ៉ាងដូចម្តេច?* ការសិក្សាទៅលើប្រធានបទស្រាវជ្រាវមួយនេះស្ថិតនៅក្រោមគោលបំណងវិភាគវែកញែកអំពីសញ្ញាណរបស់ប្រភេទសិទ្ធិប្រត្យក្សទាំងពីរ និងជាប្រធានបទដែលអាចជាជំនួយដល់សិស្សប្អូនជំនាន់ក្រោយស្រាវជ្រាវ ព្រមទាំងពង្រីកពុទ្ធិសាមញ្ញជនដែលពុំបានយល់ច្បាស់ពីវា ដើម្បីជៀសវាងការចាញ់បោកឈ្នួញទុច្ចរិត ហេតុតែពុំបានយល់ច្បាស់ និងអនុវត្តទៅតាមច្បាប់អោយបានត្រឹមត្រូវជៀសវាងភាពអសន្តិសុខក្នុងសង្គម និងទង្វើកេងបន្លំផ្សេងៗ ដែលជាកត្តាសីលធម៌មួយសម្រួលដល់ការរីកចម្រើនវិស័យសេដ្ឋកិច្ចជាតិផងដែរ។

ដោយហេតុថាច្បាប់ផ្សេងៗដែលពាក់ព័ន្ធ ត្រូវបាននិរាករណ៍ក្រោយពេលដែលក្រមរដ្ឋប្បវេណីថ្មី ឆ្នាំ ២០០៧ បានប្រកាសអោយអនុវត្តកាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដូចនេះយើងនឹងយកក្រមរដ្ឋប្បវេណីថ្មីឆ្នាំ២០០៧ មកធ្វើជាមូលដ្ឋានដើម្បីធ្វើការសិក្សាស្រាវជ្រាវ និងវិភាគអំពីប្រធានបទនេះ។ ជាមួយគ្នានេះផងដែរនឹងមានការបកស្រាយខ្លះៗដែលពាក់ព័ន្ធនឹងក្រមនីតិវិធីរដ្ឋប្បវេណីទាក់ទិននឹងការអនុវត្តសិទ្ធិករណីរំលោភកិច្ចសន្យា។ ចំណែកបទដ្ឋានចាស់ៗដែលពាក់ព័ន្ធនឹង

សញ្ញាណានៃប្រាតិភោគទាំងពីរ យើងនឹងលើកយកមកធ្វើការវែកញែក ដើម្បីអោយបានយល់ពីឬសគល់ និងការវិវត្តនៃយន្តការរបស់វា។ ដូចនេះដើម្បីអោយមានភាពងាយស្រួលនឹងកាន់តែច្បាស់អំពីប្រធានបទប្រៀបធៀបនេះ យើងនឹងធ្វើការប្រៀបធៀបជាចម្បងទៅលើចំណុចបីសំខាន់ៗ គឺ

ជំពូក ១ សញ្ញាណទូទៅ

ជំពូក ២ ការបង្កើត និងអានុភាពនៃកិច្ចសន្យាបញ្ចាំចលនវត្ថុ និងប្រាតិភោគដោយអនុប្បទាន

ជំពូក ៣ នីតិវិធីអនុវត្តសិទ្ធិលើការបញ្ចាំចលនវត្ថុ និងប្រាតិភោគដោយអនុប្បទាន។

# ជំពូក ១

# សញ្ញាណទូទៅ

# ជំពូកទី១ សញ្ញាណទូទៅ

ជាការពិតណាស់ប្រាតិភោគដោយអនុប្បទាន និងការបញ្ចាំត្រូវបានទទួលការភាន់ច្រលំនូវសញ្ញាណគតិយុត្តរបស់វា ដោយសារវាស្ថិតនៅក្នុងប្រភេទនៃសិទ្ធិប្រាតិភោគប្រត្យក្សដូចគ្នា ព្រមទាំងជាកិច្ចសន្យាដែលភ្ជាប់ទៅនឹងការធានាកាតព្វកិច្ច។ ទាំងការអនុវត្ត ក៏ដូចជាបញ្ញត្តិច្បាប់ប្រសិនបើ ពុំបានសិក្សាវែកញែកពីភាពខុសគ្នានៃសញ្ញាណរបស់របបគតិយុត្តនីមួយៗអោយច្បាស់លាស់នោះទេ នឹងបង្កអោយមានការអនុវត្តខុសទៅលើប្រភេទគតិយុត្តនីមួយៗ ទាំងប្រជាពលរដ្ឋទូទៅ អ្នកបើកអាជីវកម្មនេះ រួមទាំងមន្ត្រីអនុវត្តផងដែរ ដោយហេតុសញ្ញាណនៃប្រតិបត្តិការធានាកាតព្វកិច្ចរបៀបនេះ មានជាច្រើនសណ្ឋានផ្សេងទៀត ជាក់ស្តែងក្រោមរូបភាពដូចជា ហ៊ីប៉ូតែក និងប្រតិបត្តិការដែលមានកិច្ចធានាជាដើម។ ដើម្បីសិក្សាពីភាពខុសគ្នានេះ យើងនឹងសិក្សាពីប្រវត្តិ ព្រមទាំងលំហូរគតិយុត្តរបស់វាជាមុន មុននឹងឈានចូលដល់សញ្ញាណជាក់លាក់ អានុភាព ក៏ដូចជាសិទ្ធិ និងករណីយកិច្ចនៃប្រាតិភោគប្រត្យក្សទាំងពីរ។

## ១.១. ការវិវត្តន៍

គំនិតនៃកម្ចីដោយមានទ្រព្យធានានេះបានករកើតឡើងនៅក្នុងសង្គម មិនថាប្រទេសណានោះឡើយ។ ជាក់ស្តែងកម្ចីដោយភ្ជាប់នឹងការធានាកាតព្វកិច្ចនេះធ្លាប់មានកំណត់នៅក្នុងយុត្តិសាស្ត្រនៃប្រទេសអង់គ្លេសក្នុងអំឡុងឆ្នាំ ១១៩០ ដែលបទដ្ឋានទាំងនេះបកស្រាយអំពីការចាប់ផ្តើមនៃប្រព័ន្ធមូលដ្ឋានកិច្ចសន្យាដែលមានការធានាកាតព្វកិច្ច។ កម្ចីរបៀបនេះតម្រូវអោយកូនបំណុលមាននូវទ្រព្យដាក់ធានាកាតព្វកិច្ច។ គំនិតនេះបានឆ្លងរីករាលដាលតាំងពីឆ្នាំ ១១៩០នោះមកដល់លោកខាងលិច យ៉ាងឆាប់រហ័ស និងវិវត្តជាបន្តបន្ទាប់មក។ ការធានាកាតព្វកិច្ចនេះលេចមុខនៅសហរដ្ឋអាមេរិច ដោយក្នុងកំឡុងឆ្នាំ ១៨០០ និង ១៩០០ កំណើននៃអន្តោប្រវេសន៍ និងចំណូលស្រុកមានការកើនឡើងច្រើនគួរអោយកត់សម្គាល់ ជាហេតុនាំអោយតម្រូវការកម្ចីទិញផ្ទះ ឬទ្រព្យមានការកើនឡើង។ ត្បិតតែលក្ខណៈនៃកម្ចីនៅពេលនោះមានលក្ខណៈមិនទាន់ល្អឥតខ្ចោះ ប៉ុន្តែវាពិតជាបានជួយដល់ប្រជាពលរដ្ឋអាមេរិចជាច្រើនមានផ្ទះនៅ។ ក្រោយមកនៅពេលដែល អាមេរិចទទួលរងនូវវិបត្តិសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរអំឡុងសង្គ្រាមលោកលើកទីពីរ វិបត្តិក៏កើតមានឡើងលើបញ្ហានេះដែរ។ អាមេរិចបានខិតខំស្វែងរកដំណោះស្រាយជាច្រើនដើម្បីសម្រួលដល់បញ្ហាទាំងនេះ តាមរយៈការបង្កើតនូវភ្នាក់ងារ ឬស្ថាប័នផ្សេងៗស្វែងរកដំណោះស្រាយ ដូចជាការបង្កើនចំនួនឆ្នាំកម្ចី និងការត្រួតពិនិត្យគុណភាពសំណង់ជាដើម។ ឆ្លងកាត់ជាច្រើនដំណាក់កាល ការធានាកាតព្វកិច្ចរបៀបនេះ កាន់តែមានលក្ខណៈតឹងរឹងនៅសហរដ្ឋអាមេរិចគិតមកដល់ពេលបច្ចុប្បន្ន។ មិនខុសអ្វីពី

នៅប្រទេសកម្ពុជាវិញ ប្រជាជនមួយចំនួនប្រើប្រាស់កម្ចីដែលមានការប្រាក់ ភាគច្រើនគេនាំគ្នាហៅថា របរចងការ ឬរាប់លុយ ក្រោយមកគំនិតរបៀបនេះវិវត្តទៅជាប្រតិបត្តិការជាច្រើនប្រភេទ ដែលត្រូវបានអនុវត្តនៅក្នុងទីផ្សារបច្ចុប្បន្ន។ បន្ទាប់ពីប្រទេសបានបើកទំព័រសករាជនៃសុខសន្តិភាពជាថ្មីមករបរបង្វិលប្រាក់របៀបនេះចេះតែរីកដុំដាល បូករួមទាំងកិច្ចសហការជាអន្តរជាតិលើវិស័យពាណិជ្ជកម្ម និងវិស័យផ្សេងៗ ក្នុងទ្រង់ទ្រាយជារបបទីផ្សារសេរីមក គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនានា និងធនាគារផ្សេងៗមិនខុសអីពីកុងស៊ីបញ្ចាំបានដុំដាលរីកដូចផ្សិតពិសេសនៅរាជធានី និងបណ្តាខេត្តធំៗដែលមានចំនួនប្រជាជនរស់នៅច្រើន ។

នៅក្នុងសង្គមកម្ពុជាបច្ចុប្បន្នអាជីវកម្មទទួលបញ្ចាំវត្ថុ និងប្រាតិភោគដោយអនុប្បទាន មានការពេញនិយមជាខ្លាំងពីសំណាក់ប្រជាពលរដ្ឋទូទៅ និងធ្វើការបិទផ្សាយពាណិជ្ជកម្មទទួលបញ្ចាំ ឬប្រាតិភោគដោយអនុប្បទានវត្ថុ[2] ស្ទើរតែគ្រប់ទីកន្លែងក្នុងទីក្រុងភ្នំពេញ ដោយអាជីវកម្មមួយចំនួនធំពុំទទួលបានការអនុញ្ញាតពីច្បាប់អោយប្រកបអាជីវកម្មឡើយ។ ដោយមើលឃើញនូវភាពអាណាធិបតេយ្យនៃអាជីវកម្មទទួលបញ្ចាំ ឬប្រាតិភោគដោយអនុប្បទាន និងការកើនឡើងនូវអំពើចោរកម្មក្នុងប្រទេស ទើបក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចាត់វិធានការដើម្បីរឹតបន្តឹងការទទួលបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ដោយការផ្តល់អាជ្ញាប័ណ្ណដល់អាជីវករទទួលបញ្ចាំទាំងនោះ ក្នុងគោលបំណងគ្រប់គ្រង និងដាក់អាជីវកម្មនេះអោយស្ថិតនៅក្រោមច្បាប់។ ជាពិសេស គឺឈានដល់ការលុបបំបាត់អំពើចោរកម្ម ដែលជាក្តីព្រួយបារម្មណ៍ដ៏ធំបំផុតសម្រាប់ប្រជាពលរដ្ឋទូទៅ ព្រមទាំងបញ្ហាទទួលផលចោរកម្មក៏ក្លាយជាបទល្មើសព្រហ្មទណ្ឌ។ វាក៏ជាវិធីសាស្ត្រមួយដែលជួយបង្កើតប្រាក់ចំណូលរបស់រដ្ឋតាមរយៈការបង់ថ្លៃពន្ធផងដែរ។

នាថ្ងៃទី១២ ខែមករា ឆ្នាំ២០១០ ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ០២៨ សហវ-ប្រក ចុះ ស្តីពីការផ្តល់អាជ្ញាប័ណ្ណទទួលបញ្ចាំ និងទិញលក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន ត្រូវបានបង្កើតឡើងដែលបញ្ជាក់អោយដឹងថា ដើម្បីលើកកម្ពស់ការយល់ដឹងនៃការងារអាជីវកម្ម និងសណ្តាប់ធ្នាប់សង្គម តម្រូវអោយអាជីវករទាំងអស់នៅក្នុងឧស្សាហកម្មនេះដាក់ពាក្យសុំអាជ្ញាប័ណ្ណនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីទទួលបានការណែនាំ និងរបៀបធ្វើអាជីវកម្ម។ បន្ថែមលើនេះទៅទៀត ការប្រកបអាជីវកម្មទទួលបញ្ចាំវត្ថុ ប្រតិបត្តិករទាំងអស់ត្រូវតែមានទុនអប្បបរមា ៨០លានរៀល ដែលក្នុងនោះទុន ១០ភាគរយ ឬយ៉ាងច្រើនបំផុត ៨០ លានរៀល ត្រូវតម្កល់ទុកក្នុងគណនីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅធនាគារជាតិនៃកម្ពុជា

---
[2] ឧបសម្ព័ន្ធ ៦

(NBC)។ ជាងនេះទៅទៀត ប្រកាសខាងលើនេះ តម្រូវអោយអាជីវករដែលដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណទាំងអស់ បង់ថ្លៃអាជ្ញាប័ណ្ណចំនួន ២លានរៀល ឬ ៥០០ដុល្លារ សម្រាប់ប្រចាំឆ្នាំ និងត្រូវបង់ពន្ធទៅអគ្គនាយកដ្ឋានរតនាគារជាតិ តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ [3]។

អាជីវកម្មទទួលបញ្ចាំ និងទិញលក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានទាំងអស់ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងតម្រូវអោយអាជីវករទាំងអស់ត្រូវធ្វើកិច្ចសន្យាបញ្ចាំ ជាលាយលក្ខណ៍អក្សរអោយបានត្រឹមត្រូវតាមច្បាប់ និងមិនត្រូវធ្វើអាជីវកម្មដើម្បីបម្រើដល់សកម្មភាពសម្អាតប្រាក់ ឬបម្រើផលប្រយោជន៍ដល់ពពួកឧក្រិដ្ឋជនណាមួយឡើយ។ ហេតុដូចនេះប្រសិនបើអាជីវករទទួលបញ្ចាំណាមួយ ទទួលបញ្ចាំ ឬប្រាតិភោគដោយអនុប្បទាន ឬទិញរបស់ចោរ (ទទួលផលចោរកម្ម) នោះនឹងត្រូវផ្តន្ទាទោសដូចជនល្មើសផងដែរ។

បើទោះបីជាអាជីវកម្មបញ្ចាំត្រូវបានរឹតត្បិតដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងនេះក៏ដោយ ក៏នៅតែមានអាជីវករមួយចំនួនធំ មិនបានទៅសុំអាជ្ញាប័ណ្ណ ហើយក៏ពុំទាន់បានអនុវត្តការណែនាំរបស់ក្រសួងឡើយ។ ការអនុវត្តជាក់ស្តែងជាបញ្ហាមួយដែលអាជីវករពុំបានគោរពទៅតាមច្បាប់ ដោយហេតុប្រាតិភោគដោយអនុប្បទាន ជាសញ្ញាណដែលអនុវត្តតែចំពោះចលនវត្ថុ រីឯការបញ្ចាំ មាននីតិវិធីច្រើន ក៏ត្រូវឆ្លងកាត់នីតិវិធីតុលាការជាមុននឹងវត្ថុធានាត្រូវបានលក់ឬទូទាត់សងទៅម្ចាស់បំណុលដែលបង្កលក្ខណៈតឹងរឹងជាងប្រាតិភោគដោយអនុប្បទាន។ កាលដែលមានសញ្ញាណគតិយុត្តច្រើនអនុវត្តទៅលើចលនវត្ថុដូចគ្នា ជាដើមចមនាំអោយការអនុវត្តជាក់ស្តែងមានការភាន់ច្រលំ ឬពុំត្រូវបានយល់ដឹងគ្រប់ជ្រុងជ្រោយដោយបណ្តាអ្នកអនុវត្តច្បាប់។

### ១.២ ទិដ្ឋភាពគតិយុត្ត

សញ្ញាណនៃការបញ្ចាំ មិនមែនជាសញ្ញាណមួយថ្មីដែលទើបនឹងកកើតនៅក្នុងពេលបច្ចុប្បន្ននោះទេ ពោលគឺចាប់បដិសន្ធិឡើងតាំងពីយូរលង់ណាស់មកហើយ ដែលត្រូវបានយកមកអនុវត្តយ៉ាងទូលំទូលាយពីសំណាក់ប្រជាពលរដ្ឋទូទៅ ដោយសញ្ញាណនេះមានចែងនៅក្នុង **ក្រមរដ្ឋប្បវេណីចាស់ឆ្នាំ ១៩២០** ជាភាសាបារាំង។ ដោយប្រទេសកម្ពុជាយើងមានការផ្លាស់ប្តូររបបគ្រប់គ្រងជាហូរហែ សញ្ញាណនៃការបញ្ចាំក៏បានលេចឡើងជាថ្មីម្តងទៀតក្នុងសម័យអន្តរកាល ដោយមានចែងនៅក្នុង **ក្រឹត្យច្បាប់លេខ ៣៨ ក្រច** ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៨៨ បន្ទាប់ពីប្រទេសកម្ពុជាបានផ្លាស់ប្តូរប្រព័ន្ធសេដ្ឋកិច្ចផែនការ ទៅជាប្រព័ន្ធ

[3] ឧបសម្ព័ន្ធ៣

សេដ្ឋកិច្ចទីផ្សារសេរី។ លើសពីនេះទៅទៀតរបបគតិយុត្តនៃការបញ្ចាំនៅតែបន្តអត្ថិភាពមកដល់បច្ចុប្បន្ន តាមរយៈអត្ថបទ **ច្បាប់ភូមិបាល ឆ្នាំ១៩៩២ ច្បាប់ភូមិបាល ឆ្នាំ ២០០១** និង **ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧** នេះ។

រីឯប្រាតិភោគដោយអនុប្បទានវិញ គឺជាសញ្ញាណថ្មីមួយផ្សេងទៀតដែលទើបនឹងកើតមាននៅក្នុង **ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧** នេះប៉ុណ្ណោះ។ ដោយឡែកឆ្នាំ ១៩៩២ ច្បាប់ភូមិបាលដំបូងនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានបង្កើតឡើង ពុំមានវត្តមានប្រាតិភោគដោយអនុប្បទាននេះនៅក្នុងប្រតិបត្តិការភ្ជាប់នឹងការធានាដែល។ មកដល់ឆ្នាំ ២០០១ ដែលជាឆ្នាំកំណើតច្បាប់ភូមិបាលថ្មីនោះក៏ពុំមានអ្វីគួរអោយកត់សម្គាល់អំពីការផ្លាស់ប្តូរនូវរបបប្រាតភោគប្រត្យក្សនេះដែរ។ ក្រោយមកដោយមានកិច្ចសហប្រតិបត្តិការជាមួយប្រទេសជប៉ុន តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ហៅកាត់ថា JICA គណៈកម្មការតាក់តែងសេចក្តីព្រៀងក្រមរដ្ឋប្បវេណី២០០៧ បានបង្កើតឡើង។ ចាប់ពីខែមីនា ឆ្នាំ ១៩៩៩ គម្រោងតាក់តែងសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមរដ្ឋប្បវេណីបានចាប់ផ្តើម[4]។ នៅក្នុងនោះសញ្ញាណថ្មីៗដែលពីមុនមករបបគតិយុត្តនៅកម្ពុជា ពុំធ្លាប់មាន ត្រូវបានបញ្ចូលទៅក្នុងក្រមរដ្ឋប្បវេណីនេះ ជាអាទិ៍ប្រាតិភោគដោយអនុប្បទាននេះក៏ត្រូវបានបញ្ចូលផងដែរ។ នៅក្នុងសេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី រៀបរៀងដោយគណៈកម្មការ ទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនត្រង់មាត្រា ៧៦៧ បានកំណត់ថា "**ប្រាតិភោគដោយអនុប្បទាន គឺជាសញ្ញាណថ្មីសន្លាងមួយដែលមាននៅក្នុងក្រមរដ្ឋប្បវេណី ដោយវាត្រូវបានប្រែសម្រួលពីយុត្តិសាស្ត្ររបស់ប្រទេសជប៉ុន។**" ដូចនេះទាំងប្រទេសជប៉ុនដែលជាដៃគូសហប្រតិបត្តិការផ្នែកកំណែទម្រង់ប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ក៏ពុំមានចែងពីរបបប្រាតិភោគដោយអនុប្បទាននេះនៅក្នុងក្រមរដ្ឋប្បវេណីរបស់ខ្លួនដែរ នៅមុនពេលដែលប្រទេសជប៉ុនបង្កើត **ច្បាប់ពិសេសស្តីពីប្រាតិភោគដោយអនុប្បទាន**។

បញ្ញត្តិនៃសិទ្ធិប្រាតិភោគប្រត្យក្សទាំងអស់ដែលត្រូវបានកំណត់ឡើងនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧នេះត្រូវបាននិតិនិពន្ធពន្លិចឡើងនៅក្នុងគន្ថីទី ៦ ការធានាកាតព្វកិច្ចដែលក្នុងនោះមានរហូតទៅដល់ ៨ជំពូក ហើយសិទ្ធិប្រាតិភោគប្រត្យក្សស្ថិតនៅចាប់ពីជំពូក២ ដល់ជំពូក៦។ សិទ្ធិលើការបញ្ចាំ ត្រូវបានបញ្ញត្តិនៅជំពូក៤ រីឯសិទ្ធិប្រាតិភោគដោយអនុប្បទានវិញបញ្ញត្តិនៅជំពូក៦ បញ្ញត្តិគតិយុត្តដែលប្រតិបត្តិការធានាទាំងពីរនេះគឺជាកម្មវត្ថុនៃការសិក្សាស្រាវជ្រាវនេះ។ យើងបានដឹងរួចមកហើយថា សិទ្ធិលើការបញ្ចាំ សិទ្ធិប្រាតិភោគដោយអនុប្បទាន និងហ៊ីប៉ូតែក សុទ្ធសឹងតែជាកិច្ច

[4] ព្រឹត្តប័ត្រ ៖ កិច្ចសហប្រតិបត្តិការរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន នៅកម្ពុជា របស់ទីភ្នាក់ងារ JICA បោះពុម្ព ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៦

សន្យាដែលកើតឡើងពីការព្រមព្រៀងដោយឆន្ទៈរបស់ភាគី ប៉ុន្តែនីតិនិពន្ធពុំបញ្ញត្តិកិច្ចសន្យាទាំងបីនេះនៅក្នុងគន្ថីទី៥ ដែលកំណត់ពីកិច្ចសន្យាសំខាន់ៗឡើយ ហេតុនេះក៏ព្រោះតែគោលការណ៍នៃការតាក់តែងឡើងនេះបានដាក់បញ្ញត្តិដែលទាក់ទងទៅនឹងការធានាកាតព្វកិច្ចនៅដោយឡែក ទោះបីវាកើតឡើងនៅក្នុងរូបភាពនៃកិច្ចសន្យាក៏ដោយ។

បន្ទាប់ពីសិក្សាអំពីទិដ្ឋភាពគតិយុត្តនៃកិច្ចសន្យាទាំងពីរ យើងនឹងសិក្សាកាន់តែស៊ីជម្រៅអំពីការបញ្ចាំ និងប្រាតិភោគដោយអនុប្បទាននេះ ដោយសិក្សាថាតើមានលិខិតបទដ្ឋានអ្វីផ្សេងទៀតមកចង្អុលបង្ហាញជាធរមានក្រៅពីក្រមរដ្ឋប្បវេណី២០០៧ បច្ចុប្បន្ន។

### ១.៣ និយមន័យ

ការបញ្ចាំ ត្រូវបានបញ្ញត្តិនៅក្នុងក្រមរដ្ឋវេណីកម្ពុជា ២០០៧ មាត្រា ៨១៦ ដែលសំដៅទៅលើ "**ម្ចាស់សិទ្ធិលើការបញ្ចាំ មាន សិទ្ធិកាន់កាប់វត្ថុ ដែលបានទទួលពីកូនបំណុល ឬតតិយជនដើម្បីធានាសិទ្ធិលើបំណុលរបស់ខ្លួន និងទទួលការសងចំពោះសិទ្ធិលើលើបំណុលរបស់ខ្លួនពីវត្ថុនោះដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត**" ។

*ឧទាហរណ៍ ៖ បុគ្គល ក បានទៅខ្ចីប្រាក់ពីបុគ្គល ខ ចំនួន ៣ម៉ឺនដុល្លារអាមេរិច។ បុគ្គល ខ ត្រូវអោយបុគ្គល ក មានទ្រព្យមកដាក់ធានាលើប្រាក់កម្ចីរបស់ខ្លួន។ បុគ្គល ក យកគ្រឿងអលង្ការរបស់ខ្លួនតម្លៃខ្ទង់ ៧ម៉ឺនដុល្លារទៅដាក់ជាទ្រព្យធានា អោយបុគ្គល ខ ។ រូបភាពនៃការបញ្ចាំ ម្ចាស់សិទ្ធិ ឬបុគ្គល ខ មានសិទ្ធិកាន់កាប់លើគ្រឿងអលង្ការនោះ ដែលនាំអោយកិច្ចសន្យាបញ្ចាំមួយនេះមានសុពលភាពគតិយុត្ត។*

ចំណែកឯប្រាតិភោគដោយអនុប្បទាន យោងតាមក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ មាត្រា ៨៤៨ ត្រូវបានអោយនិយមន័យថា "**ប្រាតិភោគដោយអនុប្បទាន ជាការណ៍ដែលកូនបំណុល ឬតតិយជនធ្វើអនុប្បទាននូវចលនវត្ថុរបស់ខ្លួនជាកំណត់ ទៅអោយម្ចាស់បំណុលដើម្បីធានាកាតព្វកិច្ច**"។

*ឧទាហរណ៍ ៖ បុគ្គល ក បានទៅខ្ចីប្រាក់ពីបុគ្គល ខ ចំនួន ៣ម៉ឺនដុល្លារអាមេរិច។ បុគ្គល ខ ត្រូវអោយបុគ្គល ក មានទ្រព្យមកដាក់ធានាលើប្រាក់កម្ចីរបស់ខ្លួន។ បុគ្គល ក យករថយន្ត Rang Rover របស់ខ្លួនទៅដាក់ជាទ្រព្យធានា។ ក្រោមរូបភាពនៃប្រាតិភោគដោយអនុប្បទាន ម្ចាស់សិទ្ធិ ឬបុគ្គល ខ មានសិទ្ធិកាន់កាប់ ឬមិនកាន់កាប់លើវត្ថុធានានោះបាន ដោយហេតុថា ប្រាតិភោគដោយអនុប្បទានទទួលស្គាល់ការប្តូរលក្ខណៈនៃការកាន់កាប់ (សិក្សាលម្អិតនៅចំណុច ២.១ ការបង្កើតកិច្ចសន្យា) ។*

តាមរយៈនិយមន័យនេះហាក់បីដូចជាធ្វើអោយយើងពិបាកនឹងញែកអោយដាច់ពីសញ្ញាណនៃសិទ្ធិប្រាតិភោគប្រត្យក្សទាំងពីរប្រភេទនេះ ប្រសិនបើពុំបានសិក្សាលើលក្ខណៈខុសគ្នារបស់

សញ្ញាណនៃការបង្កើត និងអានុភាពរបស់វាអោយបានជាក់លាក់ជាមុន ប៉ុន្តែចំណុចនេះនឹងត្រូវបន្តបកស្រាយនៅជំពូក ២ នៃសារណាបទនេះ។

បន្តទៅទៀតយើងនឹងសិក្សាពីកម្មវត្ថុ ក៏ដូចជាប្រភេទនៃកិច្ចសន្យាបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការវែកញែកពីភាពខុសគ្នា ដោយហេតុថាការប្រៀបធៀបនេះនឹងលើកឡើងមកតែយន្តការទៅលើចលនវត្ថុមួយមកធ្វើការសិក្សាប៉ុណ្ណោះ។

### ១.៤ កម្មវត្ថុនៃកិច្ចសន្យាបញ្ចាំ

ដោយយោងទៅតាមក្រមរដ្ឋប្បវេណីថ្មី កម្មវត្ថុនៃសិទ្ធិលើការបញ្ចាំអាចជាចលនវត្ថុ ឬអចលនវត្ថុ និងការបញ្ចាំសិទ្ធិ។ តើកម្មវត្ថុនៃការបញ្ចាំទាំងបីខាងលើនេះមានអត្ថន័យយ៉ាងដូចម្តេច?

- ❖ ការបញ្ចាំចលនវត្ថុ មានប្រតិបត្តិស្ទើរតែរាល់ថ្ងៃដោយហេតុថាសំដៅលើវត្ថុដែលអាចផ្លាស់ទីបាន លើកដាក់ ដែលនាំអោយមានភាពងាយស្រួលក្នុងការវាយតម្លៃ និងមានលក្ខណៈឆាប់រហ័ស។ កម្មវត្ថុនៃការបញ្ចាំត្រង់ចំណុចនេះ ជាវត្ថុដែលក្រៅពីអចលនវត្ថុ[5] ម្យ៉ាងវិញទៀតចលនវត្ថុដែលដាក់បញ្ចាំ ត្រូវតែជាកម្មសិទ្ធិរបស់កូនបំណុល ប្រសិនបើកូនបំណុលជាអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ឬអាចជាកម្មសិទ្ធិរបស់តតិយជន ប្រសិនបើតតិយជននោះជាអ្នកបង្កើតសិទ្ធិលើការបញ្ចាំដើម្បីធានាបំណុលអ្នកដទៃ។ ជាងនេះទៅទៀតចលនវត្ថុត្រូវតែជាចលនវត្ថុដែលអាចរឹបអូសបាន។
- ❖ ការបញ្ចាំអចលនវត្ថុ មានចែងក្នុងក្រមរដ្ឋប្បវេណីពីមាត្រា ៨៣៤ ដល់ ៨៣៩ និងបានអោយនិយមន័យអចលនវត្ថុ សំដៅទៅលើដីធ្លី និងវត្ថុជាប់នៅលើដី ហើយមិនអាចផ្លាស់ទីកន្លែងបាន ដូចជាអគារ សំណង់ ដំណាំ រុក្ខជាតិជាអាទិ៍[6]។ ចំណែកនៅក្នុងច្បាប់ភូមិបាលថ្មី ឆ្នាំ ២០០១ សញ្ញាណនៃអចលនវត្ថុត្រូវបានបែងចែកជាបី គឺអចលនវត្ថុពីកំណើត អចលនវត្ថុតាមភ័ព្វវាសនា និងអចលនវត្ថុតាមការកំណត់ដោយច្បាប់[7]។ ប៉ុន្តែអចលនវត្ថុនៅក្នុងក្រមរដ្ឋប្បវេណីថ្មី ២០០៧ ជំពូក ៤ ផ្នែកទី ៣ ការបញ្ចាំអចលនវត្ថុ គឺផ្តោតសំខាន់តែទៅលើអចលនវត្ថុដីធ្លី និងវត្ថុជាប់នៅលើដី ដូចជាផ្ទះ អគារ សំណង់តែប៉ុណ្ណោះ។
- ❖ ការបញ្ចាំសិទ្ធិ សំដៅទៅលើការដែលកូនបំណុលយកសិទ្ធិលើបំណុលរបស់ខ្លួនដែលមានចំពោះកូនបំណុលទី៣ ទៅដាក់បញ្ចាំអោយម្ចាស់សិទ្ធិលើការបញ្ចាំរបស់ខ្លួន ដើម្បីធានានូវការសងបំណុលនោះ។ ក្រៅពីសិទ្ធិលើបំណុល នៅមានសិទ្ធិអ្នកនិពន្ធ និងកម្មសិទ្ធិបញ្ញា ក៏

[5] មាត្រា ១២០ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[6] មាត្រា ១២០ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[7] មាត្រា ២ នៃច្បាប់ភូមិបាលថ្មី ២០០១

អាចក្លាយជាកម្មវត្ថុនៃការបញ្ចាំសិទ្ធិនេះផងដែរ។ ប៉ុន្តែនៅប្រទេសកម្ពុជាបច្ចុប្បន្ន ពុំទាន់ឃើញមានការប្រើប្រាស់នូវសញ្ញាណនេះនៅឡើយទេ ដោយសារតែការយល់ដឹងរបស់ប្រជាពលរដ្ឋទូទៅអំពីសិទ្ធិលើបំណុលក៏ដូចជាកម្មសិទ្ធិបញ្ញាផ្សេងទៀតនៅមានកម្រិត ព្រមជាមួយនឹងសញ្ញាណនៃការបញ្ចាំសិទ្ធិនេះថ្មីផងនោះ ទើបធ្វើអោយយន្តការនៃការបញ្ចាំសិទ្ធិនេះ ពុំសូវមានគេស្គាល់ និងយកមកអនុវត្តពីសំណាក់ប្រជាពលរដ្ឋទូទៅ គ្រឹះស្ថានហិរញ្ញវត្ថុ ឬធនាគារ នៅឡើយនាពេលបច្ចុប្បន្ននេះ។

## ១.៥ កម្មវត្ថុនៃកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន

### ❖ ចលនវត្ថុ

ត្រង់ចំណុចនេះក៏មិនខុសអ្វីពីកម្មវត្ថុនៃការបញ្ចាំដែលបានរៀបរាប់ខាងលើដែរ សិទ្ធិប្រត្យក្សជាសិទ្ធិដែលមានលើវត្ថុ មិនមែនមានលើមនុស្សនោះទេ ហើយពាក្យថាវត្ថុនៅទីនេះសំដៅលើកម្មវត្ថុនៃសិទ្ធិប្រត្យក្ស។ ចំណែកប្រភេទចលនវត្ថុដែលជាកម្មវត្ថុនៃការបង្កើតសិទ្ធិប្រត្យក្សបាន គឺចលនវត្ថុដែលយើងអាចមើលឃើញជាធម្មតាទូទៅ ដែលច្បាប់ពុំបានបញ្ញត្តិហាមឃាត់តឹងរឹងនោះទេ។ ចលនវត្ថុនេះដូចគ្នាទៅនឹងចលនវត្ថុដែលធ្លាប់បានបញ្ជាក់នៅក្នុងកម្មវត្ថុនៃប្រតិបត្តិការបញ្ចាំដែរ។ ដោយសារសម័យនេះជាសម័យបច្ចេកវិទ្យាខ្ពស់ មិនត្រឹមតែអចលនវត្ថុនោះទេ ដែលត្រូវបានគេអោយតម្លៃ ចលនវត្ថុនាពេលបច្ចុប្បន្នក៏មានចរាចរណ៍យ៉ាងសកម្មផងដែរ ព្រមទាំងបង្កើតនូវប្រតិបត្តិការស្ទើររាប់មិនអស់ក្នុងមួយថ្ងៃៗ ជាជាងប្រតិបត្តិការទៅលើអចលនវត្ថុទៀតផង។ ទោះជាយ៉ាងនេះក្តីការចាត់ចែងចលនវត្ថុមានផលប៉ះពាល់ទៅលើសុវត្ថិភាពខាងជំនួយ ដោយហេតុថាពិបាកក្នុងការវិនិច្ឆ័យពីអ្នកដែលជាម្ចាស់សិទ្ធិពិតប្រាកដ ព្រោះវាអាស្រ័យទៅលើការកាន់កាប់ចលនវត្ថុនោះជាក់ស្តែង។

### ❖ ចលនវត្ថុផ្តុំគ្នាតែមួយ

កថាខណ្ឌ ២ នៃមាត្រា ៨៨៨ ដដែលនេះចែងអោយនិយមន័យនៃ **ចលនវត្ថុផ្តុំគ្នាតែមួយ**។ ចលនវត្ថុច្រើន ដែលត្រូវបានកំណត់ទំហំតាមមាត្រដ្ឋាន ដូចជាប្រភេទ ឬកន្លែងស្ថិតនៅនៃចលនវត្ថុ អាចយកមកធ្វើជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន ដោយចាត់ទុកជាចលនវត្ថុផ្តុំគ្នាតែមួយបាន ទោះបីជាចលនវត្ថុនីមួយៗដែលផ្តុំគ្នានោះ មានការប្រែប្រួលក៏ដោយ។ ជាចំណុចពិសេសដែលប្រាតិភោគប្រត្យក្សដទៃផ្សេងទៀតពុំមាន គឺការចាត់ទុកចលនវត្ថុច្រើន ជាចលនវត្ថុផ្តុំគ្នា។ ប្រសិនបើយើងមិនចាត់ទុកដូចនេះទេ នោះយើងនឹងត្រូវបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សមួយសម្រាប់ចលនវត្ថុមួយ ដូចនេះវាមានលក្ខខណ្ឌសាំញ៉ាំ និងស្មុគស្មាញ។ ឧទាហរណ៍ រោងចក្រមួយមានម៉ាស៊ីនដេរចំនួន ១០០គ្រឿង។ ម្ចាស់រោងចក្រចង់យកម៉ាស៊ីនដេរទៅដាក់ប្រាតិភោគដោយអនុប្បទាន ដូចនេះ

គាត់ពុំចាំបាច់បង្កើតកិច្ចសន្យាប្រាតិភោគដោយអនុប្បទានចំនួន ១០០ច្បាប់នោះទេ។ គាត់គ្រាន់តែបង្កើតកិច្ចសន្យាប្រាតិភោគដោយ អនុប្បទានចំនួន ០១ច្បាប់ ដោយវាមានអានុភាពលើម៉ាស៊ីនដេរ ១០០គ្រឿង តាមនិយមន័យនៃចលនវត្ថុផ្គុំគ្នាបាន។

ចំពោះករណីដែលចលនវត្ថុដែលផ្គុំគ្នាតែមួយមានការប្រែប្រួលក៏អាចអនុវត្តបានផងដែរ។ *ឧទាហរណ៍ ៖ ឃ្លាំងទំនិញមួយមានទំនិញចេញ និងចូលរាល់ថ្ងៃ។ ដាក់ស្តែងហាងលក់សំលៀកបំពាក់ដែល ក បានជួលពី ខ ប៉ុន្តែសំលៀកបំពាក់ទាំងអស់នៅក្នុងហាងគឺជាកម្មសិទ្ធិរបស់ ក។ ក្នុងករណីដែល ក មានការខ្វះខាតប្រាក់ត្រូវបង្វិល នោះ ក អាចបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានជាមួយ គ ដែលកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាននោះគឺ សំលៀកបំពាក់ទាំងអស់ដែលនៅក្នុងហាងរបស់ ក។ ក្នុងករណីនេះសំលៀកបំពាក់ទាំងអស់នៅក្នុងហាង គឺត្រូវបានចាត់ទុកជាចលនវត្ថុដែលមានចែងនៅក្នុង មាត្រា ៨៨៨ កថាខណ្ឌ ២។ ចំណុចនេះនឹងមានប្រយោជន៍ បន្ទាប់ពីយើងបានសិក្សាពីការចាត់ចែងវត្ថុដោយអ្នកបង្កើត នៃមាត្រា ៨៩៩ កថាខណ្ឌ២។*

ដូចដែលបានបកស្រាយខាងលើអំពីកម្មវត្ថុនៃយន្តការនៃការបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន យើងឃើញថាប្រធានបទបញ្ចាំទាំងមូលត្រូវការពេលវេលាច្រើនទៀត ដើម្បីធ្វើការបកស្រាយ ដូច្នេះនៅក្នុងសារណាបទមួយនេះនឹងកំណត់វិសាលភាពត្រឹមតែការបញ្ចាំចលនវត្ថុ មកសិក្សាប្រៀបធៀបជាមួយប្រាតិភោគដោយអនុប្បទានតែប៉ុណ្ណោះដោយនឹងមិននិយាយពីការបញ្ចាំអចលនវត្ថុ និងការបញ្ចាំសិទ្ធិទៀតនោះឡើយ។

# ជំពូក ២

# ការបង្កើត និង អានុភាព នៃកិច្ចសន្យាបញ្ចាំចលនវត្ថុ និងប្រាតិភោគដោយអនុប្បទាន

# ជំពូកទី២ ការបង្កើត និងអានុភាព នៃកិច្ចសន្យាបញ្ចាំចលនវត្ថុ និងប្រាតិភោគដោយអនុប្បទាន

កិច្ចសន្យានីមួយៗដែលត្រូវបានបង្កើតឡើងតែងតែគោរពនូវលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់នៃកិច្ចសន្យាទូទៅ មុននឹងឈានទៅដល់លក្ខខណ្ឌពិសេសដែលជាលក្ខខណ្ឌតម្រូវដែលអនុញ្ញាតអោយប្រភេទនៃកិច្ចសន្យានីមួយៗនោះមានសុពលភាព។ រីឯអានុភាពនៃប្រភេទកិច្ចសន្យានីមួយៗនោះក៏ត្រូវបាននិតិនិពន្ធសិក្សាយ៉ាងលម្អិតអំពីការប្រើប្រាស់ បរិបទសង្គម និងភាពប្រទាក់ក្រឡាគ្នារវាងចំណងគតិយុត្តនីមួយៗ មុននឹងចងក្រងឡើងអោយមានអានុភាពអនុវត្ត។ ដើម្បីអោយកាន់តែច្បាស់ពីប្រធានបទប្រៀបធៀបមួយនេះ យើងនឹងធ្វើការសិក្សាប្រៀបធៀបលម្អិតពីការបង្កើត និងអានុភាពនៃកិច្ចសន្យាបញ្ចាំចលនវត្ថុ និងប្រាតិភោគដោយអនុប្បទានដូចខាងក្រោមនេះ។

## ២.១ ការបង្កើតកិច្ចសន្យា

កិច្ចសន្យាកម្ចីកើតឡើងដោយកំណារកំណើតនៃការខ្ចីប្រាក់ ឬរបស់របរគ្នាទៅវិញទៅមកពេលមានកង្វះខាត ដែលកិច្ចសន្យាខ្ចីប្រាក់ ស្បៀងអាហារ វត្ថុជំនួសផ្សេងទៀត ក្នុងអំឡុងពេលដែលមានកំណត់នោះត្រូវបានក្រមរដ្ឋប្បវេណីហៅថាជាកិច្ចសន្យាខ្ចីបរិភោគ[8]។ តែដោយហេតុដូចបានបញ្ជាក់ជូនរួចមកហើយ ម្ចាស់បំណុលបានទទួលរងនូវហានិភ័យនៅពេលដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដូចដែលបានចែងនៅក្នុងកិច្ចសន្យា ជាហេតុនាំអោយមានគំនិតនៃការធានាកាតព្វកិច្ចនោះដោយការយកវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុលមកដាក់ធានា ទើបបង្កើតបានជាប្រភេទនៃកិច្ចសន្យាប្រាតិភោគ ដែលសារណាបទមួយនេះលើកឡើងនូវកិច្ចសន្យាបញ្ចាំ និងប្រាតិភោគដោយអនុប្បទានមកធ្វើការប្រៀបធៀបគ្នា។

ចំពោះការបញ្ចាំ នៅក្នុងសេចក្តីកំណត់ក្រម ក៏បានបញ្ជាក់ដែរពីសិទ្ធិម្ចាស់សិទ្ធិក្នុងការកាន់កាប់វត្ថុ ដែលជាកម្មវត្ថុ ដោយពុំបានដកចេញនូវប្រភេទនៃការបញ្ចាំសិទ្ធិនោះឡើយ។ ហេតុនេះនាំអោយ **ការប្រគល់វត្ថុ ឬផ្ទេរការកាន់កាប់** ដែលជាកម្មវត្ថុជាលក្ខណ្ឌចាំបាច់មួយ[9]។ ដូចនេះប្រសិនបើចង់បានការធានាកាតព្វកិច្ចមានលក្ខណៈជាការបញ្ចាំ ត្រូវតែអនុវត្តតាមលក្ខខណ្ឌទម្រង់ដែលមានចែងក្នុងមាត្រា ៨១៨នេះ (ផ្ទេរការកាន់កាប់) ទើបបញ្ញត្តិផ្សេងទៀតនៃផ្នែកទី១ ជំពូកទី៤ នេះអាចអនុវត្តចំពោះទំនាក់ទំនងគតិយុត្តនេះបាន។

---

[8] មាត្រា ៥៧៨ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[9] មាត្រា ៨១៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

*ឧទាហរណ៍៖ ក ជាកូនបំណុល ខ្ចីលុយ ខ ចំនួន ៥ម៉ឺនដុល្លារ ដោយបានសន្យាថាដាក់ទោចក្រយានយន្តរបស់ខ្លួនបញ្ចាំ។ ប៉ុន្តែ ក ពុំបានប្រគល់វត្ថុជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំទៅអោយ ខ ជាម្ចាស់បំណុលរបស់ខ្លួនឡើយ។ ដូចនេះអានុភាពនៃសិទ្ធិលើការបញ្ចាំពុំអាចកើតឡើងឡើយ ប្រសិនបើពុំអនុវត្តតាមលក្ខខណ្ឌទម្រង់គឺ ការប្រគល់វត្ថុ (ការប្រគល់ដោយដាក់ស្តែង ប្រគល់ដោយសង្ខេប និងការផ្ទេរការកាន់កាប់ដោយបញ្ជា)។*

ចំពោះប្រាតិភោគដោយអនុប្បទានវិញប្រសិនបើញែកពីការបកស្រាយពាក្យនីមួយៗ យើងអាចទាញបានថា៖

- **ប្រាតិភោគ** គឺជាមធ្យោបាយក្នុងការធានាសងកាតព្វកិច្ច ដែលម្ចាស់សិទ្ធិដែលមានសិទ្ធិនេះអាចអនុវត្តសិទ្ធិរបស់ខ្លួនបាន ដូចជាការទាមទារអោយលក់វត្ថុជាកម្មវត្ថុដើម្បីទទួលការសងបំណុលដោយមានប្រសិទ្ធិភាព និងការចាត់ចែងប្តូរជាប្រាក់ ឬអនុប្បទានស្ថាពរលើវត្ថុដែលជាកម្មវត្ថុ។
- **អនុប្បទាន** គឺជាការផ្ទេរសិទ្ធិ ពីអនុប្បទាយី ដែលជាកម្មសិទ្ធិករនៃវត្ថុ ទៅអោយអនុប្បទានិកដែលជាអ្នកធ្វើលទ្ធកម្មនូវសិទ្ធិនោះពីអនុប្បទាយី។ ឧទាហរណ៍ អនុប្បទានសិទ្ធិលើបំណុល អនុប្បទានឋានៈក្នុងកិច្ចសន្យាជាអាទិ៍។

នៅក្នុងសេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីផងដែរ បានអោយនិយមន័យកាន់តែច្បាស់ចំពោះពាក្យថាអនុប្បទាននេះ។ ជាគោលគំនិត អនុប្បទាននៅត្រង់នេះមានន័យថា **អនុប្បទានកម្មសិទ្ធិ** (ផ្ទេរកម្មសិទ្ធិ) លើ**ចលនវត្ថុ**។ ដូចនេះលក្ខខណ្ឌដើម្បីបង្កើតប្រាតិភោគដោយអនុប្បទាន គឺ **ការផ្ទេរកម្មសិទ្ធិ**[10]**។**

និយាយជារួមមក ប្រាតិភោគដោយអនុប្បទាន គឺជាការធ្វើអនុប្បទាននូវវត្ថុជាកម្មវត្ថុនៃប្រាតិភោគ ដោយកូនបំណុល ឬតតិយជនដែលធានាកាតព្វកិច្ច ទៅអោយម្ចាស់បំណុលដើម្បីធានាកាតព្វកិច្ច។

*ឧទាហរណ៍ ក ចង់ខ្ចីលុយពី ខ ចំនួន ៥០០០ដុល្លារ ។ ក មានរថយន្តកាមរីមួយ តម្លៃប្រហែល ១០០០០ដុល្លារ។ ក និង ខ ព្រមព្រៀងគ្នាយករថយន្តកាមរីនោះដាក់ បង្កើតបានជាកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន។ ដូចនេះ ក ត្រូវតែប្រគល់រថយន្តក្រោមលក្ខណៈជា**ការផ្ទេរកម្មសិទ្ធិ។***

យើងអាចនិយាយបានថាក្រោយពេលកិច្ចសន្យាប្រាតិភោគដោយអនុប្បទានមានអានុភាពកម្មសិទ្ធិករនៃរថយន្ត គឺជា **ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន**។

[10] ផ្ទេរការកាន់កាប់តាមមាត្រា ២២៩ មាន ៥ទម្រង់

នៅក្នុងបញ្ញត្តិនៃការបញ្ចាំ ពុំអនុញ្ញាតអោយភាគីផ្ទេរការកាន់កាប់ក្រោមទម្រង់ជា **ការផ្លាស់ប្តូរលក្ខណៈនៃការកាន់កាប់** ឡើយ[11]។ ចំណែកឯប្រាតិភោគដោយអនុប្បទានវិញ គឺអនុញ្ញាតអោយផ្ទេរការកាន់កាប់ក្នុងន័យផ្ទេរកម្មសិទ្ធិ ក្រោមទម្រង់ជាការផ្លាស់ប្តូរលក្ខណៈនៃការកាន់កាប់បាន។ ហេតុនេះហើយទើប ការបង្កើតប្រាតិភោគដោយអនុប្បទានអាចមានអានុភាព ទោះបីជាវត្ថុជាកម្មវត្ថុនៅក្នុងដៃរបស់អ្នកបង្កើតក៏ដោយ ខុសពីការបញ្ចាំ ដែលម្ចាស់សិទ្ធិលើការបញ្ចាំ ចាំបាច់ត្រូវកាន់កាប់វត្ថុជាកម្មវត្ថុជាចាំបាច់ និងជានិរន្តរ៍[12]។

ការបង្កើតកិច្ចសន្យាមិនខុសអីពីកិច្ចសន្យាដទៃទៀត ការបញ្ចាំ និងប្រាតិភោគដោយអនុប្បទានត្រូវការលក្ខខណ្ឌទម្រង់ និងលក្ខខណ្ឌគ្រឹះដើម្បីបង្កើតអោយកិច្ចសន្យាមួយមានសុពលភាពផងដែរ ។

### ២.១.១ លក្ខខណ្ឌសុពលភាព

ជាទូទៅសិទ្ធិប្រាតិភោគនីមួយៗត្រូវបានបង្កើតឡើងតាមទម្រង់ ពីរធំៗ។ ទីមួយ ប្រាតិភោគដែលកំណត់ដោយច្បាប់មានដូចជា សិទ្ធិឃាត់ទុក និងឯកសិទ្ធិ ដែលសិទ្ធិទាំងពីរប្រភេទនេះកើតឡើងដោយពុំមានការព្រមព្រៀងនោះទេ។ ចំណែកទីពីរ គឺ ការបញ្ចាំ ហ៊ីប៉ូតែក និងប្រាតិភោគដោយអនុប្បទាន ដែលការបង្កើតសិទ្ធិទាំងនេះចាំបាច់ត្រូវធ្វើឡើងតាមការព្រមព្រៀងរបស់ភាគី។

ជាគោលការណ៍ ការបង្កើតកិច្ចសន្យានីមួយៗត្រូវគោរពទៅតាមបញ្ញត្តិទូទៅ និងបញ្ញត្តិពិសេស ដោយក្នុងករណីដែលបទបញ្ញត្តិពិសេសមិនមានចែង ត្រូវយកបទបញ្ញត្តិទូទៅយកមកអនុវត្ត។ រីឯការបញ្ចាំ និងប្រាតិភោគដោយអនុប្បទានត្រូវគោរពលក្ខខណ្ឌដូចគ្នាទៅនឹងការបង្កើតកិច្ចសន្យាផ្សេងទៀតផងដែរ គឺត្រូវមានការព្រមព្រៀងដោយពិតប្រាកដ និងដោយសេរីរវាងអ្នកបង្កើតសិទ្ធិហៅថា កូនបំណុល និងម្ចាស់សិទ្ធិលើការបញ្ចាំ ហៅថា ម្ចាស់បំណុល ។ ផ្ទុយទៅវិញ ប្រសិនបើមានវិការៈនៃការព្រមព្រៀងដែលបានស្តែងឡើងនៅពេលបង្កើតកិច្ចសន្យា នោះនាំអោយកិច្ចសន្យានោះពុំអាចអនុវត្តបានឡើយ។ ជាមួយគ្នានេះផងដែរ ដើម្បីអោយកិច្ចសន្យាមានសុពលភាព និងអាចអនុវត្តទៅបាន ភាគីនៃកិច្ចសន្យាត្រូវតែជាជនដែលមានសមត្ថភាពពេញលេញ ក្នុងការបង្កើតកិច្ចសន្យាអោយស្របទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះជនដែលមានសមត្ថភាពចុះកិច្ចសន្យាទៅបាន មានតែជនដែលជាសមត្ថជនតែប៉ុណ្ណោះ។ សមត្ថជន នៅក្នុងសន្ទានក្រមនៃក្រមរដ្ឋប្បវេណីថ្មី ឆ្នាំ២០០៧ ទំព័រទី ២១ សំដៅទៅដល់ជនទាំងឡាយណា ក្រៅពីជននៅក្រោមអាណាព្យាបាលទូទៅ និងក្រៅពីជននៅក្រោមហិតូបត្ថម្ភ និងក្រៅពីអនីតិជន លើកលែងតែអនីតិជន ដែលទទួលបានអត្តាធិនភាព។

[11] សេចក្តីកំណត់មាត្រានីមួយនៃក្រមរដ្ឋប្បវេណី ភាគ៥ មាត្រា ៨១៨ ទំព័រ ៣៧

[12] មាត្រា ៨២៥ លក្ខខណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំ

ការបង្កើតកិច្ចសន្យាបញ្ចាំ គឺផ្តោតសំខាន់ទៅលើការប្រគល់វត្ថុបញ្ចាំទៅម្ចាស់សិទ្ធិលើការបញ្ចាំ និងបានហាមឃាត់ម្ចាស់សិទ្ធិលើការបញ្ចាំអោយអ្នកបង្កើតសិទ្ធិនោះកាន់កាប់ដោយផ្ទាល់លើវត្ថុបញ្ចាំនោះទេ ដែលយើងនឹងធ្វើការសិក្សានៅជំពូក ២ ចំណុច **២.២.១.១ លក្ខខណ្ឌតតាំងចាំបាច់នៃសិទ្ធិលើការបញ្ចាំ** ការប្រគល់វត្ថុដែលជាកម្មវត្ថុ។ នេះមានន័យថាសិទ្ធិលើការបញ្ចាំមិនត្រូវបានកើតមានអានុភាពនោះទេ ប្រសិនបើវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំនោះមិនត្រូវបានប្រគល់ទៅ អោយម្ចាស់សិទ្ធិលើការបញ្ចាំកាន់កាប់។ រីឯប្រាតិភោគដោយអនុប្បទានវិញទទួលស្គាល់ការប្តូរ លក្ខណៈនៃការកាន់កាប់ដែលមានន័យថាអាស្រ័យលើការព្រមព្រៀងរបស់ភាគីថាតើយល់ព្រមអោយភាគីម្ចាស់សិទ្ធិ ឬអ្នកបង្កើតសិទ្ធិកាន់កាប់វត្ថុធានា ឬកាន់កាប់ដោយប្រយោល ដែលនឹងបកស្រាយពីការកាន់កាប់វត្ថុប្រាតិភោគដោយអនុប្បទាននេះនៅចំណុច **២.២.២.១ អានុភាពតតាំងនៃកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន។** ចំពោះទម្រង់នៃកិច្ចសន្យាប្រាតិភោគទាំងពីរប្រភេទនេះដែលថាត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬមិនលាយលក្ខណ៍អក្សរ ឬជាយថាភូតឬយ៉ាងណានោះ នៅក្នុងក្រមរដ្ឋប្បវេណី ២០០៧ ពុំបានតម្រូវអោយមានទម្រង់ពិសេសណាមួយនោះទេ គឺសំខាន់តម្រូវអោយមានការព្រមព្រៀងរបស់ភាគីតែប៉ុណ្ណោះ។ ប្រសិនបើមានករណីណាមួយដែលភាគីយល់ព្រមនឹងគ្នាថាត្រូវតែមានលិខិតយថាភូតចំពោះកិច្ចសន្យារបស់ខ្លួនក៏អាចធ្វើឡើងបាន ដែរ។ គួរបញ្ជាក់ផងដែរថា ក្រឹត្យច្បាប់លេខ ៣៨ ក្រ.ច ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ត្រង់មាត្រា ៦៥ ដែលត្រូវបាននិរាករណ៍ទៅហើយនោះ បានចែងអំពីការបង្កើតកិច្ចសន្យាបញ្ចាំចលនវត្ថុដែរថា "កិច្ចសន្យាបញ្ចាំត្រូវធ្វើឡើងជាឱឡារិក និងភណ្ឌិក ហើយតម្រូវអោយធ្វើជាលាយលក្ខណ៍អក្សរ ហើយកិច្ចសន្យានេះ នឹងអាចយកជាការបានលុះត្រាតែទ្រព្យដាក់ធានាត្រូវបានប្រគល់ដល់ដៃម្ចាស់បំណុល"។

ក្រោយពីយល់ដឹងពីលក្ខខណ្ឌសុពលភាពរួចមក យើងនឹងបន្តទៅសិក្សាសញ្ញាណមួយទៀត គឺសិទ្ធិក្នុងការទាមទារបំណុល និងប្រាក់ផ្សេងៗទៀតរបស់ម្ចាស់សិទ្ធិលើការបញ្ចាំនៅពេលដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន។ ដូច្នេះ តើទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានាចំពោះម្ចាស់សិទ្ធិមានទំហំប៉ុណ្ណា? តើមានអ្វីខ្លះ?

### ២.១.២ ទំហំនៃសិទ្ធិលើបំណុលដែលត្រូវធានា

ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ជាទំហំដែលម្ចាស់សិទ្ធិលើការបញ្ចាំ ឬប្រាតិភោគដោយអនុប្បទាននោះ មានសិទ្ធិប្តឹងទាមទារសំណងនៃការខូចខាត ដែលកើតឡើងដោយការរំលោភបំពានដោយអ្នកបង្កើតសិទ្ធិលើការបញ្ចាំមានដូចជា ប្រាក់ដើម ការប្រាក់ ប្រាក់ធានាសងក្នុងករណីមិនគោរពកិច្ចសន្យា សោហ៊ុយដើម្បីថែរក្សាវត្ថុបញ្ចាំ ឬប្រាតិភោគដោយអនុប្បទាន ព្រមទាំង

សំណងនៃការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ឬវិការៈកំបាំងនៃវត្ថុធានា[13]។ នៅក្នុងកិច្ចសន្យាបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ភាគីត្រូវកំណត់ពីចំនួនប្រាក់ដើម ការប្រាក់[14] និងវត្ថុដែលដាក់ប្រាតិភោគអោយបានច្បាស់លាស់ ។ ក្នុងនោះដែរច្បាប់ក៏បានអនុញ្ញាតអោយភាគីនៃកិច្ចសន្យាធ្វើការសន្យាពិសេសនៅក្នុងសកម្មភាពបង្កើត ដូចជាការកម្រិតអត្រាការប្រាក់ និងអនុញ្ញាត ឬមិនអនុញ្ញាតអោយម្ចាស់បំណុលប្រើប្រាស់អាស្រ័យផលទ្រព្យធានា។ ក្នុងករណីប្រាក់ដែលបានមកពីការចាត់ចែងវត្ថុធានា ក្រោយសងទៅម្ចាស់សិទ្ធិលើការបញ្ចាំ ឬប្រាតិភោគដោយអនុប្បទាន និងសំណងផ្សេងៗទៀត និងសំណងដែលបានទាមទារខាងលើរួចរាល់ ប្រសិនបើនៅសល់ត្រូវយកប្រាក់ទាំងនោះទៅទូទាត់សងជាមួយម្ចាស់បំណុលផ្សេងទៀតនោះទេ គឺប្រាក់ដែលនៅសល់នោះត្រូវអោយទៅកូនបំណុលនៃការអនុវត្តវិញទាំងអស់។

សោហ៊ុយដើម្បីអនុវត្តសិទ្ធិលើការបញ្ចាំ គឺជាសោហ៊ុយទាំងឡាយណាដែលចំណាយទៅលើផ្លូវច្បាប់ទាក់ទងនឹងការអនុវត្តសិទ្ធិ ដូចជាពន្ធដាក់ពាក្យសុំ ចំណាយសម្រាប់សេវាមេធាវី និងចំណាយផ្សេងៗពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ រហូតដល់ម្ចាស់សិទ្ធិលើការបញ្ចាំទទួលបានសំណង។ រីឯប្រាតិភោគដោយអនុប្បទានវិញក៏ដូចគ្នាករណីត្រូវឈានទៅដល់ការអនុវត្តដោយបង្ខំ។ ចំណែកសោហ៊ុយដើម្បីថែរក្សាវត្ថុបញ្ចាំ យើងនឹងធ្វើការបកស្រាយស៊ីជម្រៅនៅជំពូក២ ចំណុច **២.២.៣.៣.៣ សិទ្ធិទាមទារអោយសងសោហ៊ុយរបស់ម្ចាស់សិទ្ធិ** នៃសារណានេះ។

ដោយមើលឃើញពីគុណសម្បត្តិខាងលើនេះផង ទើបនាំអោយយន្តការនៃការធានាបំណុលក្រោមរូបភាពនៃការបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន មានការពេញនិយមជាជាងការដាក់ធានាបំណុលផ្សេងទៀតនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន។

## ២.២ អានុភាពនៃការបញ្ចាំចលនវត្ថុ និងប្រាតិភោគដោយអនុប្បទាន

ខាងក្រោមនេះយើងនឹងធ្វើការសិក្សាប្រៀបធៀបពីអានុភាពនីមួយៗដែលលកើតចេញពីកិច្ចសន្យាបញ្ចាំចលនវត្ថុ និងកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន ដោយលើកឡើងពីចំណុចដោយឡែកពីគ្នា និងចំណុចរួមគ្នាមួយចំនួន ក៏ដូចជាបញ្ញត្តិអនុវត្តដូចគ្នា។

[13] មាត្រា ៨២០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
មាត្រា ៨៩៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[14] ការកំណត់អត្រាការប្រាក់ អាចកំណត់បានទៅតាមការព្រមព្រៀង ប៉ុន្តែមិនអោយលើសពីច្បាប់កម្រិតនោះឡើយ។ ក្នុងការកំណត់អត្រាការប្រាក់នៅក្នុងកិច្ចសន្យាឯកជនទូទៅ អត្រាការប្រាក់ត្រូវបានកម្រិតនៅក្រោមប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប៉ុន្តែប្រសិនបើក្នុងវិស័យធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុ អត្រាការប្រាក់ត្រូវកម្រិតនៅក្រោមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា

### ២.២.១ ការបញ្ចាំចលនវត្ថុ

#### ២.២.១.១ លក្ខខណ្ឌតតាំងចាំបាច់នៃសិទ្ធិលើការបញ្ចាំ

លក្ខខណ្ឌតតាំង សំដៅដល់មូលហេតុមួយដែលអាចអោយម្ចាស់បំណុលអាចយកសិទ្ធិលើការបញ្ចាំរបស់ខ្លួនមកប្រើប្រាស់ និងតតាំងចំពោះកូនបំណុល ឬការរំលោភបំពានដោយពុំសុចរិតពីសំណាក់តតិយជន។ នៅក្នុងការសិក្សាពីលក្ខខណ្ឌតតាំងចាំបាច់នៃសិទ្ធិលើការបញ្ចាំនេះ យើងនឹងលើកយកការបញ្ចាំអចនលនវត្ថុ និងការបញ្ចាំសិទ្ធិមកសិក្សា មកសិក្សាផងដែរ ដើម្បីអោយកាន់តែលម្អិត និងមិនមានការភ័ន្តច្រលំនៅពេលអនុវត្ត។

#### ក. ការបញ្ចាំចលនវត្ថុ

នៅក្នុងកិច្ចសន្យាបញ្ចាំចលនវត្ថុមិនបានតម្រូវឲ្យយកវត្ថុបញ្ចាំនោះទៅចុះបញ្ជីអ្វីនោះទេ គឺគ្រាន់តែអ្នកបង្កើតសិទ្ធិលើការបញ្ចាំប្រគល់វត្ថុបញ្ចាំទៅឲ្យម្ចាស់សិទ្ធិលើការបញ្ចាំ ដើម្បីធ្វើការកាន់កាប់ប៉ុណ្ណោះ។ ម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុមិនអាចតតាំងសិទ្ធិលើការបញ្ចាំនោះចំពោះតតិយជនបានឡើយ ប្រសិនបើខ្លួនមិនបានកាន់កាប់ជានិរន្តរ៍នូវវត្ថុបញ្ចាំនោះ[15]។ ផ្ទុយមកវិញ ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំ បានកាន់កាប់វត្ថុបញ្ចាំនៅក្នុងដៃរបស់ខ្លួនជានិរន្តរ៍ នោះម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុអាចយកសិទ្ធិកាន់កាប់នេះ ទៅធ្វើការតតាំងជាមួយតតិយជនបាន ។ មានន័យថា នៅក្នុងយន្តការនៃការបញ្ចាំចលនវត្ថុ ការប្រគល់វត្ថុបញ្ចាំទៅឲ្យម្ចាស់សិទ្ធិលើការបញ្ចាំកាន់កាប់ គឺវាជាលក្ខខណ្ឌមួយសម្រាប់យកទៅតតាំងជាមួយនឹងតតិយជន។ ដូច្នេះនៅពេលដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ច ម្ចាស់សិទ្ធិលើការបញ្ចាំអាចដាក់ពាក្យសុំទៅតុលាការ ដើម្បីយកវត្ថុបញ្ចាំមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនផ្ទាល់ ឬលក់ដើម្បីទូទាត់សងបំណុលរបស់ខ្លួនបានដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត។ ផ្ទុយទៅវិញ ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុ មិនបានកាន់កាប់វត្ថុបញ្ចាំដោយផ្ទាល់នោះទេ នោះវានឹងធ្វើឲ្យម្ចាស់សិទ្ធិថ្លោះធ្លោយ មិនអាចយកសិទ្ធិនេះទៅតតាំងជាមួយតតិយជនបានឡើយ ដែលវានឹងធ្វើឲ្យខាតបង់ផលប្រយោជន៍ជាក់ជាមិនខាន។ យ៉ាងណាមិញ នៅក្នុងករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំបាត់បង់ការកាន់កាប់វត្ថុបញ្ចាំ តាមរយៈការដេកហូតរបស់កូនបំណុល ឬតតិយជន ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្ដឹងទាមទារយកវត្ថុបញ្ចាំនោះមកវិញតាមរយៈការដាក់ពាក្យបណ្ដឹងទៅតុលាការ ដើម្បីទាមទារឲ្យកូនបំណុល ឬតតិយជននោះប្រគល់វត្ថុបញ្ចាំមកវិញ[16]។ គួរបញ្ជាក់ថា ការកាន់កាប់នៅក្នុងន័យនេះ គឺក្នុងន័យចង្អុលបង្ហាញទៅរកមាត្រា ៨១៨ នៃក្រមរដ្ឋប្បវេណី គឺការប្រគល់វត្ថុចាំបាច់ដើម្បីបង្កើតសិទ្ធិលើការបញ្ចាំ ដោយរាប់បញ្ចូល

[15] មាត្រា ៨២៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[16] មាត្រា ៨៣០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ទាំងការប្រគល់ដោយសង្ខេប ដែលមានកំណត់នៅក្នុងកថាខណ្ឌទី ៣ នៃមាត្រា ២២៩ (ការផ្ទេរការកាន់កាប់) នៃក្រមរដ្ឋប្បវេណីផងដែរ។ មានន័យថាដើម្បីទទួលបានការកាន់កាប់ជាក់ស្តែង តម្រូវអោយកូនបំណុល ប្រគល់វត្ថុទៅអោយម្ចាស់បំណុលនៃការបញ្ចាំ ដើម្បីអោយកិច្ចសន្យាបញ្ចាំមានអានុភាព។ ម្ចាស់សិទ្ធិលើការបញ្ចាំ មិនអាចអោយអ្នកបង្កើតសិទ្ធិលើការបញ្ចាំនោះកាន់កាប់ដោយផ្ទាល់លើវត្ថុបញ្ចាំនោះបានឡើយ[17]។

*ឧទាហរណ៍ ៖ បុគ្គល ក បានយកទូរស័ព្ទដៃរបស់ខ្លួនតម្លៃ ៥០០ដុល្លារអាមេរិចទៅដាក់ប្រាតិភោគដោយអនុប្បទានបានទឹកប្រាក់ចំនួន ២០០ដុល្លារ។ កិច្ចសន្យាប្រាតិភោគដោយអនុប្បទាននេះកើតឡើងដោយ បុគ្គល ក ប្រគល់ទូរស័ព្ទរបស់ខ្លួនដែលជាកម្មវត្ថុនៃការដាក់ធានានោះ ទៅអោយបុគ្គល ខ ដែលជាម្ចាស់ហាងប្រាតិភោគដោយអនុប្បទាននោះ មានន័យថាបុគ្គល ខ ទទួលបានសិទ្ធិក្នុងការកាន់កាប់ទូរស័ព្ទដោយផ្ទាល់ ជាក់ស្តែង។*

### ខ. ការបញ្ចាំអចលនវត្ថុ

នៅក្នុងការបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុ ដែលអាចយកទៅធ្វើជាលក្ខខណ្ឌតតាំងជាមួយតតិយជនបាន លុះត្រាតែកិច្ចសន្យាបញ្ចាំនោះធ្វើជាលិខិតយថាភូត និងបានចុះបញ្ជីត្រឹមត្រូវនៅមន្ទីរសុរិយោដីដែលលក្ខខណ្ឌទាំងនេះ វាខុសគ្នាទៅនឹងការបង្កើតសិទ្ធិលើការបញ្ចាំចលនវត្ថុ និងការបញ្ចាំសិទ្ធិ។ ទាក់ទិនទៅនឹងការអនុវត្តចំពោះការបញ្ចាំអចលនវត្ថុនេះ យោងតាមមាត្រា ៨៣៩ នៃក្រមរដ្ឋប្បវេណី ក៏បានបញ្ញត្តិអោយយកបញ្ញត្តិស្តីពីហ៊ីប៉ូតែកមកអនុវត្តដូចគ្នាចំពោះការបញ្ចាំអចលនវត្ថុផងដែរ។ ប៉ុន្តែបញ្ញត្តិមាត្រានេះ មិនបានបញ្ជាក់អោយបានច្បាស់លាស់អំពីការអនុវត្តទៅតាមចំណុចណាខ្លះនៃហ៊ីប៉ូតែក ឬក៏ត្រូវអនុវត្តទៅតាមបញ្ញត្តិស្តីពីហ៊ីប៉ូតែកទាំងអស់ ឬយ៉ាងណានោះទេ។ យោងទៅលើសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ដែលបានរៀបរៀងដោយក្រសួងយុត្តិធម៌ បោះពុម្ពឆ្នាំ ២០១០ បានសង្កត់ធ្ងន់ទៅលើការអនុវត្តដូចគ្នារវាងសិទ្ធិលើការបញ្ចាំអចលនវត្ថុ និងហ៊ីប៉ូតែក តែទៅលើមាត្រា ៨៤៥ នៃក្រមរដ្ឋប្បវេណី ដោយតម្រូវអោយម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុមិនអាចយកសិទ្ធិលើការបញ្ចាំរបស់ខ្លួន ទៅតតាំងចំពោះតតិយជនបានឡើយ ប្រសិនបើខ្លួនមិនបានបង្កើតសិទ្ធិលើការបញ្ចាំ ដោយលិខិតយថាភូត និងមិនបានចុះបញ្ជីនៅមន្ទីសុរិយោដី។ ដូចនេះការកាន់កាប់វត្ថុបញ្ចាំ វាមិនមែនជាលក្ខខណ្ឌតតាំងចំពោះតតិយជន ចំពោះសិទ្ធិលើការបញ្ចាំអចលនវត្ថុឡើយ លើកលែងតែការបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុ ធ្វើឡើងជាលិខិតយថាភូត និងបានចុះបញ្ជីនៅមន្ទីសុរិយោដី ទើបម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ អាចយកសិទ្ធិលើការបញ្ចាំរបស់ខ្លួន ទៅតតាំងចំពោះតតិយជនបាន។

[17] មាត្រា ៨១៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

*ឧទាហរណ៍ ៖ លោក សំណាង និងអ្នកស្រី កុលាប បានបង្កើតកិច្ចសន្យាបញ្ចាំមួយដោយលោកសំណាង បានដាក់ដីរបស់ខ្លួនចំនួន ១ហិចតាកន្លះជាទ្រព្យធានា។ ហេតុនេះដើម្បីអោយកិច្ចសន្យាបញ្ចាំនេះត្រូវបានបង្កើតឡើង តម្រូវអោយភាគី យកដីនោះទៅធ្វើការចុះបញ្ជី និងធ្វើជាលិខិតយថាភូតត្រឹមត្រូវតាមច្បាប់។*

**គ. ការបញ្ចាំសិទ្ធិ**

លក្ខខណ្ឌតតាំងចំពោះការបញ្ចាំសិទ្ធិ វាមានលក្ខណៈខុសគ្នាទៅនឹងការបញ្ចាំចលនវត្ថុ និងការបញ្ចាំអចលនវត្ថុ ដែលវាទាមទារអោយមានការជូនដំណឹង ឬមានការយល់ព្រមពីកូនបំណុលទី ៣ អំពីការបង្កើតសិទ្ធិលើការបញ្ចាំដល់កូនបំណុលទី ៣ ទើបអាចធ្វើអោយម្ចាស់សិទ្ធិលើការបញ្ចាំអាចតតាំងជាមួយនឹងកូនបំណុលទី ៣ បាន[18]។ ការជូនដំណឹង ឬការយល់ព្រមពីកូនបំណុលទី៣ វាជាលក្ខខណ្ឌមួយសម្រាប់តតាំងចំពោះកូនបំណុលទី ៣ ប៉ុណ្ណោះ វាមិនអាចយកទៅតតាំងចំពោះតតិយជនផ្សេងទៀតបានឡើយ លើកលែងតែធ្វើឡើងដោយលិខិតដែលមានកាលបរិច្ឆេទស្ថាពរ[19]។ ឧទាហរណ៍ ៖ ក ជាម្ចាស់បំណុលរបស់ គ ចំនួន ២ម៉ឺនដុល្លារអាមេរិច។ តែ ក ចង់ខ្ចីបំណុលពី ខ ចំនួន ១ម៉ឺនដុល្លារ។ ប្រសិនបើ ក គ្មានទ្រព្យអ្វីផ្សេងយកមកបញ្ចាំអោយ ខ ដើម្បីធានាបំណុលទេ ក អាច យកសិទ្ធិលើបំណុលរបស់ខ្លួនដែលមានចំពោះ គ ទៅដាក់បញ្ចាំអោយ ខ ដើម្បីធានានូវការសងបំណុលដែលខ្លួនមានចំពោះ ខ បាន។

**២.២.១.២ អានុភាពចំពោះផលពីទ្រព្យបញ្ចាំ**

សិទ្ធិប្រាតិភោគភ្ជាប់ទៅនឹងទ្រព្យធានា វាក៏ត្រូវបានភ្ជាប់ដោយស្វ័យប្រវត្តិទៅនឹងផលនៃទ្រព្យធានាផងដែរ។ ទោះបីកិច្ចព្រមព្រៀងមិនបានបញ្ជាក់ថាសិទ្ធិប្រាតិភោគគ្របដណ្តប់លើផលក៏ដោយ ក៏វាមានអានុភាពលើផលដោយស្វ័យប្រវត្តិ ក៏ប៉ុន្តែគូភាគីអាចយល់ព្រមថាផលនៃទ្រព្យធានាមិនត្រូវបានគ្របដណ្តប់ដោយសិទ្ធិប្រាតិភោគក៏បាន។ ងាកទៅមើលសិទ្ធិលើការបញ្ចាំ មិនខុសគ្នាឡើយ សិទ្ធិលើការបញ្ចាំក៏មានលើផលដែរ តែភាគីអាចព្រមព្រៀងគ្នាថា ទំហំនៃសិទ្ធិលើបំណុលគ្មានទៅលើផលនៃទ្រព្យធានា[20] ព្រោះជាទូទៅគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន តែងតែយកមកប្រើប្រាស់នៅក្នុងក្រមរដ្ឋប្បវេណី ព្រោះនីតិករមិនចង់រិតត្បិតសកម្មភាពនៃការបង្កើតសិទ្ធិលើការបញ្ចាំហួសហេតុពេកទេ មិនដូចច្នោះទេច្បាប់នឹងត្រូវវិសោធនកម្មជាញឹកញាប់ ព្រមទាំងមិនសមស្របនឹងស្ថានភាពរបស់ប្រជាពលរដ្ឋ។ សិទ្ធិដែលទទួបានផលកើតចេញពីវត្ថុដែលជាកម្មវត្ថុនៃការ

[18] មាត្រា ៨៤១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី

[19] មាត្រា ៨៤១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី

[20] មាត្រា ៨២០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

បញ្ចាំ ត្រូវយកទៅទូទាត់ការប្រាក់នៃសិទ្ធិលើបំណុលជាមុន បន្ទាប់មកយកទៅទូទាត់នឹងប្រាក់ដើម ហើយបើនៅសល់ត្រូវប្រគល់ជូនអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ឬម្ចាស់បំណុលដទៃទៀត [21] ។ ទោះបីជាយ៉ាងណាក៏ដោយ ការយកផលនៃវត្ថុដែលដាក់ធានាមកសងសិទ្ធិលើបំណុលតាមរបបគតិយុត្តនៃការបញ្ចាំ គឺជាបញ្ញត្តិតាមការព្រមព្រៀងតែប៉ុណ្ណោះ។ ប៉ុន្តែគួរកត់សំគាល់ថា បើយកផលមកសង ម្ចាស់បំណុលត្រូវតែយកមកកាត់ការប្រាក់នៃសិទ្ធិលើបំណុលជាមុន សល់ប៉ុន្មានយកទៅកាត់ប្រាក់ដើមដោយមិនមែនទទួលផលទទេៗបាននោះទេ។

### ២.២.១.៣ ការប្រើប្រាស់ និងអាស្រ័យផលចំពោះការបញ្ចាំចលនវត្ថុ

យើងបានដឹងហើយថា ការបញ្ចាំទោះបីជាចលនវត្ថុក្តី ឬអចលនវត្ថុក្តី អ្នកបង្កើតសិទ្ធិលើការបញ្ចាំមានកាតព្វកិច្ចក្នុងការប្រគល់វត្ថុបញ្ចាំទៅអោយម្ចាស់សិទ្ធិលើការបញ្ចាំកាន់កាប់ ក្នុងចំណុចនេះ យើងអាចចោទជាសំណួរបានថា ក្រោយពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំបានប្រគល់វត្ថុបញ្ចាំទៅម្ចាស់សិទ្ធិលើការបញ្ចាំកាន់កាប់ហើយនោះ តើម្ចាស់សិទ្ធិលើការបញ្ចាំមានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលទៅលើវត្ថុបញ្ចាំនោះបានដែរ ឬទេ?

ដោយហេតុថាប្រធានបទយើងលើកយកតែការបញ្ចាំចលនវត្ថុមកសិក្សាប្រៀបធៀប ហេតុនេះ នៅក្នុងការបញ្ចាំចលនវត្ថុដូចជាឡាន ម៉ូតូជាដើម ម្ចាស់សិទ្ធិលើការបញ្ចាំមានសិទ្ធិកាន់កាប់វត្ថុបញ្ចាំ ក៏ប៉ុន្តែមិនមានសិទ្ធិយកវត្ថុនេះទៅប្រើប្រាស់ ឬយកទៅអាស្រ័យផល ដូចជាយកទៅជួលបាននោះទេ។ ប៉ុន្តែបើមានការអនុញ្ញាត និងមានការព្រមព្រៀងពីសំណាក់អ្នកបង្កើតសិទ្ធិលើការបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើប្រាស់ និងជួលវត្ថុបញ្ចាំនោះបាន ព្រោះថា ជាគោលការណ៍ច្បាប់គោរពនូវសេរីភាពឆន្ទះរបស់បុគ្គលឯកជន។ ហើយម្យ៉ាងទៀត ទោះបីជាគ្មានការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំក៏ដោយ ក៏ម្ចាស់សិទ្ធិលើការបញ្ចាំ នៅតែអាចប្រើប្រាស់វត្ថុបញ្ចាំបានដដែល ប៉ុន្តែការប្រើប្រាស់នោះត្រូវបានកម្រិត ត្រឹមតែជាការប្រើប្រាស់ចាំបាច់ក្នុងការថែរក្សាវត្ថុបញ្ចាំ និងមិនអាចយកវត្ថុបញ្ចាំនោះទៅជួលបានទេ។

ក្នុងករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំប្រើប្រាស់ ឬជួលវត្ថុបញ្ចាំ ដោយគ្មានការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ឬមិនមានភាពចាំបាច់ក្នុងការថែរក្សាវត្ថុបញ្ចាំទេនោះ អ្នកបង្កើតសិទ្ធិលើការបញ្ចាំអាចទាមទារអោយរំលត់សិទ្ធិលើការបញ្ចាំនេះបាន[22]។

[21] មាត្រា ៨២២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[22] មាត្រា ៨៣១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ២.២.១.៤ ការបញ្ចាំបន្ត

ជាគោលការណ៍នៅក្នុងកិច្ចសន្យា គូភាគីអាចកំណត់លក្ខខណ្ឌរបស់ខ្លួនបានដោយសេរី ដោយផ្អែកទៅលើការព្រមព្រៀងគ្នា លើកលែងតែការព្រមព្រៀងនោះវាផ្ទុយទៅនឹងច្បាប់ និង ទំនៀមទំលាប់ប្រពៃណីល្អរបស់សង្គមតែប៉ុណ្ណោះ។ ក្នុងករណីខ្លះ ច្បាប់បានអនុញ្ញាតអោយភាគី ដាក់លក្ខខណ្ឌពិសេសណាមួយ ប៉ុន្តែត្រូវមានការព្រមព្រៀងពីភាគីម្ខាងទៀតជាមុនសិន។ យ៉ាង ណាមិញ នៅក្នុងករណីរបស់យើង អ្នកបង្កើតសិទ្ធិលើការបញ្ចាំបានប្រគល់វត្ថុបញ្ចាំមកអោយម្ចាស់ សិទ្ធិលើការបញ្ចាំកាន់កាប់ ហើយច្បាប់ក៏បានអនុញ្ញាតអោយម្ចាស់សិទ្ធិលើការបញ្ចាំក្នុងការយកវត្ថុ បញ្ចាំនោះទៅដាក់បញ្ចាំបន្តជាមួយនឹងតតិយជនផ្សេងទៀតបានផងដែរ។ ដូចច្នេះ តើការបញ្ចាំបន្ត នូវវត្ថុបញ្ចាំនេះ ម្ចាស់សិទ្ធិលើការបញ្ចាំចាំបាច់ត្រូវមានការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ដែរ ឬទេ? ពាក់ព័ន្ធទៅនឹងចំណុចនេះក្រមរដ្ឋប្បវេណីថ្មី ឆ្នាំ ២០០៧ បានធ្វើការបែងចែកជា ២ ករណីផ្សេងគ្នា គឺការបញ្ចាំបន្តដោយមានការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំ និងការបញ្ចាំ បន្តក្រោមការទទួលខុសត្រូវរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ។

#### ក. ការបញ្ចាំបន្ត ដោយមានការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំ

ជាគោលការណ៍នៃការបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំត្រូវកាន់កាប់វត្ថុបញ្ចាំដោយផ្ទាល់ តាមរ យៈ ការកាន់កាប់នេះម្ចាស់សិទ្ធិលើការបញ្ចាំអាចយកវត្ថុបញ្ចាំ ទៅដាក់បញ្ចាំបន្តទៀតបានដើម្បី ធានានូវកាតព្វកិច្ចរបស់ខ្លួន អោយតែមានការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំ[23]។ ក្នុងករណី នេះអានុភាពនៃការបញ្ចាំបន្ត នឹងត្រូវអាស្រ័យទៅលើកិច្ចព្រមព្រៀងក្នុងការបញ្ចាំក្រោយនេះ ប៉ុន្តែ នៅក្នុងក្រមរដ្ឋប្បវេណីថ្មីមិនបានបញ្ជាក់ពីអានុភាពនៃការបញ្ចាំបន្ត ក៏ដូចជាខ្លឹមសារនៃអានុភាពនៃ ការបញ្ចាំបន្តនោះឡើយ។

#### ខ. ការបញ្ចាំបន្តក្រោមការទទួលខុសត្រូវរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ

ក្នុងករណីដែលមិនមានការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ក្នុងការយកវត្ថុបញ្ចាំទៅ ដាក់បញ្ចាំបន្តទេនោះ ម្ចាស់សិទ្ធិលើការបញ្ចាំនៅតែអាចយកវត្ថុបញ្ចាំ ទៅដាក់បញ្ចាំបន្តបានដដែល ដោយស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ខ្លួន[24]។ ក្នុងករណីនេះម្ចាស់សិទ្ធិលើការបញ្ចាំដែលជា អ្នកបង្កើតសិទ្ធិលើការបញ្ចាំបន្ត នឹងត្រូវទទួលខុសត្រូវចំពោះការខូចខាតនូវវត្ថុបញ្ចាំនោះ ទោះបីជា ការខូចខាតនោះកើតឡើងដោយសារម្ចាស់សិទ្ធិលើការបញ្ចាំបន្ត (អ្នកទទួលបញ្ចាំបន្ត) ឬខូចខាត ដោយករណីប្រធានសក្តិក៏ដោយ។

---

[23] មាត្រា ៨២៦ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី ២០០៧

[24] មាត្រា ៨២៦ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី ២០០៧

មួយវិញទៀតនៅក្នុងករណីអ្នកបង្កើតសិទ្ធិលើការបញ្ចាំបន្ត មិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងការសងបំណុលទៅអោយម្ចាស់សិទ្ធិលើការបញ្ចាំបន្ត ហើយម្ចាស់សិទ្ធិលើការបញ្ចាំបន្តបានអនុវត្តសិទ្ធិលើការបញ្ចាំរបស់ខ្លួន ម្ចាស់សិទ្ធិលើការបញ្ចាំបន្តអាចទទួលនូវការសងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនទាំងអស់ ដោយមានកម្រិតនូវចំនួនទឹកប្រាក់ដែលត្រូវចែកចំណែកទៅអោយម្ចាស់សិទ្ធិលើការបញ្ចាំដើមប៉ុណ្ណោះ។ ប៉ុន្តែប្រសិនបើសិទ្ធិលើបំណុលរបស់ខ្លួន (ការបញ្ចាំបន្ត) មិនទាន់ដល់ពេលកំណត់ត្រូវសងទេនោះ ម្ចាស់សិទ្ធិលើការបញ្ចាំបន្ត គ្រាន់តែអាចទាមទារអោយតម្កល់ នូវចំនួនទឹកប្រាក់ដែលខ្លួនអាចទទួលការសងនោះប៉ុណ្ណោះ[25]។ នោះមានន័យថា ទំហំនៃការបញ្ចាំបន្តត្រូវបានបង្កើតដោយម្ចាស់សិទ្ធិលើការបញ្ចាំ នឹងត្រូវបានកម្រិតត្រឹមសិទ្ធិនៃការបញ្ចាំដើមប៉ុណ្ណោះ។ ទោះបីជាការបញ្ចាំបន្តត្រូវបង្កើតឡើងហួសពីទំហំនៃសិទ្ធិនៃការបញ្ចាំដើម ចំពោះអំឡុងពេល ឬចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលត្រូវបានធានាក៏ដោយ ក៏ការបញ្ចាំបន្តនោះមិនមែនមោឃៈឡើយ ប៉ុន្តែអាចតតាំងចំពោះអ្នកបង្កើតសិទ្ធិលើការបញ្ចាំដើមត្រឹមទំហំនៃសិទ្ធិលើការបញ្ចាំដើមប៉ុណ្ណោះ។

**២.២.១.៥ ឧបាទេសកម្មលើវត្ថុបញ្ចាំ**

ឧបាទេសកម្ម គឺជាសិទ្ធិដើម្បីប្តូរនឹងតម្លៃនៃកម្មវត្ថុជាក់លាក់ណាមួយ។ ដូចនេះហើយម្ចាស់សិទ្ធិប្រាតិភោគអាចអនុវត្តសិទ្ធិលើការបញ្ចាំរបស់ខ្លួនចំពោះប្រាក់ ឬវត្ថុផ្សេងទៀតដែលអ្នកបង្កើតសិទ្ធិប្រាតិភោគមានសិទ្ធិទទួល ដោយមូលហេតុនៃការលក់ ឬការបាត់បង់ ឬការខូចខាតកម្មវត្ថុនៃការបញ្ចាំ ព្រោះមូលហេតុទាំងនោះត្រូវបានគេចាត់ទុកជាការបំប្លែងនូវតម្លៃនៃចលនវត្ថុដែលជាប់ការបញ្ចាំ ឬប្រាតិភោគដោយអនុប្បទាន។ ប៉ុន្តែម្ចាស់សិទ្ធិប្រាតិភោគពុំអាចអនុវត្តសិទ្ធិរបស់ខ្លួនបានឡើយ នៅក្រោយពេលដែលប្រាក់ត្រូវបានបង់ ឬវត្ថុផ្សេងទៀត ត្រូវបានប្រគល់ទៅអោយអ្នកបង្កើតសិទ្ធិប្រាតិភោគនោះ [26]។

ករណីនេះក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះតម្លៃថ្នូរនឹងសិទ្ធិប្រត្យក្សដែលបង្កើតឡើង ដោយអ្នកបង្កើតសិទ្ធិលើការបញ្ចាំ លើវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ។ ដោយសារតែសិទ្ធិប្រាតិភោគក្នុងរូបភាពនៃការបញ្ចាំ ត្រូវបានបង្កើតឡើង និងអាចអនុវត្តបានតែចំពោះកម្មវត្ថុណាមួយជាក់លាក់តែប៉ុណ្ណោះ ដូចនេះប្រាក់ ឬវត្ថុផ្សេងទៀតមិនអាចត្រូវបានគេបែងចែកពីទ្រព្យសម្បត្តិផ្សេងទៀតបានទេ នៅក្រោយពេលដែលប្រាក់ ឬវត្ថុផ្សេងទៀតនោះ ត្រូវបានប្រគល់ទៅអោយអ្នកបង្កើតសិទ្ធិលើការបញ្ចាំ[27]។

[25] មាត្រា ៨២៦កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[26] មាត្រា ៨១៧ កថាខណ្ឌ ១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[27] មាត្រា ១៩៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ឧទាហរណ៍ ៖ ក បានបង្កើតសិទ្ធិប្រាតិភោគនៅលើរថយន្តមួយគ្រឿងរបស់ខ្លួនទៅអោយ ខ ដើម្បីធានាបំណុលរបស់ខ្លួនចំនួន ១០០០០ដុល្លារ ប៉ុន្តែ គ ជាអ្នកដែលបានធ្វើអោយរថយន្តនោះខូចខ្ទេចខ្ទីគ្មានសល់។ ដូចនេះ ខ ដែលជាម្ចាស់សិទ្ធិប្រាតិភោគអាចប្ដឹងទាមទារប្រាក់ដែលជាថ្លៃសំណងការខូចខាតរថយន្តពី គ បានតាមរយៈឧបាទេសកម្មលើវត្ថុនៃម្ចាស់សិទ្ធិប្រាតិភោគលើរថយន្តដែលបានខូចខ្ទេចខ្ទីនោះ។ តែបើ គ បានផ្តល់ប្រាក់សំណងខូចខាតនៃរថយន្តនោះទៅអោយ ក រួចហើយ នោះ ខ មិនអាចប្ដឹងទាមទារប្រាក់ពី ក តាមរយៈឧបាទេសកម្មលើវត្ថុបានទៀតទេ ព្រោះថាប្រាក់ដែលជាសំណងនៃថ្លៃខូចខាតនៃរថយន្តដែល ក បានទទួលនោះ នឹងក្លាយទៅជាទ្រព្យទូទៅរបស់ ក ហើយ។ ប៉ុន្តែ ខ នៅតែមានសិទ្ធិទាមទារប្រាក់ជំពាក់ពី ក ក្នុងនាមជាម្ចាស់បំណុលធម្មតា។

### ២.២.១.៦ ការហាមឃាត់ចំពោះកិច្ចសន្យាបញ្ចាំផ្ដាច់

នៅក្នុងការអនុវត្តក្នុងសង្គមខ្មែរតាំងពីដើមមក យើងតែងតែឃើញមានករណីយកទ្រព្យដូចជាឡាន ម៉ូតូ គ្រឿងអលង្ការ ឬទូរស័ព្ទជាដើមទៅដាក់បញ្ចាំ ដោយបានកំណត់គ្នាជាមុននៅក្នុងកិច្ចសន្យា នូវរយៈពេលមួយជាកំណត់ត្រូវយកប្រាក់មកលោះ បើកូនបំណុលពុំមានវត្តមានមកលោះវត្ថុរបស់ខ្លួនវិញតាមកាលកំណត់នោះទេ វត្ថុបញ្ចាំនឹងត្រូវក្លាយជាកម្មសិទ្ធិរបស់ម្ចាស់បំណុល។

*សំណួរសួរថា តើការអនុវត្តរបៀបនេះ ជាការអនុវត្តស្របច្បាប់ដែរឬយ៉ាងណា?*

ជាការពិតណាស់ កន្លងមកយើងតែងតែឃើញការអនុវត្តបែបនេះកើតមានឡើងជាធម្មតា ក៏ប៉ុន្តែនៅក្នុងក្រមរដ្ឋប្បវេណីថ្មី បានចែងយ៉ាងច្បាស់អំពីការហាមលើការបញ្ចាំផ្ដាច់ មិនថាការបញ្ចាំនោះជាចលនវត្ថុ ឬអចលនវត្ថុក៏ដោយ គឺបានហាមឃាត់មិនអោយមានការបង្កើតសិទ្ធិលើការបញ្ចាំផ្ដាច់នោះទេ[28]។ នៅក្នុងយន្តការនៃការបញ្ចាំចលនវត្ថុ ម្ចាស់សិទ្ធិលើការបញ្ចាំ អាចទាមទារយកទ្រព្យបញ្ចាំមកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ជំនួសការសងបំណុលមកខ្លួនបាន ប៉ុន្តែការទាមទារនេះអាចធ្វើទៅបានលុះត្រាតែមានមូលហេតុត្រឹមត្រូវ និងចាំបាច់ត្រូវធ្វើឡើងតាមផ្លូវតុលាការ មិនអាចធ្វើឡើងតាមរយៈការកំណត់ជាមុននៅក្នុងកិច្ចសន្យាបាននោះទេ។ ក្នុងករណីនេះ ម្ចាស់សិទ្ធិលើការបញ្ចាំត្រូវជូនដំណឹងអំពីការទាមទារនេះទៅកូនបំណុលជាមុន។

ជាមួយគ្នានេះផងដែរក្រមរដ្ឋប្បវេណីបានសង្កត់ធ្ងន់ទៅលើ "មូលហេតុត្រឹមត្រូវ"[29] ដែលជាលក្ខខណ្ឌមួយសម្រាប់អោយម្ចាស់សិទ្ធិលើការបញ្ចាំ អាចធ្វើការទាមទារយកទ្រព្យបញ្ចាំមកធ្វើជា

[28] មាត្រា ៨២៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[29] មាត្រា ៨៣២ កថាខណ្ឌ ១ នៃក្រមរដ្ឋប្បវេណី ២០០៧

កម្មសិទ្ធិផ្ទាល់ខ្លួន។ មូលហេតុត្រឹមត្រូវ គឺសំដៅទៅលើម្ចាស់បំណុលផ្សេងៗទៀតរបស់កូនបំណុល ដែលមានសិទ្ធិប្រាតិភោគប្រត្យក្ស ដោយមានអាទិភាពជាងម្ចាស់សិទ្ធិលើការបញ្ចាំនេះ។ យើងឃើញថាអ្នកបង្កើតសិទ្ធិលើការបញ្ចាំបានយកវត្ថុបញ្ចាំមកដាក់បញ្ចាំជាមួយម្ចាស់សិទ្ធិលើការបញ្ចាំក៏ពិតមែន ក៏មិនអាចប្រាកដថាម្ចាស់សិទ្ធិលើការបញ្ចាំ មានអាទិភាពជាងម្ចាស់បំណុលផ្សេងៗទៀតនោះទេ ដែលនោះវាអាស្រ័យលំដាប់នៃអាទិភាពនៃសិទ្ធិប្រាតិភោគតែប៉ុណ្ណោះ។ ដូច្នេះប្រសិនបើម្ចាស់បំណុលផ្សេងទៀត ដែលមានសិទ្ធិប្រាតិភោគប្រត្យក្សដែលមានអាទិភាពខ្ពស់ជាងម្ចាស់សិទ្ធិលើកាបញ្ចាំនឹងត្រូវបានចាត់ទុកថាមិនមានមូលហេតុត្រឹមត្រូវនោះទេ។

### ២.២.១.៧ អានុភាពលើវត្ថុភ្ជាប់នឹងវត្ថុបញ្ចាំ

#### ក. សមាសភាគនៃវត្ថុ

សមាសភាគនៃវត្ថុ សំដៅទៅលើសមាសភាគ ដែលមិនអាចបំបែកបាន ដោយមិនប្តូរលក្ខណៈដើមនៃវត្ថុ [30] ដូចជាទ្វាររថយន្តជាដើម។ ចំពោះការបញ្ចាំ មិនអាចធ្វើបាននោះទេលើចលនវត្ថុដែលភ្ជាប់នឹងវត្ថុធានារបៀបនេះ ព្រោះវាបានក្លាយជាសមាសភាគនៃវត្ថុ ដូចជាអេក្រង់កុំព្យូទ័រដែលភ្ជាប់ទៅនឹងម៉ាស៊ីន កុំព្យូទ័រយ៉ាងដូច្នេះដែរ ដែលអ្នកបង្កើតបានយកទៅបង្កើតសិទ្ធិលើការបញ្ចាំ។ អ្វីដែលគួរអោយកត់សម្គាល់ថាសិទ្ធិលើការបញ្ចាំមិនអាចបង្កើតបានលើចលនវត្ថុដែលត្រូវបានភ្ជាប់នឹងវត្ថុធានា ព្រោះអ្នកបង្កើតសិទ្ធិគ្មានលទ្ធភាពក្នុងការប្រគល់វត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ទៅម្ចាស់សិទ្ធិលើការបញ្ចាំនោះទេ និងម្យ៉ាងទៀត លក្ខខណ្ឌអានុភាពរបស់របបគតិយុត្តនៃការបញ្ចាំ គឺការប្រគល់វត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ។ បើភាគីព្រមព្រៀងថាមិនចាំបាច់ប្រគល់ ការបញ្ចាំនៅតែអាចធ្វើបានតែគ្មាន អានុភាពការពារតាមផ្លូវច្បាប់នោះទេ។

#### ខ. វត្ថុចំណុះ និងវត្ថុចម្បង

ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មិនបានបញ្ញត្តិអំពីនិយមន័យនៃវត្ថុចម្បងនោះទេ ប៉ុន្តែយើងអាចធ្វើការស្វែងយល់អំពីអត្ថន័យនៃវត្ថុចម្បងតាមរយៈនិយមន័យនៃវត្ថុចំណុះបានថា វត្ថុចំណុះជាវត្ថុដែលមិនមែនជាសមាសភាគនៃវត្ថុចម្បង ហើយដែលកម្មសិទ្ធិករនៃវត្ថុចំណុះបានភ្ជាប់ទៅនឹងវត្ថុចម្បងក្នុងគោលបំណងសេដ្ឋកិច្ចនៃវត្ថុចម្បង។ ការបង្កើត និងការផ្ទេរសិទ្ធិចំពោះវត្ថុចម្បង ត្រូវមានអានុភាពចំពោះវត្ថុចំណុះផងដែរ លើកលែងតែមានការសន្យាពិសេស [31] ។ នេះមានន័យថាការបង្កើតសិទ្ធិប្រាតិភោគលើវត្ថុចម្បង អាចនឹងមិនមានអានុភាពដល់វត្ថុចំណុះ លើកលែងតែភាគីធ្វើការព្រមព្រៀងផ្សេង។ ករណីនេះក៏មិនខុសអីពីការបង្កើតសិទ្ធិលើសមាសភាគនៃវត្ថុធានា ឬ

[30] មាត្រា ១២១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[31] មាត្រា ១២៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ចលនវត្ថុតាំងភ្ជាប់ទេ ការបង្កើតសិទ្ធិលើការបញ្ចាំលើវត្ថុចម្បង ហើយក្រោយមកវត្ថុចម្បងនោះត្រូវបានភ្ជាប់ទៅនឹងវត្ថុចំណុះដោយសារការកែច្នៃ និងការលម្អជាអាទិ៍ ក៏មិនអាចនឹងមិនអាចកើតមានដែរ ដោយយើងបានដឹងហើយថា ការបញ្ចាំមានលក្ខខណ្ឌអានុភាពនៃការប្រគល់វត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំទៅម្ចាស់សិទ្ធិ ដូចនេះគ្មានករណីណាដែលវត្ថុចម្បងត្រូវបានភ្ជាប់នឹងវត្ថុចំណុះដោយអ្នកបង្កើតសិទ្ធិដើម្បីបង្កើនតម្លៃសេដ្ឋកិច្ចអ្វីទេ ព្រោះវត្ថុនេះមិននៅក្នុងដៃអ្នកបង្កើតសិទ្ធិលើការបញ្ចាំស្រាប់ទៅហើយ។

### ២.២.២ ប្រាតិភោគដោយអនុប្បទាន

ថ្វីត្បិតតែប្រាតិភោគដោយអនុប្បទាន គឺជាសញ្ញាណថ្មីមួយក៏ពិតមែន ប៉ុន្តែវាត្រូវបានប្រើប្រាស់រួចជាយូរមកហើយ ដោយត្រូវបានបុគ្គលទូទៅមានការភ័ន្តច្រលំ ហៅថាជាការបញ្ចាំទៅវិញ មូលហេតុដែលយើងនិយាយបែបនេះបាន ដោយសារតែការអនុវត្តជាក់ស្តែង កិច្ចសន្យាបញ្ចាំ គឺត្រូវបានគេបញ្ចាំផ្តាច់តែម្តង ព្រមទាំងនៅមានអានុភាពមួយចំនួនទៀតដែលយើងនឹងសិក្សានៅខាងក្រោមនេះ។

#### ២.២.២.១ លក្ខខណ្ឌតតាំងនៃកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន

ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ពុំអាចតតាំងសិទ្ធិប្រាតិភោគដោយអនុប្បទាននោះចំពោះតតិយជនក្រៅពីអ្នកបង្កើតបានឡើយ បើពុំបានទទួលការផ្ទេរការកាន់កាប់វត្ថុដែលជាកម្មវត្ថុ[32]។ ដើម្បីតតាំងប្រាតិភោគអនុប្បទានដែលត្រូវបានបង្កើតតាមកិច្ចព្រមព្រៀងរវាងភាគី ចំពោះតតិយជន ចាំបាច់ត្រូវផ្ទេរការកាន់កាប់នៃវត្ថុដែលជាកម្មវត្ថុ។ ការផ្ទេរការកាន់កាប់អាចស្តែងឡើងតាមរូបភាពបួនយ៉ាងគឺ ការប្រគល់ដោយជាក់ស្តែង ការប្តូរលក្ខណៈនៃការកាន់កាប់ ការប្រគល់ដោយសង្ខេប និង ការផ្ទេរការកាន់កាប់ដោយបញ្ជា[33]។ ជាពិសេសបើយោងតាម "ការប្តូរលក្ខណៈនៃការកាន់កាប់" គឺការកាន់កាប់អាចត្រូវបានផ្ទេរ ដោយការព្រមព្រៀងរវាងគូភាគីតែប៉ុណ្ណោះ ដោយគ្មានការប្រគល់ដោយជាក់ស្តែង។ ក្នុងករណីនេះអនុប្បទានិកនៃការកាន់កាប់ត្រូវទទួលការកាន់កាប់ដោយប្រយោលតាមរយៈអនុប្បទាយី នោះកូនបំណុលអាចដាក់ចលនវត្ថុជាប្រាតិភោគ ដោយបន្តការកាន់កាប់ និងប្រើប្រាស់ចលនវត្ថុដែលជាកម្មវត្ថុនោះ។ ការកាន់កាប់សំដៅដល់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានក្តាប់ទុកវត្ថុដោយខ្លួនឯង មានន័យថាវត្ថុនោះនៅនឹងដៃរបស់ម្ចាស់សិទ្ធិនោះ តតិយជនដែលទទួលបញ្ជាពីម្ចាស់សិទ្ធិនោះ។ បញ្ញត្តិសិទ្ធិលើការបញ្ចាំ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះករណីដែលម្ចាស់សិទ្ធិប្រាតិភោគអនុប្បទានកាន់កាប់នូវវត្ថុដែលជាកម្មវត្ថុ ពីព្រោះទំនាក់

[32] មាត្រា ៨៩០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[33] មាត្រា ២២៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ទំនងរវាងម្ចាស់សិទ្ធិ និងវត្ថុដែលជាកម្មវត្ថុ គឺស្រដៀងគ្នានឹងទំនាក់ទំនងរវាងម្ចាស់សិទ្ធិលើការបញ្ចាំ និង វត្ថុដែលជាកម្មវត្ថុ។ រីឯការផ្ទេរការកាន់កាប់ដែលជាលក្ខខណ្ឌតតាំងនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ទាំងនោះមានដូចជា៖

- ការប្រគល់វត្ថុជាក់ស្តែង គែជាការផ្ទេរតាមរយៈការប្រគល់វត្ថុកាន់កាប់។
- ការប្តូរលក្ខណៈនៃការកាន់កាប់ សំដៅទៅលើការកាន់កាប់ដែលអាចធ្វើការផ្ទេរតាមការព្រមព្រៀងរបស់ភាគី ដោយមិនចាំបាច់ធ្វើការប្រគល់ជាក់ស្តែងនោះទេ។ *តួយ៉ាង លោក ក បានទិញរថយន្តពីលោក ខ បន្ទាប់ពីចុះកិច្ចសន្យាទិញលក់រួច លោក ខ ចង់ជួលរថយន្តពីលោក ក ដូចនេះលោក ក ជាអ្នកកាន់កាប់ដោយប្រយោលចំណែកលោក ខ ជាអ្នកកាន់កាប់ដោយផ្ទាល់។ បើមើលទៅវាហាក់បីដូចជាការកាន់កាប់ពុំបានផ្ទេរនោះទេ តែជាក់ស្តែងការកាន់កាប់ត្រូវបានផ្ទេរតាមការព្រមព្រៀងពីលោក ខ ទៅលោក ក។ មើលទៅរូបភាពនេះលោក ក មិនទាន់បានកាន់កាប់ដោយចំពោះម្តងណាទេ។*
- ការប្រគល់ដោយសង្ខេប គឺជាការផ្ទេរការកាន់កាប់តាមរយៈការព្រមព្រៀងរបស់ភាគី ក្នុងករណីដែលអនុប្បទានិកបានក្តាប់ទុកវត្ថុដែលជាកម្មវត្ថុនៃការកាន់កាប់នោះនៅក្នុងដៃតាមការជាក់ស្តែង ហើយអនុប្បទាយីបានបាត់បង់ការកាន់កាប់ដោយប្រយោលរបស់ខ្លួនដែលធ្លាប់មាន។ *ឧទាហរណ៍ ៖ លោក ក បានជួលរថយន្តពីលោក ខ តែក្រោយមកលោក ក បានទិញរថយន្តនោះពីលោក ខ តែម្តង។ ក្នុងករណីនេះលោក ខ បានបាត់បង់ការកាន់កាប់ដោយប្រយោលដែលខ្លួនធ្លាប់មានព្រោះលោក ខ បានបាត់បង់ការកាន់កាប់វត្ថុដោយចំពោះតាំងពីដើមមកម្លេះដោយសារតែកិច្ចសន្យាជួល លុះដល់ពេលកិច្ចសន្យាទិញលក់កើតឡើង លោក ខ មិនមានវត្ថុដែលត្រូវប្រគល់អោយលោក ក នោះទេ ព្រោះវត្ថុនោះនៅនឹងដៃលោក ក ស្រាប់ទៅហើយ។ នេះហើយជារូបភាពនៃការប្រគល់ដោយសង្ខេប។*
- ការផ្ទេរការកាន់កាប់ដោយការបញ្ជា សំដៅលើម្ចាស់សិទ្ធិដែលកាន់កាប់ដោយប្រយោលលើវត្ថុបានបង្កើតកិច្ចព្រមព្រៀងថាផ្ទេរការកាន់កាប់ទៅ តតិយជន ហើយក្នុងករណីនេះម្ចាស់សិទ្ធិមានករណីយកិច្ចក្នុងការជូនដំណឹងអំពីហេតុនោះទៅអ្នកកាន់កាប់ដោយចំពោះលើវត្ថុនោះដើម្បីគាត់ធ្វើការផ្ទេរទៅតតិយជន។ *ឧទាហរណ៍ ៖ លោក ក ជួលផ្ទះអោយលោក ខ ហើយកំឡុងពេលជួលនេះលោក ក បានលក់ផ្ទះនេះទៅលោក គ ដែលជាតតិយជន។ ដូចនេះលោក ក មាន*

*ករណីយកិច្ចជូនដំណឹងទៅលោក ខ ដើម្បីអោយដឹងថាលោក គ កំពុងកាន់កាប់ដោយចំពោះលើទ្រព្យរបស់លោក ខ តាមរយៈអត្ថិភាពនៃកិច្ចសន្យាជួលដែលបានបង្កើត។*

**២.២.២.២ អានុភាពចំពោះផលដែលកើតចេញពីទ្រព្យធានា**

នៅក្រោមរបបគតិយុត្តនៃប្រាតិភោគដោយអនុប្បទាន អានុភាពចំពោះផលត្រូវបានបែងចែកជាពីរករណី៖

**ក. ករណីអ្នកបង្កើតប្រាតិភោគដោយអនុប្បទាន ឬតតិយជនដែលទទួលបញ្ញាពីអ្នកបង្កើត កាន់កាប់វត្ថុដោយចំពោះ**

ករណីដែលវត្ថុដែលជាកម្មវត្ថុ នៅក្នុងដៃកូនបំណុល ឬតតិយជនដែលទទួលបញ្ញា ដូច្នេះអានុភាពនៃផលមិនភ្ជាប់សិទ្ធិប្រាតិភោគដោយអនុប្បទានទេ មានន័យថាកូនបំណុលអាចប្រើប្រាស់ និងអាស្រ័យផលពីវត្ថុដែលជាកម្មវត្ថុ។ ប៉ុន្តែផលត្រូវទទួលបាននូវអានុភាពករណីដែលពេលកំណត់ត្រូវសងបានមកដល់ (ផុតអំឡុងពេលប្រាតិភោគ ឬនៅពេលម្ចាស់បំណុលទាមទារនៅពេលក្រោយ) ហើយម្ចាស់បំណុលបានទាមទារ ដោយធ្វើការចាត់ចែងប្តូរជាប្រាក់ ឬអនុប្បទានជាស្ថាពរ នោះកូនបំណុលលែងមានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលពីវត្ថុនោះទៀតហើយ[34]។

**ខ. ករណីម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬតតិយជនដែលទទួលការបញ្ញាពីម្ចាស់សិទ្ធិ កាន់កាប់វត្ថុដោយចំពោះ**

ករណីដែលម្ចាស់បំណុល ឬតតិយជនដែលទទួលបញ្ញា កាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ គាត់មានសិទ្ធិទទួលផលដែលកើតឡើងពីវត្ថុនោះ ហើយត្រូវកាត់សិទ្ធិលើបំណុលដោយយកផលទៅកាត់ការប្រាក់ជាមុនសិន ហើយប្រសិនបើមានសល់ត្រូវយកកាត់ប្រាក់ដើម[35]។ ម្ចាស់បំណុលមិនចាំបាច់ យកផលមកកាត់សិទ្ធិលើបំណុលទេ ក្នុងករណីដែលម្ចាស់បំណុលមិនអាចទាមទារការប្រាក់ពីកូនបំណុលបាន និយាយរួមគឺមិនចាំបាច់យកផលនេះទៅទូទាត់នឹងការប្រាក់ដែលខ្លួនអាចទទួលបាន។ ផ្ទុយទៅវិញ បើសិនជាកូនបំណុលបង្កើតកិច្ចព្រមព្រៀងពិសេសដើម្បីបង្កើតកិច្ចសន្យាប្រាតិភោគដោយអនុប្បទានដោយមានការប្រាក់ ដូចជាកិច្ចសន្យាខ្ចីបរិភោគជាអាទិ៍ នោះម្ចាស់បំណុលចាំបាច់ត្រូវយកផលដែលខ្លួនទទួលបានពីវត្ថុដែលជាកម្មវត្ថុ ទៅកាត់សិទ្ធិលើបំណុល នេះដោយសារតែខ្លួនបានទទួលការប្រាក់ទៅហើយ មិនគួរអាស្រ័យផលថែមទៀតទេ។[36]

[34] មាត្រា ៨៩២ កថាខណ្ឌ ១ នៃក្រមរដ្ឋប្បវេណី ២០០៧

[35] មាត្រា ៨២២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[36] មាត្រា៨៩២ កថាខណ្ឌ ២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

តាមការកំណត់នៃមាត្រា៨៩២ នៃកថាខណ្ឌទី ១ ការអនុវត្តរបស់ប្រាតិភោគដោយអនុប្បទានហាក់មានលក្ខណៈស្រដៀងគ្នាទៅនឹងការអនុវត្តហ៊ីប៉ូតែក ដោយហេតុថាអ្នកបង្កើតបានកាន់កាប់នូវកម្មវត្ថុនោះដោយចំពោះ នោះគេអាចមានសិទ្ធិក្នុងការប្រើប្រាស់ផលដែលបានពីវត្ថុដោយផ្អែកលើសិទ្ធិប្រើប្រាស់ និងអាស្រ័យផល។ ការកំណត់បែបនេះអាចធ្វើអោយយើងយល់ថាអ្នកបង្កើតហាក់ដូចជាមានប្រយោជន៍លើសលប់លើម្ចាស់សិទ្ធិ ព្រោះថាអាចយកផលពីកម្មវត្ថុមកធ្វើជារបស់ខ្លួនបាន តែបើមិនមានការកំណត់បែបនេះវាធ្វើអោយការកាន់កាប់របស់អ្នកបង្កើតលើកម្មវត្ថុនោះទៅជាគ្មានប្រយោជន៍ទៅវិញ ព្រោះថាគាត់មានការកាន់កាប់ដោយចំពោះតែបែជាមិនអាចទទួលយកផលពីវត្ថុនោះបានវាដូចគ្នានឹងការប្រគល់កម្មវត្ថុទៅម្ចាស់សិទ្ធិដែរ។ ម្យ៉ាងវិញទៀតនៅក្នុងការកាន់កាប់កម្មវត្ថុ អ្នកបង្កើតអាចមានការចំណាយផ្សេងៗដើម្បីថែរក្សាកម្មវត្ថុ បើគាត់បានចំណាយថវិកាដើម្បីថែរក្សាកម្មវត្ថុហើយ មិនបានទទួលផលទៀតនោះ វានឹងធ្វើអោយគាត់ខាត់ប្រយោជន៍ជាក់ជាមិនខាន។ ហេតុដូចនេះហើយទើបពេលដែលអ្នកបង្កើតកាន់កាប់វត្ថុដោយចំពោះគាត់អាចយកផលពីវត្ថុធានានោះបាន។

ទោះបីជាមានការបញ្ញត្តិក្នុងកថាខណ្ឌ១ ហើយក៏ដោយ ក៏មានអញ្ញត្រកម្មមួយដែលអ្នកបង្កើតកាន់កាប់វត្ថុដោយចំពោះមិនមានសិទ្ធិទទួលយកផលបានដែរ ដោយអនុវត្តបញ្ញត្តិដែលមានចែងក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ មាត្រា ៨៩១នេះ គឺនៅក្រោយពេលដែលម្ចាស់សិទ្ធិបានទាមទារអោយប្រគល់វត្ថុដែលជាកម្មវត្ថុមកវិញហើយ ទោះបីជាអ្នកបង្កើតនៅតែបន្តកាន់កាប់វត្ថុនោះក៏ដោយក៏ផលដែលបានទទួលមកមិនអាចក្លាយជារបស់អ្នកបង្កើតនោះដែរ។ ចំណែកឯមូលហេតុដែលគេមិនអនុវត្តចំពោះផលដែលផ្អែកលើ**មាត្រា ៨៩៨ ការចាត់ចែងប្តូរជាប្រាក់ ឬអនុប្បទានជាស្ថាពរ (ចំណុច ៣.២.២ ករណីកម្មវត្ថុនៅក្នុងដៃអ្នកបង្កើត)** នេះគឺផ្តោតសំខាន់លើការមិនគោរពកាតព្វកិច្ចរបស់អ្នកបង្កើតទើបម្ចាស់សិទ្ធិអាចយកវត្ថុនោះមកកាន់កាប់ដោយខ្លួនឯងវិញ ដើម្បីអោយអ្នកបង្កើតសងនូវកាតព្វកិច្ចដែលមានចំពោះខ្លួន។

ចំពោះករណីដែលម្ចាស់សិទ្ធិបានកាន់កាប់កម្មវត្ថុដោយចំពោះវិញ ការអនុវត្តចំពោះផលមានលក្ខណៈដូចគ្នានឹងសិទ្ធិប្រត្យក្សដទៃទៀតយោងតាមមាត្រា ៨៩២ កថាខណ្ឌ ២។ យើងអាចមានការភ័ន្តច្រលំថាការធ្វើប្រាតិភោគដោយអនុប្បទានជាការផ្ទេរកម្មសិទ្ធិ នោះផលដែលបានមកពីការកាន់កាប់នឹងក្លាយជារបស់ម្ចាស់សិទ្ធិក្នុងនាមជាកម្មសិទ្ធិករ ដែលមានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលពីវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួន តែដោយសារសិទ្ធិ ប្រាតិភោគជាផ្នែកមួយនៃសិទ្ធិប្រត្យក្ស គេយល់ឃើញថាគួរតែធ្វើអោយការអនុវត្តសិទ្ធិនេះមានលក្ខណៈដូចគ្នាច្រើនទនឹងសិទ្ធិប្រត្យក្សផ្សេងទៀតដែរ គឺថាទោះបីជាម្ចាស់សិទ្ធិបានកាន់កាប់វត្ថុនោះក៏ដោយ ក៏ប្រាក់ដែលបាន

ផលត្រូវយកមកកាត់សិទ្ធិលើបំណុល ត្រូវបានអនុវត្តតាមមាត្រា ៨២២[37] សិទ្ធិទទួលការសងពីផល ដោយមានអាទិភាព របស់បញ្ញត្តិស្តីពីការបញ្ចាំ នៃក្រមរដ្ឋប្បវេណី ២០០៧ ដែរ ដែលបញ្ញត្តិថា ៖

**១. ម្ចាស់សិទ្ធិលើការបញ្ចាំអាចទទួលផលដែលកើតពីវត្ថុបញ្ចាំ និងអាចយកផលនោះមកកាត់សិទ្ធិលើបំណុលរបស់ខ្លួនដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតបាន។**

**២. ផលដែលកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកកាត់ការប្រាក់នៃសិទ្ធិលើបំណុលជាមុន ហើយប្រសិនបើមានសំណល់ត្រូវយកទៅកាត់ប្រាក់ដើម។**

តាមន័យនៃមាត្រា ៨៩២ នេះ សិទ្ធិលើបំណុលក្នុងកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន ត្រូវអនុវត្តដូចគ្នានឹងសិទ្ធិលើការបញ្ចាំ មានន័យថាបើម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានជាអ្នកកាន់កាប់កម្មវត្ថុដោយចំពោះហើយបានទទួលផលពីកម្មវត្ថុនោះ ត្រូវយកផលនោះមកកាត់ការប្រាក់អោយអស់ជាមុនសិន ហើយបើនៅសល់ផលត្រូវយកផលនោះមកកាត់ប្រាក់ដើមមិនអាចយកមកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនបានឡើយ។

ទោះជាមានការបញ្ញត្តិអោយមានការអនុវត្តតាមមាត្រា ៨២២ ក្តី បើម្ចាស់សិទ្ធិមានបំណងយកផលមកធ្វើជារបស់ខ្លួនវិញ គេអាចធ្វើបានតែមិនត្រូវយកការប្រាក់នោះ វៀរលែងតែមានករណីដែលចែងផ្ទុយពីនេះ។ ការចែងផ្ទុយពីនេះគឺ ករណីដែលអ្នកបង្កើត និងម្ចាស់សិទ្ធិបានព្រមព្រៀងគ្នាថាយល់ព្រមអោយម្ចាស់សិទ្ធិយកទាំងការប្រាក់ ទាំងផល បើពុំមានចែងនោះទេ នឹងត្រូវអនុវត្តចំពោះផលដូចដែលចែងក្នុងមាត្រា ៨៩២ កថាខណ្ឌទី២ ជាកំហិត[38]។

យើងគួរពិនិត្យមើលលើអង្គហេតុមួយ ដើម្បីបង្ហាញពីលក្ខណៈនៃការអនុវត្តរបស់ផលនេះ។ លោក ក និងលោក ខ បានបង្កើតនូវសិទ្ធិប្រាតិភោគដោយអនុប្បទានមួយដោយលោក ក ជាអ្នកបង្កើត និងលោក ខ ជាម្ចាស់សិទ្ធិ។ ដើម្បីជាការធានាដល់ការអនុវត្ត កាតព្វកិច្ចរបស់ខ្លួន លោក ក បានយករថយន្តទេសចរណ៍ ១៥កៅអី មួយគ្រឿងតម្លៃ ១៦០លានរៀល ដែលគាត់ប្រើដើម្បីប្រកបអាជីវកម្មជួលយកកម្រៃជាប្រចាំ មកដាក់ធ្វើជាកម្មវត្ថុ ក្នុងការខ្ចីប្រាក់ ១០០លានរៀល ដោយមានកំណត់ការសងកាតព្វកិច្ចក្នុងរយៈពេល ១ឆ្នាំ ជាមួយការប្រាក់ ៥% ក្នុងមួយឆ្នាំ ដែលនឹងត្រូវទូទាត់នៅដំណាច់ឆ្នាំតែម្តង។ នៅក្នុងករណីនេះលក្ខណៈនៃការកាន់កាប់ពីរយ៉ាងបានកើតឡើង ដែលនាំអោយមានលក្ខខណ្ឌពីរក្នុងការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទានផងដែរ។

---

[38] សេចក្តីកំណត់ក្រមរដ្ឋប្បវេណី ភាគទី៤ គន្ថីទី៦ មាត្រា ៨៩២ ទំព័រ ១០៥

*ករណីសិក្សាទីមួយ លោក ក និងលោក ខ បានព្រមព្រៀងគ្នាថាអោយលោក ក បន្តកាន់កាប់រថយន្តដដែលតាមរយៈការប្តូរលក្ខណៈនៃការកាន់កាប់វត្ថុដូចមានចែងក្នុងមាត្រា ២២៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។ ដោយរថយន្តដែលយកមកធ្វើជាកម្មវត្ថុនេះ ត្រូវបានជួលយកកម្រៃជាប្រចាំដើម្បីទ្រទ្រង់ជីវភាព ហេតុនេះហើយលោក ក ស្នើសុំបន្តកាន់កាប់វត្ថុនោះ ហើយផលដែលកើតពីការជួលរថយន្តនេះ ត្រូវធ្លាក់ជារបស់លោក ក មិនមែនជារបស់លោក ខ ដែលជាម្ចាស់សិទ្ធិនោះទេ ដោយផ្អែកតាមបញ្ញត្តិនៃមាត្រា ៨៩១ កថាខណ្ឌទី ១។ លុះដល់ពេលមួយឆ្នាំបន្ទាប់ពីការធ្វើប្រាតិភោគដោយអនុប្បទានរួចមក គឺដល់ពេលកំណត់ត្រូវសងកាតព្វកិច្ច តែលោក ក មិនអាចអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមកិច្ចសន្យាបានឡើយ ជាហេតុនាំអោយលោក ខ ទាមទារអោយប្រគល់កម្មវត្ថុមកវិញ ដោយផ្អែកលើសិទ្ធិជាម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន។ បន្ទាប់ពីមនាការទាមទារនេះហើយ ផលដែលទទួលបានត្រូវតែជារបស់លោក ខ ដើម្បីយកមកកាត់សិទ្ធិលើបំណុល ទោះជាលោក ក នៅតែបន្តកាន់កាប់កម្មវត្ថុដោយចំពោះដ៏ដោយ។ ក្នុងករណីដែលលោក ក នៅតែបន្តប្រើប្រាស់ផលនោះ បើមានសេចក្តីសម្រេចពីតុលាការអោយប្រគល់កម្មវត្ថុទៅអោយលោក ខ ផលដែលលោក ក បានប្រើប្រាស់បន្ទាប់ពីការទាមទារនោះត្រូវតែសងទៅលោក ខ វិញ។ ពេលវេលានៃការទាមទារ គឺចាប់ផ្តើមពីការជូនដំណឹងអោយប្រគល់វត្ថុ មិនមែនបន្ទាប់ពីពេលប្រកាសសេចក្តីសម្រេចរបស់តុលាការនោះទេ។ បើលោក កមិនអាចសងផលបាននោះទេ វានឹងក្លាយជាបំណុលបន្ថែមលើបំណុលដែលលោក ក បានជំពាក់លោក ខ។*

*ករណីសិក្សាទី ២ លោក ខ ដែលជាម្ចាស់សិទ្ធិបានកាន់កាប់វត្ថុដោយចំពោះវិញ។ លោក ខ បានយករថយន្តដែលជាកម្មវត្ថុមកប្រើប្រាស់ធ្វើអាជីវកម្មដើម្បីយកផល។ តាមការអនុវត្តនៃការផ្ទេរកម្មសិទ្ធិ ផលដែលទទួលបានពីការជួលនេះត្រូវក្លាយជារបស់លោក ខ ក៏ប៉ុន្តែតាមការអនុវត្តនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន លោល ខ មិនអាចប្រើប្រាស់ផលនេះក្នុងគោលដៅផ្ទាល់ខ្លួនឡើយ តែត្រូវយកមកកាត់សិទ្ធិលើបំណុលដូចជាប្រាក់ដើម ការប្រាក់ ឬសោហ៊ុយចំណាយផ្សេងៗ។ ឧបមារថយន្តនេះអាចរកចំណូលបាន ១០លានរៀន ក្នុងមួយខែ នៅដំណាច់ឆ្នាំ លោក ខ នឹងរកបានប្រាក់ ១២០លានរៀល ប្រាក់នេះនឹងយកមកកាត់សិទ្ធិលើបំណុលទាំងការប្រាក់ ប្រាក់ដើម និងសោហ៊ុយផ្សេងៗអោយអស់ បើមានសល់ប្រាក់គេនឹងប្រគល់ទៅអោយលោក ក ដែលហៅថាប្រាក់ជម្រះ។ ក៏ប៉ុន្តែបើនៅក្នុងសកម្មភាពបង្កើតបានចែងផ្ទុយ គឺអនុញ្ញាតអោយលោក ខ អាចប្រើប្រាស់ផលបាន ហើយលោក ក ត្រូវបង់ប្រាក់អោយលោក ខ ដដែល នោះគេនឹងយកបញ្ញត្តិក្នុងសកម្មភាពនេះមកអនុវត្តវិញ។*

### ២.២.២.៣ ការចាត់ចែងវត្ថុធានា

យ៉ាងណាមិញយើងបានសិក្សារួចមកហើយពីអានុភាពនៃការបញ្ចាំបន្ត ក្រោមរូបភាពដោយមានការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំ និងការបញ្ចាំបន្តក្រោមការទទួលខុសត្រូវរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ។ ក្រមរដ្ឋប្បវេណី២០០៧ ដែលកំពុងអនុវត្តជាធរមានសព្វថ្ងៃ ក៏ពុំបានបញ្ញត្តិហាមឃាត់ពុំអោយមានការយកទៅដាក់ប្រាតិភោគដោយអនុប្បទានបន្តនោះដែរ ដោយវាអាស្រ័យទៅលើកិច្ចសន្យា ឬការព្រមព្រៀងរបស់គូភាគីប៉ុណ្ណោះ។ បន្ថែមទៅលើការមិនហាមឃាត់ចំពោះករណីប្រាតិភោគដោយអនុប្បទានបន្តនេះ ដោយហេតុថាមាត្រា ៨៩០ នៃក្រមរដ្ឋប្បវេណី បានចង្អុលបង្ហាញទៅរកការប្តូរ លក្ខណៈនៃការកាន់កាប់ដូចបានបកស្រាយខាងលើនោះ នាំអោយវត្ថុធានាអាចនៅតែស្ថិតក្នុងដៃអ្នកបង្កើតសិទ្ធិលើប្រាតិភោគដោយអនុប្បទានជាអ្នកកាន់កាប់ បញ្ហាក៏អាចនឹងកើតមានឡើង នៅពេលដែលអ្នកបង្កើតនោះមានភាពមិនស្មោះត្រង់ យកវត្ថុធានានោះទៅដាក់ធានាប្រាតិភោគដោយអនុប្បទានជាមួយតតិយជនផ្សេងទៀត។ ចំណោទបញ្ហានេះនឹងត្រូវបានដោះស្រាយដោយយើងវិភាគទៅលើគោលការណ៍ទូទៅ ថាតើការកាន់កាប់ជាក់ស្តែងវត្ថុធានាស្ថិតនៅក្នុងដៃម្ចាស់បំណុលទីមួយ ឬម្ចាស់បំណុលទីពីរ ហើយនឹងភាពសុចរិត និងគ្មានកំហុសរបស់ម្ចាស់បំណុលរបស់ម្ចាស់បំណុលទី២នោះ ក្នុងការទទួលយកចលនវត្ថុដែលជាកម្មវត្ថុដាក់ធានាបំណុល។ ពោលគឺគេអាចអនុវត្តបញ្ញត្តិស្តីពីលទ្ធកម្មដោយសុចរិត (មាត្រា ១៩៣នៃក្រមរដ្ឋប្បវេណី) ចំពោះប្រាតិភោគដោយអនុប្បទានលំដាប់ទីពីរនេះ។

### ២.២.២.៤ ឧបាទេសកម្មលើវត្ថុនៃកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន

ប្រាតិភោគដោយអនុប្បទានមានលក្ខណៈដូចគ្នានឹងការបញ្ចាំចំពោះករណី ដែលអោយម្ចាស់សិទ្ធិប្រាតិភោគ អាចធ្វើឧបាទេសកម្មចំពោះប្រាក់ ឬវត្ថុផ្សេងដទៃទៀត ដែលត្រូវទទួលការលក់ ការបាត់បង់ ឬការខូចខាតនូវវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាននោះ។ ដូចគ្នានេះដែរម្ចាស់សិទ្ធិប្រាតិភោគពុំអាចអនុវត្តសិទ្ធិរបស់ខ្លួនបានឡើយ នៅក្រោយពេលដែលប្រាក់ត្រូវបានបង់ ឬវត្ថុផ្សេងទៀត ត្រូវបានប្រគល់ទៅអោយអ្នកបង្កើតសិទ្ធិប្រាតិភោគនោះ[39]។ ប៉ុន្តែករណីពិសេសរបស់ប្រាតិភោគដោយអនុប្បទាន ដែលខុសពីការបញ្ចាំ ដែលធ្វើឡើងតែចំពោះវត្ថុជាក់លាក់នោះ គឺក្នុងករណីចលនវត្ថុផ្គុំគ្នា ហើយចលនវត្ថុនោះត្រូវមានគម្រោងលក់តាំងពីដំបូង នូវចលនវត្ថុនេះទៅអោយ អ្នកផ្សេងទៀត ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានមិនអាចធ្វើឧបាទេសកម្មបានទេ។

[39] មាត្រា ៨៩៣ កថាខណ្ឌ ១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

*ឧទាហរណ៍ ៖ លោក ក បានយកទំនិញរបស់ខ្លួន ទៅបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានជាមួយលោក ខ។ ក្រោយមកលោក ក បានលក់សាងទំនិញទាំងអស់នោះទៅអោយលោក គ។ ក្នុងករណីនោះលោក ក អាចធ្វើឧបាទេសកម្មលើប្រាក់ដែលជាថ្លៃសាងទំនិញនោះពីលោក គ បាន ប៉ុន្តែក្នុងករណីដែលប្រាក់នោះត្រូវបានប្រគល់ទៅអោយលោក ក ហើយនោះ គឺលោក គ មិនអាចធ្វើឧបាទេសកម្មបាននោះទេ។*

ក្នុងករណីមួយផ្សេងទៀត លោក ក បានយកទំនិញរបស់ខ្លួននៅក្នុងឃ្លាំងដែលជាចលនវត្ថុផ្គុំគ្នាដែលត្រូវបានគ្រោងលក់ ទៅបង្កើតប្រាតិភោគដោយអនុប្បទានជាមួយ លោក ខ។ ក្នុងករណីនេះ អ្វីក៏ដោយដែលចូល ឬចេញ ទំនិញដែលមាននៅក្នុងឃ្លាំងនាពេលនេះ ត្រូវបានចាត់ទុកថាជាចលនវត្ថុផ្គុំគ្នា។ ហេតុដូច្នេះ អានុភាពនៃប្រាតិភោគ មិនមានចំពោះវត្ថុដែលត្រូវបានយកចេញនោះទេ។ ក្នុងករណីនេះ លោក ខ មិនអាចធ្វើឧបាទេសកម្មលើទឹកប្រាក់ដែលបានពីការលក់ទំនិញនោះទេ។

### ២.២.២.៥ ប្រាតិភោគដោយអនុប្បទានធៀបនឹងការបញ្ចាំផ្ដាច់

ទាក់ទងនឹងសញ្ញាណនៃការបញ្ចាំផ្ដាច់ដូចដែលបានសិក្សានៅចំណុច **២.២.១.៦ នៃជំពូកដដែលនេះ** យើងឃើញថាវាមានលក្ខណៈស្រដៀងគ្នាទៅនឹងសញ្ញាណនៃប្រាតិភោគដោយអនុប្បទាន។ ប្រាតិភោគដោយអនប្បទាន គឺជាកិច្ចសន្យាប្រាតិភោគមួយប្រភេទដែលកូនបំណុលឬតតិយជនបានធ្វើអនុប្បទាននូវចលនវត្ថុរបស់ខ្លួន ទៅអោយម្ចាស់បំណុលដើម្បីធានាកាតព្វកិច្ចរបស់ខ្លួន។ ក្នុងករណីបើកាតព្វកិច្ចត្រូវបានសងរួចហើយ កម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុ ត្រូវផ្ទេរទៅអ្នកបង្កើតវិញ[40]។ តាមន័យនេះបញ្ជាក់អោយយើងឃើញថាសញ្ញាណនៃប្រាតិភោគដោយអនុប្បទាន វត្ថុត្រូវផ្ទេរសិទ្ធិទៅអោយម្ចាស់បំណុលតែម្ដងប្រៀបបាននឹងការបញ្ចាំផ្ដាច់ ក្នុងករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ច ដូចនេះរបបគតិយុត្តនៃប្រាតិភោគដោយអនុប្បទាន ខុសពីការបញ្ចាំចលនវត្ថុដែលវាគ្រាន់តែផ្ទេរការកាន់កាប់ប៉ុណ្ណោះ។

ចំណែកឯចំណុចដែលមានលក្ខណៈខុសគ្នាសំខាន់បំផុតរវាងការបញ្ចាំចលនវត្ថុ និងប្រាតិភោគដោយអនុប្បទាននោះ គឺស្ថិតនៅត្រង់ឆន្ទៈរបស់កូនបំណុល។ នៅក្នុងការបញ្ចាំចលនវត្ថុ កូនបំណុលពុំមានឆន្ទៈផ្ទេរនូវកម្មសិទ្ធិលើវត្ថុទៅអោយម្ចាស់សិទ្ធិលើការបញ្ចាំនោះទេ ទោះបីជាខ្លួនគ្មានលទ្ធភាពសងបំណុលក៏ដោយ។ ប៉ុន្តែចំពោះប្រាតិភោគដោយអនុប្បទានវិញ កូនបំណុលមានឆន្ទៈក្នុងការផ្ទេរកម្មសិទ្ធិលើវត្ថុទៅអោយម្ចាស់បំណុល នៅពេលដែលខ្លួនគ្មានលទ្ធភាពសងបំណុលនោះ។ ដូច្នេះ ម្ចាស់សិទ្ធិលើប្រាតិភោគដោយអនុប្បទាន ពុំចាំបាច់ប្ដឹងទាមទារទៅតុលាការនោះទេ

[40] មាត្រា ៨៨៨ នៃក្រមរដ្ឋប្បវេណី ២០០៧

ដោយគ្រាន់តែធ្វើការជូនដំណឹងអំពីការធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុទៅអ្នកបង្កើតតែប៉ុណ្ណោះជាការស្រេច[41]។

### ២.២.២.៦ អានុភាពលើវត្ថុដែលភ្ជាប់នឹងវត្ថុធានាប្រាតិភោគដោយអនុប្បទាន

#### ក. សមាសភាគនៃវត្ថុ

ប្រាតិភោគដោយអនុប្បទានបានផ្តល់អានុភាពរបស់ខ្លួនទៅលើវត្ថុទាំងអស់ដែលភ្ជាប់នឹងកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទានដែលជាផ្នែកមួយនៃកម្មវត្ថុនោះ នៅពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន[42]។ មានន័យថាបើសិនជាម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានទទួលបានសិទ្ធិប្រាតិភោគដោយអនុប្បទានលើរថយន្ត នោះនាំអោយគាត់មានសិទ្ធិទៅលើចំណែកផ្សេងៗនៃរថយន្តនោះ ទាំងទ្វារនៃរថយន្ត ឬបំពង់ស៊ីម៉ាំងក៏ដោយ។ ដោយសារវត្ថុទាំងអស់នេះមិនអាចដកចេញពីរថយន្តបានទេ ប្រសិនបើបំបែកវត្ថុនេះចេញនឹងនាំអោយរថយន្តដំណើការមិនកើត ឬនាំអោយមានការផ្លាស់ប្តូរលក្ខណៈដើមនៃរថយន្តជាមិនខាន។

#### ខ. វត្ថុចំណុះ និងវត្ថុចម្បង

ប្រាតិភោគដោយអនុប្បទានវិញ បានបញ្ញត្តិពីអានុភាពនៃវត្ថុដែលភ្ជាប់នឹងវត្ថុដែលជាកម្មវត្ថុ។ ប្រាតិភោគដោយអនុប្បទានមានអានុភាពទៅលើចលនវត្ថុតាំងភ្ជាប់ ក្នុងរូបភាពជា "វត្ថុដែលភ្ជាប់នឹងវត្ថុដែលជាកម្មវត្ថុ និងជាផ្នែកមួយនៃវត្ថុដែលជាកម្មវត្ថុនោះ នៅពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន"[43]។ ហេតុនេះវាក៏អាចបង្កើតលើវត្ថុចំណុះផងដែរ ដែលភ្ជាប់ទៅនឹងវត្ថុចម្បងដែលបង្កើតតម្លៃលើវត្ថុចម្បងនោះ។ ក្នុងករណីនេះភាគីក៏អាចធ្វើកិច្ចព្រមព្រៀងដកចេញនូវវត្ថុចំណុះពីអានុភាពនៃប្រាតិភោគដោយអនុប្បទានបានដែរ បើសិនជាមានការព្រមព្រៀងថាបង្កើតសិទ្ធិប្រាតិភោគតែទៅលើវត្ថុចម្បងតែប៉ុណ្ណោះ [44]។ ដូចនេះនៅពេលកូនបំណុលមិនសងបំណុលម្ចាស់បំណុលអាចដករុះរើយកវត្ថុចំណុះនោះចេញពីចលនវត្ថុជាវត្ថុចម្បងនោះ។ តាមការពិតទៅវាមានភាពពិបាកបន្តិចក្នុងការកំណត់ថា មួយណាជាវត្ថុចំណុះ មួយណាជាវត្ថុចម្បង ព្រោះបើយើងមើលទៅលើតម្លៃប្រហែលជាអាចសម្គាល់ដឹង តែវាអាស្រ័យតាមការព្រមព្រៀងរបស់ភាគីក្នុងការកំណត់តែប៉ុណ្ណោះ។ ឧទាហរណ៍ដូចជា ត្បូងដែលភ្ជាប់ទៅនឹងចិញ្ចៀនអញ្ចឹង តើមួយណាជាវត្ថុចំណុះ មួយណាជាវត្ថុចម្បង? បើមើលលើស្ថានភាពជាក់ស្តែងចិញ្ចៀនអាចមានតម្លៃតិចជាងត្បូង ត្បូងនោះអាចមានតម្លៃថ្លៃជាង អាស្រ័យទៅតាមស្ថានភាពសេដ្ឋកិច្ច តម្លៃ និងទំហំជាក់ស្តែង។

---

[41] មាត្រា ៨៩៨ នៃក្រមរដ្ឋប្បវេណី ២០០៧

[42] មាត្រា ៨៩១ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[43] មាត្រា ៨៩១ កថាខណ្ឌ ១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[44] មាត្រា ៨៩១ កថាខណ្ឌ ២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

### ២.២.៣ លក្ខណៈរួម និងបញ្ញត្តិអនុវត្តដូចគ្នា

ការបកស្រាយខាងក្រោមនេះ និងបង្ហាញពីលក្ខណៈរួមពីរចំណុច គឺ ប្រាតិភោគដោយអនុប្បទាន និងការបញ្ចាំ ស្ថិតនៅក្នុងប្រភេទនៃសិទ្ធិប្រាតិភោគប្រត្យក្ស និងជាប្រាតិភោគទៅលើចលនវត្ថុដូចគ្នា។ រីឯបញ្ញត្តិដែលត្រូវអនុវត្តដូចគ្នាត្រូវបានកំណត់នៅក្នុងមាត្រា ៨៩៦នៃក្រមរដ្ឋប្បវេណី។

#### ២.២.៣.១ ប្រភេទនៃសិទ្ធិប្រាតិភោគប្រត្រក្ស

ការបញ្ចាំ និង ប្រាតិភោគដោយអនុប្បទាន គឺជាប្រភេទនៃសិទ្ធិប្រាតិភោគប្រត្យក្ស។ រីឯសិទ្ធិប្រាតិភោគប្រត្យក្សនេះ ជាទូទៅមាននូវអានុភាពពីរយ៉ាង។ អានុភាពទី១ គឺអានុភាពនៃការឃាត់ទុក។ អានុភាពនេះជាអានុភាពដែលជម្រុញអោយកូនបំណុលសងកាតព្វកិច្ច ដោយម្ចាស់បំណុលកាន់កាប់កម្មវត្ថុនៃការធានា ដែលដាក់សម្ពាធផ្លូវចិត្តបន្ថែមលើកូនបំណុល។ អានុភាពនេះមានន័យថាប្រសិនបើបុគ្គល ក បានខ្ចីប្រាក់ពីបុគ្គល ខ នាំអោយយើងទាញបាន បុគ្គល ខ អាចកាន់កាប់កម្មវត្ថុនៃការធានានោះ។ ចំណែកឯអានុភាពទី២វិញ គឺអានុភាពនៃការសងដោយមានអាទិភាព។ វាជាអានុភាពដែលនាំអោយម្ចាស់បំណុលអាចលក់កម្មវត្ថុនៃការធានាហើយអាចទទួលយកការសងពីប្រាក់នៃការលក់នោះ នៅក្នុងករណីដែលកូនបំណុលមិនសងកាតព្វកិច្ច។ ប្រសិនបើយើងធ្វើការប្រៀបធៀបសិទ្ធិលើការបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ទៅនឹងសិទ្ធិប្រាតិភោគប្រត្រក្សផ្សេងទៀតដែលត្រូវបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីវិញ ឃើញថា សិទ្ធិលើការបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ជាប្រភេទសិទ្ធិប្រាតិភោគប្រត្យក្សដែលកើតឡើងតាមរយៈកិច្ចសន្យារបស់គូភាគីបូករួមទាំងសិទ្ធដែលកើតឡើងពីកិច្ចសន្យាហ៊ីប៉ូតែកផងដែរ ផ្ទុយពីសិទ្ធិឃាត់ទុក និងឯកសិទ្ធិ ដែលជាប្រភេទសិទ្ធិប្រាតិភោគប្រត្យក្សដែលកើតឡើងដោយស្វ័យប្រវត្តិតាមច្បាប់ទៅវិញ។ រីឯអានុភាពទាំងពីររបស់សិទ្ធិប្រាតិភោគប្រត្យក្ស ដែលកំណត់នៅក្នុងរបបគតិយុត្តរបស់សិទ្ធិនីមួយៗវិញ ក៏មានលក្ខណៈខុសគ្នាមួយចំនួនដែរ តួយ៉ាងមានតែសិទ្ធិលើការបញ្ចាំ និងសិទ្ធិឃាត់ទុកប៉ុណ្ណោះដែលមានអានុភាពឃាត់ទុក រីឯសិទ្ធិប្រាតិភោគដោយអនុប្បទាន ហ៊ីប៉ូតែក និងឯកសិទ្ធិវិញ ពុំមានអានុភាពឃាត់ទុកនោះទេ ប៉ុន្តែចំណុចនេះនឹងអាចប្រែប្រួលដោយហេតុក្រមសារធាតុទទួលស្គាល់នូវការគោរពការព្រមព្រៀងដែលកើតឡើងពីឆន្ទះដោយសុចរិតរបស់បុគ្គល (ស្វ័យភាពឆន្ទះបុគ្គលឯកជន)។ សិទ្ធិប្រាតិភោគប្រត្យក្សទាំងអស់នេះសុទ្ធសឹងតែទទួលបានអានុភាពនៃការសងដោយមានអាទិភាព ដកចេញតែសិទ្ធិឃាត់ទុកប៉ុណ្ណោះដែលពុំមាន។

### ២.២.៣.២ ប្រាតិភោគចលនវត្ថុ

ចលនវត្ថុ ត្រូវបានអោយនិយមន័យដោយ វចនានុក្រមសម្តេច ជួនណាត ថាជាវត្ថុ ឬទ្រព្យរបស់ដែលកម្រើកបាន ដែលលើកដាក់ ឬដឹកនាំពីកន្លែងមួយទៅកាន់កន្លែងមួយផ្សេងទៀតបាន មាន តុ ទូ កៅអីជាដើម។ រីឯនៅក្នុងសន្ទានុក្រមផ្នែករដ្ឋប្បវេណីនៃក្រមរដ្ឋប្បវេណី២០០៧ វិញ ចលនវត្ថុ ជាវត្ថុទាំងឡាយក្រៅពីអចលនវត្ថុ។ ចលនវត្ថុទាំងឡាយដែលអាច រំកិល ឬផ្លាស់ទីបាន មានឡាន ម៉ូតូ ទូរស័ព្ទ គ្រឿងសង្ហារឹម សម្ភារៈការិយាល័យ នាឡិកា ចិញ្ចៀនពេជ្រ របស់សបរប្រើប្រាស់ទំនិញផ្សេងៗជាដើម។ របស់ទាំងអស់នេះសុទ្ធតែជាកម្មវត្ថុនៃការបង្កើតសិទ្ធប្រត្យក្សបានទាំងអស់ ដែលសុទ្ធសឹងតែមានតម្លៃសេដ្ឋកិច្ចចូនល្មមទៅនឹងបង្កើតសិទ្ធិប្រាតិភោគទៅតាមការវាយតម្លៃរបស់ម្ចាស់សិទ្ធិប្រាតិភោគ។

ក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧ បញ្ញត្តិថាកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន មានអានុភាពគតិយុត្តតែចំពោះកម្មវត្ថុដែលជាចលនវត្ថុប៉ុណ្ណោះ (សិក្សានៅចំណុច ១.៦)។ រីឯការបញ្ចាំវិញក៏បង្កើតអានុភាពគតិយុត្តនៅពេលដែលកិច្ចសន្យានោះមានវត្ថុធានាជាចលនវត្ថុផងដែរ (សិក្សានៅចំណុច ១.៥)។ ប៉ុន្តែរបបគតិយុត្តលើការបញ្ចាំពុំបានអនុញ្ញាតចំពោះចលនវត្ថុមួយចំនួន ដូចជាលិខិតសម្គាល់ម្ចាស់កម្មសិទ្ធិលើចលនវត្ថុទាំងនោះឡើយ ដោយហេតុថា ក្រមរដ្ឋប្បវេណីបច្ចុប្បន្នបញ្ញត្តិពីអានុភាពនៃកិច្ចសន្យាបញ្ចាំ លុះត្រាតែម្ចាស់បំណុលទទួលបានការផ្ទេរការកាន់កាប់ជាក់ស្តែងពីកូនបំណុលជាមុននូវចលនវត្ថុដែលជាកម្មវត្ថុនោះតែម្តង មានន័យថា ម្ចាស់បំណុលត្រូវកាន់កាប់ទ្រព្យធានា មិនមែនកាន់កាប់តែឯកសារបញ្ជាក់កម្មសិទ្ធិនោះទេ មូលហេតុគឺដើម្បីបង្ការការខាតបង់ផលប្រយោជន៍របស់ម្ចាស់បំណុល ប្រសិនបើកូនបំណុលចាត់ចែងវត្ថុធានានោះបាត់ទៅ។ ប្រសិនបើម្ចាស់បំណុលព្រមទទួលឯកសារកម្មសិទ្ធិចលនវត្ថុ នោះ ម្ចាស់បំណុលនឹងក្លាយជាម្ចាស់បំណុលធម្មតាប៉ុណ្ណោះ ដោយពុំទទួលបានលក្ខខណ្ឌតតាំងដូចម្ចាស់បំណុលអាទិភាពនោះទេ នេះក៏ជាភាពខុសគ្នានៃសិទ្ធិលើបំណុលធម្មតា និងសិទ្ធិប្រាតិភោគប្រត្យក្ស។ ប្រាតិភោគដោយអនុប្បទានក៏ដូចទៅនឹងការបញ្ចាំដែរនៅត្រង់ចំណុចនេះ ដោយផ្អែកទៅលើកិច្ចសន្យាដែលព្រមព្រៀងអោយភាគីខាងណាជាអ្នកកាន់កាប់វត្ថុធានា[45]។

### ២.២.៣.៣ បញ្ញត្តិអនុវត្តដូចគ្នា

#### ក. អានុភាពនៃការឃាត់ទុក

ជាទូទៅនៅក្នុងទំនាក់ទំនងនៃកិច្ចសន្យា ប្រសិនបើភាគីបានបំពេញនូវកាតព្វកិច្ចរបស់ខ្លួនយ៉ាងខ្ជាប់ខ្ជួនហើយនោះ វានឹងមិនកើតមាននូវទំនាស់អ្វីឡើង ប៉ុន្តែក្នុងករណីដែលភាគីម្ខាងរំលោភបំពាន

[4545] មាត្រា ៨៩៦ នៃក្រមរដ្ឋប្បវេណី ២០០៧

កិច្ចសន្យាដោយមិនអនុវត្តកាតព្វកិច្ច ឬករណីយកិច្ចរបស់ខ្លួននោះ វានឹងធ្វើអោយភាគីម្ខាងទៀតខាតបង់ប្រយោជន៍ដែលជាហេតុធ្វើអោយភាគីម្ខាងដែលជាជនរងគ្រោះមានសិទ្ធិក្នុងការចាត់វិធានការណាមួយ ដើម្បីការពារផលប្រយោជន៍របស់ខ្លួនដោយសារការរំលោភបំពាននោះ។ យ៉ាងណាមិញ នៅក្នុងកិច្ចសន្យាបញ្ចាំក៏ដូចគ្នា នៅក្នុងករណីដែលអ្នកបង្កើតសិទ្ធិលើការបញ្ចាំ មិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងការសងបំណុលទៅអោយម្ចាស់សិទ្ធលើការបញ្ចាំទេនោះ ម្ចាស់សិទ្ធលើការបញ្ចាំទទួលបាននូវសិទ្ធនានា រួមបញ្ចូលទាំងសិទ្ធិឃាត់ទុកវត្ថុបញ្ចាំដែរ។ ការបញ្ចាំត្រូវបានធ្វើឡើងដោយមានការព្រមព្រៀង និងការប្រគល់វត្ថុបញ្ចាំរបស់អ្នកបង្កើតសិទ្ធិលើការបញ្ចាំ ឬតតិយជន ទៅអោយម្ចាស់សិទ្ធិលើការបញ្ចាំកាន់កាប់។ ការកាន់កាប់នេះធ្វើអោយម្ចាស់សិទ្ធិលើការបញ្ចាំមានសិទ្ធិឃាត់ទុកវត្ថុបញ្ចាំ ព្រោះថា កូនបំណុលត្រូវបានបង្ខំតាមផ្លូវចិត្តអោយអនុវត្តកាតព្វកិច្ចរបស់ខ្លួនដើម្បីទទួលបាននូវវត្ថុបញ្ចាំនោះមកវិញតាមរយៈអានុភាពនេះ។ ប៉ុន្តែសិទ្ធិឃាត់ទុកនេះ មិនអាចយកទៅតតាំងចំពោះម្ចាស់បំណុលដែលមានអាទិភាពជាងខ្លួនបានឡើយ។

មាត្រា ៨៩៦ ចង្អុលបង្ហាញពីបញ្ញត្តិពិសេសក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានកាន់កាប់វត្ថុដែលជាកម្មវត្ថុ ហេតុនេះនាំអោយអានុភាពនៃការឃាត់ទុករបស់ម្ចាស់សិទ្ធិលើការបញ្ចាំចំពោះវត្ថុធានានោះ គឺត្រូវយកមកអនុវត្តដូចគ្នានឹងកិច្ចសន្យាប្រាតិភោគដោយអនុប្បទានដែរ។

### ខ. ការថែរក្សាវត្ថុ

ជាគោលការណ៍នៅក្នុងកិច្ចសន្យាមួយ កូនបំណុលត្រូវបានចងដោយកាតព្វកិច្ចយ៉ាងច្រើនជាពិសេសសង្កត់ធ្ងន់ទៅលើការអនុវត្តកាតព្វកិច្ចក្នុងការសងបំណុល ដូច្នេះដើម្បីឲ្យមានភាពស្មើគ្នានៅក្នុងកិច្ចសន្យាបញ្ចាំក៏ដូចគ្នា ម្ចាស់សិទ្ធិលើការបញ្ចាំក៏ត្រូវបានចងដោយករណីយកិច្ចសំខាន់មួយផងដែរនោះគឺ ករណីយកិច្ចក្នុងការថែរក្សាកម្មវត្ថុ ។ នៅក្នុងកិច្ចសន្យាបញ្ចាំម្ចាស់សិទ្ធិលើការបញ្ចាំមានករណីយកិច្ចចម្បងរបស់ខ្លួនក្នុងការកាន់កាប់វត្ថុបញ្ចាំដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត[46] ។ ករណីយកិច្ចនេះគឺជាករណីយកិច្ចមួយដែលតម្រូវឲ្យម្ចាស់សិទ្ធិលើការបញ្ចាំថែរក្សាវត្ថុបញ្ចាំឲ្យបានល្អ និងឲ្យបានគង់វង្សទោះបីជាខ្លួនមានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលទៅលើវត្ថុបញ្ចាំក៏ដោយ ក៏ការប្រើប្រាស់នោះត្រូវប្រើប្រាស់ដោយប្រុងប្រយ័ត្ន និងទៅតាមវិធីប្រើប្រាស់នៃវត្ថុបញ្ចាំនោះ។ ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំបានធ្វើផ្ទុយនឹងបញ្ញត្តិខាងលើនេះ នោះកូនបំណុលអាចទាមទាររំលត់សិទ្ធិលើការបញ្ចាំនោះបាន។ តាមន័យនៃមាត្រា ៨២៣នេះ

[46] មាត្រា ៨២៣ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ម្ចាស់សិទ្ធិលើការបញ្ចាំត្រូវតែថែរក្សាកម្មវត្ថុយ៉ាងយកចិត្តទុកដាក់ដើម្បីក្លាយជាអ្នកគ្រប់គ្រងដោយសុចរិត ពោលគឺជាអ្នកគ្រប់គ្រងដោយមិនមានបំណងបំផ្លិចបំផ្លាញកម្មវត្ថុក្នុងគោលបំណងមិនល្អអ្វីមួយនោះទេ ពុំនោះទេអ្នកបង្កើតអាចទាមទារអោយរំលត់កិច្ចសន្យាបានដោយសម្អាងថា ម្ចាស់សិទ្ធិរូបនេះមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងនាមជាអ្នកថែរក្សា និងគ្រប់គ្រងលើវត្ថុរបស់ខ្លួន។

ដូចគ្នានេះដែរនៅក្នុងការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន ដែលបានបកស្រាយខាងលើយើងអាចនឹងយល់ថាការផ្ទេរត្រូវបានធ្វើឡើងក្នុងកិច្ចសន្យាប្រាតិភោគដោយអនុប្បទាននេះ ហេតុនេះហើយការថែរក្សាកម្មវត្ថុប្រៀបបាននឹងការថែរក្សារបស់ផ្ទាល់ខ្លួន ហេតុនេះទោះបីជាមានការខូចខាតក៏វាត្រឹមតែទំហំនៃវត្ថុរបស់ខ្លួនតែប៉ុណ្ណោះ មិនពាក់ព័ន្ធនឹងអ្នកបង្កើតនោះឡើយ តែការយល់បែបនេះមិនអាចយកមកអនុវត្តបានឡើយ ព្រោះថាគោលគំនិតនៃការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទានក្នុងក្រមនេះ គេចង់អោយវាមានលក្ខណៈដូចនឹងសិទ្ធិប្រាតិភោគប្រត្យក្សដទៃទៀតអោយបានកាន់តែច្រើនតាមដែលអាចធ្វើទៅបាន ដូចគ្នានឹងបញ្ញត្តិស្តីពីការទទួលផលដែរ។ គួរបញ្ជាក់ថាតាមការអនុវត្តនៃមាត្រា ៨២៣ អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានអាចទាមទាររំលត់កិច្ចសន្យាបាន បើម្ចាស់សិទ្ធិពុំបានបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការថែរក្សាកម្មវត្ថុ។

មាត្រា ៨៩៦ ចង្អុលបង្ហាញពីបញ្ញត្តិពិសេសក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានកាន់កាប់វត្ថុដែលជាកម្មវត្ថុ ហេតុនេះនាំអោយករណីយកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ចាំក្នុងការរក្សាទុកនូវវត្ថុបញ្ចាំគឺត្រូវយកមកអនុវត្តដូចគ្នានឹងកិច្ចសន្យាប្រាតិភោគដោយអនុប្បទានដែរ។

### គ. សិទ្ធិទាមទារអោយសងសោហ៊ុយរបស់ម្ចាស់សិទ្ធិ

ជាទូទៅនៅពេលដែលម្ចាស់សិទ្ធិលើការបញ្ចាំកាន់កាប់វត្ថុធានាដោយផ្ទាល់ ម្ចាស់សិទ្ធិត្រូវតែធ្វើការ ថែរក្សាវត្ថុធានានោះអោយបានល្អ ដោយមិនអាចធ្វើអោយវត្ថុធានានោះមានការខូចខាត ឬបាត់បង់ដោយប្រការណាមួយបានឡើយ។ ជាពិសេសទៅទៀតម្ចាស់សិទ្ធិត្រូវយកចិត្តទុកដាក់ថែរក្សាវត្ថុនោះ អោយដូចជាវត្ថុរបស់ខ្លួនផ្ទាល់ ដើម្បីទុកប្រគល់ទៅអោយកូនបំណុលវិញក្រោយពីបានសងបំណុលរួចរាល់។ តាមរយៈស្ថានភាពនេះ បើសិនជាម្ចាស់សិទ្ធិលើការបញ្ចាំបានចំណាយជាចាំបាច់ក្នុងការគ្រប់គ្រង និងថែរក្សាវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំ ក៏អាចទាមទារអោយកម្មសិទ្ធិករនៃវត្ថុបញ្ចាំនោះសងនូវចំណាយនោះមកវិញបានដែរ [47] ។ លើសពីនេះទៅទៀតប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំបានចេញចំណាយដើម្បីបង្កើនតម្លៃនៃវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំអាចទាមទារអោយកម្មសិទ្ធិករនៃវត្ថុបញ្ចាំនោះ សងនូវចំណាយទាំងអស់នោះដែលបាន

[47] មាត្រា ៨២៤ កថាខណ្ឌ ១ នៃក្រមរដ្ឋប្បវេណី ២០០៧

ចំណាយ ឬសងនូវតម្លៃប្រាក់ដែលកើននោះមកវិញ តាមជម្រើសរបស់ខ្លួនបានក្នុងករណីដែលកំណើនតម្លៃនោះនៅតែមាន[48]។ មាត្រា ៨៩៦ បានចង្អុលបង្ហាញពីបញ្ញត្តិពិសេសក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានកាន់កាប់វត្ថុដែលជាកម្មវត្ថុ ហេតុនេះនាំអោយម្ចាស់សិទ្ធិលើការបញ្ជាំដែលមានសិទ្ធិទាមទារអោយកូនបំណុលសងសោហ៊ុយចំណាយចាំបាច់នោះ គឺត្រូវយកមកអនុវត្តដូចគ្នានៅក្នុងកិច្ចសន្យាប្រាតិភោគដោយអនុប្បទានដែរ។

[48] មាត្រា ៨២៤ កថាខណ្ឌ ២ នៃក្រមរដ្ឋប្បវេណី ២០០៧

# ជំពូក ៣

# នីតិវិធីអនុវត្តសិទ្ធិលើការបញ្ចាំ ចលនវត្ថុ និងប្រាតិភោគដោយ អនុប្បទាន

# ជំពូកទី៣ នីតិវិធីអនុវត្តសិទ្ធិលើការបញ្ចាំចលនវត្ថុ និងប្រាតិភោគដោយអនុប្បទាន

ជាទូទៅនៅពេលដែលគូភាគីនៃកិច្ចសន្យាប្រាតិភោគ បានព្រមព្រៀងគ្នាយ៉ាងពិតប្រាកដ ក្នុងការបង្កើតកិច្ចសន្យា និងបានប្រគល់វត្ថុជាក់លាក់ណាមួយដើម្បីអោយម្ចាស់បំណុលកាន់កាប់ ឬប្តូរលក្ខណៈនៃការកាន់កាប់ នោះវានឹងធ្វើអោយមានអានុភាពចាប់បង្ខំអោយគូភាគីអនុវត្តទៅតាមកិច្ចសន្យា។ ដូចនេះនៅពេលដែលកូនបំណុលមិនអនុវត្តកាតពកិច្ចរបស់ខ្លួន វានឹងធ្វើអោយម្ចាស់សិទ្ធិប្រាតិភោគមាននូវសិទ្ធិក្នុងការអនុវត្តសិទ្ធិប្រាតិភោគមួយនោះ។ ការអនុវត្តសិទ្ធិរបស់ម្ចាស់សិទ្ធិនេះជាការទាមទារសិទ្ធិ ខណៈពេលដែលកាតព្វកិច្ចរបស់អ្នកបង្កើតសិទ្ធិ ឬកូនបំណុល មិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួន។ ក្នុងករណីនេះ ម្ចាស់សិទ្ធិលើកិច្ចសន្យាប្រាតិភោគ ត្រូវអនុវត្តសិទ្ធិរបស់ខ្លួនស្របទៅតាមប្រភេទនៃកិច្ចសន្យាប្រាតិភោគនោះ។ កិច្ចសន្យាបញ្ចាំ នឹងតម្រូវអោយម្ចាស់សិទ្ធិលើការបញ្ចាំដាក់ពាក្យស្នើសុំអនុវត្តសិទ្ធិលើការបញ្ចាំទៅតុលាការ ចំណែកឯប្រាតិភោគដោយអនុប្បទានវិញ ពុំចាំចាច់ឆ្លងកាត់នីតិវិធីតុលាការនោះទេ ពីព្រោះបញ្ញត្តិនៃកិច្ចសន្យាប្រាតិភោគដោយអនុប្បទានពុំបានហាមឃាត់ដូចទៅនឹងការបញ្ចាំផ្ដាច់ឡើយ។ ដើម្បីអោយកាន់តែច្បាស់យើងនឹងសិក្សាទៅតាមលំដាប់ដូចខាងក្រោម។

## ៣.១ ការអនុវត្តសិទ្ធិរបស់ម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុ

នៅក្នុងការអនុវត្តសិទ្ធិលើការបញ្ចាំចលនវត្ថុ គឺផ្ដោតសំខាន់លើការកាន់កាប់ចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ដែលយើងបានបកស្រាយរួចមកហើយថា កិច្ចសន្យាបញ្ចាំមានអានុភាពទៅបានលុះត្រាតែអ្នកបង្កើតសិទ្ធិលើការបញ្ចាំប្រគល់វត្ថុបញ្ចាំ ទៅអោយម្ចាស់សិទ្ធិលើការបញ្ចាំកាន់កាប់។ ដូច្នេះប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំ មិនកាន់កាប់វត្ថុបញ្ចាំដោយផ្ទាល់ទេនោះ វានឹងក្លាយជាប្រាតិភោគដោយអនុប្បទាន។

### ៣.១.១ បណ្ដឹងទាមទារអោយប្រគល់វត្ថុ

នៅក្នុងករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុ កាន់កាប់វត្ថុបញ្ចាំ ហើយការកាន់កាប់នោះត្រូវបានដកយក ម្ចាស់សិទ្ធិលើការបញ្ចាំអាចយកវត្ថុបញ្ចាំនោះមកវិញបាន តាមរយៈបណ្ដឹងទាមទារអោយប្រគល់វត្ថុកាន់កាប់មកវិញទៅតុលាការ [49] ។ ប៉ុន្តែប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំមិនអាចធ្វើបណ្ដឹងទាមទារអោយប្រគល់វត្ថុកាន់កាប់មកវិញទេ នោះម្ចាស់សិទ្ធិលើការបញ្ចាំមិនអាចទាមទារអោយមានសិទ្ធិលើការបញ្ចាំបានវិញឡើយ។

[49] មាត្រា ៨៣០ នៃក្រមរដ្ឋប្បវេណី ២០០៧

### ៣.១.២ ការអនុវត្តជាក់ស្តែងចំពោះការបញ្ចាំចលនវត្ថុ នៅមុនពេល និង ក្រោយពេលក្រមរដ្ឋប្បវេណីចូលជាធរមាន

នៅមុនពេលក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ចូលជាធរមាន ការអនុវត្តសិទ្ធិលើការបញ្ចាំចលនវត្ថុ ជាពិសេសនៅកន្លែងប្រកបអាជីវកម្មទទួលបញ្ចាំវត្ថុ ឬហៅថា "កុងស៊ីបញ្ចាំ" រាល់ការបញ្ចាំចលនវត្ថុត្រូវបានធ្វើជាកិច្ចសន្យាលាយលក្ខណ៍អក្សរ ហើយបានកំណត់គ្នាជាមុននៅក្នុងកិច្ចសន្យានោះថា ប្រសិនបើកូនបំណុលមិនយកប្រាក់មកលោះយកវត្ថុបញ្ចាំទៅតាមកាលបរិច្ឆេទកំណត់ទេ វត្ថុបញ្ចាំនឹងក្លាយជាកម្មសិទ្ធិរបស់ថៅកែកុងស៊ីបញ្ចាំនោះតែម្តង។ ប៉ុន្តែក្រោយពីការប្រកាសអោយអនុវត្តក្រមរដ្ឋប្បវេណីថ្មី កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១មក ការអនុវត្តសិទ្ធិលើការបញ្ចាំក៏ត្រូវបានផ្លាស់ប្តូរបន្តិចបន្តួច ដោយពេលបង្កើតកិច្ចសន្យាបញ្ចាំ អាជីវករទាំងនោះធ្វើកិច្ចសន្យាបញ្ចាំជាលាយលក្ខណ៍អក្សរចំនួនពីរច្បាប់ផ្សេងគ្នា គឺមួយជាកិច្ចសន្យាបញ្ចាំវត្ថុដោយកំណត់កាលបរិច្ឆេទលោះយកវត្ថុ និងមួយទៀតជាកិច្ចសន្យាលក់ផ្តាច់ ដោយតម្រូវអោយកូនបំណុលផ្តិតមេដៃទៅលើកិច្ចសន្យាទាំងពីរនោះ។ ក្នុងករណីដែលកូនបំណុលមិនយកលុយមកលោះទៅតាមពេលកំណត់ម្ចាស់សិទ្ធិលើការបញ្ចាំនឹងយកកិច្ចសន្យាលក់ផ្តាច់មកអនុវត្តតែម្តងជាការស្រេច។ យើងឃើញថាទោះបីជាវាជាកិច្ចសន្យាលក់ផ្តាច់ក៏ដោយ ក៏ការអនុវត្តបែបនេះវាមិនខុសគ្នាទៅនឹងការបញ្ចាំផ្តាច់នោះទេ ដែលការអនុវត្តបែបនេះវាជាការអនុវត្តផ្ទុយទៅនឹងច្បាប់ ជាពិសេសវាខុសឆ្គងទៅនឹងនីតិវិធីនៃការវាយតម្លៃវត្ថុបញ្ចាំពីអ្នកជំនាញ ដើម្បីអោយមាបតម្លាភាពនៅក្នុងការទិញលក់វត្ថុបញ្ចាំ។

ការអនុវត្តសិទ្ធិលើការបញ្ចាំចំពោះចលនវត្ថុ ការទាមទារយកវត្ថុបញ្ចាំមកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ចាំបាច់ត្រូវឆ្លងកាត់នីតិវិធីនៃការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប ជំនួសអោយការអនុវត្តនីតិវិធីនៃការលក់ដោយបង្ខំ។ ម្យ៉ាងទៀតវាក៏ជានីតិវិធីមួយនៃរឿងក្តីដែលពុំមែនជាបណ្តឹង ជាពិសេសនីតិវិធីនៃការអនុវត្តលើការបញ្ចាំដោយសង្ខេប វាជានីតិវិធីផ្សេងពីនីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគទូទៅ។ យើងក៏បានធ្វើការបកស្រាយរួចមកហើយនៅក្នុងចំណុច ១.២.៤ ការបញ្ចាំផ្តាច់និងប្រាតិភោគដោយអនុប្បទាន ដែលហាមឃាត់ចំពោះកិច្ចសន្យាបញ្ចាំផ្តាច់ ដែលត្រូវមានហេតុផលត្រឹមត្រូវ ចំពោះការទាមទារយកវត្ថុបញ្ចាំជាចលនវត្ថុមកសងខ្លួនដោយផ្ទាល់។

### ៣.១.៣ នីតិវិធីអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប

នីតិវិធីនៃការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប ម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុ អាចដាក់ពាក្យសុំអោយចេញដីការសម្រេចអនុញ្ញាតអោយយកវត្ថុបញ្ចាំនោះមកសងផ្ទាល់តែម្តង ទៅសាលាដំបូង ដែលមានសមត្ថកិច្ចលើទីកន្លែងដែលត្រូវអនុវត្តកាតព្វកិច្ច[50]។ នៅក្នុងពាក្យសុំនោះ

[50]មាត្រា ៥០៤ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

អ្នកដាក់ពាក្យត្រូវបំពេញចំណុចសំខាន់ៗមួយចំនួន ដូចជាសញ្ញាណនៃម្ចាស់បំណុលនៃការអនុវត្ត កម្មសិទ្ធិករនៃចលនវត្ថុដែលជាកូនបំណុលនៃការអនុវត្ត កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា សញ្ញាណនៃចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តសិទ្ធិប្រាតិភោគ និងទីកន្លែងចលនវត្ថុនោះ ហេតុការណ៍ និងទំហំនៃផ្នែកនៃសិទ្ធិលើបំណុលដែលត្រូវបានធានា[51]។ ជាគោលការណ៍ នៅក្នុងរឿងរដ្ឋប្បវេណី តុលាការគោរពឆន្ទៈរបស់បុគ្គលឯកជន ដូចនេះប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំបានដាក់ពាក្យសុំ ដោយភ្ជាប់ជាមួយនឹងការកំណត់តម្លៃវត្ថុបញ្ចាំតាមការវាយតម្លៃដោយខ្លួនឯង និងកម្មសិទ្ធិករនៃវត្ថុបញ្ចាំបានយល់ព្រមទៅនឹងតម្លៃនោះ តុលាការពុំចាំបាច់ជ្រើសតាំងអ្នកវាយតម្លៃនោះទេ។ ផ្ទុយទៅវិញ ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំមិនបានកំណត់តម្លៃវត្ថុបញ្ចាំនៅក្នុងពាក្យសុំរបស់ខ្លួន ឬក៏កម្មសិទ្ធិករនៃវត្ថុបញ្ចាំ បដិសេធចំពោះតម្លៃដែលម្ចាស់សិទ្ធិលើការបញ្ចាំធ្វើការវាយតម្លៃ តុលាការចាំបាច់ត្រូវធ្វើការជ្រើសតាំងអ្នកវាយតម្លៃអោយវាយតម្លៃវត្ថុបញ្ចាំនោះ [52] ។ ក្រោយពីធ្វើការវាយតម្លៃវត្ថុបញ្ចាំរួច បើតុលាការយល់ឃើញថា ពាក្យសុំរបស់ម្ចាស់សិទ្ធិលើការបញ្ចាំមានលក្ខណៈសមស្របទៅតាមច្បាប់ និងមានមូលហេតុត្រឹមត្រូវ តុលាការត្រូវចេញដីកាសម្រេច និងប្រកាសអនុញ្ញាតអោយយកវត្ថុបញ្ចាំមកសងម្ចាស់សិទ្ធិលើការបញ្ចាំដោយផ្ទាល់ ក្នុងចំនួនទឹកប្រាក់ដែលអ្នកវាយតម្លៃបានវាយតម្លៃ ហើយរាល់សោហ៊ុយចំណាយនៅក្នុងនីតិវិធីនេះ និងសោហ៊ុយចំណាយសម្រាប់នីតិវិធី តុលាការត្រូវបង្គាប់អោយសងចំនួនប្រាក់ដែលលើសនោះទៅអោយកម្មសិទ្ធិករនៃវត្ថុវិញ [53] ។ ចំពោះដីការសម្រេចអនុញ្ញាតអោយយកវត្ថុបញ្ចាំមកសងផ្ទាល់តែម្តង ទៅតាមពាក្យសុំរបស់ម្ចាស់សិទ្ធិលើការបញ្ចាំខាងលើ អ្នកដែលពាក់ព័ន្ធទៅនឹងផលប្រយោជន៍ចំពោះវត្ថុបញ្ចាំមានសិទ្ធិប្តឹងជំទាស់បាន ហើយដីកាសម្រេចនេះនឹងមិនមានអានុភាពឡើយ ប្រសិនបើមិនទាន់ចូលជាស្ថាពរ[54]។

### ៣.១.៤ លំដាប់នៃសិទ្ធិលើការបញ្ចាំចលនវត្ថុ

នៅក្នុងករណីដែលកូនបំណុលបានបង្កើតសិទ្ធិលើការបញ្ចាំលើចលនវត្ថុតែមួយ ដើម្បីធានាសិទ្ធិលើបំណុលច្រើន លំដាប់នៃសិទ្ធិលើការបញ្ចាំទាំងនោះត្រូវអនុឡោមទៅតាមពេលវេលាដែលបានបង្កើតសិទ្ធិលើការបញ្ចាំនោះ[55]។ ចំពោះពាក្យថា "សិទ្ធិលើបំណុលច្រើន" សំដៅទៅលើការដែលកូនបំណុលយកចលនវត្ថុតែមួយ ទៅដាក់ធានាជាមួយម្ចាស់បំណុលច្រើនជាងម្នាក់ នេះ

[51] មាត្រា ៥០២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[52] មាត្រា ៥០៤ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[53] មាត្រា ៥០៤ កថាខណ្ឌទី ៤ និងកថាខណ្ឌទី ៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[54] មាត្រា ៥០៤ កថាខណ្ឌទី ៦ និងកថាខណ្ឌទី ៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[55] មាត្រា ៨៣៣ នៃក្រមរដ្ឋប្បវេណី ២០០៧

ដោយសារតែការកាន់កាប់វត្ថុដោយប្រយោល ឬការកាន់កាប់តាមរយៈអ្នកតំណាង ក៏អាចក្លាយជាលក្ខខណ្ឌសម្រាប់ម្ចាស់សិទ្ធិលើការបញ្ចាំ ដើម្បីបន្តកាន់កាប់ផងដែរ។ ជាគោលការណ៍នៅក្នុងការបញ្ចាំ អ្នកបង្កើតសិទ្ធិលើការបញ្ចាំ ចាំបាច់ត្រូវផ្ទេរការកាន់កាប់វត្ថុបញ្ចាំទៅអោយម្ចាស់សិទ្ធិលើការបញ្ចាំ ហើយច្បាប់ក៏ហាមឃាត់អ្នកបង្កើតសិទ្ធិលើការបញ្ចាំ មិនអោយកាន់កាប់វត្ថុបញ្ចាំដោយផ្ទាល់នោះទេ។ ប៉ុន្តែមិនបានហាមឃាត់ម្ចាស់បំណុលផ្សេងទៀតកាន់កាប់វត្ថុបញ្ចាំនោះដែរ ដូច្នេះវាច្បាស់ណាស់ថា ចលនវត្ថុតែមួយក៏អាចក្លាយជាកម្មវត្ថុនៃការបញ្ចាំ ដើម្បីធានាសិទ្ធិលើបំណុលច្រើនបានផងដែរ។ ចំណែកពាក្យថាការកាន់កាប់ដោយប្រយោល នៅក្នុងជំពូកទី ៣ មាត្រា ២២៧ និងមាត្រា ២២៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ក៏បានអោយនិយមន័យថាគឺជាការកាន់កាប់តាមរយៈអ្នកដទៃ។

*ឧទាហរណ៍ ៖ លោក ក គឺជាកម្មសិទ្ធិករនៃរថយន្ត Luxus 570 មួយគ្រឿង។ លោក ក បានយកឡានរបស់គាត់ទៅទៅដាក់បញ្ចាំអោយលោក ខ ព្រមព្រៀងគ្នាចំនួន ៥ម៉ឺនដុល្លារអាមេរិច ហើយក៏ប្រគល់រថយន្តនោះទៅអោយលោក ខ កាន់កាប់។ ក្រោយមកទៀត លោក ក ខ្វះខាតប្រាក់បន្ថែមទៀត ប៉ុន្តែលោក ខ ពុំមានប្រាក់គ្រប់គ្រាន់ដើម្បីអោយទៅលោក ក ខ្ចីនោះទេ។ ដូចនេះលោក ក ក៏សម្រេចចិត្តទៅខ្ចីប្រាក់ពីលោក គ ចំនួន ៥ម៉ឺនដុល្លារទៀត ដោយដាក់បញ្ចាំរថយន្ត Luxus 570 ដដែល ប៉ុន្តែរថយន្តនោះកំពុងត្រូវបានកាន់កាប់ដោយលោក ខ ជាម្ចាស់បំណុលមុន។ ប៉ុន្តែដោយហេតុលោក គ យល់ឃើញថារថយន្តនោះមានតម្លៃខ្ពស់លើសពីបំណុលដែលត្រូវបានធានា ហើយលោក ខ ជាមិត្តជិតដិតនឹងខ្លួនទៀត ចំណែក ខ ក៏មានការយល់ព្រមអំពីកិច្ចសន្យាបញ្ចាំលើកក្រោយនេះដែរ។ លោក គ ក៏យល់ព្រមអោយ លោក ក ខ្ចីប្រាក់ចំនួន ២០០០ដុល្លារ តាមរយៈការដាក់បញ្ចាំរថយន្តខាងលើ ដោយអោយ លោក ខ ជាអ្នកកាន់កាប់រថយន្តនោះដោយផ្ទាល់។*

### ៣.២ ការអនុវត្តសិទ្ធិរបស់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន

ប្រាតិភោគដោយអនុប្បទានពុំតម្រូវអោយឆ្លងកាត់នីតិវិធីតុលាការដូចការបញ្ចាំនោះទេ។ នៅពេលដែលដល់ការកំណត់នៃកិច្ចសន្យា នៅពេលដែលកូនបំណុលពុំមានលទ្ធភាព ឬពុំបានអនុវត្តទៅតាមកាតព្វកិច្ចដែលចែងនៅក្នុងកិច្ចសន្យា ឬពុំយកប្រាក់មកលោះទ្រព្យធានាវិញនោះទេ ជាការពិតណាស់នឹងនាំអោយម្ចាស់សិទ្ធិធ្វើការអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការទូទាត់កាត់កងទ្រព្យធានានោះជាមួយនឹងបំណុលព្រមទាំងសោហ៊ុយផ្សេងៗ។ របបគតិយុត្តនៃការបញ្ចាំត្រូវបានហាមឃាត់ដាច់ខាតចំពោះការបញ្ចាំផ្តាច់ ដោយក្រមរដ្ឋប្បវេណីថ្មី ២០០៧ សំណួរសួរថាចំណែកឯការបញ្ចាំវិញ តើការអនុវត្តសិទ្ធិយ៉ាងណាទៅវិញ?

ខុសអំពីការបញ្ចាំចលនវត្ថុ ក្នុងការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន មិនមែនជាភាពចាំបាច់ឡើយដែលទាល់តែជាម្ចាស់សិទ្ធិជាអ្នកកាន់កាប់វត្ថុធានាទើបបង្កើតអានុភាពតតាំង និងនាំ

អោយកិច្ចសន្យាមានសុពលភាព ប៉ុន្តែប្រាតិភោគដោយអនុប្បទានមិនបានកំណត់ថាត្រូវតែអោយវត្ថុធានាទៅម្ចាស់សិទ្ធិជាអ្នកកាន់កាប់នោះទេ ដោយគ្រាន់តែបានទទួលការផ្ទេរការកាន់កាប់ពីអ្នកបង្កើតសិទ្ធិ ឬហៅថាកូនបំណុលនោះ ជាការស្រេច[56]។ ជារួមមានន័យថា ក្នុងរបបប្រាតិភោគដោយអនុប្បទាន អាចមានករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ជាអ្នកកាន់កាប់ចលនវត្ថុជាទ្រព្យធានា ឬអាចជាអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានធ្វើការកាន់កាប់ទ្រព្យធានា ហេតុនេះជាចាំបាច់យើងត្រូវបែងចែកការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្តទានជាពីរករណីដូចខាងក្រោមះ

### ៣.២.១ ករណីវត្ថុនៅក្នុងដៃម្ចាស់សិទ្ធិ

បើកាតព្វកិច្ចពុំត្រូវបានអនុវត្ត ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចប្តូរវត្ថុដែលជាកម្មវត្ថុនោះជាប្រាក់ ដោយផ្ទាល់ខ្លួន ឬធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុជាស្ថាពរបាន ដោយជូនដំណឹងទៅអ្នកបង្កើត[57]។ ករណីនេះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន តម្រូវអោយជូនដំណឹងទៅអ្នកបង្កើតសិទ្ធិអំពីការប្តូរជាប្រាក់ ឬការធ្វើលទ្ធកម្មកម្មសិទ្ធិនោះ។ ក្នុងន័យនេះ កថាខណ្ឌ ១ នៃមាត្រា ៨៩៨ មានចែងអំពីកាតព្វកិច្ចដែលពុំត្រូវបានអនុវត្ត សំដៅដល់ភាគីអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ពុំបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនដែលមានចែងនៅក្នុងកិច្ចសន្យាប្រាតិភោគដោយអនុប្បទានជាមួយនឹងម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន។ ចំណែកការប្តូរវត្ថុជាកម្មវត្ថុនោះជាប្រាក់ដោយផ្ទាល់ខ្លួន ឬធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុជាស្ថាពរ មានន័យថាជាការយកវត្ថុដែលជាកម្មវត្ថុនោះទៅលក់ ឬវិធីអ្វីផ្សេងដើម្បីបានជាប្រាក់មកវិញ ឬការឡើងជាម្ចាស់សិទ្ធិលើវត្ថុនោះតែម្តង។ ហេតុនេះកថាខណ្ឌនេះមានន័យថាប្រសិនបើដល់ពេលកំណត់នៃការអនុវត្តកាតព្វកិច្ចហើយ អ្នកបង្កើតសិទ្ធិនៅមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួន ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន មានសិទ្ធិលក់ ឬគាត់អាចឡើងធ្វើជាម្ចាស់កម្មសិទ្ធិលើវត្ថុនោះតែម្តង ដោយគ្រាន់តែអោយដំណឹងទៅអ្នកបង្កើតសិទ្ធិនោះ។

ឧទាហរណ៍ បុគ្គល ក បានទៅខ្ចីប្រាក់ពីបុគ្គល ខ ចំនួន ២ លានរៀល ដោយដាក់ទោចក្រយានយន្តមួយគ្រឿងធ្វើជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន។ លុះដល់កាលកំណត់នៃការប្រគល់ប្រាក់ បុគ្គល ក នៅតែពុំមានប្រាក់ប្រគល់អោយបុគ្គល ខ ដើម្បីកាត់បំណុល។ ពេលនោះបុគ្គល ខ អាចយកទោចក្រយាន្តយន្តនោះទៅលក់យកលុយមកកាត់បំណុលបាន ដោយហេតុថាគាត់ជាម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានដោយគ្រាន់តែជូនដំណឹង [58] អំពីការចាត់ចែងសិទ្ធិនោះប៉ុណ្ណោះ។

---

[56] មាត្រា ៨៩០ និងមាត្រា ២២៩ នៃក្រមរដ្ឋប្បវេណី ២០០៧

[57] មាត្រា ៨៩៨ កថាខណ្ឌ ១ នៃក្រមរដ្ឋប្បវេណី ២០០៧

[58] ការជូនដំណឹងមានអានុភាពនៅពេលដែលដំណឹងនោះបានទៅដល់ភាគីម្ខាងទៀត (មាត្រា ៣១០ និយមន័យនៃការបង្ហាញឆន្ទៈ)។

### ៣.២.២ ករណីវត្ថុនៅក្នុងដៃអ្នកបង្កើត

ប្រសិនបើអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ឬតតិយជនដែលបានទទួលការបញ្ជាពីអ្នកបង្កើតនេះ កាន់កាប់វត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានអាចទាមទារអោយជននោះប្រគល់នូវវត្ថុដែលជាកម្មវត្ថុនោះបាន[59]។ កថាខណ្ឌ ២ នៃមាត្រា៨៩៨ បានភ្ជាប់មកនូវករណីដូចនៅក្នុងកថាខណ្ឌទី ១ ដែរ គឺកាតព្វកិច្ចពុំត្រូវបានអនុវត្ត។ អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ឬតតិយជនដែលបានទទួលការបញ្ជាពីអ្នកបង្កើតនេះ កាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ គឺសំដៅដល់វត្ថុនោះអាចស្ថិតនៅលើដៃរបស់អ្នកបង្កើតសិទ្ធិ ឬនៅលើដៃជនទីបីដែលអ្នកបង្កើតសិទ្ធិនេះបញ្ជាអោយកាន់កាប់។ ជាទូទៅយើងពិនិត្យឃើញថាកាលណាមានការធ្វើប្រាតិភោគដោយអនុប្បទាន វត្ថុនោះត្រូវស្ថិតក្រោមការកាន់កាប់របស់ ម្ចាស់សិទ្ធិប្រាតិភោគ ប៉ុន្តែករណីនេះគឺគេធ្វើ ការផ្លាស់ប្តូរលក្ខណៈនៃការកាន់កាប់ នេះ ដោយអាចអោយអ្នកបង្កើតសិទ្ធិ ជាអ្នកកាន់កាប់វត្ថុដែលជាកម្មវត្ថុនោះបានតាមរយៈកិច្ចសន្យាបង្កើតដែលភាគីបានចែងផ្សេងពីនេះ។ បើមានករណីដូចនេះម្ចាស់សិទ្ធិអាចទាមទារ ឬបញ្ជាអោយអ្នកដែលកំពុងកាន់កាប់វត្ថុនោះដោយផ្ទាល់ប្រគល់វត្ថុនោះមកវិញបាន។

ឧទាហរណ៍ដដែល បុគ្គល ក និងបុគ្គល ខ ព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាប្រាតិភោគដោយអនុប្បទានមួយដោយដាក់ទោចក្រយានយន្ត ដែលជាកម្មវត្ថុនោះស្ថិតនៅលើដៃអ្នកបង្កើតសិទ្ធិ គឺបុគ្គល ក។ នៅពេលដល់កាលកំណត់នៃការសង បុគ្គល ក នៅតែពុំមានលទ្ធភាពសងនោះ តាមរយៈកថាខណ្ឌ ២ នៃមាត្រានេះ អនុញ្ញាតអោយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានអាចអនុវត្តសិទ្ធិប្រាតិភោគរបស់ខ្លួនបាន ដោយទាមទារអោយអ្នកបង្កើតប្រគល់ការកាន់កាប់ទោចក្រយានយន្តនោះបាន។ ករណីមួយទៀត បុគ្គល ក ពុំបានកាន់កាប់ទោចក្រយានយន្តនោះដោយផ្ទាល់ទេ តែខ្លួនបែរជាប្រគល់វាអោយប្អូនរបស់ខ្លួនប្រើប្រាស់ជិះទៅរៀនជារៀងរាល់ថ្ងៃ ហេតុនេះពេលដល់ការកណត់សងបំណុល ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានលើទោចក្រយានយន្តនោះ នៅតែមានសិទ្ធិបញ្ជាអោយបុគ្គល ក ប្រគល់ទោចក្រយានយន្ត។

ករណីនេះបើយើងធៀបជាមួយការបញ្ចាំវិញ ប្រាតិភោគដោយអនុប្បទាន គឺរឹតតែមានលក្ខណៈធូរលុងជាងព្រោះករណីនេះ ប្រាតិភោគដោយអនុប្បទានអនុញ្ញាតអោយវត្ថុដែលជាកម្មវត្ថុនោះស្ថិតនៅក្នុងដៃ តតិយជន ប៉ុន្តែការបញ្ចាំវិញវត្ថុដែលជាកម្មវត្ថុនោះត្រូវតែស្ថិតនៅក្នុងដៃម្ចាស់សិទ្ធិនៃការបញ្ចាំ។

---

[59] មាត្រា ៨៩៨ កថាខណ្ឌ ២ នៃក្រមរដ្ឋប្បវេណី ២០០៧

### ៣.២.៣ ករណីយកិច្ចសងប្រាក់ជម្រះ និងសិទ្ធិទទួលយកមកវិញរបស់អ្នកបង្កើត

កថាខណ្ឌទី ៣ នៃមាត្រា៨៩៨ ក្រមរដ្ឋប្បវេណី ២០០៧ ចែងថាម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន មានករណីយកិច្ចសងប្រាក់ជម្រះ ដើម្បីកុំអោយម្ចាស់សិទ្ធិនោះទទួលចំណេញហួសហេតុ ដោយធ្វើលទ្ធកម្មនូវវត្ថុ ដែលជាកម្មវត្ថុដែលមានតម្លៃថ្លៃជាងតម្លៃនៃសិទ្ធិលើបំណុលដែលត្រូវបានធានា។ ក្នុងករណីដែលប្រាក់ទទួលបានពីការប្តូរវត្ថុដែលជាកម្មវត្ថុមានចំនួនលើសពីប្រាក់ដែលអ្នកបង្កើត ត្រូវសងទៅអោយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន នោះម្ចាស់សិទ្ធិនោះត្រូវប្រគល់ប្រាក់ដែលនៅសល់មកអោយអ្នកបង្កើតវិញដែលគេហៅវាថាជាប្រាក់ជម្រះ (ប្រាក់ដែលទូទាត់សងសល់ពីប្រាក់បំណុល និងការប្រាក់ដែលអ្នកបង្កើតត្រូវបង់)។

ឧទាហរណ៍ខាងលើ ករណីដែលប្រាក់ទទួលបានពីការលក់ទោចក្រយានយន្ត មានចំនួនលើសពី ២លានរៀល ហេតុនេះប្រាក់ជម្រះត្រូវតែមាន។ ដូចនេះបុគ្គល ខ មានករណីយកិច្ចបង់ចំនួនទឹកប្រាក់ដែលលើសនោះមកអោយបុគ្គល ក វិញ ដោយចាត់ទុកប្រាក់នោះជាប្រាក់ជម្រះបន្ទាប់ពីការកាត់កងបំណុល និងការប្រាក់រួចហើយ។

ករណីនេះបើយើងធៀបទៅនឹងការបញ្ចាំវាមានលក្ខណៈខុសគ្នា ការបញ្ចាំ គឺមិនត្រូវបានអនុវត្តចំពោះកិច្ចសន្យានៃការបញ្ចាំផ្តាច់ឡើយ [60] គឺត្រូវអនុវត្តទៅតាមនីតិវិធីតុលាការដោយការវាយតម្លៃរបស់អ្នកជំនាញទៅលើវត្ថុដែលជាកម្មវត្ថុនោះ បន្ទាប់មកទើបលក់វត្ថុនោះ និងទូទាត់ប្រាក់ ប៉ុន្តែចំពោះប្រាតិភោគដោយអនុប្បទានវិញ គឺអាចអនុវត្តបានប្រៀបទៅនឹងការបញ្ចាំផ្តាច់។ យើងត្រូវដឹងថាការធ្វើប្រាតិភោគដោយអនុប្បទាន គឺមិនទាមទារអោយមាននីតិវិធីវែងឆ្ងាយឈានដល់នីតិវិធីដូចការបញ្ចាំឡើយ ដោយគ្រាន់តែប្តូរវត្ថុនោះជាប្រាក់ ឬម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានអាចឡើងធ្វើជាម្ចាស់សិទ្ធិតែប៉ុណ្ណោះ ករណីមានប្រាក់ជម្រះម្ចាស់សិទ្ធិប្រគល់វាទៅអោយអ្នកបង្កើតដើម្បីទូទាត់ជាការស្រេច។ បច្ចុប្បន្នការធ្វើប្រាតិភោគដោយអនុប្បទាន គឺត្រូវបានអនុវត្ត និងធ្វើចរាចរណ៍ក្នុងទីផ្សារប្រទេសកម្ពុជាយើងក្នុងរូបភាពជាការបញ្ចាំ តែបើយើងមើលទៅលើនីតិវិធីនៃការអនុវត្តវិញគឺសុទ្ធសឹងតែជាធាតុនៃប្រាតិភោគដោយអនុប្បទាន។

តែទោះបីជាពេលកំណត់ត្រូវសងកាតព្វកិច្ចបានកន្លងផុតក៏ដោយ ក៏អ្នកបង្កើតអាចទទួលយកមកវិញនូវវត្ថុដែលជាកម្មវត្ថុ ដោយផ្តល់នូវកាតព្វកិច្ចគ្រប់ចំនួន និងបង្ហាញអំពីការផ្តល់នោះទៅម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានបាន នៅមុនពេលមានការផ្តល់ប្រាក់ជម្រះដែលបានកំណត់នៅ

[60] មាត្រា ៨២៧ នៃក្រមរដ្ឋប្បវេណី ២០០៧

ក្នុងកថាខណ្ឌទី ៣ នៃមាត្រា ៨៩៨ (ការចាត់ចែងប្តូរជាប្រាក់ ឬអនុប្បទានជាស្ថាពរ) ខាងលើនេះ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីតម្លៃវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាននោះ មិនលើសពីចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលត្រូវសង ក្រោយពេលដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន បានជូនដំណឹងអំពីចំនួនដែលមិនលើសនោះ ទៅអោយអ្នកបង្កើតហើយ[61]។

គោលការណ៍នេះចង់ការពារដល់អ្នកបង្កើតប្រាតិភោគដោយអនុប្បទាន និងក្រោមទំហំនៃសិទ្ធិរបស់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានផងដែរ។ កាលណាកូនបំណុលពិតជាចង់បានវត្ថុដែលជាកម្មវត្ថុនោះមកវិញមែន ទោះបីជាហួសថ្ងៃកំណត់ក៏ដោយ គឺអាចទទួលបានតាមរយៈការអនុវត្តកាតព្វកិច្ច ជាមួយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានមុនពេលដែលប្រាក់ជម្រះ ត្រូវបានប្រគល់មកដល់ដៃខ្លួន ផ្ទុយទៅវិញបើប្រាក់មកដល់ដៃគាត់ហើយ គាត់គ្មានសិទ្ធិទទួលបានវត្ថុនោះមកវិញឡើយ ប្រសិនបើគ្មានការព្រមព្រៀងផ្សេងទៀត។ ចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចកូនបំណុលនឹងប្រឈមនឹងការបង់ការប្រាក់ចំនួន ៥ភាគរយក្នុងមួយឆ្នាំ[62]។ មួយវិញទៀតប្រការនេះមិនអាចយកមកអនុវត្តឡើយ ក្នុងករណីដែលម្ចាស់បំណុលបានជូនដំណឹងទៅកូនបំណុល អំពីប្រាក់ដែលប្តូរបានពីចលនវត្ថុនោះមិនមានចំនួនលើពីបំណុល (គ្មានប្រាក់ជម្រះ)។ ដូចនេះមានន័យថាប្រាក់ដែលបានមកពីការប្តូរ មិនគ្រប់គ្រាន់សម្រាប់រំលត់សិទ្ធិលើបំណុលទាំងស្រុងឡើយ ដូចនេះប្រាតិភោគដោយអនុប្បទាន ត្រូវបានរលត់ ព្រោះលែងមានវត្ថុជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទានទៀត ហើយវាមិនរារាំងអត្ថិភាពនៃសិទ្ធិលើបំណុលមួយភាគដែលនៅសល់ មានន័យថាម្ចាស់បំណុលនៅតែមានសិទ្ធិលើបំណុល ចំពោះភាគដែលនៅសល់នោះ។

*ឧទាហរណ៍៖ បុគ្គល ខ ជាម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានលើនាឡិកាមួយតម្លៃ ២៥០ដុល្លារអាមេរិច ហើយបុគ្គល ខ មានសិទ្ធិលើបំណុលដែលធានាដោយប្រាតិភោគចំនួន ៥០០ដុល្លារអាមេរិច។ នៅពេល បុគ្គល ខ អនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន ដោយប្តូរជាប្រាក់ ប្រាកដណាស់ថានាឡិកានោះលក់បានតែ ២៥០ដុល្លារអាមេរិច ករណីនេះ គឺគ្មានប្រាក់ជម្រះ។ ប៉ុន្តែសិទ្ធិលើបំណុលរបស់ ខ មានចំពោះកូនបំណុល ក មិនទាន់រលត់អស់ទាំងស្រុងទេ។ ប្រាក់ដែលបានពីការអនុវត្តនេះគ្រាន់តែជាប្រាក់សម្រាប់រំលត់កាតព្វកិច្ចមួយភាគតែប៉ុណ្ណោះ។ ដូចនេះ បុគ្គល ខ នៅមានសិទ្ធិលើបំណុលចំពោះ ក។ ក្រោយមក ខ បានជូនដំណឹងពីការដែលគ្មានប្រាក់ជម្រះនេះទៅ*

[61] មាត្រា ៨៩៩ នៃក្រមរដ្ឋប្បវេណី ២០០៧

[62] មាត្រា ៣១៨ អត្រាការប្រាក់ដែលច្បាប់កំណត់

*កាន់ ក។ នៅពេលដែល ក បានទទួលដំណឹងនេះហើយ ខ្លួនពុំអាចមានសិទ្ធិទទួលយកមកវិញនូវវត្ថុនោះឡើយទោះបីជាខ្លួនបង្ហាញពីការផ្តល់កាតព្វកិច្ចគ្រប់ចំនួនក៏ដោយ។*

### ៣.២.៤ លំដាប់នៃសិទ្ធិករណីមានម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានទី២

តាមរយៈការសិក្សាកន្លងមកយើងពិនិត្យឃើញថា បញ្ញត្តិស្តីពីប្រាតិភោគដោយអនុប្បទាន (មាត្រា ៨៨៨ ដល់ ៨៩៩ នៃក្រមរដ្ឋប្បវេណី) មិនបានបញ្ញត្តិពីលំដាប់នៃសិទ្ធិដូចការបញ្ចាំចលនវត្ថុនោះទេ (មាត្រា ៨៣៣ លំដាប់នសិទ្ធិលើការបញ្ចាំចនលវត្ថុ) ហេតុនេះប្រសិនបើមានករណីដូចដែលបានរៀបរាប់នៅក្នុងចំណុច **២.២.២.៣ ការចាត់ចែងវត្ថុធានា** ត្រង់ចំណុចមានអ្នកបង្កើតយកវត្ថុធានាទៅដាក់ប្រាតិភោគដោយអនុប្បទានម្តងទៀតជាមួយម្ចាស់បំណុលទីពីរ ករណីនេះតើការសងត្រលប់ទៅវិញ ម្ចាស់បំណុលទីមួយអាចមានសិទ្ធិទាមទារសិទ្ធិអាទិភាពតាមពេលចំពោះម្ចាស់បំណុលក៏ដូចជាកូនបំណុលបានដែរឬទេ? បញ្ហានេះ មិនទាន់អាចនឹងត្រូវបានដោះស្រាយទេ ព្រោះថាម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានលំដាប់ក្រោយ មិនមែនធ្វើលទ្ធកម្មដោយសុចរិតតែម្តងលើចលនវត្ថុនោះឡើយ គឺគ្រាន់តែយកចលនវត្ថុនោះមកធ្វើជាកម្មវត្ថុនៃការធានាលើការសងត្រលប់នៃបំណុលតែប៉ុណ្ណោះ។ បញ្ញត្តិស្រដៀងនឹងប្រាតិភោគដោយអនុប្បទាន គឺការបញ្ចាំចលនវត្ថុ ដែលជាកម្មវត្ថុនៃការសិក្សាប្រៀបធៀបនៃសារណាបទនេះ នៅក្នុងក្រមរដ្ឋប្បវេណី ២០០៧ ត្រង់មាត្រា ៨៣៣ ដែលកំណត់ថាបើបានបង្កើតសិទ្ធិលើការបញ្ចាំលើចលនវត្ថុតែមួយដើម្បីធានាសិទ្ធិលើបំណុលច្រើន លំដាប់នៃសិទ្ធិលើការបញ្ចាំនោះ ត្រូវអនុឡោមទៅតាមពេលវេលាដែលបានបង្កើតនោះ។ ដោយការបញ្ញត្តិបែបនេះហើយ មានមតិមួយចំនួនយល់ឃើញថា បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះលំដាប់នៃសិទ្ធិប្រាតិភោគដោយអនុប្បទាន។ មិនមែនមានន័យថា ការយល់ឃើញបែបនេះខុសទាំងស្រុងនោះទេ ប៉ុន្តែមិនមានគោលការណ៍ណាមួយ ចង្អុលបង្ហាញថាត្រូវអនុឡោមតាមវិធីនេះឡើយ។

# សេចក្ដីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

ជារួមមកកិច្ចសន្យាទាំងពីរប្រភេទនេះសុទ្ធសឹងតែជាកិច្ចសន្យាប្រាតិភោគប្រត្យក្សដែលភ្ជាប់ទៅនឹងកិច្ចធានាកាតព្វកិច្ច និងអនុវត្តបានទៅលើចលនវត្ថុដែលបង្កលក្ខណៈងាយស្រួលក្នុងការដោះដូរដូចគ្នាព្រោះពុំចាំបាច់តម្រូវអោយមានការចុះបញ្ជី ឬលិខិតយថាភូតអ្វីឡើយ។ លក្ខណៈរួមគ្នាមួយទៀតនោះគឺបញ្ញត្តិអនុវត្តដូចគ្នាដែលមានដូចជាសិទ្ធិឃាត់ទុក ករណីយកិច្ចថែរក្សាកម្មវត្ថុ និងសិទ្ធិទាមទារអោយសងសោហ៊ុយរបស់ម្ចាស់សិទ្ធិ។ បើយើងមើលទៅលើការលក្ខខណ្ឌនៃការបង្កើតវិញនោះ ការបញ្ចាំ សង្កត់ធ្ងន់ទៅលើការប្រគល់វត្ថុ រួមទាំងការប្រគល់ដោយសង្ខេប ហេតុនេះបើមានបំណងបង្កើតកិច្ចសន្យាក្នុងរូបភាពជាការបញ្ចាំត្រូវតែអនុវត្តទៅតាមលក្ខខណ្ឌទម្រង់មួយនេះ ចំណែកឯប្រាតិភោគដោយអនុប្បទានវិញមិនបានសង្កត់ធ្ងន់ទៅលើការប្រគល់វត្ថុចាំបាច់ដូចនឹងការបញ្ចាំនោះទេ សំខាន់អោយតែម្ចាស់បំណុលបានទទួលការផ្ទេរការកាន់កាប់នោះកិច្ចសន្យាប្រាតិភោគដោយអនុប្បទាននឹងមានសុពលភាព។ បន្ថែមលើភាពខុសគ្នានេះដែរ លក្ខខណ្ឌតតាំងចាំបាច់ក៏ដូចជាអានុភាពនៃកិច្ចសន្យាទាំងពីរត្រូវបានទទួលស្គាល់ អាស្រ័យថាតើកិច្ចសន្យាបញ្ចាំនោះ ម្ចាស់សិទ្ធិលើការបញ្ចាំបានទទួលសិទ្ធិកាន់កាប់ដោយចំពោះទៅលើវត្ថុធានានោះដែរទេ រីឯប្រាតិភោគដោយអនុប្បទានវិញក៏អាស្រ័យ ថាតើម្ចាស់បំណុលបានទទួលការផ្ទេរការកាន់កាប់ក្រោមរូបភាពទាំងបួនទម្រង់ផងដែរ។ អានុភាពបន្ទាប់បន្សំដែលបង្កអោយសញ្ញាណទាំងពីរនេះមានលក្ខណៈខុសគ្នាទៀតសោធ គឺអានុភាពចំពោះផលពីវត្ថុធានា សិទ្ធិចាត់ចែង ប្រើប្រាស់អាស្រ័យផល និងការបញ្ចាំបន្ត សិទ្ធិឧបាទេសកម្មលើកម្មវត្ថុដែលខុសគ្នា ការបញ្ចាំផ្តាច់ អានុភាពលើវត្ថុដែលភ្ជាប់នឹងវត្ថុធានា ជាអាទិ៍ ដូចដែលបានធ្វើការរៀបរាប់នៅក្នុងជំពូកពីរខាងលើ។

ឆ្លើយតបទៅនឹងគោលបំណងនៃសារណានេះ អាចអោយយើងវែកញែកដាច់ពីគ្នាថា ការបញ្ចាំចលនវត្ថុ សំដៅតែលើករណីដែលម្ចាស់បំណុលជាអ្នកកាន់កាប់ដោយផ្ទាល់លើចលនវត្ថុនៅក្នុងអំឡុងពេលដែលកូនបំណុលមិនទាន់បានអនុវត្តកាតព្វកិច្ចសងចប់សព្វគ្រប់។ ចំណែកឯប្រាតិភោគដោយអនុប្បទានវិញ មានន័យថាម្ចាស់បំណុលមិនបាច់កាន់កាប់ដោយផ្ទាល់លើចលនវត្ថុដែលជាកម្មវត្ថុនៃការធានាសិទ្ធិលើបំណុល ហើយអនុញ្ញាតអោយកូនបំណុលប្រើប្រាស់ចលនវត្ថុនោះបានក្នុងកំឡុងពេលអនុវត្តកាតព្វកិច្ចសង។ គោលបំណងសំខាន់ក្នុងការផ្តល់ប្រាក់កម្ចីទៅអោយកូនបំណុល គឺដើម្បីទទួលបាននូវផលប្រយោជន៍ពីការផ្តល់កម្ចីនោះ ដូចជាការប្រាក់ និងផលប្រយោជន៍ដែលបានមកពីទ្រព្យធានា។ លក្ខខណ្ឌបង្កើតតម្រូវអោយកូនបំណុលប្រគល់វត្ថុបញ្ចាំនាំអោយម្ចាស់បំណុលធ្វើការកាន់កាប់វត្ថុនោះ ធ្វើអោយម្ចាស់បំណុលមានភាពកក់ក្តៅក្នុងចិត្តដែល

អាចធានាបានថា កូនបំណុលរបស់ខ្លួននឹងអនុវត្តកាតព្វកិច្ចបានយ៉ាងត្រឹមត្រូវ និងទៀងទាត់ ទាំងនេះនាំអោយយើងសន្និដ្ឋានបានថា យន្តការនៃការបញ្ចាំ គឺជាយន្តការដ៏មានសុវត្ថិភាពមួយប្រភេទ ដែលផ្តល់ទំនុកចិត្តយ៉ាងកក់ក្តៅដល់ម្ចាស់បំណុលនៃការបញ្ចាំ ក្នុងការធានានូវកាតព្វកិច្ចរបស់កូនបំណុល។ ទន្ទឹមនឹងគុណសម្បត្តិទាំងនេះ លក្ខខណ្ឌតឹងរឹងនៃកិច្ចសន្យាបញ្ចាំ បានបង្កផលវិបាកផងដែរដល់បណ្ដាអ្នកអនុវត្ត។ ជាក់ស្ដែងកាលណារបៀបនៃការអនុវត្តសិទ្ធិកាន់តែមានលក្ខណៈតឹងរឹងកាន់តែគួរអោយទុកចិត្ត ភាពលំបាកទាំងការបង្កើត និងការអនុវត្ត ក៏កើតឡើងមកដោយឯកឯង ដែលការនេះបណ្ដាលអោយបណ្ដាអាជីវករខ្នាតតូចក្ដី ធំក្ដីដែលប្រកបរបរនេះ ខាតពេលវេលាច្រើន និងចំណាយថវិកាបន្ថែមចំពោះដំណើរការនីតិវិធីតុលាការ។ ដោយភាពតឹងរឹងចំពោះការអនុវត្តសិទ្ធិលើការបញ្ចាំនេះហើយ ដែលនាំអោយរបបគតិយុត្តនៃប្រាតិភោគដោយអនុប្បទាន បានចូលខ្លួនមកសម្របសម្រួលបញ្ហាវិបាកនានាដែលអនុវត្តនៅក្នុងប្រាតិភោគតាមការព្រមព្រៀង ជាពិសេសគឺ ការបញ្ចាំផ្ទាល់តែម្ដង។ ប្រាតិភោគដោយអនុប្បទានជាសញ្ញាណដ៏ក្មេងខ្ចីមួយ ប៉ុន្តែទន្ទឹមនឹងការចូលទៅសម្របសម្រួលរបស់ប្រាតិភោគដោយអនុប្បទាន ចរាចរណ៍ប្រាតិភោគចលនវត្ថុនេះកាន់តែមានការកើនឡើងទៅៗ។ នៅក្នុងការអនុវត្តសព្វថ្ងៃជាពិសេសនៅក្នុងហាងកុងស៊ីបញ្ចាំនានាបានធ្វើទំនើបកម្មវាក្យស័ព្ទ ដោយដាក់ថាទទួលប្រាតិភោគដោយអនុប្បទានជំនួសអោយការបញ្ចាំ។ មូលហេតុនោះគឺនៅពេលដែលមានវិវាទ ការលើកឡើងនឹងប្រឆាំងគ្នា ព្រោះប្រាតិភោគដោយអនុប្បទាន ដើរតួនាទីសំខាន់ជាងប្រាតិភោគដទៃទៀតដែលត្រូវបានបង្កើតជាញឹកញាប់ជាងគេនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជា។ ប៉ុន្តែវាក៏មានគុណវិបត្តិមួយចំនួនដែរ គឺក្នុងករណីដែលវត្ថុនៅក្នុងដៃរបស់អ្នកបង្កើត ហើយអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាននោះបានធ្វើអនុប្បទានចលនវត្ថុនោះទៅតតិយជនសុចរិត ដូចនេះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន នឹងត្រូវបាត់បង់លក្ខខណ្ឌតតាំងនៃប្រាតិភោគដោយអនុប្បទានរបស់ខ្លួនចំពោះទ្រព្យធានានោះ។ គុណវិបត្តិមួយផ្សេងទៀតគឺនៅពេលអនុវត្ត ប្រាតិភោគដោយអនុប្បទានគឺពុំឆ្លងកាត់នីតិវិធីតុលាការ (ធៀបនឹងនីតិវិធីអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេបចំពោះចលនវត្ថុ) ជាហេតុនាំអោយពុំមានអ្នកវាយតម្លៃអោយបានត្រឹមត្រូវ និងសុក្រឹត្យ ដើម្បីការពារផលប្រយោជន៍របស់កូនបំណុល ឬតតិយជនដែលធានា ដោយវត្ថុ ដោយសារតែតម្លៃគឺស្ថិតនៅលើម្ចាស់សិទ្ធិជាអ្នកអារកាត់។

បន្ទាប់ពីបានសិក្សាពីគុណសម្បត្តិ និងគុណវិបត្តិសញ្ញាណនៃសិទ្ធិប្រាតិភោគប្រត្យក្សទាំងពីរនេះ យើងឃើញថារបបគតិយុត្តិនៃការបញ្ចាំពិតជាធានាសុវត្ថិភាពទៅដល់ម្ចាស់បំណុលជាជាងប្រាតិភោគដោយអនុប្បទាន ដោយហេតុថាម្ចាស់បំណុលមានសិទ្ធិកាន់កាប់វត្ថុធានានៅក្នុងដៃ

ប្រសិនបើកូនបំណុលមិនអនុវត្តកាតព្វកិច្ច វាបង្កលក្ខណៈងាយស្រួលដល់ម្ចាស់បំណុលក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន ដោយមិនមានការភ័យខ្លាចថាខ្លួននឹងអាចបាត់បង់សិទ្ធិទៅលើវត្ថុធានាដែលត្រូវបានកំណត់រួចទៅហើយនោះ។ វាបានបង្កលក្ខណៈតឹងរឹងបន្តិចចំពោះកូនបំណុលក្នុងការមិនបានប្រើប្រាស់អាស្រ័យផលលើវត្ថុបញ្ចាំក៏ពិតមែន ប៉ុន្តែវាក៏ជួយដល់កូនបំណុលមិនអោយបាត់បង់វត្ថុធានារបស់ខ្លួនក្នុងតម្លៃមួយដែលទាបជាងទីផ្សារ។ ចំណុចត្រង់នេះបញ្ជាក់ថាជាផលអវិជ្ជមាននៃប្រាតិភោគដោយអនុប្បទាន ដោយពុំឆ្លងកាត់នីតិវិធីតុលាការនៅពេលអនុវត្តសិទ្ធិ។ សញ្ញាណនៃកិច្ចសន្យាប្រាតិភោគថ្មីមួយនេះ គឺមានចរាចរមមាញឹកជាងគេនាពេលបច្ចុប្បន្ននេះ ដោយហេតុថាលក្ខខណ្ឌនៃប្រាតិភោគដោយអនុប្បទាន អនុញ្ញាតអោយកូនបំណុលអាចកាន់កាប់វត្ថុធានារបស់ខ្លួន ហេតុនេះកូនបំណុលនៅតែអាចទទួលបានចំណូលពីវត្ថុធានានោះដដែល នេះហើយបញ្ជាក់ថាកូនបំណុលទទួលបានផលប្រយោជន៍ពីប្រាតិភោគដោយអនុប្បទានជាងការបញ្ចាំ ដោយហេតុថាគាត់នៅតែអាចមានចំណូលពីវត្ថុធានានោះដដែល។ ប៉ុន្តែវាក៏បានបង្កហានិភ័យយ៉ាងធំមួយចំពោះម្ចាស់បំណុលដែរ ដោយហេតុថាម្ចាស់បំណុលជាអ្នកចំណាយប្រាក់ទៅអោយកូនបំណុលខ្ចីប៉ុន្តែទ្រព្យធានាបែរជានៅលើដៃកូនបំណុល ប្រសិនបើកូនបំណុលលក់ទ្រព្យធានានោះបាត់ទៅនៅពេលដល់កាលកំណត់សង បញ្ហានឹងកើតឡើង។ គួរបញ្ជាក់នូវចំណុចមួយទៀតផងដែរ របបបញ្ចាំនិងប្រាតិភោគដោយអនុប្បទាននេះចរាចរតាមរយៈហាងបញ្ចាំ ឬហៅថាកុងស៊ីបញ្ចាំស្ទើរគ្រប់ទីកន្លែងនៅតំបន់ដែលប្រជុំជន ដោយរដ្ឋពុំអាចកំណត់ពីទិន្នន័យបានច្បាស់លាស់ និងគ្រប់គ្រងបានល្អឡើយ បច្ចុប្បន្ននៅតែមានហាងកុងស៊ីបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ជាច្រើនបានចាប់ផ្តើមបើដំណើរការដោយពុំមានការអនុញ្ញាតពីច្បាប់នៅឡើយជាពិសេសការបើកបញ្ចាំក្នុងរូបភាពជាប្រាតិភោគដោយអនុប្បទានតូចៗភាគច្រើនគឺពុំបានសុំអាជ្ញាប័ណ្ណបើកដំណើរការនោះឡើយ។

ជារួមរបបគតិយុត្តិទាំងពីរសុទ្ធសឹងតែបង្កប់នូវគុណសម្បត្តិ និងគុណវិបត្តិរៀងខ្លួន។ នេះអាស្រ័យលើម្ចាស់បំណុល និងកូនបំណុលប៉ុណ្ណោះថាតើជ្រើសរើសយករបបគតិយុត្តណាមួយមកប្រើដើម្បីអោយស្របទៅនឹងស្ថានភាពជីវភាព និងលទ្ធភាពជាក់ស្តែងរបស់ខ្លួន ដោយថ្លឹងថ្លែងពីទម្ងន់នៃផលវិបាក និងផលប្រយោជន៍នៃរបបគតិយុត្តនីមួយៗមុននឹងយកមកអនុវត្ត។ តាមការពិតការប្រើប្រាស់ចលនវត្ថុធ្វើជាទ្រព្យធានានេះ ពិតជាប្រភពមួយដ៏សំខាន់ ក្នុងការរួមចំណែកផ្តល់នូវហិរញ្ញប្បទានអាជីវកម្មក្រៅពីអចលនវត្ថុ ព្រោះវាក៏ជាផ្នែកមួយជួយលើកស្ទួយកំណើនសេដ្ឋកិច្ចផងដែរ។ ប្រាតិភោគចលនវត្ថុ ដែលបានបង្កើតឡើងមានលក្ខខណ្ឌខុសពីប្រាតិភោគអចលនវត្ថុខ្លះៗដែលមិនតម្រូវនីតិវិធីនៃការចុះបញ្ជីនៅក្រសួងដែនដីនគរូបនីយកម្ម ដូចជាការប្រើប្រាស់អចលនវត្ថុដើម្បីដាក់ជាទ្រព្យធានានោះទេ។ នេះជាចំណុចល្អមួយសម្រាប់ប្រជាជន ឬអាជីវករ ដោយហេតុ

ថា ការបញ្ចាំចលនវត្ថុ និងប្រាតិភោគដោយអនុប្បទាន ដែលសុទ្ធសឹងតែមានកម្មវត្ថុជាចលនវត្ថុ វាមានភាពឆាប់រហ័ស និងងាយស្រួលក្នុងការអនុវត្ត។ បើទោះបីជាសញ្ញាណនៃប្រាតិភោគទាំងពីរប្រភេទនេះ មានអនុភាព និងការបង្កើតខុសគ្នាក្តី ប៉ុន្តែសុទ្ធតែក្នុងចែករំលែកនូវគោលបំណងរួមគ្នា គឺដើម្បីបង្កើននូវចរាចរណ៍នៃការផ្តល់ប្រាក់កម្ចី តាមរយៈការអនុញ្ញាតការអោយដាក់ចលនវត្ថុដើម្បីធានាកាតព្វកិច្ច។ ដូចនេះមិនគួរមើលរំលងនូវប្រតិបត្តិការចលនវត្ថុជាទ្រព្យធានានោះទេ ព្រោះវាបានចូលរួមចំណែកយ៉ាងសកម្មក្នុងការបង្កើននូវការផ្តល់ឥណទានផ្សេងៗគ្នា ជួយបង្កើតនូវការប្រកួតប្រជែងក្នុងទីផ្សារ ដែលនាំអោយមានកំណើននៃសកម្មភាពសេដ្ឋកិច្ចខ្លាំងក្លា និងកាត់បន្ថយភាពក្រីក្រ។

# អនុសាសន៍

# អនុសាសន៍

ដោយមើលឃើញពីបញ្ហាទាំងនេះ ដើម្បីការពារម្ចាស់បំណុលប្រាតិភោគដោយអនុប្បទាន គួរតែបង្កើតអោយមានការបិតស្លាកសម្គាល់ទៅលើចលនវត្ថុជាប់ប្រាតិភោគដោយអនុប្បទាន ដើម្បីអោយជនក្រៅពីម្ចាស់បំណុល និងកូនបំណុលក៏អាចដឹងពីស្ថានភាពគតិយុត្តនៃចលនវត្ថុ និងមិនហ៊ានទទួលទិញ ឬទទួលប្រាតិភោគពីកូនបំណុល។ ចំណុចមួយទៀតសញ្ញាណនៃប្រាតិភោគចលនវត្ថុនេះ មិនសូវជាត្រូវបានអនុវត្ត អោយត្រូវទៅតាមលក្ខខណ្ឌគតិយុត្តដែលច្បាប់តម្រូវនោះទេ មួយវិញទៀតក៏មិនសូវបានទូលំទូលាយដែរ ដោយកត្តាការយល់ដឹង និងការមិនអនុវត្តទៅតាមច្បាប់តែម្តង ព្រោះប្រជាពលរដ្ឋមួយចំនួនយល់ឃើញថាការបង្កើតកុងស៊ីបញ្ចាំ ឬប្រាតិភោគដោយអនុប្បទាននេះ ត្រូវចំណាយថវិការច្រើនអនេក ជាជាងផលចំណេញដែលទទួលបាន មួយវិញទៀតត្រូវការឯកសារ និងរបាយការណ៍ច្រើនដែលមិនបង្ក លក្ខណៈងាយស្រួលដល់ពួកគេ។ គោលបំណងនៃនីតិករ គឺចង់សម្របសម្រួលដល់ចរាចរណ៍ហិរញ្ញប្បទានទីផ្សារកម្ពុជា និងគ្រប់គ្រងទិន្នន័យកុងស៊ីទាំងនោះ ប៉ុន្តែជាបញ្ហា អាជីវកររកស៊ីបញ្ចាំ និងប្រាតិភោគដោយអនប្បទានធំៗ មួយចំនួន មិនយល់ឃើញពីចំណុចសំខាន់មួយនេះ មិនគិតអំពីប្រយោជន៍រួមនោះទេ ដោយពួកគាត់ពុំបានទៅសុំអាជ្ញាប័ណ្ឌតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឡើយ។ ការធ្វើបែបនេះវាបានផ្តល់ផលប៉ះពាល់ជាខ្លាំងដល់សង្គមជាតិដោយវាអាចបង្កើននូវអំពើចោរកម្មលួចឆក់ប្លន់ហើយយកទ្រព្យដែលបានពីសកម្មភាពខុសច្បាប់ទាំងនោះទៅដាក់បញ្ចាំ ឬប្រាតិភោគដោយអនុប្បទាន នៅកុងស៊ីទាំងនោះ ទោះបីជាទទួលបានតម្លៃទាបជាងទីផ្សារក៏ដោយ។ ទន្ទឹមគ្នានេះដែរដោយក្នុងប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានការកម្រិតថ្លៃសុំអាជ្ញាប័ណ្ណប្រកបអាជីវកម្មទទួលបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន និងការអនុវត្តសិទ្ធិ។ យើងឃើញថាទោះបីជាក្រសួងចេញប្រកាសអោយអាជីវករទទួលបញ្ចាំ និងប្រាតិភោគដោយអនុប្បទានទាំងអស់មកដាក់ពាក្យសុំអាជ្ញាប័ណ្ណក៏ដោយ ក៏អាជីវករមួយចំនួន មិនអាចអនុវត្តទៅតាមប្រកាសរបស់ក្រសួងឡើយ។ កត្តានេះដោយសារតែការកម្រិតដើមទុនអប្បបរមា និងតម្លៃបង់ថ្លៃអាជ្ញាប័ណ្ណមានកម្រិតខ្ពស់ដែលធ្វើអោយអាជីវកម្មទទួលបញ្ចាំខ្នាតតូចមួយចំនួនដូចជា ហាងលក់ទូរស័ព្ទតូចៗជាដើមមិនព្រមទៅដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណឡើយ។ នៅក្នុងការប្រកបអាជីវកម្មទទួលបញ្ចាំ និងប្រាតិភោគដោយអនុប្បទានបែបនេះ អាជីវករមួយចំនួនរកប្រាក់ចំណូលបានត្រឹមតែផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃតែប៉ុណ្ណោះ ជាហេតុពួកគាត់ពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបង់ថ្លៃអាជ្ញាប័ណ្ណ ជាពិសេសដើមទុនអប្បបរមាដែលមានចំនួនខ្ពស់ហួសពីសមត្ថភាពរបស់ពួកគាត់។ ម្យ៉ាងទៀតបើបណ្តោយអោយមាន

អាជីវកម្មទទួលបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ដែលគ្មានការអនុញ្ញាត ឬគ្មានអាជ្ញាប័ណ្ណ ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ វានឹងធ្វើអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈជាក់ជាមិនខានឡើយទៅថ្ងៃអនាគត។

ដើម្បីដោះស្រាយបញ្ហានេះ ការស្នើសុំអាជ្ញាប័ណ្ណបើកកុងស៊ីទាំងនេះ គួរត្រូវបានកែសម្រួល ប្រសិនមានការអនុគ្រោះដល់កុងស៊ីដែលរកស៊ីតាមខ្នាតតូចៗ គួរសម្រួលតម្លៃនៃការស្នើសុំអាជ្ញាប័ណ្ណ អោយទាបជាងកុងស៊ីបញ្ចាំដែលមានខ្នាតធំៗ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរតែបង្កើតលក្ខខណ្ឌថ្មីមួយផ្សេងទៀត សម្រាប់អាជីវកម្មទទួលបញ្ចាំខ្នាតតូច ដោយកម្រិតដើមទុនអប្បបរមា និងថ្លៃបង់អាជ្ញាប័ណ្ណសម្រាប់អាជីវកម្មទទួលបញ្ចាំវត្ថុខ្នាតតូចទាំងនោះ អោយមានកម្រិតទាបជាងអាជីវកម្មទទួលបញ្ចាំខ្នាតធំ ហើយអោយវាសមស្របទៅតាមលទ្ធភាពដែលពួកគាត់អាចធ្វើទៅបាន។ លើសពីនេះទៅទៀត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គម្បីចាត់មន្ត្រីមានសមត្ថកិច្ចធ្វើការចុះត្រួតពិនិត្យគ្រប់អាជីវកម្មទទួលបញ្ចាំទាំងអស់ ជារៀងរាល់ខែ ឬឆ្នាំទៅតាមលទ្ធភាពដែលអាចធ្វើទទៅបាន និងពង្រឹងការអនុវត្តច្បាប់អោយកាន់តែមានប្រសិទ្ធិភាព ចំពោះអាជីវករទទួលបញ្ចាំ និងប្រាតិភោគដោយអនុប្បទានទាំងឡាយណាដែលទទួលផលពីអំពើចោរកម្ម ដើម្បីផ្តន្ទាទោសទៅតាមច្បាប់។

ចំណុចមួយទៀតប្រជាជនកម្ពុជាបច្ចុប្បន្នភាគច្រើនប្រើប្រាស់នូវប្រតិបត្តិការហិរញ្ញប្បទានរបៀបនេះ ដើម្បីជាទុនក្នុងការប្រកបអាជីវកម្មរបស់ខ្លួន ទាំងកម្ចីពីកុងស៊ីបញ្ចាំ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នឹងរហូតទៅដល់ធនាគារទាំងខ្នាតធំ និងតូច ដែលជាហេតុផលយ៉ាងសំខាន់ដែលពួកគាត់ត្រូវយល់ដឹងពីរបបគតិយុត្តទាំងពីរនេះអោយកាន់តែច្បាស់ សិក្សាពីចំណូល ចំណាយ លទ្ធភាពផ្ទាល់ខ្លួនអោយលម្អិត ជៀសវាងការបាត់បង់ទ្រព្យ ទោះបីជាចលនវត្ថុក្តី ឬអចលនវត្ថុក្តី និងដើម្បីធានាបាននូវស្ថេរភាពប្រតិបត្តិការអាជីវកម្មជំនួញក្នុងស្ថានភាពប្រចាំថ្ងៃ។

# ឯកសារយោង

# ឯកសារយោង


១.	រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣
២.	ក្រមរដ្ឋប្បវេណី ប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧
៣.	ក្រមនីតិវិធីរដ្ឋប្បវេណី ប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។
៤.	ក្រមរដ្ឋប្បវេណីចាស់ឆ្នាំ ១៩២០
៥.	ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៧/០១២
៦.	ច្បាប់ភូមិបាល ឆ្នាំ២០០១
៧.	ច្បាប់ភូមិបាលឆ្នាំ ១៩៩២
៨.	សេក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី រៀបចំដោយគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី ឆ្នាំ ២០១១។
៩.	សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៤ គន្ថីទី៦ រៀបចំដោយគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី,ក្រសួងយុត្តិធម៌, ឆ្នាំ២០០៩។
១០.	សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ១ គន្ថីទី១ ដល់គន្ថីទី៣, រៀបចំដោយគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី,ក្រសួងយុត្តិធម៌, ឆ្នាំ២០០៩។
១១.	សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគ ១ និងភាគ២ ដែលរៀបរៀងដោយក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាល នៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការខែមេសា ឆ្នាំ២០១៣។
១២.	សេចក្តីពន្យល់អំពី ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ២ ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ ដែលរៀបចំដោយក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ ២០០៩។
១៣.	សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦។

១៤. ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ០២៨ សហវ ប្រក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មទទួលបញ្ចាំ និងទិញ លក់ ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន។

១៥. សៀវភៅមេរៀន "នីតិប្រាតិភោគ" លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ ២០១៣-២០១៤

១៦. ឯកសារសិក្ខាសាលាស្តី "ការអនុវត្តសិទ្ធិប្រាតិភោគប្រត្យក្សលើចលនវត្ថុ" នាថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៦ នៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ធ្វើបទបង្ហាញដោយលោកមេធាវី នង មានន្ទ លោក មេធាវី ស៊ន់ សុជាតិ និងលោកមេធាវី ហួ លីហ៊ូវ។

១៧. វចនានុក្រមសម្តេចព្រះសង្ឃរាជ ជួនណាត បោះពុម្ពក្នុងឆ្នាំ ១៩៦៧។

១៨. ក្រឹត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ដែលត្រូវបានប្រកាសអោយប្រើនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៨ (ត្រូវបាននិរាករណ៍ដោយផ្នែក ដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ប្រកាសអោយប្រើនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ត្រង់មាត្រា ៧៩)។

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

+ **ឧបសម្ព័ន្ធទី ១** សម្រង់បញ្ញត្តិពាក់ព័ន្ធក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា
+ **ឧបសម្ព័ន្ធទី ២** សម្រង់ផ្នែកដែលពាក់ព័ន្ធក្នុងសេចក្តីពន្យល់ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា
+ **ឧបសម្ព័ន្ធទី ៣** ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ០២៨ សហវ ប្រក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មទទួលបញ្ចាំ និងទិញ លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន
+ **ឧបសម្ព័ន្ធទី ៤** គម្រូកិច្ចព្រមព្រៀងប្រាក់កម្ចី និងដាក់បញ្ចាំចលនវត្ថុ
+ **ឧបសម្ព័ន្ធទី ៥** គម្រូកិច្ចព្រមព្រៀងប្រាតិភោគដោយអនុប្បទាន
+ **ឧបសម្ព័ន្ធទី ៦** ក្រដាសបិតផ្សាយពីកម្ចីដាក់ទ្រព្យបញ្ចាំ

# ឧបសម្ព័ន្ធ ១

[illegible]

# ប្រកាសរួម

ស្ដីពី

[illegible]

[illegible]

# ក្រមរដ្ឋប្បវេណី

# ជំពូកទី ៤
# សិទ្ធិលើការបញ្ចាំ

## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ៨១៦.-** អត្ថន័យនៃសិទ្ធិលើការបញ្ចាំ

ម្ចាស់សិទ្ធិលើការបញ្ចាំ មានសិទ្ធិកាន់កាប់វត្ថុដែលបានទទួលពីកូនបំណុល ឬ តតិយជនដើម្បីធានាសិទ្ធិលើបំណុលរបស់ខ្លួន និង ទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនពីវត្ថុនោះ ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត ។

**មាត្រា ៨១៧.-** ឧបាទេសកម្មលើវត្ថុ

១-សិទ្ធិលើការបញ្ចាំអាចអនុវត្តបានចំពោះទឹកប្រាក់ ឬ វត្ថុផ្សេងទៀតដែលអ្នកបង្កើតត្រូវទទួល ដោយការលក់ ការបាត់បង់ ឬ ការខូចខាតនូវវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ។ ប៉ុន្តែ ម្ចាស់សិទ្ធិលើការបញ្ចាំពុំអាចអនុវត្តសិទ្ធិរបស់ខ្លួនបានឡើយ នៅក្រោយពេលដែលទឹកប្រាក់ត្រូវបានបង់ ឬ វត្ថុផ្សេងត្រូវបានប្រគល់ ទៅឱ្យអ្នកបង្កើត ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះតម្លៃថ្នូរនឹងសិទ្ធិប្រត្យក្សដែលបង្កើតឡើង ដោយអ្នកបង្កើតសិទ្ធិលើការបញ្ចាំ លើវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ ។

**មាត្រា ៨១៨.-** ការបង្កើតសិទ្ធិលើការបញ្ចាំ និង ការប្រគល់វត្ថុជាចាំបាច់

១-សិទ្ធិលើការបញ្ចាំត្រូវកើតឡើង ដោយកូនបំណុល ឬ តតិយជនដែលបង្កើតសិទ្ធិលើការបញ្ចាំនោះ ប្រគល់នូវវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ ។

២-ការប្រគល់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវរាប់បញ្ចូលទាំងការប្រគល់ដោយសង្ខេប ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ នៃមាត្រា ២២៩

(ការផ្ទេរការកាន់កាប់) នៃក្រមនេះ ។

**មាត្រា ៨១៩.-** ការហាមការកាន់កាប់ដោយផ្ទាល់ ដោយអ្នកបង្កើតសិទ្ធិលើការបញ្ចាំ

ម្ចាស់សិទ្ធិលើការបញ្ចាំមិនអាចឱ្យអ្នកបង្កើតសិទ្ធិលើការបញ្ចាំនោះកាន់កាប់ដោយផ្ទាល់លើវត្ថុបញ្ចាំនោះបានឡើយ ។

**មាត្រា ៨២០.-** ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា

សិទ្ធិលើការបញ្ចាំត្រូវធានានូវ ប្រាក់ដើម ការប្រាក់ ប្រាក់ធានាសងក្នុងករណីមិនគោរពកិច្ចសន្យា សោហ៊ុយដើម្បីអនុវត្តសិទ្ធិលើការបញ្ចាំ សោហ៊ុយដើម្បីថែរក្សាវត្ថុបញ្ចាំព្រមទាំងសំណងនៃការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ឬ វិការៈកំបាំងនៃវត្ថុបញ្ចាំ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានកំណត់ផ្សេង ក្នុងសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំនោះ ។

**មាត្រា ៨២១.-** អានុភាពនៃការឃាត់ទុក

ម្ចាស់សិទ្ធិលើការបញ្ចាំអាចឃាត់ទុកវត្ថុបញ្ចាំបាន រហូតដល់ពេលដែលទទួលការសងចំពោះសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងមាត្រា ៨២០ (ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា) ខាងលើនេះ ។ ប៉ុន្តែ សិទ្ធិនេះមិនអាចតតាំង ចំពោះម្ចាស់បំណុលដែលមានអាទិភាពជាងខ្លួនបានឡើយ ។

**មាត្រា ៨២២.-** សិទ្ធិទទួលការសងពីផលដោយមានអាទិភាព

១-ម្ចាស់សិទ្ធិលើការបញ្ចាំអាចទទួលផលដែលកើតពីវត្ថុបញ្ចាំ និង អាចយកផលនោះមកកាត់សិទ្ធិលើបំណុលរបស់ខ្លួន ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតបាន ។

២-ផលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកកាត់ការប្រាក់នៃសិទ្ធិលើបំណុលជាមុនសិន ហើយ ប្រសិនបើមានសំណល់ ត្រូវយកទៅកាត់ប្រាក់ដើម ។

**មាត្រា ៨២៣.–** ករណីយកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ចាំក្នុងការរក្សាទុកនូវវត្ថុបញ្ចាំ

១-ម្ចាស់សិទ្ធិលើការបញ្ចាំ ត្រូវកាន់កាប់វត្ថុបញ្ចាំនោះដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

២-ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំបានធ្វើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ កូនបំណុលអាចទាមទាររំលត់សិទ្ធិលើការបញ្ចាំនោះបាន ។

**មាត្រា ៨២៤.–** សិទ្ធិទាមទារឱ្យសងសោហ៊ុយរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ

១-ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំបានចេញចំណាយជាចាំបាច់សម្រាប់ការគ្រប់គ្រង និង ថែរក្សាវត្ថុ ចំពោះវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនោះ អាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះសងនូវចំណាយនោះវិញបាន ។

២-ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំបានចេញចំណាយបង្កើនតម្លៃនៃវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនោះអាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះសងនូវចំណាយទាំងអស់ដែលខ្លួនបានចេញ ឬ សងនូវតម្លៃប្រាក់ដែលកើននោះវិញ តាមការជ្រើសរើសរបស់ខ្លួនបាន ក្នុងករណីដែលកំណើនតម្លៃនោះនៅតែមាន ។ ប៉ុន្តែ តុលាការអាចកំណត់ពេលសមរម្យដើម្បីសង តាមការទាមទាររបស់កម្មសិទ្ធិករបាន ។

**មាត្រា ៨២៥.–** អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ការប្រើសិទ្ធិលើការបញ្ចាំ មិនរារាំងដំណើរការនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលឡើយ ។

**មាត្រា ៨២៦.–** ការបញ្ចាំបន្ត

១-ម្ចាស់សិទ្ធិលើការបញ្ចាំអាចយកវត្ថុបញ្ចាំនោះទៅដាក់បញ្ចាំបន្តទៀតបាន ដោយទទួលការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំនោះ ដើម្បីធានានូវកាតព្វកិច្ចរបស់ខ្លួន ។

២-ក្នុងអំឡុងពេលដែលមានអត្ថិភាពនៃសិទ្ធិលើការបញ្ចាំ ម្ចាស់សិទ្ធិនោះអាចយកវត្ថុបញ្ចាំនោះទៅដាក់បញ្ចាំបន្តទៀត ក្រោមការទទួលខុសត្រូវរបស់ខ្លួនបាន ។ ក្នុងករណី

នេះ ម្ចាស់សិទ្ធិលើការបញ្ចាំនោះក៏ត្រូវទទួលខុសត្រូវ ចំពោះការខូចខាតដោយប្រធានសក្តិ ដែលមិនអាចកើតមានឡើងប្រសិនបើមិនបានដាក់បញ្ចាំបន្តទេ ។

៣-នៅពេលចែកចំណែកថ្លៃលក់ដោយបង្ខំនៃវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំបន្ត អាចទទួលនូវការសងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនទាំងអស់ ដោយមានកម្រិត នៃចំនួនទឹកប្រាក់ដែលត្រូវចែកចំណែកទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ ។ ប៉ុន្តែ ប្រសិនបើ សិទ្ធិលើបំណុលរបស់ខ្លួន មិនទាន់ដល់ពេលកំណត់ត្រូវសងទេ ម្ចាស់សិទ្ធិលើការបញ្ចាំបន្ត គ្រាន់តែអាចទាមទារឱ្យតម្កល់នូវចំនួនទឹកប្រាក់ដែលខ្លួនអាចទទួលការសងបានប៉ុណ្ណោះ ។

**មាត្រា ៨២៧.–** ការហាមកិច្ចសន្យាបញ្ចាំផ្តាច់

បើពុំមានបញ្ញត្តិពិសេសនៅក្នុងក្រមនេះ ឬ ច្បាប់ផ្សេងទៀតទេ អ្នកដែលបង្កើត សិទ្ធិលើការបញ្ចាំ មិនអាចព្រមព្រៀង ឱ្យម្ចាស់សិទ្ធិលើការបញ្ចាំទទួលកម្មសិទ្ធិលើវត្ថុបញ្ចាំ ឬ ចាត់ចែងវត្ថុបញ្ចាំ តាមវិធីផ្សេងពីវិធីដែលច្បាប់បានកំណត់ ដោយសកម្មភាពបង្កើត សិទ្ធិលើការបញ្ចាំ ឬ ដោយកិច្ចសន្យាដែលធ្វើមុនកំណត់ពេលត្រូវសងបានទេ ។

**មាត្រា ៨២៨.–** សិទ្ធិទាមទារសំណងរបស់អ្នកធានាដោយវត្ថុ

ប្រសិនបើអ្នកដែលបង្កើតសិទ្ធិលើការបញ្ចាំដើម្បីធានាកាតព្វកិច្ចរបស់អ្នកដទៃ បានសងចំពោះកាតព្វកិច្ចនោះ ឬ បានបាត់បង់នូវកម្មសិទ្ធិលើវត្ថុបញ្ចាំ ដោយសារការ អនុវត្តសិទ្ធិលើការបញ្ចាំនោះ អ្នកនោះត្រូវមានសិទ្ធិទាមទារសំណង ចំពោះកូនបំណុល ដោយយោងទៅតាមបញ្ញត្តិស្តីពីការធានា ។

## ផ្នែកទី ២
## ការបញ្ចាំចលនវត្ថុ

**មាត្រា ៨២៩.–** ល័ក្ខខ័ណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំ

ម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុ មិនអាចតតាំងសិទ្ធិលើការបញ្ចាំនោះចំពោះតតិយ-

ជនបានឡើយ ប្រសិនបើខ្លួនមិនបានកាន់កាប់ជានិរន្តរ៍នូវវត្ថុបញ្ចាំនោះ ។

**មាត្រា ៨៣០.-** ករណីដែលការកាន់កាប់ត្រូវបានដកយក

ក្នុងករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុត្រូវបានដកយកនូវការកាន់កាប់វត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនោះ អាចយកវត្ថុបញ្ចាំមកវិញបាន តាមរយៈបណ្ដឹងទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ តែប៉ុណ្ណោះ ។

**មាត្រា ៨៣១.-** ការប្រើប្រាស់ និង អាស្រ័យផលពីវត្ថុបញ្ចាំ ដោយម្ចាស់សិទ្ធិលើការបញ្ចាំ

១-បើពុំមានការយល់ព្រមពីសំណាក់កូនបំណុលទេ ម្ចាស់សិទ្ធិលើការបញ្ចាំ មិនអាចប្រើប្រាស់ ឬ ជួលវត្ថុបញ្ចាំបានឡើយ ។ ប៉ុន្តែ ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើប្រាស់បាន ត្រឹមតែកម្រិតដែលចាំបាច់ក្នុងការរក្សាវត្ថុបញ្ចាំនោះ ។

២-បើម្ចាស់សិទ្ធិលើការបញ្ចាំបានប្រព្រឹត្តផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ កូនបំណុលអាចទាមទារឱ្យរំលត់សិទ្ធិលើការបញ្ចាំបាន ។

**មាត្រា ៨៣២.-** ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប

១-ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុមិនបានទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនទេ ម្ចាស់សិទ្ធិនោះអាចទាមទារទៅតុលាការឱ្យយកវត្ថុបញ្ចាំមកសងផ្ទាល់តែម្ដង តាមការវាយតម្លៃរបស់អ្នកវាយតម្លៃបាន លុះត្រាតែមានមូលហេតុត្រឹមត្រូវ ។ ក្នុងករណីនេះ ម្ចាស់សិទ្ធិលើការបញ្ចាំត្រូវជូនដំណឹងអំពីការទាមទារនោះទៅកូនបំណុលជាមុន ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើចំនួនទឹកប្រាក់ដែលវាយតម្លៃដោយអ្នកវាយតម្លៃនោះ លើសពីចំនួននៃកាតព្វកិច្ចដែលត្រូវសងម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុ ត្រូវសងនូវចំនួនទឹកប្រាក់ដែលនៅសល់ ទៅកម្មសិទ្ធិករនៃវត្ថុបញ្ចាំនោះវិញ ។

**មាត្រា ៨៣៣.-** លំដាប់នៃសិទ្ធិលើការបញ្ចាំចលនវត្ថុ

ក្នុងករណីដែលបានបង្កើតសិទ្ធិលើការបញ្ចាំលើចលនវត្ថុតែមួយ ដើម្បីធានាសិទ្ធិលើបំណុលច្រើន លំដាប់នៃសិទ្ធិលើការបញ្ចាំទាំងនោះត្រូវអនុលោមតាមពេលវេលាដែលបានបង្កើតនោះ ។

## ផ្នែកទី ៣
## ការបញ្ចាំអចលនវត្ថុ

**មាត្រា ៨៣៤.-** សិទ្ធិប្រើប្រាស់ និង អាស្រ័យផលរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ

១-ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុអាចប្រើប្រាស់ និង អាស្រ័យផលពីអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ តាមវិធីប្រើប្រាស់នៃអចលនវត្ថុនោះ ។

២-ចំពោះដីដែលសិទ្ធិលើការបញ្ចាំបានបង្កើតដើម្បីធានាសិទ្ធិលើបំណុលដែលគ្មានពេលកំណត់ ក្នុងករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំប្រើដីនោះដើម្បីធ្វើកសិកម្ម ទោះបីជាសិទ្ធិលើបំណុលរលត់ដោយការសងក៏ដោយ បើរដូវប្រមូលផលពីដំណាំដែលម្ចាស់សិទ្ធិបំណុលបានសាប ឬ ដាំពីមុន នឹងដល់ នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក៏ម្ចាស់សិទ្ធិលើការបញ្ចាំ អាចប្រើដីនោះ រហូតដល់ពេលដល់រដូវប្រមូលផលនោះ ។

៣-ចំពោះដីដែលសិទ្ធិលើការបញ្ចាំបានបង្កើតដើម្បីធានាសិទ្ធិលើបំណុលដែលមានពេលកំណត់ ក្នុងករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំប្រើដីនោះដើម្បីធ្វើកសិកម្ម ទោះបីជាសិទ្ធិលើបំណុលរលត់ដោយការសងនៅមុនពេលកំណត់ក៏ដោយ បើរដូវប្រមូលផលពីដំណាំដែលម្ចាស់សិទ្ធិបំណុលបានសាប ឬ ដាំពីមុន នឹងដល់ នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក៏ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើដីនោះ រហូតដល់ពេលដល់រដូវប្រមូលផលនោះ ។ ប៉ុន្តែ ទោះបីជារដូវប្រមូលផលនោះ នឹងដល់ នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំក្រោយការសងនៅមុនពេលកំណត់ក៏ដោយ បើរដូវប្រមូលផលនោះ នឹងដល់ ក្រោយពេលកំណត់នៃការសងកាតព្វកិច្ច ម្ចាស់សិទ្ធិលើការបញ្ចាំ ត្រូវប្រគល់ដីវិញភ្លាម ក្រោយពេលទទួលការសង ។

**មាត្រា ៨៣៥.–** បន្ទុកសោហ៊ុយគ្រប់គ្រង

ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុត្រូវចេញសោហ៊ុយគ្រប់គ្រង និង ត្រូវទទួលបន្ទុកផ្សេងៗចំពោះអចលនវត្ថុនោះ ។

**មាត្រា ៨៣៦.–** ការប្រាក់នៃសិទ្ធិលើបំណុល

ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ មិនអាចទាមទារការប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនបានទេ ។

**មាត្រា ៨៣៧.–** អានុភាពនៃការសន្យាពិសេស

បញ្ញត្តិនៃមាត្រា ៨៣៤ (សិទ្ធិប្រើប្រាស់ និង អាស្រ័យផលរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ) មាត្រា ៨៣៥ (បន្ទុកសោហ៊ុយគ្រប់គ្រង) និង មាត្រា ៨៣៦ (ការប្រាក់នៃសិទ្ធិលើបំណុល) ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានការសន្យាពិសេសនៅក្នុងសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំ ។

**មាត្រា ៨៣៨.–** អំឡុងពេលដែលមានអត្ថិភាព

១-អំឡុងពេលដែលមានអត្ថិភាពនៃសិទ្ធិលើការបញ្ចាំអចលនវត្ថុ មិនអាចលើសពី ៥ (ប្រាំ) ឆ្នាំបានឡើយ ។ ប្រសិនបើបានបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុលើសពីអំឡុងពេលនេះ អំឡុងពេលត្រូវបន្ថយមកត្រឹម ៥ (ប្រាំ) ឆ្នាំ ។

២-កិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុអាចធ្វើបន្តទៀតបាន ។ ប៉ុន្តែអំឡុងពេលនៃការបន្តនេះមិនអាចធ្វើឱ្យលើសពី ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលបន្តបានឡើយ ។

**មាត្រា ៨៣៩.–** ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីហ៊ីប៉ូតែក

ក្រៅពីបញ្ញត្តិនៃផ្នែកទី ៣ (ការបញ្ចាំអចលនវត្ថុ) នេះ បញ្ញត្តិនៃជំពូកទី ៥ (ហ៊ីប៉ូតែក) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការបញ្ចាំអចលនវត្ថុ ។

# ផ្នែកទី ៤
# ការបញ្ចាំសិទ្ធិ

**មាត្រា ៨៤០.–** កម្មវត្ថុនៃការបញ្ចាំសិទ្ធិ

១-សិទ្ធិលើការបញ្ចាំអាចមានកម្មវត្ថុជាសិទ្ធិលើទ្រព្យសម្បត្តិបាន ។

២-ក្រៅពីបញ្ញត្តិនៃផ្នែកទី ៤ (ការបញ្ចាំសិទ្ធិ) នេះ បញ្ញត្តិនៃផ្នែកទី ២ (ការបញ្ចាំចលនវត្ថុ) និង ផ្នែកទី ៣ (ការបញ្ចាំអចលនវត្ថុ) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសិទ្ធិលើការបញ្ចាំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៨៤១.–** ល័ក្ខខ័ណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ

១-ក្នុងករណីដែលយកសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ មកធ្វើជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ សិទ្ធិលើការបញ្ចាំនេះ មិនអាចតតាំងចំពោះកូនបំណុលទី ៣ និងតតិយជនផ្សេងទៀតបានឡើយ លើកលែងតែករណីដែលបានជូនដំណឹងអំពីការបង្កើតសិទ្ធិលើការបញ្ចាំដល់កូនបំណុលទី ៣ ឬ មានការយល់ព្រមពីកូនបំណុលទី ៣ នោះ ។

២-ការជូនដំណឹង ឬ ការយល់ព្រមដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចតតាំងចំពោះតតិយជន ក្រៅពីកូនបំណុលទី ៣ បានឡើយ ប្រសិនបើមិនបានធ្វើឡើងដោយលិខិតដែលមានកាលបរិច្ឆេទស្លាក ។

**មាត្រា ៨៤២.–** ការអនុវត្តសិទ្ធិលើការបញ្ចាំដោយប្រមូលសិទ្ធិលើបំណុល

១-ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រមូលសិទ្ធិលើបំណុលដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំបាន ។

២-ប្រសិនបើកម្មវត្ថុនៃសិទ្ធិលើបំណុលជាប្រាក់ ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រមូលសិទ្ធិលើបំណុល ត្រឹមតែភាគដែលស្មើនឹងចំនួនប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនប៉ុណ្ណោះ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បើកំណត់ពេល

ត្រូវសងនៃសិទ្ធិលើបំណុលបានមកដល់ មុនកំណត់ពេលត្រូវសងនៃសិទ្ធិលើបំណុលរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនេះ អាចឱ្យកូនបំណុលទី ៣ តម្កល់ប្រាក់សងនេះបាន ។ ក្នុងករណីនេះ សិទ្ធិលើការបញ្ចាំមានអត្ថិភាពលើប្រាក់តម្កល់នោះ ។

៤-ប្រសិនបើកម្មវត្ថុនៃសិទ្ធិលើបំណុលមិនមែនជាប្រាក់ទេ ម្ចាស់សិទ្ធិលើការបញ្ចាំមានសិទ្ធិលើការបញ្ចាំលើវត្ថុដែលខ្លួនបានទទួលជាការសង ។

# ជំពូកទី ៥
# ហ៊ីប៉ូតែក

## ផ្នែកទី ១
## អត្ថន័យនៃហ៊ីប៉ូតែក

**មាត្រា ៨៤៣.-** អត្ថន័យនៃហ៊ីប៉ូតែក

១-ម្ចាស់បំណុលហ៊ីប៉ូតែកមានសិទ្ធិទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួន ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត ចំពោះអចលនវត្ថុដែលបានដាក់ជាប្រាតិភោគនៃកាតព្វកិច្ច ដោយកូនបំណុល ឬ តតិយជនមិនផ្ទេរការកាន់កាប់ ។

២-សិទ្ធិជួលអចិន្ត្រៃយ៍ និង ផលុបភោគ ក៏អាចយកមកធ្វើជាកម្មវត្ថុនៃហ៊ីប៉ូតែកបានដែរ ។ ក្នុងករណីនេះ បញ្ញត្តិនៃជំពូកទី ៥ (ហ៊ីប៉ូតែក) នេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

៣-ក្នុងករណីដែលច្បាប់ពិសេសទទួលស្គាល់ការយកទ្រព្យសម្បត្តិផ្សេងក្រៅពីអចលនវត្ថុ មកធ្វើជាកម្មវត្ថុនៃហ៊ីប៉ូតែក បញ្ញត្តិនៃច្បាប់ពិសេសនោះត្រូវយកមកអនុវត្ត ។

## ផ្នែកទី ២
## ការបង្កើតហ៊ីប៉ូតែក

**មាត្រា ៨៤៤.-** ការបង្កើតហ៊ីប៉ូតែក

ហ៊ីប៉ូតែកនឹងត្រូវបានបង្កើតឡើង ដោយការព្រមព្រៀងគ្នារវាងម្ចាស់បំណុល និង

ការទាមទារឱ្យរំលត់ ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបានឡើយ ។

៤-តតិយជនដែលបានធ្វើលទ្ធកម្មនូវកម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀត ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ដោយភ្ជាប់នឹងល័ក្ខខ័ណ្ឌបង្អង់ មិនអាចធ្វើការទាមទារឱ្យរំលត់ ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ផែលនេះបានឡើយ នៅក្នុងពេលដែលពុំដឹងថាល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញ ឬ មិនទាន់បានបំពេញ ។

## ជំពូកទី ៦
## ប្រាតិភោគដោយអនុប្បទាន

### ផ្នែកទី ១
### និយមន័យនៃប្រាតិភោគដោយអនុប្បទាន

**មាត្រា ៨៨៨.–** និយមន័យនៃប្រាតិភោគដោយអនុប្បទាន

១-ប្រាតិភោគដោយអនុប្បទាន សំដៅទៅលើករណីដែលកូនបំណុល ឬ តតិយជនធ្វើអនុប្បទាននូវចលនវត្ថុរបស់ខ្លួនជាកំណត់ ទៅឱ្យម្ចាស់បំណុល ដើម្បីធានាកាតព្វកិច្ច ។ ក្នុងករណីនេះ បើកាតព្វកិច្ចត្រូវបានសងរួចហើយ កម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុ ត្រូវផ្ទេរទៅអ្នកបង្កើត ។

២-ចលនវត្ថុច្រើនដែលត្រូវបានកំណត់ទំហំតាមមាត្រដ្ឋាន ដូចជាប្រភេទ ឬ កន្លែងស្ថិតនៅនៃចលនវត្ថុ អាចយកមកធ្វើជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ដោយចាត់ទុកជាចលនវត្ថុផ្គុំគ្នាតែមួយបាន ទោះបីជាចលនវត្ថុនីមួយៗដែលផ្គុំគ្នានោះ មានការប្រែប្រួលក៏ដោយ ។

### ផ្នែកទី ២
### ការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន

**មាត្រា ៨៨៩.–** ការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន

សិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវបានបង្កើតឡើង ដោយការព្រមព្រៀងរវាង

ម្ចាស់បំណុល និង កូនបំណុល ឬ តតិយជន ដែលផ្តល់ចលនវត្ថុសម្រាប់ប្រាតិភោគដោយអនុប្បទាន ។

**មាត្រា ៨៩០.-** អានុភាពតតាំងនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ពុំអាចតតាំងសិទ្ធិប្រាតិភោគដោយអនុប្បទាននោះ ចំពោះតតិយជនក្រៅពីអ្នកបង្កើតបានឡើយ បើមិនបានទទួលការផ្ទេរការកាន់កាប់វត្ថុដែលជាកម្មវត្ថុ ដោយយោងតាមបញ្ញត្តិនៃមាត្រា ២២៩ (ការផ្ទេរការកាន់កាប់) នៃក្រមនេះទេ ។

## ផ្នែកទី ៣

## អានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

**មាត្រា ៨៩១.-** ទំហំដែលមានអានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

១-សិទ្ធិប្រាតិភោគដោយអនុប្បទាន មានអានុភាពលើវត្ថុដែលភ្ជាប់នឹងវត្ថុដែលជាកម្មវត្ថុ និង ជាផ្នែកមួយនៃវត្ថុដែលជាកម្មវត្ថុនោះ នៅពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ។ អានុភាពនេះក៏មានលើវត្ថុដែលត្រូវបានភ្ជាប់នៅក្រោយពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានផងដែរ ។

២-ភាគីអាចកំណត់ផ្សេងពីបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះបាន នៅក្នុងកិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ។

**មាត្រា ៨៩២.-** អានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទានចំពោះផល

១-ក្នុងករណីដែលអ្នកបង្កើត ឬ តតិយជនដែលបានទទួលការបញ្ជាពីអ្នកបង្កើតនោះ កាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ បញ្ញត្តិនៃមាត្រា ៨៩១ (ទំហំដែលមានអានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន) ខាងលើនេះ មិនត្រូវយកមកអនុវត្តចំពោះផលឡើយ ។ ប៉ុន្តែ បញ្ញត្តិនៃវាក្យខណ្ឌទី ១ នេះមិនត្រូវយកមកអនុវត្តឡើយ នៅក្រោយពេលដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន បានទាមទារឱ្យប្រគល់វត្ថុដែលជាកម្មវត្ថុ

ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៨៩៨ (ការចាត់ចែងប្តូរជាប្រាក់ ឬ អនុប្បទានជាស្ថាពរ) នៃក្រមនេះ ។

២-ក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬ តតិយជនដែលបានទទួលការបញ្ជាពីម្ចាស់សិទ្ធិនោះ កាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ បញ្ញត្តិនៃមាត្រា ៨២២ (សិទ្ធិទទួលការសងពីផលដោយមានអាទិភាព) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះផលដែលកើតឡើងពីវត្ថុដែលជាកម្មវត្ថុនោះ ។

**មាត្រា ៨៩៣.–** ឧបាទេសកម្មលើវត្ថុ

១-ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចអនុវត្តសិទ្ធិរបស់ខ្លួនបាន ចំពោះទឹកប្រាក់ ឬ វត្ថុផ្សេង ដែលអ្នកបង្កើតត្រូវទទួល ដោយការលក់ ការបាត់បង់ ឬ ការខូចខាតនូវវត្ថុដែលជាកម្មវត្ថុ ។ ប៉ុន្តែ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ពុំអាចអនុវត្តសិទ្ធិរបស់ខ្លួនបានឡើយ នៅក្រោយពេលដែលប្រាក់ត្រូវបានបង់ ឬ វត្ថុផ្សេងត្រូវបានប្រគល់ទៅឱ្យអ្នកបង្កើត ។

២-ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ បើវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ជាចលនវត្ថុដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៨៨៨ (និយមន័យនៃប្រាតិភោគដោយអនុប្បទាន) នៃក្រមនេះ ហើយបើអ្នកបង្កើតមានគម្រោងនឹងលក់វត្ថុដែលជាកម្មវត្ថុនេះទៅជនដទៃ សិទ្ធិប្រាតិភោគដោយអនុប្បទានពុំអាចអនុវត្តចំពោះទឹកប្រាក់ដែលបានមកពីការលក់នោះឡើយ ។

**មាត្រា ៨៩៤.–** ការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយអ្នកបង្កើត

១-បើអ្នកបង្កើតដែលបន្តការកាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន នៅក្រោយពេលបង្កើតសិទ្ធិនោះ បានធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនោះទៅតតិយជន ឬ បានបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សលើវត្ថុនោះដើម្បីតតិយជន ប្រសិនបើតតិយជននោះបំពេញគ្រប់ល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងមាត្រា ១៩៣ (លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមនេះ តតិយជននោះអាចយកសិទ្ធិរបស់ខ្លួន ទៅតតាំងចំពោះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានបាន ។

# ជំពូកទី ៤
# សិទ្ធិលើការបញ្ចាំ

## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ៨១៦.-** អត្ថន័យនៃសិទ្ធិលើការបញ្ចាំ

ម្ចាស់សិទ្ធិលើការបញ្ចាំ មានសិទ្ធិកាន់កាប់វត្ថុដែលបានទទួលពីកូនបំណុល ឬ តតិយជនដើម្បីធានាសិទ្ធិលើបំណុលរបស់ខ្លួន និង ទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនពីវត្ថុនោះ ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត ។

**មាត្រា ៨១៧.-** ឧបាទេសកម្មលើវត្ថុ

១-សិទ្ធិលើការបញ្ចាំអាចអនុវត្តបានចំពោះទឹកប្រាក់ ឬ វត្ថុផ្សេងទៀតដែលអ្នកបង្កើតត្រូវទទួល ដោយការលក់ ការបាត់បង់ ឬ ការខូចខាតនូវវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ។ ប៉ុន្តែ ម្ចាស់សិទ្ធិលើការបញ្ចាំពុំអាចអនុវត្តសិទ្ធិរបស់ខ្លួនបានឡើយ នៅក្រោយពេលដែលទឹកប្រាក់ត្រូវបានបង់ ឬ វត្ថុផ្សេងត្រូវបានប្រគល់ ទៅឱ្យអ្នកបង្កើត ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះតម្លៃថ្នូរនឹងសិទ្ធិប្រត្យក្សដែលបង្កើតឡើង ដោយអ្នកបង្កើតសិទ្ធិលើការបញ្ចាំ លើវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ ។

**មាត្រា ៨១៨.-** ការបង្កើតសិទ្ធិលើការបញ្ចាំ និង ការប្រគល់វត្ថុជាចាំបាច់

១-សិទ្ធិលើការបញ្ចាំត្រូវកើតឡើង ដោយកូនបំណុល ឬ តតិយជនដែលបង្កើតសិទ្ធិលើការបញ្ចាំនោះ ប្រគល់នូវវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ ។

២-ការប្រគល់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវរាប់បញ្ចូលទាំងការប្រគល់ដោយសង្ខេប ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ នៃមាត្រា ២២៩

(ការផ្ទេរការកាន់កាប់) នៃក្រមនេះ ។

**មាត្រា ៨១៩.–** ការហាមការកាន់កាប់ដោយផ្ទាល់ ដោយអ្នកបង្កើតសិទ្ធិលើការបញ្ចាំ

ម្ចាស់សិទ្ធិលើការបញ្ចាំមិនអាចឱ្យអ្នកបង្កើតសិទ្ធិលើការបញ្ចាំនោះកាន់កាប់ដោយផ្ទាល់លើវត្ថុបញ្ចាំនោះបានឡើយ ។

**មាត្រា ៨២០.–** ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា

សិទ្ធិលើការបញ្ចាំត្រូវធានានូវ ប្រាក់ដើម ការប្រាក់ ប្រាក់ធានាសងក្នុងករណីមិនគោរពកិច្ចសន្យា សោហ៊ុយដើម្បីអនុវត្តសិទ្ធិលើការបញ្ចាំ សោហ៊ុយដើម្បីថែរក្សាវត្ថុបញ្ចាំ ព្រមទាំងសំណងនៃការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ឬ វិការៈកំបាំងនៃវត្ថុបញ្ចាំ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានកំណត់ផ្សេង ក្នុងសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំនោះ ។

**មាត្រា ៨២១.–** អានុភាពនៃការឃាត់ទុក

ម្ចាស់សិទ្ធិលើការបញ្ចាំអាចឃាត់ទុកវត្ថុបញ្ចាំបាន រហូតដល់ពេលដែលទទួលការសងចំពោះសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងមាត្រា ៨២០ (ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា) ខាងលើនេះ ។ ប៉ុន្តែ សិទ្ធិនេះមិនអាចតតាំង ចំពោះម្ចាស់បំណុលដែលមានអាទិភាពជាងខ្លួនបានឡើយ ។

**មាត្រា ៨២២.–** សិទ្ធិទទួលការសងពីផលដោយមានអាទិភាព

១-ម្ចាស់សិទ្ធិលើការបញ្ចាំអាចទទួលផលដែលកើតពីវត្ថុបញ្ចាំ និង អាចយកផលនោះមកកាត់សិទ្ធិលើបំណុលរបស់ខ្លួន ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតបាន ។

២-ផលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកកាត់ការប្រាក់នៃសិទ្ធិលើបំណុលជាមុនសិន ហើយ ប្រសិនបើមានសំណល់ ត្រូវយកទៅកាត់ប្រាក់ដើម ។

**មាត្រា ៨២៣.–** ករណីយកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ចាំក្នុងការរក្សាទុកនូវវត្ថុបញ្ចាំ

១-ម្ចាស់សិទ្ធិលើការបញ្ចាំ ត្រូវកាន់កាប់វត្ថុបញ្ចាំនោះដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

២-ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំ បានធ្វើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ កូនបំណុលអាចទាមទាររំលត់សិទ្ធិលើការបញ្ចាំនោះបាន ។

**មាត្រា ៨២៤.–** សិទ្ធិទាមទារឱ្យសងសោហ៊ុយរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ

១-ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំ បានចេញចំណាយជាចាំបាច់សម្រាប់ការគ្រប់គ្រង និង ថែរក្សាវត្ថុ ចំពោះវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនោះ អាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះសងនូវចំណាយនោះវិញបាន ។

២-ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំ បានចេញចំណាយបង្កើនតម្លៃនៃវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនោះអាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះសងនូវចំណាយទាំងអស់ដែលខ្លួនបានចេញ ឬ សងនូវតម្លៃប្រាក់ដែលកើននោះវិញ តាមការជ្រើសរើសរបស់ខ្លួនបាន ក្នុងករណីដែលកំណើនតម្លៃនោះនៅតែមាន ។ ប៉ុន្តែ តុលាការអាចកំណត់ពេលសមរម្យដើម្បីសង តាមការទាមទាររបស់កម្មសិទ្ធិករបាន ។

**មាត្រា ៨២៥.–** អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ការប្រើសិទ្ធិលើការបញ្ចាំ មិនរារាំងដំណើរការនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលឡើយ ។

**មាត្រា ៨២៦.–** ការបញ្ចាំបន្ត

១-ម្ចាស់សិទ្ធិលើការបញ្ចាំអាចយកវត្ថុបញ្ចាំនោះទៅដាក់បញ្ចាំបន្តទៀតបាន ដោយទទួលការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំនោះ ដើម្បីធានានូវកាតព្វកិច្ចរបស់ខ្លួន ។

២-ក្នុងអំឡុងពេលដែលមានអត្ថិភាពនៃសិទ្ធិលើការបញ្ចាំ ម្ចាស់សិទ្ធិនោះអាចយកវត្ថុបញ្ចាំនោះទៅដាក់បញ្ចាំបន្តទៀត ក្រោមការទទួលខុសត្រូវរបស់ខ្លួនបាន ។ ក្នុងករណី

នេះ ម្ចាស់សិទ្ធិលើការបញ្ចាំនោះក៏ត្រូវទទួលខុសត្រូវ ចំពោះការខូចខាតដោយប្រធានសក្តិ ដែលមិនអាចកើតមានឡើងប្រសិនបើមិនបានដាក់បញ្ចាំបន្តទេ ។

៣-នៅពេលចែកចំណែកថ្លៃលក់ដោយបង្ខំនៃវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំបន្ត អាចទទួលនូវការសងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនទាំងអស់ ដោយមានកម្រិត នៃចំនួនទឹកប្រាក់ដែលត្រូវចែកចំណែកទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ ។ ប៉ុន្តែ ប្រសិនបើ សិទ្ធិលើបំណុលរបស់ខ្លួន មិនទាន់ដល់ពេលកំណត់ត្រូវសងទេ ម្ចាស់សិទ្ធិលើការបញ្ចាំបន្ត គ្រាន់តែអាចទាមទារឱ្យតម្កល់នូវចំនួនទឹកប្រាក់ដែលខ្លួនអាចទទួលការសងបានប៉ុណ្ណោះ ។

**មាត្រា ៨២៧.-** ការហាមកិច្ចសន្យាបញ្ចាំផ្តាច់

បើពុំមានបញ្ញត្តិពិសេសនៅក្នុងក្រមនេះ ឬ ច្បាប់ផ្សេងទៀតទេ អ្នកដែលបង្កើត សិទ្ធិលើការបញ្ចាំ មិនអាចព្រមព្រៀង ឱ្យម្ចាស់សិទ្ធិលើការបញ្ចាំទទួលកម្មសិទ្ធិលើវត្ថុបញ្ចាំ ឬ ចាត់ចែងវត្ថុបញ្ចាំ តាមវិធីផ្សេងពីវិធីដែលច្បាប់បានកំណត់ ដោយសកម្មភាពបង្កើត សិទ្ធិលើការបញ្ចាំ ឬ ដោយកិច្ចសន្យាដែលធ្វើមុនកំណត់ពេលត្រូវសងបានទេ ។

**មាត្រា ៨២៨.-** សិទ្ធិទាមទារសំណងរបស់អ្នកធានាដោយវត្ថុ

ប្រសិនបើអ្នកដែលបង្កើតសិទ្ធិលើការបញ្ចាំដើម្បីធានាកាតព្វកិច្ចរបស់អ្នកដទៃ បានសងចំពោះកាតព្វកិច្ចនោះ ឬ បានបាត់បង់នូវកម្មសិទ្ធិលើវត្ថុបញ្ចាំ ដោយសារការ អនុវត្តសិទ្ធិលើការបញ្ចាំនោះ អ្នកនោះត្រូវមានសិទ្ធិទាមទារសំណង ចំពោះកូនបំណុល ដោយយោងទៅតាមបញ្ញត្តិស្តីពីការធានា ។

## ផ្នែកទី ២
## ការបញ្ចាំចលនវត្ថុ

**មាត្រា ៨២៩.-** ល័ក្ខខ័ណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំ

ម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុ មិនអាចតតាំងសិទ្ធិលើការបញ្ចាំនោះចំពោះតតិយ-

ជនបានឡើយ ប្រសិនបើខ្លួនមិនបានកាន់កាប់ជានិរន្តរ៍នូវវត្ថុបញ្ចាំនោះ ។

**មាត្រា ៨៣០.–** ករណីដែលការកាន់កាប់ត្រូវបានដកយក

ក្នុងករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុត្រូវបានដកយកនូវការកាន់កាប់វត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនោះ អាចយកវត្ថុបញ្ចាំមកវិញបាន តាមរយៈបណ្ដឹងទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ តែប៉ុណ្ណោះ ។

**មាត្រា ៨៣១.–** ការប្រើប្រាស់ និង អាស្រ័យផលពីវត្ថុបញ្ចាំ ដោយម្ចាស់សិទ្ធិលើការបញ្ចាំ

១-បើពុំមានការយល់ព្រមពីសំណាក់កូនបំណុលទេ ម្ចាស់សិទ្ធិលើការបញ្ចាំ មិនអាចប្រើប្រាស់ ឬ ជួលវត្ថុបញ្ចាំបានឡើយ ។ ប៉ុន្តែ ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើប្រាស់បាន ត្រឹមតែកម្រិតដែលចាំបាច់ក្នុងការរក្សាវត្ថុបញ្ចាំនោះ ។

២-បើម្ចាស់សិទ្ធិលើការបញ្ចាំបានប្រព្រឹត្តផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ កូនបំណុលអាចទាមទារឱ្យរំលត់សិទ្ធិលើការបញ្ចាំបាន ។

**មាត្រា ៨៣២.–** ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប

១-ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុមិនបានទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនទេ ម្ចាស់សិទ្ធិនោះអាចទាមទារទៅតុលាការឱ្យយកវត្ថុបញ្ចាំមកសងផ្ទាល់តែម្ដង តាមការវាយតម្លៃរបស់អ្នកវាយតម្លៃបាន លុះត្រាតែមានមូលហេតុត្រឹមត្រូវ ។ ក្នុងករណីនេះ ម្ចាស់សិទ្ធិលើការបញ្ចាំត្រូវជូនដំណឹងអំពីការទាមទារនោះទៅកូនបំណុលជាមុន ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើចំនួនទឹកប្រាក់ដែលវាយតម្លៃដោយអ្នកវាយតម្លៃនោះ លើសពីចំនួននៃកាតព្វកិច្ចដែលត្រូវសងម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុ ត្រូវសងនូវចំនួនទឹកប្រាក់ដែលនៅសល់ ទៅកម្មសិទ្ធិករនៃវត្ថុបញ្ចាំនោះវិញ ។

**មាត្រា ៨៣៣.–** លំដាប់នៃសិទ្ធិលើការបញ្ចាំចលនវត្ថុ

ក្នុងករណីដែលបានបង្កើតសិទ្ធិលើការបញ្ចាំលើចលនវត្ថុតែមួយ ដើម្បីធានាសិទ្ធិលើបំណុលច្រើន លំដាប់នៃសិទ្ធិលើការបញ្ចាំទាំងនោះត្រូវអនុលោមតាមពេលវេលាដែលបានបង្កើតនោះ ។

## ផ្នែកទី ៣
## ការបញ្ចាំអចលនវត្ថុ

**មាត្រា ៨៣៤.–** សិទ្ធិប្រើប្រាស់ និង អាស្រ័យផលរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ

១-ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុអាចប្រើប្រាស់ និង អាស្រ័យផលពីអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ តាមវិធីប្រើប្រាស់នៃអចលនវត្ថុនោះ ។

២-ចំពោះដីដែលសិទ្ធិលើការបញ្ចាំបានបង្កើតដើម្បីធានាសិទ្ធិលើបំណុលដែលគ្មានពេលកំណត់ ក្នុងករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំប្រើដីនោះដើម្បីធ្វើកសិកម្ម ទោះបីជាសិទ្ធិលើបំណុលរលត់ដោយការសងក៏ដោយ បើរដូវប្រមូលផលពីដំណាំដែលម្ចាស់សិទ្ធិបំណុលបានសាប ឬ ដាំពីមុន នឹងដល់ នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក៏ម្ចាស់សិទ្ធិលើការបញ្ចាំ អាចប្រើដីនោះ រហូតដល់ពេលដល់រដូវប្រមូលផលនោះ ។

៣-ចំពោះដីដែលសិទ្ធិលើការបញ្ចាំបានបង្កើតដើម្បីធានាសិទ្ធិលើបំណុលដែលមានពេលកំណត់ ក្នុងករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំប្រើដីនោះដើម្បីធ្វើកសិកម្ម ទោះបីជាសិទ្ធិលើបំណុលរលត់ដោយការសងនៅមុនពេលកំណត់ក៏ដោយ បើរដូវប្រមូលផលពីដំណាំដែលម្ចាស់សិទ្ធិបំណុលបានសាប ឬ ដាំពីមុន នឹងដល់ នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក៏ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើដីនោះ រហូតដល់ពេលដល់រដូវប្រមូលផលនោះ ។ ប៉ុន្តែ ទោះបីជារដូវប្រមូលផលនោះ នឹងដល់ នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំក្រោយការសងនៅមុនពេលកំណត់ក៏ដោយ បើរដូវប្រមូលផលនោះ នឹងដល់ ក្រោយពេលកំណត់នៃការសងកាតព្វកិច្ច ម្ចាស់សិទ្ធិលើការបញ្ចាំ ត្រូវប្រគល់ដីវិញភ្លាម ក្រោយពេលទទួលការសង ។

**មាត្រា ៨៣៥.-** បន្ទុកសោហ៊ុយគ្រប់គ្រង

ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុត្រូវចេញសោហ៊ុយគ្រប់គ្រង និង ត្រូវទទួលបន្ទុកផ្សេងៗចំពោះអចលនវត្ថុនោះ ។

**មាត្រា ៨៣៦.-** ការប្រាក់នៃសិទ្ធិលើបំណុល

ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ មិនអាចទាមទារការប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនបានទេ ។

**មាត្រា ៨៣៧.-** អានុភាពនៃការសន្យាពិសេស

បញ្ញត្តិនៃមាត្រា ៨៣៤ (សិទ្ធិប្រើប្រាស់ និង អាស្រ័យផលរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ) មាត្រា ៨៣៥ (បន្ទុកសោហ៊ុយគ្រប់គ្រង) និង មាត្រា ៨៣៦ (ការប្រាក់នៃសិទ្ធិលើបំណុល) ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានការសន្យាពិសេសនៅក្នុងសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំ ។

**មាត្រា ៨៣៨.-** អំឡុងពេលដែលមានអត្ថិភាព

១-អំឡុងពេលដែលមានអត្ថិភាពនៃសិទ្ធិលើការបញ្ចាំអចលនវត្ថុ មិនអាចលើសពី ៥ (ប្រាំ) ឆ្នាំបានឡើយ ។ ប្រសិនបើបានបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុលើសពីអំឡុងពេលនេះ អំឡុងពេលត្រូវបន្ថយមកត្រឹម ៥ (ប្រាំ) ឆ្នាំ ។

២-កិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុអាចធ្វើបន្តទៀតបាន ។ ប៉ុន្តែអំឡុងពេលនៃការបន្តនេះមិនអាចធ្វើឱ្យលើសពី ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលបន្តបានឡើយ ។

**មាត្រា ៨៣៩.-** ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីហ៊ីប៉ូតែក

ក្រៅពីបញ្ញត្តិនៃផ្នែកទី ៣ (ការបញ្ចាំអចលនវត្ថុ) នេះ បញ្ញត្តិនៃជំពូកទី ៥ (ហ៊ីប៉ូតែក) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការបញ្ចាំអចលនវត្ថុ ។

## ផ្នែកទី ៤
## ការបញ្ចាំសិទ្ធិ

**មាត្រា ៨៤០.–** កម្មវត្ថុនៃការបញ្ចាំសិទ្ធិ

១-សិទ្ធិលើការបញ្ចាំអាចមានកម្មវត្ថុជាសិទ្ធិលើទ្រព្យសម្បត្តិបាន ។

២-ក្រៅពីបញ្ញត្តិនៃផ្នែកទី ៤ (ការបញ្ចាំសិទ្ធិ) នេះ បញ្ញត្តិនៃផ្នែកទី ២ (ការបញ្ចាំចលនវត្ថុ) និង ផ្នែកទី ៣ (ការបញ្ចាំអចលនវត្ថុ) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសិទ្ធិលើការបញ្ចាំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៨៤១.–** ល័ក្ខខ័ណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ

១-ក្នុងករណីដែលយកសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ មកធ្វើជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ សិទ្ធិលើការបញ្ចាំនេះ មិនអាចតតាំងចំពោះកូនបំណុលទី ៣ និងតតិយជនផ្សេងទៀតបានឡើយ លើកលែងតែករណីដែលបានជូនដំណឹងអំពីការបង្កើតសិទ្ធិលើការបញ្ចាំដល់កូនបំណុលទី ៣ ឬ មានការយល់ព្រមពីកូនបំណុលទី ៣ នោះ ។

២-ការជូនដំណឹង ឬ ការយល់ព្រមដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចតតាំងចំពោះតតិយជន ក្រៅពីកូនបំណុលទី ៣ បានឡើយ ប្រសិនបើមិនបានធ្វើឡើងដោយលិខិតដែលមានកាលបរិច្ឆេទស្ថាពរ ។

**មាត្រា ៨៤២.–** ការអនុវត្តសិទ្ធិលើការបញ្ចាំដោយប្រមូលសិទ្ធិលើបំណុល

១-ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រមូលសិទ្ធិលើបំណុលដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំបាន ។

២-ប្រសិនបើកម្មវត្ថុនៃសិទ្ធិលើបំណុលជាប្រាក់ ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រមូលសិទ្ធិលើបំណុល ត្រឹមតែភាគដែលស្មើនឹងចំនួនប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនប៉ុណ្ណោះ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បើកំណត់ពេល

ត្រូវសងនៃសិទ្ធិលើបំណុលបានមកដល់ មុនកំណត់ពេលត្រូវសងនៃសិទ្ធិលើបំណុលរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនេះ អាចឱ្យកូនបំណុលទី ៣ តម្កល់ប្រាក់សងនេះបាន ។ ក្នុងករណីនេះ សិទ្ធិលើការបញ្ចាំមានអត្ថិភាពលើប្រាក់តម្កល់នោះ ។

៤-ប្រសិនបើកម្មវត្ថុនៃសិទ្ធិលើបំណុលមិនមែនជាប្រាក់ទេ ម្ចាស់សិទ្ធិលើការបញ្ចាំមានសិទ្ធិលើការបញ្ចាំលើវត្ថុដែលខ្លួនបានទទួលជាការសង ។

# ជំពូកទី ៥
# ហ៊ីប៉ូតែក

## ផ្នែកទី ១
## អត្ថន័យនៃហ៊ីប៉ូតែក

**មាត្រា ៨៤៣.-** អត្ថន័យនៃហ៊ីប៉ូតែក

១-ម្ចាស់បំណុលហ៊ីប៉ូតែកមានសិទ្ធិទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួន ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត ចំពោះអចលនវត្ថុដែលបានដាក់ជាប្រាតិភោគនៃកាតព្វកិច្ច ដោយកូនបំណុល ឬ តតិយជនមិនផ្ទេរការកាន់កាប់ ។

២-សិទ្ធិជួលអចិន្ត្រៃយ៍ និង ផលុបភោគ ក៏អាចយកមកធ្វើជាកម្មវត្ថុនៃហ៊ីប៉ូតែកបានដែរ ។ ក្នុងករណីនេះ បញ្ញត្តិនៃជំពូកទី ៥ (ហ៊ីប៉ូតែក) នេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

៣-ក្នុងករណីដែលច្បាប់ពិសេសទទួលស្គាល់ការយកទ្រព្យសម្បត្តិផ្សេងក្រៅពីអចលនវត្ថុ មកធ្វើជាកម្មវត្ថុនៃហ៊ីប៉ូតែក បញ្ញត្តិនៃច្បាប់ពិសេសនោះត្រូវយកមកអនុវត្ត ។

## ផ្នែកទី ២
## ការបង្កើតហ៊ីប៉ូតែក

**មាត្រា ៨៤៤.-** ការបង្កើតហ៊ីប៉ូតែក

ហ៊ីប៉ូតែកនឹងត្រូវបានបង្កើតឡើង ដោយការព្រមព្រៀងគ្នារវាងម្ចាស់បំណុល និង

ការទាមទារឱ្យរំលត់ ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបានឡើយ ។

៤-តតិយជនដែលបានធ្វើលទ្ធកម្មនូវកម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀត ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ដោយភ្ជាប់នឹងល័ក្ខខ័ណ្ឌបង្អង់ មិនអាចធ្វើការទាមទារឱ្យរំលត់ ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនេះបានឡើយ នៅក្នុងពេលដែលពុំដឹងថាល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញ ឬ មិនទាន់បានបំពេញ ។

## ជំពូកទី ៦

## ប្រាតិភោគដោយអនុប្បទាន

### ផ្នែកទី ១

### និយមន័យនៃប្រាតិភោគដោយអនុប្បទាន

**មាត្រា ៨៨៨.–** និយមន័យនៃប្រាតិភោគដោយអនុប្បទាន

១-ប្រាតិភោគដោយអនុប្បទាន សំដៅទៅលើករណីដែលកូនបំណុល ឬ តតិយជនធ្វើអនុប្បទាននូវចលនវត្ថុរបស់ខ្លួនជាកំណត់ ទៅឱ្យម្ចាស់បំណុល ដើម្បីធានាកាតព្វកិច្ច ។ ក្នុងករណីនេះ បើកាតព្វកិច្ចត្រូវបានសងរួចហើយ កម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុ ត្រូវផ្ទេរទៅអ្នកបង្កើត ។

២-ចលនវត្ថុច្រើន ដែលត្រូវបានកំណត់ទំហំតាមមាត្រដ្ឋាន ដូចជាប្រភេទ ឬកន្លែងស្ថិតនៅនៃចលនវត្ថុ អាចយកមកធ្វើជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ដោយចាត់ទុកជាចលនវត្ថុផ្តុំគ្នាតែមួយបាន ទោះបីជាចលនវត្ថុនីមួយៗដែលផ្តុំគ្នានោះ មានការប្រែប្រួលក៏ដោយ ។

### ផ្នែកទី ២

### ការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន

**មាត្រា ៨៨៩.–** ការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន

សិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវបានបង្កើតឡើង ដោយការព្រមព្រៀងរវាង

ម្ចាស់បំណុល និង កូនបំណុល ឬ តតិយជន ដែលផ្តល់ចលនវត្ថុសម្រាប់ប្រាតិភោគដោយអនុប្បទាន ។

**មាត្រា ៨៩០.-** អានុភាពតតាំងនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ពុំអាចតតាំងសិទ្ធិប្រាតិភោគដោយអនុប្បទាននោះ ចំពោះតតិយជនក្រៅពីអ្នកបង្កើតបានឡើយ បើមិនបានទទួលការផ្ទេរការកាន់កាប់វត្ថុដែលជាកម្មវត្ថុ ដោយយោងតាមបញ្ញត្តិនៃមាត្រា ២២៩ (ការផ្ទេរការកាន់កាប់) នៃក្រមនេះទេ ។

## ផ្នែកទី ៣
## អានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

**មាត្រា ៨៩១.-** ទំហំដែលមានអានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

១-សិទ្ធិប្រាតិភោគដោយអនុប្បទាន មានអានុភាពលើវត្ថុដែលភ្ជាប់នឹងវត្ថុដែលជាកម្មវត្ថុ និង ជាផ្នែកមួយនៃវត្ថុដែលជាកម្មវត្ថុនោះ នៅពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ។ អានុភាពនេះក៏មានលើវត្ថុដែលត្រូវបានភ្ជាប់នៅក្រោយពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានផងដែរ ។

២-ភាគីអាចកំណត់ផ្សេងពីបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះបាន នៅក្នុងកិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ។

**មាត្រា ៨៩២.-** អានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទានចំពោះផល

១-ក្នុងករណីដែលអ្នកបង្កើត ឬ តតិយជនដែលបានទទួលការបញ្ជាពីអ្នកបង្កើតនោះ កាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ បញ្ញត្តិនៃមាត្រា ៨៩១ (ទំហំដែលមានអានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន) ខាងលើនេះ មិនត្រូវយកមកអនុវត្តចំពោះផលឡើយ ។ ប៉ុន្តែ បញ្ញត្តិនៃវាក្យខណ្ឌទី ១ នេះមិនត្រូវយកមកអនុវត្តឡើយ នៅក្រោយពេលដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន បានទាមទារឱ្យប្រគល់វត្ថុដែលជាកម្មវត្ថុ

ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៨៩៨ (ការចាត់ចែងប្ដូរជាប្រាក់ ឬ អនុប្បទានជាស្ថាពរ) នៃក្រមនេះ ។

២-ក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬ តតិយជនដែលបានទទួលការបញ្ជាពីម្ចាស់សិទ្ធិនោះ កាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ បញ្ញត្តិនៃមាត្រា ៨២២ (សិទ្ធិទទួលការសងពីផលដោយមានអាទិភាព) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះផលដែលកើតឡើងពីវត្ថុដែលជាកម្មវត្ថុនោះ ។

**មាត្រា ៨៩៣.-** ឧបាទេសកម្មលើវត្ថុ

១-ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចអនុវត្តសិទ្ធិរបស់ខ្លួនបាន ចំពោះទឹកប្រាក់ ឬ វត្ថុផ្សេង ដែលអ្នកបង្កើតត្រូវទទួល ដោយការលក់ ការបាត់បង់ ឬ ការខូចខាតនូវវត្ថុដែលជាកម្មវត្ថុ ។ ប៉ុន្តែ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ពុំអាចអនុវត្តសិទ្ធិរបស់ខ្លួនបានឡើយ នៅក្រោយពេលដែលប្រាក់ត្រូវបានបង់ ឬ វត្ថុផ្សេងត្រូវបានប្រគល់ទៅឱ្យអ្នកបង្កើត ។

២-ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ បើវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ជាចលនវត្ថុដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៨៨៨ (និយមន័យនៃប្រាតិភោគដោយអនុប្បទាន) នៃក្រមនេះ ហើយបើអ្នកបង្កើតមានគម្រោងនឹងលក់វត្ថុដែលជាកម្មវត្ថុនេះទៅជនដទៃ សិទ្ធិប្រាតិភោគដោយអនុប្បទានពុំអាចអនុវត្តចំពោះទឹកប្រាក់ដែលបានមកពីការលក់នោះឡើយ ។

**មាត្រា ៨៩៤.-** ការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយអ្នកបង្កើត

១-បើអ្នកបង្កើតដែលបន្តការកាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន នៅក្រោយពេលបង្កើតសិទ្ធិនោះ បានធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនោះទៅតតិយជន ឬ បានបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សលើវត្ថុនោះដើម្បីតតិយជន ប្រសិនបើតតិយជននោះបំពេញគ្រប់ល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងមាត្រា ១៩៣ (លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមនេះ តតិយជននោះអាចយកសិទ្ធិរបស់ខ្លួន ទៅតតាំងចំពោះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានបាន ។

២-ចំពោះចលនវត្ថុដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៨៤៣ (និយមន័យនៃប្រាតិភោគដោយអនុប្បទាន) នៃក្រមនេះ ហើយដែលអ្នកបង្កើតមានគម្រោងនឹងលក់នៅពេលនៃ ក្នុងករណីដែលអ្នកបង្កើតដែលបន្តការកាន់កាប់ដោយចំពោះនូវវត្ថុដែលដាក់ធានា នៅក្រោយពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន បានលក់វត្ថុដែលដាក់ធានានោះទៅតតិយជន ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ពុំអាចយកសិទ្ធិប្រាតិភោគដោយអនុប្បទាននោះ ទៅតតាំងចំពោះតតិយជននោះ បានឡើយ នោះបើតតិយជននោះ បំពេញ ឬ មិនបំពេញគ្រប់លក្ខខណ្ឌដែលបានកំណត់នៅក្នុងមាត្រា ១៩៣ (លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមនេះ ក៏ដោយ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកដទៃដែលទទួលការបញ្ជាពីអ្នកបង្កើត បន្តការកាន់កាប់ដោយចំពោះ នូវវត្ថុដែលដាក់ធានានៃសិទ្ធិប្រាតិភោគដោយអនុប្បទាន នៅក្រោយពេលបង្កើតសិទ្ធិនោះ ហើយអ្នកបង្កើតបានផ្ទេរអនុប្បទាននូវវត្ថុដែលដាក់ធានានោះទៅតតិយជន ឬបានបង្កើតសិទ្ធិប្រាតិភោគប្រហាក់ប្រហែលលើវត្ថុនោះដើម្បីតតិយជន ។

**មាត្រា ៨៥៥.–** ទំហំនៃសិទ្ធិលើបិណ្ឌផលដែលត្រូវបានធានា

សិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវធានានូវប្រាក់ដើម ការប្រាក់ ប្រាក់ពិន័យ ព្រមទាំងក្នុងករណីមិនគោរពកិច្ចសន្យា សោហ៊ុយដើម្បីអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន សោហ៊ុយដើម្បីថែរក្សាវត្ថុដែលដាក់ធានា ព្រមទាំងសំណងនៃការខូចខាតដែលកើតឡើងដោយហេតុការមិនអនុវត្តកាតព្វកិច្ច ឬវិការៈកំបាំងនៃវត្ថុដែលដាក់ធានា ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានកំណត់ផ្សេង ក្នុងសកម្មភាពបង្កើតនោះ ។

**មាត្រា ៨៥៦.–** បញ្ញត្តិពិសេសក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានកាន់កាប់វត្ថុដែលដាក់ធានា

បញ្ញត្តិនៃមាត្រា ៨២១ (អានុភាពនៃការឃាត់ទុក) មាត្រា ៨២៣ (ករណីយកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ចាំក្នុងការរក្សាទុកនូវវត្ថុបញ្ចាំ) និង មាត្រា ៨២៤ (សិទ្ធិទាមទារឱ្យសង

សោហ៊ុយរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬ តតិយជនដែលបានទទួលការបញ្ជាក់ពីម្ចាស់សិទ្ធិនោះ កាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុ ។

**មាត្រា ៨៤៧.–** ការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន

១-បើម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានដែលកាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុ បានធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនោះទៅតតិយជន ឬ បានបង្កើតសិទ្ធិប្រាតិភោគប្រយោលលើវត្ថុនោះដើម្បីតតិយជន ប្រសិនបើតតិយជននោះ បំពេញគ្រប់ល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងមាត្រា ១៩៣ (លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមនេះ តតិយជននោះអាចយកសិទ្ធិរបស់ខ្លួន ទៅតតាំងចំពោះអ្នកបង្កើតបាន ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកដទៃដែលទទួលការបញ្ជាក់ពីម្ចាស់សិទ្ធិប្រាតិភោគ កាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុ ហើយម្ចាស់សិទ្ធិនោះបានធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនោះទៅតតិយជន ឬ បានបង្កើតសិទ្ធិប្រាតិភោគប្រយោលលើវត្ថុនោះដើម្បីតតិយជន ។

## ផ្នែកទី ៤
## ការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន

**មាត្រា ៨៤៨.–** ការចាត់ចែងបម្លែងជាប្រាក់ ឬ អនុប្បទានជាស្ថាពរ

១-បើកាតព្វកិច្ចពុំត្រូវបានអនុវត្ត ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចប្តូរវត្ថុដែលជាកម្មវត្ថុនោះជាប្រាក់ ដោយផ្ទាល់ខ្លួន ឬ ធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុជាស្ថាពរបាន ដោយជូនដំណឹងទៅអ្នកបង្កើត ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ឬ តតិយជនដែលបានទទួលការបញ្ជាក់ពីអ្នកបង្កើតនេះ

កាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចទាមទារឲ្យជននោះប្រគល់វត្ថុដែលជាកម្មវត្ថុនោះបាន ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើតម្លៃនៃវត្ថុដែលជាកម្មវត្ថុ មានចំនួនលើសពីចំនួនទឹកប្រាក់នៃការពារកិច្ចដែលត្រូវសង ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានត្រូវបង់ចំនួនទឹកប្រាក់ដែលលើសនោះ ទៅឲ្យអ្នកបង្កើត ដោយចាត់ជាប្រាក់ជម្រះ ។

**មាត្រា ៨៩៩.–** សិទ្ធិទទួលយកមកវិញរបស់អ្នកបង្កើត

ទោះបីជាពេលកំណត់ត្រូវសងការពារកិច្ចបានកន្លងផុតក៏ដោយ ក៏អ្នកបង្កើតអាចទទួលយកមកវិញនូវវត្ថុដែលជាកម្មវត្ថុ ដោយផ្តល់នូវការពារកិច្ចគ្រប់ចំនួន និង បន្ទាប់ពីការផ្តល់នោះទៅម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានបាន នៅមុនពេលមានការផ្តល់ប្រាក់ជម្រះដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ នៃមាត្រា ៨៩៨ ការបង់តំលៃជំនួសប្រាក់ ឬ អនុប្បទានជាសម្ភារៈ ខាងលើនេះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីតម្លៃវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាននោះ មិនលើសពីចំនួនទឹកប្រាក់នៃការពារកិច្ចដែលត្រូវសង ក្រោយពេលដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន បានជូនដំណឹងអំពីចំនួនដែលមិនលើសនោះ ទៅឲ្យអ្នកបង្កើតហើយ ។

## ជំពូកទី ៧
## ការធានា

### ផ្នែកទី ១
### ការបង្កើតកិច្ចសន្យាធានា

**មាត្រា ៩០០.–** ការបង្កើតកិច្ចសន្យាធានា

១-កិច្ចសន្យាធានាត្រូវបង្កើតឡើង ដោយសារបុគ្គលដែលមានបំណងធ្វើជាអ្នកធានា បានសន្យាជាមួយនឹងម្ចាស់បំណុលថា ខ្លួននឹងអនុវត្តការពារកិច្ចមួយផ្នែក ឬ ទាំងមូល

# ឧបសម្ព័ន្ធ ២

## ផ្នែកទី ៣

## សិទ្ធិលើការបញ្ចាំ

### ១. សេចក្ដីផ្ដើម

*ម្ចាស់សិទ្ធិលើការបញ្ចាំ មានសិទ្ធិកាន់កាប់វត្ថុដែលបានទទួលពីកូនបំណុល ឬ តតិយជនដើម្បីធានាសិទ្ធិលើបំណុលរបស់ខ្លួន និង ទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនពីវត្ថុនោះដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត ។*

### ២. ប្រភេទនៃកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ

យោងតាមមាត្រា ៨១៦ ពាក្យវត្ថុត្រូវបានប្រើជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ ប៉ុន្តែមាត្រានេះពុំមានបញ្ជាក់ច្បាស់លាស់ច្រើននោះទេ ។ ដូច្នេះ កម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ គឺចលនវត្ថុ ( មាត្រា ៨២៩) អចលនវត្ថុ ( មាត្រា ៨៣៤) និង សិទ្ធិលើទ្រព្យសម្បត្តិ ( មាត្រា ៨៤០) ។

### ៣. លក្ខណៈទូទៅ

#### ៣.១. លក្ខខណ្ឌ

មាត្រា ៨១៨ កថាខណ្ឌទី ១ ចែងថា *សិទ្ធិលើការបញ្ចាំត្រូវកើតឡើងដោយកូនបំណុល ឬ តតិយជន ដែលបង្កើតសិទ្ធិលើការបញ្ចាំនោះ ប្រគល់នូវវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ ។*

មាត្រានេះមានន័យថា ការបញ្ចាំកើតឡើងដោយការព្រមព្រៀងរបស់ភាគីតែប៉ុណ្ណោះ ដោយមិនទាមទារឱ្យមានទម្រង់ពិសេសណាមួយឡើយ ។ លើសពីនេះទៅទៀត ការប្រគល់វត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ក៏ជាលក្ខខណ្ឌចាំបាច់ ដើម្បីឱ្យការបញ្ចាំមានអានុភាពផងដែរ ព្រោះថាច្បាប់បានហាមឃាត់អ្នកបង្កើតសិទ្ធិលើការបញ្ចាំ កាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំដោយផ្ទាល់ ។

#### ៣.២. ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា

*សិទ្ធិលើការបញ្ចាំត្រូវធានានូវប្រាក់ដើម ការប្រាក់ ប្រាក់ធានាសងក្នុងករណីមិនគោរពកិច្ចសន្យា សោហ៊ុយដើម្បីអនុវត្តសិទ្ធិលើការបញ្ចាំ សោហ៊ុយដើម្បីថែរក្សាវត្ថុបញ្ចាំ ព្រមទាំងសំណងនៃការខូចខាតដែលកើតឡើង ដោយសារការមិនអនុវត្តកាតព្វកិច្ច ឬ វិការៈកំបាំងនៃវត្ថុបញ្ចាំ ។*

#### ៣.៣. អានុភាព

##### ៣.៣.១. សិទ្ធិឃាត់ទុក

ការបញ្ចាំត្រូវធ្វើឡើងដោយការព្រមព្រៀង និង ការប្រគល់វត្ថុបញ្ចាំរបស់អ្នកបង្កើតសិទ្ធិលើការបញ្ចាំ ឬ តតិយជនទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ ។ ហេតុនេះ ម្ចាស់សិទ្ធិលើការបញ្ចាំមានសិទ្ធិកាន់កាប់វត្ថុបញ្ចាំ ។ ម្ចាស់សិទ្ធិ

លើការបញ្ចាំ មានសិទ្ធិឃាត់ទុកវត្ថុតាមរយៈការកាន់កាប់នេះ ហើយកូនបំណុលត្រូវបានបង្ខំតាមផ្លូវចិត្តឱ្យអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដើម្បីទទួលបាននូវវត្ថុបញ្ចាំនោះមកវិញតាមរយៈអានុភាពនេះ ។

**៣.៣.២. ភាពមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតពីវត្ថុបញ្ចាំ និង សិទ្ធិទទួលសំណង ពីផលដោយមានអាទិភាព**

ម្ចាស់សិទ្ធិលើការបញ្ចាំ អាចទទួលផលដែលកើតពីវត្ថុបញ្ចាំ និង អាចយកផលនោះមកកាត់សិទ្ធិលើបំណុលរបស់ខ្លួនដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតបាន ។ ផលដែលបានមកនោះ ត្រូវយកមកកាត់ការប្រាក់នៃសិទ្ធិលើបំណុលជាមុនសិន ហើយបើមានសំណល់ត្រូវយកទៅកាត់ប្រាក់ដើម ។

**៣.៣.៣. ករណីយកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ**

ម្ចាស់សិទ្ធិលើការបញ្ចាំ ត្រូវកាន់កាប់វត្ថុបញ្ចាំនោះដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។ ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំមិនគោរពតាមកាតព្វកិច្ចនេះទេ កូនបំណុលអាចទាមទារឱ្យរំលត់សិទ្ធិលើការបញ្ចាំនោះបាន ។ មានន័យថា កូនបំណុលអាចទាមទារឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ ប្រគល់វត្ថុបញ្ចាំមកវិញបាន ក្នុងករណីបំពានករណីយកិច្ចនេះ ។

**៣.៣.៤. សិទ្ធិទាមទារឱ្យសងសោហ៊ុយរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ**

*ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំ បានចេញចំណាយជាចាំបាច់សម្រាប់ការគ្រប់គ្រង និង ថែរក្សាវត្ថុចំពោះវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនោះ អាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះសងនូវចំណាយនោះវិញបាន* (មាត្រា ៨២៤ កថាខណ្ឌទី ១) ។

*ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំបានចេញចំណាយបង្កើនតម្លៃនៃវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនោះអាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុបញ្ចាំនោះ សងនូវចំណាយទាំងអស់ដែលខ្លួនបានចេញ ឬ សងនូវតម្លៃប្រាក់ដែលកើននោះវិញ តាមជម្រើសរបស់ខ្លួនបាន ក្នុងករណីដែលកំណើនតម្លៃនោះនៅតែមាន ។ ប៉ុន្តែ តុលាការអាចកំណត់ពេលសមរម្យដើម្បីសងតាមការទាមទាររបស់កម្មសិទ្ធិករបាន* (មាត្រា ៨២៤ កថាខណ្ឌទី ២) ។

**៣.៤. អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល**

ការប្រើសិទ្ធិលើការបញ្ចាំ មិនរារាំងដំណើរការនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលឡើយ ។

ការប្រើសិទ្ធិលើការបញ្ចាំ មានន័យខុសគ្នាពីការអនុវត្តសិទ្ធិលើបំណុល ដោយសារការប្រើសិទ្ធិលើការបញ្ចាំមិនរារាំងដំណើរការនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ម្ចាស់សិទ្ធិលើការបញ្ចាំត្រូវចាត់វិធានការផ្សេងទៀតដើម្បីផ្អាកអាជ្ញាយុកាល ។

## ៣.៥. ការបញ្ចាំបន្ត

### ៣.៥.១ ការបញ្ចាំបន្តដោយមានការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំ

*ម្ចាស់សិទ្ធិលើការបញ្ចាំ អាចយកវត្ថុបញ្ចាំនោះ ទៅដាក់បញ្ចាំបន្តទៀតបានដោយទទួលការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំនោះ ដើម្បីធានាទូវកាតព្វកិច្ចរបស់ខ្លួន ។*

### ៣.៥.២. ការបញ្ចាំបន្តក្រោមការទទួលខុសត្រូវរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ

ទោះបីជាគ្មានការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំក៏ដោយ ម្ចាស់សិទ្ធិលើការបញ្ចាំអាចយកវត្ថុបញ្ចាំនោះ ទៅបញ្ចាំបន្តទៀតបាន ទោះបីជាមានករណីប្រធានសក្តិក៏ដោយ ។

**ឧទាហរណ៍ :** ក បានដាក់បញ្ចាំគ្រឿងអលង្ការ (១) នៅនឹង ខ ដើម្បីធានាបំណុលចំនួន ១.០០០ ដុល្លារ ។ ខ បានយកគ្រឿងអលង្ការ (១) ទៅដាក់បញ្ចាំបន្តទៅនឹង គ ដើម្បីធានាបំណុលចំនួន ២.០០០ ដុល្លារ ដោយគ្មានការយល់ព្រមពី ក នោះទេ។

១- ខ មិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួននោះទេ ហើយ គ ក៏បានអនុវត្តសិទ្ធិលើការបញ្ចាំបន្តរបស់ខ្លួន។ តើ គ អាចទទួលបានប្រាក់ចំនួនប៉ុន្មាន? ករណីនេះ គ អាចទទួលបានប្រាក់ចំនួន ១.០០០ ដុល្លារ ដែលជាកម្រិតនៃចំនួនទឹកប្រាក់ដែលត្រូវចែកចំណែកទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ។

២- គ បានធ្វើឱ្យគ្រឿងអលង្ការនោះខូច ដោយសារតែកំហុសរបស់ខ្លួន។ តើ ក អាចទាមទារអ្វីបានពី ខ ប្រសិនបើ ក បានដឹងពីករណីនេះ? ករណីនេះ ខ ត្រូវទទួលខុសត្រូវចំពោះការខូចខាតនេះ ( មាត្រា ៨២៦ កថាខណ្ឌទី ២ ) ។

## ៣.៦. ការហាមកិច្ចសន្យាបញ្ចាំផ្តាច់

ថ្វីត្បិតតែកិច្ចសន្យាបញ្ចាំ ត្រូវបានធ្វើឡើងដោយផ្អែកលើការព្រមព្រៀងរវាងម្ចាស់សិទ្ធិលើការបញ្ចាំ និង អ្នកបង្កើតកិច្ចសន្យាបញ្ចាំតាម "គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន " ក៏ដោយ ក៏ច្បាប់បានកម្រិតនូវសិទ្ធិមួយចំនួនចំពោះភាគីនៃការបញ្ចាំ មិនឱ្យបង្កើតនូវកិច្ចសន្យាបញ្ចាំផ្តាច់ ដែលបានធ្វើមុនកំណត់ពេលត្រូវសងតាមការព្រមព្រៀងរបស់ភាគីទេ បើពុំមានបញ្ញត្តិពិសេសនៅក្នុងក្រមរដ្ឋប្បវេណី ឬ ច្បាប់ផ្សេងទៀត។ មូលហេតុដែលច្បាប់មិនឱ្យបង្កើតកិច្ចសន្យាបញ្ចាំផ្តាច់នៅមុនកំណត់ពេលត្រូវសង គឺក្នុងគោលបំណងដើម្បីការពារដល់អ្នកបង្កើតសិទ្ធិលើការបញ្ចាំ និង ហាមឃាត់ម្ចាស់សិទ្ធិលើការបញ្ចាំមិនឱ្យទទួលបានផលប្រយោជន៍ច្រើនហួសប្រមាណ។ ផ្ទុយមកវិញ បើកិច្ចសន្យា ឬ សកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំដែលនាំឱ្យម្ចាស់សិទ្ធិលើការបញ្ចាំទទួលកម្មសិទ្ធិលើវត្ថុបញ្ចាំ ឬ ចាត់ចែងវត្ថុបញ្ចាំ ធ្វើក្រោយពេលកំណត់សងនៃកិច្ចសន្យាបញ្ចាំ គឺមិនត្រូវបានហាមឃាត់ទេ ( មាត្រា ៨២៧ ) ។

## ៤. ការបញ្ចាំចលនវត្ថុ

### ៤.១. លក្ខខណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំ

កិច្ចសន្យាបញ្ចាំចលនវត្ថុ មិនតម្រូវឱ្យមានការចុះបញ្ជីទេ គឺគ្រាន់តែអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ប្រគល់វត្ថុបញ្ចាំទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ ដើម្បីធ្វើការកាន់កាប់ដោយផ្ទាល់ នោះកិច្ចសន្យាបញ្ចាំនឹងមានអានុភាពហើយ ។ ហេតុដូច្នេះ បើម្ចាស់សិទ្ធិលើការបញ្ចាំបានកាន់កាប់វត្ថុបញ្ចាំជានិរន្តរ៍នៅក្នុងដៃរបស់ខ្លួន ម្ចាស់សិទ្ធិលើការបញ្ចាំនឹងអាចយកសិទ្ធិនេះទៅធ្វើការតតាំងជាមួយនឹងតតិយជនបាន ( មាត្រា ៨២៩ ) ។

យ៉ាងណាមិញ បើម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុបាត់បង់ការកាន់កាប់វត្ថុបញ្ចាំ តាមរយៈការដកហូតរបស់តតិយជន ម្ចាស់សិទ្ធិលើការបញ្ចាំនៅតែអាចតតាំងជាមួយនឹងតតិយជនដែលបានដកហូតនោះ និង អាចយកវត្ថុបញ្ចាំមកវិញតាមរយៈបណ្តឹងទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ ( មាត្រា ៨៣០ ) ។

ដូច្នេះ លក្ខខណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំ គឺការកាន់កាប់វត្ថុបញ្ចាំ ។

### ៤.២. ការប្រើប្រាស់ ឬ ការអាស្រ័យផលពីវត្ថុបញ្ចាំដោយម្ចាស់សិទ្ធិលើការបញ្ចាំ

ជាគោលការណ៍ ម្ចាស់សិទ្ធិលើការបញ្ចាំមិនអាចយកវត្ថុដែលដាក់បញ្ចាំមកប្រើប្រាស់ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួន ឬ ជួលបានទេ ប៉ុន្តែបើមានការអនុញ្ញាត និង យល់ព្រមពីសំណាក់អ្នកបង្កើតសិទ្ធិលើការបញ្ចាំ អាចប្រើប្រាស់ និង ជួលវត្ថុបញ្ចាំនោះបាន ព្រោះយើងត្រូវគោរពនូវឆន្ទៈសេរីរបស់បុគ្គលឯកជន ។ លើសពីនេះទៅទៀត ដើម្បីថែរក្សាវត្ថុបញ្ចាំ និង ជៀសវាងនូវការខូចខាតផ្សេងៗ ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើប្រាស់វត្ថុបញ្ចាំ ត្រឹមកម្រិតចាំបាច់ក្នុងការរក្សាវត្ថុបញ្ចាំនោះ ដោយមិនចាំបាច់មានការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ប៉ុន្តែមិនអាចជួលវត្ថុបញ្ចាំនោះបានទេ ។ បើម្ចាស់សិទ្ធិលើការបញ្ចាំប្រើប្រាស់ ឬ ជួលវត្ថុបញ្ចាំ ដោយគ្មានការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ឬ មិនមានភាពចាំបាច់ក្នុងការរក្សាវត្ថុបញ្ចាំនោះទេ អ្នកបង្កើតសិទ្ធិលើការបញ្ចាំអាចទាមទារឱ្យរំលត់សិទ្ធិលើការបញ្ចាំបាន យោងតាមបញ្ញត្តិនៃមាត្រា ៨៣១ នៃក្រមរដ្ឋប្បវេណី ។

### ៤.៣. ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប

ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេបនេះ គឺសំដៅទៅលើការអនុវត្តសិទ្ធិរបស់ម្ចាស់សិទ្ធិលើការបញ្ចាំក្នុងការទទួលបានវត្ថុបញ្ចាំមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនតាមរយៈតុលាការតែម្តង ដោយមិនចាំបាច់ឆ្លងកាត់នីតិវិធីនៃការអនុវត្តដោយបង្ខំ មានន័យថា នៅពេលដល់កំណត់សងសិទ្ធិលើបំណុលហើយ ម្ចាស់សិទ្ធិលើការបញ្ចាំមិនបានទទួលការសងទេ ម្ចាស់សិទ្ធិលើការបញ្ចាំអាចទាមទារឱ្យតុលាការយកវត្ថុបញ្ចាំនោះមកសងខ្លួនផ្ទាល់តែម្តង ដើម្បីកាត់សិទ្ធិលើបំណុល ( មាត្រា ៨៣២ ) ។

បើយើងមើលទៅ វាហាក់បីដូចជាការបញ្ចាំផ្តាច់ដែលក្រមបានហាមមិនឱ្យធ្វើក្នុងមាត្រា ៨២៧ នៃក្រមរដ្ឋប្បវេណីដែរ ប៉ុន្តែការអនុវត្តសិទ្ធិលើការបញ្ចាំចលនវត្ថុដោយសង្ខេបក្នុងមាត្រា ៨៣២ មិនដូចការហាមការបញ្ចាំផ្តាច់ក្នុងមាត្រា ៨២៧ ទេ ពីព្រោះមាត្រា ៨២៧ ហាមមិនឱ្យភាគីធ្វើកិច្ចសន្យាដែលនាំឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ

ទទួលបាននូវកម្មសិទ្ធិលើវត្ថុបញ្ចាំដោយសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំ ឬ ដោយកិច្ចសន្យាដែលធ្វើនៅមុនពេលកំណត់ត្រូវសង រីឯមាត្រា ៨៣២ វិញ គឺម្ចាស់សិទ្ធិលើការបញ្ចាំទទួលបាននូវកម្មសិទ្ធិលើវត្ថុបញ្ចាំ មិនមែនដោយសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំ ឬ ដោយកិច្ចសន្យាដែលធ្វើមុនពេលកំណត់ត្រូវសងទេ គឺបានតាមរយៈតុលាការ ហើយត្រូវបំពេញលក្ខខណ្ឌយ៉ាងតឹងរ៉ឹងចំនួន ៤ ដូចជា តាមរយៈតុលាការ មានការវាយតម្លៃត្រឹមត្រូវការជូនដំណឹងដល់អ្នកបង្កើតសិទ្ធិលើការបញ្ចាំ (កូនបំណុល) និង មានមូលហេតុត្រឹមត្រូវ។ មូលហេតុដែលតម្រូវឱ្យមានលក្ខខណ្ឌតឹងរ៉ឹងយ៉ាងនេះ គឺដើម្បីការពារប្រយោជន៍របស់អ្នកបង្កើតសិទ្ធិលើការបញ្ចាំ និង អ្នកធានាដោយវត្ថុ។

### ៤.៤. លំដាប់នៃសិទ្ធិលើការបញ្ចាំ

ជាធម្មតា នៅពេលដែលយកចលនវត្ថុមួយទៅដាក់បញ្ចាំដើម្បីធានាសិទ្ធិលើបំណុល ចលនវត្ថុនោះត្រូវផ្ទេរឱ្យម្ចាស់សិទ្ធិលើការបញ្ចាំធ្វើការកាន់កាប់ ហេតុនេះកូនបំណុលមិនទំនងជាអាចយកចលនវត្ថុនោះទៅដាក់បញ្ចាំទៅនឹងម្ចាស់សិទ្ធិលើការបញ្ចាំផ្សេងទៀតបានទេ។ ប៉ុន្តែ មានករណីខ្លះចលនវត្ថុអាចយកទៅដាក់បញ្ចាំ ដើម្បីធានាសិទ្ធិលើបំណុលចំពោះម្ចាស់បំណុលច្រើន ដែលជាហេតុនាំឱ្យយើងត្រូវគិតពិចារណាពីលំដាប់នៃសិទ្ធិលើការបញ្ចាំ។ ជាគោលការណ៍ លំដាប់នៃសិទ្ធិលើការបញ្ចាំចលនវត្ថុតែមួយ ដើម្បីធានាសិទ្ធិលើបំណុលច្រើន លំដាប់នៃសិទ្ធិលើការបញ្ចាំនោះ ត្រូវអនុលោមទៅតាមពេលវេលាដែលបានបង្កើតសិទ្ធិលើការបញ្ចាំ (មាត្រា ៨៣៣)។

**ឧទាហរណ៍ :** ក យកកង់ទៅបញ្ចាំឱ្យ ខ ហើយកង់នោះ ត្រូវបានយកទៅផ្ញើនឹង គ។ ក បានផ្ទេរការកាន់កាប់កង់នោះ ដោយការបញ្ជាទៅឱ្យ គ (មើលមាត្រា ២២៩ កថាខណ្ឌទី ៤) បន្ទាប់មក ក យកកង់នោះទៅបញ្ចាំឱ្យ ឃ ទៀត។ ករណីនេះ លំដាប់នៃសិទ្ធិលើការបញ្ចាំគឺ ខ ស្ថិតក្នុងលំដាប់ទី១ ព្រោះ ខ បានកង់នោះមុន ឃ ។

## ៥. ការបញ្ចាំអចលនវត្ថុ

### ៥.១. សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យផលរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ

ជាគោលការណ៍ ម្ចាស់សិទ្ធិលើការបញ្ចាំ មិនអាចយកវត្ថុបញ្ចាំទៅប្រើប្រាស់ ឬ អាស្រ័យផលដោយគ្មានការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំ (កូនបំណុល) ទេ ដូចជាការប្រើប្រាស់ចលនវត្ថុដាក់បញ្ចាំ គឺត្រូវមានការយល់ព្រមពីកូនបំណុលដែលបានបញ្ញត្តក្នុងមាត្រា ៨៣១។ ប៉ុន្តែមានការប្រែប្រួលមួយយ៉ាងខ្លាំង ដែលអនុញ្ញាតឱ្យម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើប្រាស់ និង អាស្រ័យផល ដោយពុំចាំបាច់មានការយល់ព្រមពីកូនបំណុល ក្នុងករណីដែលកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ គឺជាអចលនវត្ថុ (មាត្រា ៨៣៤ កថាខណ្ឌទី ១)។

**ឧទាហរណ៍ :** ក យកដីស្រែបញ្ចាំឱ្យ ខ។ ខ អាចប្រើប្រាស់ និង អាស្រ័យផលលើដីស្រែនោះ ដោយមិនចាំបាច់មានការយល់ព្រមពី ក ទេ។

ទោះបីជាម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើប្រាស់ និង អាស្រ័យផលលើអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ ដោយមិនចាំបាច់មានការយល់ព្រមពីកូនបំណុលក៏ដោយ ក៏ការប្រើប្រាស់ និង អាស្រ័យផលនោះត្រូវធ្វើ

ឡើងដោយគោរពតាមវិធីនៃការប្រើប្រាស់អចលនវត្ថុនោះ ឬ សិទ្ធិលើបំណុលដែលគ្មានកំណត់ពេល និង មានកំណត់ពេលត្រូវសងទៅតាមបទប្បញ្ញត្តិពិសេសស្តីពីដីសម្រាប់ធ្វើកសិកម្ម ។

### ៥.២. ការគោរពតាមវិធីប្រើប្រាស់ធម្មតា

ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុអាចប្រើប្រាស់ និង អាស្រ័យផលលើអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួនបានទៅតាមវិធីប្រើប្រាស់ធម្មតានៃអចលនវត្ថុនោះ។ វិធីប្រើប្រាស់ធម្មតានៃអចលនវត្ថុ សំដៅលើការប្រើប្រាស់តាមលក្ខណៈដើមនៃអចលនវត្ថុ។ ក្នុងករណីដែលដីប្រើសម្រាប់ធ្វើកសិកម្មនោះត្រូវយកដីនោះទៅធ្វើកសិកម្ម មិនអាចយកដីកសិកម្មទៅធ្វើជាផ្ទះសម្រាប់ជួលបានទេ។ មូលហេតុដែលនាំឱ្យម្ចាស់សិទ្ធិលើការបញ្ចាំត្រូវអនុវត្តតាមវិធីប្រើប្រាស់ធម្មតានៃអចលនវត្ថុ គឺដើម្បីជៀសវាងនូវការខូចខាតធ្ងន់ធ្ងរដល់កូនបំណុល ក្នុងករណីម្ចាស់បំណុលកែប្រែ និង ផ្លាស់ប្តូរវិធីប្រើប្រាស់ធម្មតានៃអចលនវត្ថុនោះ។

### ៥.៣. បទបញ្ញត្តិពិសេសស្តីពីដីសម្រាប់ធ្វើកសិកម្ម

#### ៥.៣.១. សិទ្ធិលើបំណុលដែលគ្មានកំណត់ពេល

បើសិទ្ធិលើបំណុលត្រូវបានកំណត់ច្បាស់លាស់ ម្ចាស់បំណុលនឹងធ្វើការត្រៀមខ្លួនរួចជាស្រេចក្នុងការប្រគល់ដីសម្រាប់ធ្វើកសិកម្មឱ្យទៅកូនបំណុលវិញនៅពេលដល់កំណត់នៃកិច្ចសន្យា ដែលវាមិនធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍ម្ចាស់បំណុលទេ។ ផ្ទុយទៅវិញ សិទ្ធិលើបំណុលដែលគ្មានកំណត់ពេល អ្នកធានាដោយវត្ថុអាចធ្វើការរំលត់សិទ្ធិលើការបញ្ចាំ នៅពេលណាក៏បាន ដោយអនុវត្តកាតព្វកិច្ចដែលត្រូវបានធានាដោយសិទ្ធិលើការបញ្ចាំនោះ។ ដូច្នេះ បើកូនបំណុលរំលត់សិទ្ធិលើការបញ្ចាំ ក្នុងពេលដែលម្ចាស់បំណុលបានដាំដំណាំនៅលើដីសម្រាប់ធ្វើកសិកម្ម ហើយច្បាប់តម្រូវឱ្យម្ចាស់បំណុលប្រគល់ដីនោះឱ្យកូនបំណុលវិញ នោះវានឹងធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រយោជន៍របស់ម្ចាស់បំណុល។ កត្តានេះហើយទើបច្បាប់ ផ្តល់សិទ្ធិដល់ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ អាចប្រើដីសម្រាប់ធ្វើកសិកម្មនោះ ទោះបីជាសិទ្ធិលើបំណុលរលត់ ដោយការសងចំពោះសិទ្ធិលើបំណុលដែលគ្មានកំណត់ពេលក៏ដោយ បើរដូវប្រមូលផលដំណាំដែលម្ចាស់បំណុលបានសាប ឬ ដាំពីមុននឹងដល់នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ម្ចាស់បំណុលអាចប្រើដីនោះរហូតដល់រដូវប្រមូលផល (មាត្រា ៨៣៤ កថាខណ្ឌទី ២)។

#### ៥.៣.២. សិទ្ធិលើបំណុលដែលមានកំណត់ពេល

ទាក់ទងនឹងសិទ្ធិលើបំណុលដែលមានកំណត់ពេលច្បាស់លាស់វិញ ទោះបីជាម្ចាស់បំណុលបានសាប ឬ ដាំដំណាំនៅលើដីសម្រាប់ធ្វើកសិកម្ម បើពេលកំណត់បានមកដល់ ហើយកូនបំណុលបានសង ដែលធ្វើឱ្យរលត់សិទ្ធិលើបំណុលម្ចាស់បំណុល ត្រូវប្រគល់ដីនោះមកឱ្យកូនបំណុលវិញ។ ម្ចាស់បំណុលមិនអាចអះអាង មិនប្រគល់ដីដោយមូលហេតុរដូវប្រមូលផលនឹងដល់ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ដូចសិទ្ធិលើបំណុលដែលគ្មានកំណត់ពេលទេ។ ប៉ុន្តែ ប្រសិនបើសិទ្ធិលើបំណុលបានរលត់មុនពេលកំណត់ដោយការសង នោះម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើដីនោះដើម្បីធ្វើកសិកម្ម

បើរដូវប្រមូលផលពីដំណាំដែលខ្លួនបានសាប ឬ ដាំពីមុនមិនដល់ក្នុងអំឡុងពេលមួយឆ្នាំក្រោយពេលដល់រដូវប្រមូលផល ព្រោះសិទ្ធិលើបំណុលបានរលត់មុនពេលកំណត់ និង មិនមែនជាកំហុសរបស់ម្ចាស់បំណុល ។

ប៉ុន្តែ ទោះបីជានៅក្នុងករណីនេះក៏ដោយ ប្រសិនបើកាលបរិច្ឆេទនៃការកំណត់សងវិញដល់មុនពេលប្រមូលផល បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ពីព្រោះការបាត់បង់នូវការប្រមូលផល ក៏អាចរំពឹងទុកបាន ចាប់តាំងពីពេលចាប់ផ្តើម ( មាត្រា ៨៣៤ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ២) ។

### ៥.៤. បន្ទុកសោហ៊ុយគ្រប់គ្រងវត្ថុបញ្ចាំ

ក្រមរដ្ឋប្បវេណីកម្ពុជា តម្រូវឱ្យម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ ( ម្ចាស់បំណុល) ចេញសោហ៊ុយគ្រប់គ្រង និង ត្រូវទទួលបន្ទុកផ្សេង១ចំពោះអចលនវត្ថុនោះ ព្រោះម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុមានសិទ្ធិប្រើប្រាស់ និង អាស្រ័យផលដែលកើតចេញពីអចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំនោះ ។ ប៉ុន្តែ ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុមិនទទួលខុសត្រូវក្នុងការបង់ពន្ធលើអចលនវត្ថុនោះទេ ព្រោះការបង់ពន្ធជាបន្ទុករបស់កម្មសិទ្ធិករនៃដី ។

### ៥.៥. ការប្រាក់នៃសិទ្ធិលើបំណុល

ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ មិនអាចទាមទារការប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនបានទេ ពីព្រោះខ្លួនអាចទទួលបាននូវផលប្រយោជន៍ដែលចេញពីការប្រើប្រាស់ និង អាស្រ័យផលលើអចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំនោះហើយ ( មាត្រា ៨៣៦ នៃក្រមរដ្ឋប្បវេណី) ។

### ៥.៦. ការសន្យាពិសេសនៅក្នុងកិច្ចសន្យាបញ្ចាំ

ដូចដែលបានលើកឡើងហើយថា ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុអាចប្រើប្រាស់ និង អាស្រ័យផលពីអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ និង ត្រូវចេញសោហ៊ុយគ្រប់គ្រង និង ទទួលបន្ទុកផ្សេង១ចំពោះអចលនវត្ថុនោះ ហើយមិនអាចទាមទារការប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនបានទេ ។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏ភាគីទាំងពីរនៃកិច្ចសន្យាបញ្ចាំ អាចធ្វើការព្រមព្រៀងទាក់ទងទៅនឹងលក្ខខណ្ឌទាំងនោះខុសពីចំណុចដែលមានចែងក្នុងកិច្ចសន្យាបញ្ចាំរបស់ខ្លួនបាន ដោយផ្អែកលើបញ្ញត្តិពិសេសនៅក្នុងសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំ ( មាត្រា ៨៣៧) ។

**ឧទាហរណ៍ :** បើសិនជាមានកិច្ចព្រមព្រៀងមួយត្រូវបានធ្វើឡើង ដែលម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុអាចរួចផុតពីការចេញសោហ៊ុយគ្រប់គ្រង ឬ បន្ទុកផ្សេងទៀតទាក់ទងនឹងអចលនវត្ថុ ទោះបីជាម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុមានសិទ្ធិប្រើប្រាស់ និង អាស្រ័យផល ។ ករណីស្រដៀងគ្នានេះដែរ បើសិនជាមានកិច្ចព្រមព្រៀងមួយដែលអនុញ្ញាតឱ្យម្ចាស់បំណុលទាមទារការប្រាក់នៃសិទ្ធិលើបំណុល ទោះបីជាម្ចាស់បំណុលមានសិទ្ធិប្រើប្រាស់ និង អាស្រ័យផលលើអចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំក៏ដោយ កិច្ចព្រមព្រៀងនោះនឹងត្រូវបានទទួលស្គាល់អានុភាព ហើយម្ចាស់បំណុលអាចទាមទារការប្រាក់នៃសិទ្ធិលើបំណុលនោះបាន ។

## ៥.៧. អំឡុងពេលនៃសិទ្ធិលើការបញ្ចាំដែលមានអត្ថិភាព

*អំឡុងពេលដែលមានអត្ថិភាពនៃសិទ្ធិលើការបញ្ចាំអចលនវត្ថុ មិនអាចលើសពី ៥ (ប្រាំ) ឆ្នាំបានឡើយ ។ ប្រសិនបើបានបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុលើសពីអំឡុងពេលនេះ អំឡុងពេលត្រូវបន្ថយមកត្រឹម ៥ (ប្រាំ) ឆ្នាំ ។ កិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុអាចធ្វើបន្តទៀតបាន ។ ប៉ុន្តែ អំឡុងពេលនៃការបន្តនេះ មិនអាចធ្វើឱ្យលើសពី ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលបន្តបានឡើយ* (មាត្រា ៨៣៨ នៃក្រមរដ្ឋប្បវេណី) ។

## ៥.៨. ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីហ៊ីប៉ូតែក

យោងតាមមាត្រា ៨៣៩ នៃក្រមរដ្ឋប្បវេណីបានចែងថា *ក្រៅពីបញ្ញត្តិនៃផ្នែកទី ៣ ដែលស្តីអំពីការបញ្ចាំអចលនវត្ថុ បញ្ញត្តិនៃជំពូកទី ៥ (ដែលស្តីអំពីហ៊ីប៉ូតែក) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការបញ្ចាំអចលនវត្ថុ ។*

ខាងក្រោមនេះ គឺជាឧទាហរណ៍មួយចំនួនស្តីពីការអនុវត្តដូចគ្នានៃបញ្ញត្តិទាក់ទងនឹងហ៊ីប៉ូតែក ។

បញ្ញត្តិស្តីពីការតតាំងនៃហ៊ីប៉ូតែក ដែលមានចែងនៅក្នុងមាត្រា ៨៤៥ នៃក្រមរដ្ឋប្បវេណី ក៏ត្រូវយកមកអនុវត្តដូចគ្នានឹងការបញ្ចាំដែរ ។ ហេតុនេះ ដើម្បីឱ្យការបញ្ចាំមួយអាចតតាំងនឹងតតិយជនបាន សិទ្ធិលើការបញ្ចាំនោះត្រូវធ្វើឡើងដោយលិខិតយថាភូត និង ត្រូវចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ។

ហើយចំពោះទំហំនៃអានុភាពហ៊ីប៉ូតែក ដែលមានចែងនៅក្នុងមាត្រា ៨៤៦ ក៏ត្រូវយកមកអនុវត្តដូចគ្នាជាមួយនឹងការបញ្ចាំដែរ ពោលគឺនៅពេលដែលការបញ្ចាំមួយត្រូវបានបង្កើតឡើងនៅលើដីមួយកន្លែង ការបញ្ចាំនោះមានអានុភាពលើវត្ថុដែលភ្ជាប់នឹងដីនោះ រួមទាំងអាគារដែលមាននៅលើដីដែលជាប់ការបញ្ចាំនោះផងដែរ ។ ទោះបីជាអាគារនោះត្រូវបានសង់នៅមុនពេល ឬ ក្រោយពេលបង្កើតសិទ្ធិលើការបញ្ចាំក៏ដោយ ហើយដែលភាគីមិនអាចកំណត់នូវលក្ខខណ្ឌផ្សេងពីនេះនៅក្នុងកិច្ចសន្យាបញ្ចាំរបស់ខ្លួនបានឡើយ (មាត្រា ៨៤៦ នៃក្រមរដ្ឋប្បវេណី) ដោយហេតុថា ជាទូទៅយោងតាមមាត្រា ១២២ នៃក្រមរដ្ឋប្បវេណី វត្ថុដែលនៅជាប់នឹងដី ឬ វត្ថុដែលក្លាយជាភាគមួយនៃដី ជាពិសេសអាគារ ឬ សំណង់ដែលសង់នៅលើដី ហើយមិនអាចប្តូរកន្លែងបានគឺជាសមាសភាគនៃដី ។ ហេតុនេះ នាំឱ្យសិទ្ធិលើការបញ្ចាំដែលមាននៅលើដីមួយកន្លែង នឹងមានអានុភាពទៅលើអ្វីដែលជាសមាសភាគនៃដីនោះដែរ ។

ទន្ទឹមនឹងនេះ មាត្រា ៨៥១ ដែលស្តីអំពីលំដាប់នៃហ៊ីប៉ូតែក ក៏ត្រូវយកមកអនុវត្តដូចគ្នានឹងការបញ្ចាំដែរ មានន័យថា អាទិភាពនៃសិទ្ធិលើការបញ្ចាំ គឺអាស្រ័យលើពេលវេលានៃការចុះបញ្ជីនៃសិទ្ធិទាំងនោះ ។

ដូចគ្នាដែរ មាត្រា ៨៥២ ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ដែលអនុវត្តចំពោះហ៊ីប៉ូតែក ក៏ត្រូវអនុវត្តចំពោះសិទ្ធិលើការបញ្ចាំដែរ ។ មានន័យថា ក្នុងករណីដែលម្ចាស់បំណុលនៃសិទ្ធិលើការបញ្ចាំមានសិទ្ធិទាមទារការប្រាក់ ឬ ធនលាភផ្សេងទៀត ម្ចាស់បំណុលនៃសិទ្ធិលើការបញ្ចាំអាចអនុវត្តសិទ្ធិលើការបញ្ចាំនោះ បានតែចំពោះចំនួននៃការសងដែលដល់កំណត់ពេលសម្រាប់អំឡុងពេល ២ (ពីរ) ឆ្នាំ ចុងក្រោយតែប៉ុណ្ណោះ ។ ប៉ុន្តែ ចំពោះ

ធនលាភដែលមានពីមុនមក ប្រសិនបើបានចុះបញ្ជីពិសេសក្រោយពីបានដល់ពេលកំណត់ត្រូវសង សិទ្ធិលើការបញ្ចាំនេះ អាចអនុវត្តបានចាប់ពីពេលដែលបានចុះបញ្ជីនោះ ។

ការកំណត់ដូច្នេះ ពីព្រោះវាមានភាពចាំបាច់សម្រាប់ការពារម្ចាស់បំណុលនៃសិទ្ធិប្រាតិភោគប្រត្យក្សផ្សេងទៀត ដែលស្ថិតនៅក្នុងលំដាប់ទាបជាង ដើម្បីឱ្យដឹងថាតើនៅសល់ចំនួនប៉ុន្មានដែលមិនត្រូវបានធានា ដូច្នេះ អាចឱ្យពួកគេ ដឹងថាតើពួកគេត្រូវឱ្យខ្ចីប្រាក់ចំនួនប៉ុន្មាន ។

## ៦. ការបញ្ចាំសិទ្ធិ

ដូចដែលយើងបានដឹងហើយថា ការបញ្ចាំអាចត្រូវបានធ្វើឡើងក្រោមរូបភាពបីយ៉ាងគឺ ការបញ្ចាំចលនវត្ថុ ការបញ្ចាំអចលនវត្ថុ និង ការបញ្ចាំសិទ្ធិ ។

ការបញ្ចាំចលនវត្ថុ ឬ អចលនវត្ថុ គឺត្រូវយកចលនវត្ថុ ឬ អចលនវត្ថុដែលជាកម្មវត្ថុនោះ ទៅប្រគល់ឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ ។ ផ្ទុយទៅវិញ ការបញ្ចាំសិទ្ធិ សំដៅលើការដែលកូនបំណុលយកសិទ្ធិលើបំណុលរបស់ខ្លួន ដែលមានចំពោះកូនបំណុលទី ៣ ទៅដាក់បញ្ចាំឱ្យម្ចាស់សិទ្ធិលើការបញ្ចាំរបស់ខ្លួនដើម្បីធានានូវការសងបំណុលនោះ ។

**ឧទាហរណ៍ :** ក ជាម្ចាស់បំណុលរបស់លោក គ ចំនួន ២.០០០ ដុល្លារ ។ តែ ក ចង់ខ្ចីបំណុលពី ខ ចំនួន ១.០០០ ដុល្លារ ។ បើសិនជា ក គ្មានទ្រព្យអ្វីផ្សេងយកមកបញ្ចាំឱ្យ ខ ដើម្បីធានាបំណុលទេ ក អាចយកសិទ្ធិលើបំណុលរបស់ខ្លួនដែលមានចំពោះ គ ទៅដាក់បញ្ចាំឱ្យ ខ ដើម្បីធានានូវការសងបំណុលដែលខ្លួនមានចំពោះ ខ បាន ។

**តើការបញ្ចាំសិទ្ធិលើបំណុលមានសារប្រយោជន៍យ៉ាងណា?**




តើការបញ្ចាំសិទ្ធិលើបំណុលមានសារប្រយោជន៍យ៉ាងណា?

**ឧទាហរណ៍ :** ក ជាម្ចាស់បំណុលរបស់ គ ចំនួន ២.០០០ ដុល្លារ ។ តែ ក ចង់ខ្ចីបំណុលពី ខ ចំនួន ១.០០០ ដុល្លារ ។ ក បានយកសិទ្ធិលើបំណុលរបស់ខ្លួនដែលមានចំពោះ គ ចំនួន ១.០០០ ដុល្លារ (ក្នុងចំនួនទឹកប្រាក់ ២.០០០ ដុល្លារ ដែល គ ជំពាក់) ទៅដាក់បញ្ចាំឱ្យ ខ ដើម្បីធានានូវការសងបំណុលដែលខ្លួនមានចំពោះ ខ ។

សារប្រយោជន៍ចំពោះការបញ្ចាំសិទ្ធិលើបំណុលនេះកើតមានចំពោះម្ចាស់សិទ្ធិលើការបញ្ចាំ ជាពិសេសនៅពេលដែលមានម្ចាស់បំណុលធម្មតាផ្សេងទៀត ដូចជា ឃ និង ង ។

ក្នុងករណីនេះ បើសិនជា ក បានយកសិទ្ធិលើបំណុលរបស់ខ្លួនដែលមានចំពោះ គ ចំនួន ១.០០០ ដុល្លារ (នៅក្នុងសិទ្ធិលើបំណុលចំនួន ២.០០០ ដុល្លារ) ទៅដាក់បញ្ចាំឱ្យ ខ នោះ ខ នឹងទទួលបាននូវសិទ្ធិជាអាទិភាពនៃទឹកប្រាក់ចំនួន ១.០០០ ដុល្លារ ដែល គ សងទៅ ក មុន ឃ និង ង ដែលជាម្ចាស់បំណុលធម្មតារបស់ ក ។

ប៉ុន្តែ តើម្ចាស់សិទ្ធិលើការបញ្ចាំអាចយកការបញ្ចាំសិទ្ធិលើបំណុលមកតតាំងចំពោះម្ចាស់បំណុលផ្សេងទៀតបានយ៉ាងដូចម្ដេច? បញ្ហានេះ នឹងត្រូវលើកយកមកបង្ហាញនៅក្នុងប្រធានបទខាងក្រោមនេះ ។

## ៦.១. លក្ខខណ្ឌសុពលភាព/អានុភាពនៃការបញ្ចាំសិទ្ធិលើបំណុលចំពោះគូភាគី

ពាក់ព័ន្ធនឹងការបញ្ចាំសិទ្ធិ ជាទូទៅ ការព្រមព្រៀងត្រូវបានចាត់ទុកថាជាលក្ខខណ្ឌដើម្បីបង្កើតអានុភាពសម្រាប់ការបង្កើតសិទ្ធិលើការបញ្ចាំ ព្រោះសិទ្ធិ គឺជាទ្រព្យអរូបី ហើយមិនអាចប្រគល់បានទេ ។ ជាករណីលើកលែង ប្រសិនបើការអនុវត្តសិទ្ធិនោះ តម្រូវឱ្យមានការកាន់កាប់នូវឯកសារដែលបញ្ជាក់ពីសិទ្ធិនោះ ដូចជា មូលប្បទានប័ត្រ ការបង្កើតសិទ្ធិនោះតម្រូវឱ្យមានការប្រគល់នូវឯកសារនោះតាមលក្ខណៈនៃការបញ្ចាំ ។

## ៦.២. លក្ខខណ្ឌតតាំងនៃការបញ្ចាំសិទ្ធិលើបំណុលចំពោះតតិយជន

ដើម្បីឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ អាចតតាំងជាមួយនឹងកូនបំណុលទី ៣ (ករណីខាងលើ គឺ គ) និង តតិយជនផ្សេងទៀត (ករណីខាងលើ គឺ ឃ និង ង) អ្នកដែលយកសិទ្ធិលើបំណុលដែលមានចំពោះកូនបំណុលទី ៣ ទៅដាក់បញ្ចាំនោះ ត្រូវតែជូនដំណឹងអំពីការបង្កើតការបញ្ចាំសិទ្ធិលើបំណុលរបស់ខ្លួនដល់កូនបំណុលទី ៣ ឬ មានការយល់ព្រមពីកូនបំណុលទី ៣ នោះ ។ ហើយការជូនដំណឹង ឬ ការយល់ព្រមខាងលើនេះ មិនអាចយកមកតតាំងចំពោះតតិយជនក្រៅពីកូនបំណុលទី ៣ បានឡើយ ប្រសិនបើមិនបានធ្វើឡើងដោយលិខិតដែលមានកាលបរិច្ឆេទស្គាល់ ។

នៅក្នុងករណីខាងលើនេះ គ អាចបដិសេធមិនសងប្រាក់ទៅ ខ បានដោយគ្មានការយល់ព្រម ឬ ការជូនដំណឹងណាមួយនោះ ពីព្រោះ ខ មិនអាចតតាំងសិទ្ធិលើការបញ្ចាំរបស់ខ្លួនចំពោះ គ បានទេ ។ បន្ទាប់មកដើម្បីឱ្យ ខ អាចតតាំងសិទ្ធិលើការបញ្ចាំរបស់ខ្លួនចំពោះ គ បាន ខ ត្រូវការនូវការយល់ព្រម ឬ ការជូនដំណឹង ហើយ គ មិនអាចបដិសេធនូវការសងចំពោះ ខ បានទេ ។

ដោយគ្មានការយល់ព្រម ឬ ការជូនដំណឹងដោយគ្មានកាលបរិច្ឆេទស្គាល់ ខ មិនអាចតតាំងអំពីអាទិភាពរបស់ខ្លួនចំពោះ ឃ និង ង បានទេ ជាឧទាហរណ៍ ។ ហេតុដូច្នេះ ឃ និង ង អាចរឹបអូសសិទ្ធិលើបំណុល ហើយទទួលបាននូវការចែកចំណែកតាមសមាមាត្រនៃចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល ពីព្រោះ ខ មិនអាចអះអាងអំពីអាទិភាពរបស់ខ្លួនបាន ។ ប្រសិនបើ ខ ចង់អះអាងអំពីសិទ្ធិលើការបញ្ចាំរបស់ខ្លួនចំពោះ ឃ និង ង បន្ថែមលើ គ នោះ ខ ត្រូវការនូវការជូនដំណឹង ឬ ការយល់ព្រមដោយមានកាលបរិច្ឆេទស្គាល់ ។

យោងតាមមាត្រា ៨ នៃច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី លិខិតដែលមានកាលបរិច្ឆេទស្គាល់ សំដៅដល់ :

*ក- លិខិតយថាភូត : ចំពោះលិខិតយថាភូត កាលបរិច្ឆេទនៃការធ្វើលិខិតនោះ ត្រូវក្លាយជាកាលបរិច្ឆេទស្គាល់ ។*

*ខ- លិខិតឯកជនដែលសារការី ឬ ក្រឡាបញ្ជីតុលាការចុះទិដ្ឋាការពីកាលបរិច្ឆេទដែលខ្លួនត្រូវបានបង្ហាញលិខិតឯកជននេះ និង ចុះហត្ថលេខា ។ ក្នុងករណីនេះ កាលបរិច្ឆេទនោះត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរ ។*

*គ- លិខិតឯកជនដែលមានជនម្នាក់ក្នុងចំណោមជនដែលបានចុះហត្ថលេខាលើលិខិតនោះ បានទទួលមរណភាព ។ ក្នុងករណីនេះ ថ្ងៃដែលជននោះទទួលមរណភាព ត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរ ។*

*ឃ- លិខិតឯកជនដែលត្រូវបានយកជាភស្តុតាង នៅក្នុងលិខិតដែលមានកាលបរិច្ឆេទស្ថាពរ ។ ក្នុងករណីនេះ កាលបរិច្ឆេទនៅក្នុងលិខិតដែលមានកាលបរិច្ឆេទស្ថាពរនោះ ត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរ សម្រាប់លិខិតឯកជនដែលត្រូវបានយកជាភស្តុតាងនោះ ។*

តើលិខិតអ្វីខ្លះ ត្រូវចាត់ទុកជាលិខិតយថាភូតនោះ? ចំណុចនេះមានចែងនៅក្នុងមាត្រា ៩ នៃច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី គឺសំដៅដល់លិខិតដែលធ្វើឡើងដោយសារការី ឬ កុងស៊ុល ឬ ជាលិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើងដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជី ។

## ៦.៣. ការអនុវត្តសិទ្ធិលើការបញ្ចាំដោយប្រមូលសិទ្ធិលើបំណុល

ផ្អែកតាមមាត្រា ៨៤២ កថាខណ្ឌទី ១ ម្ចាស់សិទ្ធិលើការបញ្ចាំ មិនចាំបាច់ដាក់ពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគ ដើម្បីប្រមូលប្រាក់នោះទេ ។

ប្រសិនបើកម្មវត្ថុនៃសិទ្ធិលើបំណុលជាប្រាក់ ទំហំនៃការប្រមូលត្រូវបានកម្រិតត្រឹមចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលត្រូវបានធានា ( មាត្រា ៨៤២ កថាខណ្ឌទី ២) ។

បើកំណត់ពេលត្រូវសងនៃសិទ្ធិលើបំណុល ដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំបានមកដល់មុនកំណត់ពេលត្រូវសងនៃសិទ្ធិលើបំណុលរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ កូនបំណុលទី ៣ អាចដាក់ប្រាក់តម្កល់ ហើយសិទ្ធិលើការបញ្ចាំមានអត្ថិភាពលើប្រាក់តម្កល់នោះ ( មាត្រា ៨៤២ កថាខណ្ឌទី ៣) ។

ប្រសិនបើកម្មវត្ថុនៃសិទ្ធិលើបំណុលមិនមែនជាប្រាក់ទេ ម្ចាស់សិទ្ធិលើការបញ្ចាំមានសិទ្ធិលើការបញ្ចាំលើវត្ថុដែលខ្លួនបានទទួលជាការសង ( មាត្រា ៨៤២ កថាខណ្ឌទី ៤) ។

| | ការបញ្ចាំចលនវត្ថុ | ការបញ្ចាំអចលនវត្ថុ | ការបញ្ចាំសិទ្ធិលើបំណុល |
|---|---|---|---|
| **កម្មវត្ថុនៃការបញ្ចាំ** | ចលនវត្ថុ | អចលនវត្ថុ | សិទ្ធិលើបំណុល |
| **លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាចំពោះគូភាគី** | ការព្រមព្រៀង | ការព្រមព្រៀង | ការព្រមព្រៀង |
| **លក្ខខណ្ឌតតាំងនៃកិច្ចសន្យាចំពោះតតិយជន** | ការកាន់កាប់ជានិរន្តរ៍នូវវត្ថុបញ្ចាំនោះ | លិខិតយថាភូត និង ការចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី | ការជូនដំណឹងទៅកូនបំណុលទី ៣ ឬ ការទទួលព្រមពីកូនបំណុល ទី ៣ ដែលត្រូវធ្វើឡើងដោយលិខិតដែលមានកាលបរិច្ឆេទស្លាក |
| **លំដាប់នៃអាទិភាពក្នុងករណីប្រជែងជាមួយសិទ្ធិប្រត្យក្សផ្សេងទៀត** | អាស្រ័យទៅលើលំដាប់នៃការចាប់ផ្តើមការកាន់កាប់ | អាស្រ័យលើពេលវេលានៃការចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី | អាស្រ័យទៅលើ កាលបរិច្ឆេទស្លាកនៃលិខិតជូនដំណឹងនោះ |

## ផ្នែកទី ៤
# ប្រាតិភោគដោយអនុប្បទាន

## ១. សេចក្ដីផ្ដើម

ជាឧទាហរណ៍ ក គឺជាអ្នកលក់ដុំ ហើយគាត់មានបំណុលចង់ខ្ចីប្រាក់ពី ខ ។ ខ ទាមទារឱ្យដាក់ប្រាតិភោគ ទើបខ្លួនព្រមឱ្យខ្ចីប្រាក់ ។

ក មិនមានអចលនវត្ថុនោះទេ ហេតុដូច្នេះ ក មិនអាចបង្កើតហ៊ីប៉ូតែកបានទេ ហើយទ្រព្យសម្បត្តិរបស់គាត់ គឺមានតែទំនិញដែលស្ដុកទុកនៅក្នុងឃ្លាំងតែប៉ុណ្ណោះ។ គាត់មិនអាចធ្វើជំនួញបានទេ ប្រសិនបើគាត់យកទំនិញទៅក្នុងឃ្លាំងនោះទៅដាក់បញ្ចាំឱ្យ ខ ដោយសារថាទំនិញទាំងនោះ គឺជាទំនិញដែលនឹងត្រូវលក់ទៅឱ្យអ្នកលក់រាយ ។

លើសពីនេះ ទំនិញទីមួយៗត្រូវបានប្ដូរពីមួយថ្ងៃទៅមួយថ្ងៃ ហេតុដូច្នេះវាហាក់បីដូចជាមិនអាចយកមកដាក់ជាប្រាតិភោគបានទេ។ តើ ក ត្រូវធ្វើយ៉ាងដូចម្ដេច?

ប្រាតិភោគដោយគ្មានការផ្ទេរការកាន់កាប់ គឺមានសារប្រយោជន៍ខ្លាំងណាស់ចំពោះកូនបំណុល នៅក្នុងករណីដែលកូនបំណុលទទួលផលប្រយោជន៍ពីវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគ ។

ពាក់ព័ន្ធនឹងអចលនវត្ថុ ហ៊ីប៉ូតែកអាចត្រូវបានបង្កើតឡើងដោយគ្មានការផ្ទេរការកាន់កាប់ ។

ចំណែកឯចលនវត្ថុវិញ ប្រាតិភោគដោយអនុប្បទាន អាចត្រូវបានបង្កើតឡើងដោយគ្មានការផ្ទេរការកាន់កាប់ដោយចំពោះ ហើយប្រាតិភោគដោយអនុប្បទាននេះ អាចត្រូវបានបង្កើតឡើងលើចលនវត្ថុច្រើនជាងមួយ ដោយមានការព្រមព្រៀងតែមួយប៉ុណ្ណោះ ដើម្បីឱ្យកូនបំណុលអាចបន្តទទួលផលប្រយោជន៍ពីចលនវត្ថុនោះ ។

ទោះបីមើលទៅហ៊ីប៉ូតែក និង ប្រាតិភោគដោយអនុប្បទានមានលក្ខណៈខុសគ្នាក៏ដោយ ក៏នៅមានលក្ខណៈរួមដែរ។ ឧទាហរណ៍ : មានតតិយជនដែលមានផលប្រយោជន៍ត្រឹមត្រូវតាមច្បាប់ ចំពោះវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ។ នៅក្នុងករណីនៃហ៊ីប៉ូតែក មានប្រព័ន្ធចុះបញ្ជីដើម្បីឱ្យតតិយជនដឹងអំពីស្ថានភាពគតិយុត្តនៃវត្ថុដែលជាកម្មវត្ថុ ។

ផ្ទុយទៅវិញ ទាក់ទងនឹងចលនវត្ថុ វាគ្មានប្រព័ន្ធចុះបញ្ជីដូចគ្នានឹងអចលនវត្ថុ ដើម្បីជូនដំណឹងអំពីស្ថានភាពគតិយុត្តជាសាធារណៈនោះទេ។ ហេតុដូច្នេះ ចាំបាច់ត្រូវមានវិធាននៅក្នុងករណីដែលមានទំនាក់ទំនងផលប្រយោជន៍តាមផ្លូវច្បាប់របស់តតិយជន និង កម្មវត្ថុ ដូចជា ករណីដែលតតិយជនទិញវត្ថុដែលជាកម្មវត្ថុ ជាពិសេស ករណីដែលតតិយជននោះមិនបានដឹងថាវត្ថុនោះ គឺជាកម្មវត្ថុនៃប្រាតិភោគ ។

## ២. លក្ខខណ្ឌ

យោងតាមមាត្រា ៨៨៨ និងមាត្រា ៨៨៩ លក្ខខណ្ឌដើម្បីបង្កើតប្រាតិភោគដោយអនុប្បទាន គឺមានដូចខាងក្រោមនេះ :

ក- ចលនវត្ថុមួយ ឬ ច្រើនជាសមូហ

ក្នុងករណីដែលមានចលនវត្ថុច្រើនជាសមូហ ចលនវត្ថុទាំងនោះត្រូវកំណត់ទំហំតាមមាត្រដ្ឋាន ដូចជា ប្រភេទនៃចលនវត្ថុ ឬ កន្លែងស្ថិតនៅនៃចលនវត្ថុ ជាចលនវត្ថុផ្សំគ្នា ។ ប្រាតិភោគដោយអនុប្បទាន ចំពោះចលនវត្ថុផ្សំគ្នាមានសារប្រយោជន៍នៅពេលដែលជនណាម្នាក់ ដូចជា ពាណិជ្ជករ ឬ អាជីវករចង់យកទំនិញមកដាក់ជាប្រាតិភោគ ពីព្រោះពាណិជ្ជករ ឬ អាជីវករនោះ អាចដាក់ប្រាតិភោគជាចលនវត្ថុផ្សំគ្នាបាន ។

ខ- ការព្រមព្រៀង

គ- ការផ្ទេរការកាន់កាប់ ដើម្បីតតាំងសិទ្ធិប្រាតិភោគដោយអនុប្បទានចំពោះតតិយជន ។

ទាក់ទងនឹងការផ្ទេរការកាន់កាប់ លក្ខខណ្ឌនេះមិនដកចេញនូវទម្រង់ណាមួយ នៅក្នុងចំណោមទម្រង់ទាំងបួននៃការផ្ទេរការកាន់កាប់នោះទេ ហេតុដូច្នេះការប្តូរលក្ខណៈនៃការកាន់កាប់អាចបំពេញនូវលក្ខខណ្ឌនេះបាន ។

នៅក្នុងករណីដែល ក និង ខ បានព្រមព្រៀងគ្នាថា ក ត្រូវធ្វើអនុប្បទានកម្មសិទ្ធិនៃចលនវត្ថុនៅក្នុងឃ្លាំងជាប្រាតិភោគ ហើយ ក ផ្ទេរការកាន់កាប់ (ដោយប្រយោល) ទៅឱ្យ ខ តាមរយៈការប្តូរលក្ខណៈនៃការកាន់កាប់ ខ អាចតតាំងអនុប្បទាននេះចំពោះតតិយជនបាន ។

## ៣. អានុភាព

### ៣.១. ទំហំនៃអានុភាព

សិទ្ធិប្រាតិភោគដោយអនុប្បទាន មានអានុភាពលើវត្ថុដែលភ្ជាប់នឹងវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទានមុន ឬ ក្រោយការបង្កើតសិទ្ធិប្រាតិភោគប្រត្យក្ស យោងតាមមាត្រា ៨៩១ កថាខណ្ឌទី ១ ។

ភាគីអាចធ្វើការសន្យាពិសេសដែលផ្ទុយនឹងបញ្ញត្តិមាត្រា ៨៩១ កថាខណ្ឌទី ១ ។

### ៣.២. អានុភាពចំពោះផល

ក្នុងករណីដែលអ្នកបង្កើតប្រាតិភោគដោយអនុប្បទាន ឬ តតិយជនដែលបានទទួលការបញ្ជាពីអ្នកបង្កើតនោះ កាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ អានុភាពមិនមានចំពោះផលឡើយ ។ ចំណុចនេះ គឺជាចំណុចដែលមានលក្ខណៈស្រដៀងគ្នាយ៉ាងខ្លាំងទៅនឹងហ៊ីប៉ូតែក ។

មូលហេតុដែលមិនឱ្យមានអានុភាព ព្រោះថាអ្នកបង្កើត និង តតិយជនដែលទទួលការបញ្ជា មានសិទ្ធិប្រើប្រាស់ និង អាស្រ័យផលពីវត្ថុដែលខ្លួនកំពុងកាន់កាប់ដោយចំពោះ ។

**ឧទាហរណ៍ :** ក បានយកម៉ូតូជាច្រើនគ្រឿងដែលខ្លួនទុកសម្រាប់ជួលឱ្យអ្នកដទៃនោះទៅបង្កើតប្រាតិភោគដោយអនុប្បទានជាមួយ ខ ហើយបានផ្ទេរការកាន់កាប់ដោយការព្រមព្រៀង ដើម្បីខ្ចីប្រាក់ពី ខ។ ក ជាអ្នកកាន់កាប់ដោយផ្ទាល់ចំពោះលើម៉ូតូដែលជាកម្មវត្ថុនៃប្រាតិភោគនោះ។ ហេតុដូច្នេះ ក មានសិទ្ធិទទួលផលពីកម្មវត្ថុនោះតាមរយៈការជួលម៉ូតូទាំងនោះ ហើយ ខ មិនអាចទទួលផល ដូចជា ថ្លៃឈ្នួលឡើយ (អានុភាពនៃប្រាតិភោគដោយអនុប្បទានមិនមានចំពោះផលឡើយ) ។

ផ្ទុយទៅវិញ ក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬ តតិយជនដែលបានទទួលការប្រគល់ការកាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ មាត្រា ៨២២ (សិទ្ធិទទួលការសងពីផលដោយមានអាទិភាព) ត្រូវយកមកអនុវត្តដូចគ្នា។ លើសពីនេះ ផលដែលបានពីកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាននេះ ត្រូវយកមកកាត់សិទ្ធិលើបំណុលរបស់ម្ចាស់សិទ្ធិ ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតបាន។ ចំពោះវិធីនៃការកាត់សិទ្ធិលើបំណុលនោះ គឺត្រូវកាត់ការប្រាក់ជាមុនសិន ហើយប្រសិនបើមានសល់ត្រូវយកទៅកាត់ប្រាក់ដើម។

### ៣.៣. ឧបាទេសកម្ម

ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចធ្វើឧបាទេសកម្មចំពោះប្រាក់ ឬ វត្ថុផ្សេងទៀត ដែលត្រូវទទួលដោយការលក់ ការបាត់បង់ ឬ ការខូចខាតនូវវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន។

មានករណីលើកលែងចំនួន ពីរ ចំពោះបញ្ញត្តិនេះ :

ទី ១ គឺម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានមិនអាចធ្វើឧបាទេសកម្មបានទេ ក្រោយពេលដែលប្រាក់ ឬ វត្ថុផ្សេងទៀតនោះត្រូវបានសង ឬ ប្រគល់ទៅឱ្យអ្នកបង្កើតរួចហើយ។

ទី ២ ក្នុងករណីចលនវត្ថុផ្គុំគ្នា ហើយចលនវត្ថុនោះត្រូវមានគម្រោងលក់តាំងពីដំបូងនូវចលនវត្ថុនេះ ទៅឱ្យអ្នកផ្សេងទៀត ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានមិនអាចធ្វើឧបាទេសកម្មបានទេ។

**ឧទាហរណ៍ទី ១ :** ក បានយកទំនិញរបស់ខ្លួន ទៅបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានជាមួយ ខ។ ក្រោយមក ក បានលក់សាងទំនិញទាំងអស់នោះទៅឱ្យ គ ។

ក្នុងករណីនោះ ខ អាចធ្វើឧបាទេសកម្មលើប្រាក់ដែលជាថ្លៃសាងទំនិញនោះពី គ បាន។ ប៉ុន្តែ ក្នុងករណីដែលប្រាក់នោះត្រូវប្រគល់ទៅឱ្យ ក ហើយនោះ គឺ ខ មិនអាចធ្វើឧបាទេសកម្មបានទេ។

**ឧទាហរណ៍ទី ២ :** ក បានយកទំនិញរបស់ខ្លួននៅក្នុងឃ្លាំងជាចលនវត្ថុផ្គុំគ្នាដែលគ្រោងនឹងលក់ ទៅបង្កើតប្រាតិភោគដោយអនុប្បទានជាមួយ ខ។ នៅក្នុងករណីនេះ មិនថាទំនិញដែលទើបនឹងនាំចូល ឬ ទំនិញដែលបានលក់ចេញនោះទេ គឺទំនិញដែលមាននៅក្នុងឃ្លាំងនាពេលនេះត្រូវបានចាត់ទុកថាជាចលនវត្ថុផ្គុំគ្នា។ ហេតុដូច្នេះ អានុភាពនៃប្រាតិភោគមិនមានចំពោះវត្ថុដែលត្រូវបានយកចេញនោះទេ។

ក្នុងករណីនេះ ខ មិនអាចធ្វើឧបាទេសកម្មលើទឹកប្រាក់ដែលបានពីការលក់ទំនិញនោះទេ។

## ៣.៤. ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា

ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានារួមមាន ប្រាក់ដើម ការប្រាក់ ប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា សោហ៊ុយដើម្បីអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន សោហ៊ុយដើម្បីថែរក្សាវត្ថុដែលជាកម្មវត្ថុ ព្រមទាំងសំណងនៃការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ឬ វិការៈកំបាំងនៃវត្ថុដែលជាកម្មវត្ថុ យោងមាត្រា ៨៩៥។ វា មានន័យថានៅពេលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ធ្វើការអនុវត្តសិទ្ធិប្រាតិភោគ ដោយអនុប្បទាន តើទំហំសិទ្ធិលើបំណុលមានដល់កម្រិតណា? ដូចបានលើកឡើងខាងលើ វាមានអានុភាពធានាដល់ប្រាក់

ដើម ការប្រាក់ ប្រាក់ពិន័យក្នុងករណីបំពានកិច្ចសន្យា សោហ៊ុយដើម្បីអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន សោហ៊ុយដើម្បីថែរក្សាវត្ថុដែលជាកម្មវត្ថុ ព្រមទាំងសំណងនៃការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ឬ វិការៈកំបាំងនៃវត្ថុដែលជាកម្មវត្ថុ។ មាត្រានេះ ដូចគ្នាជាមួយនឹងការធានានៃបញ្ញត្តិស្តីពីសិទ្ធិលើការបញ្ចាំមានចែងក្នុងមាត្រា ៨២០ ។

### ៣.៥. ការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយអ្នកធានាដោយវត្ថុ និង ម្ចាស់សិទ្ធិប្រាតិភោគប្រកួតប្រជែង

#### ៣.៥.១. ការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយអ្នកធានាដោយវត្ថុ

##### ៣.៥.១.១. ចលនវត្ថុចម្បង

នៅក្នុងករណីដែលចលនវត្ថុត្រូវបានធ្វើអនុប្បទានជាប្រាតិភោគ ចលនវត្ថុនោះនៅតែអាចស្ថិតនៅក្រោមការកាន់កាប់របស់អ្នកធានាដោយវត្ថុ។ នៅក្នុងករណីនេះ ដោយឆ្លៀតឱកាសដែលខ្លួនកំពុងតែកាន់កាប់ជាក់ស្តែង អ្នកធានាដោយវត្ថុអាចធ្វើអនុប្បទាននូវចលនវត្ថុនោះទៅឱ្យតតិយជន ឬ ដាក់ជាប្រាតិភោគបាន។ នៅក្នុងករណីនេះ គេចាំបាច់ត្រូវកំណត់ថា តើម្ចាស់សិទ្ធិប្រាតិភោគ ឬ តតិយជនអាចអះអាងអំពីអាទិភាពអំពីចលនវត្ថុចំពោះអ្នកដទៃបាន។

**ឧទាហរណ៍ :** យោងតាមមាត្រា ៨៩៤ បញ្ហាគឺនៅត្រង់ចំណុចថា តើតតិយជនបានបំពេញលក្ខខណ្ឌនៃលទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុដែរ ឬ ទេ។ នៅក្នុងករណីដែល ក បានជំពាក់បំណុល ខ បន្ទាប់មក ក បានធ្វើអនុប្បទានឡានរបស់ខ្លួនជាប្រាតិភោគ ប៉ុន្តែ ក នៅតែបន្តការកាន់កាប់។ បន្ទាប់មក ក បានលក់ឡាននោះទៅឱ្យ គ ដែលមិនបានដឹងអំពីការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន។ នៅក្នុងករណីនេះ ដោយផ្អែកតាមលទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើអចលនវត្ថុ គ អាចធ្វើលទ្ធកម្មកម្មសិទ្ធិ ហើយវាឆ្លុះបញ្ចាំងពីការបាត់បង់ប្រាតិភោគចំពោះ ក។ ក្នុងករណីនេះ ខ មិនអាចអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទានចំពោះឡាននោះបានទេ។ ផ្ទុយទៅវិញ នៅក្នុងករណីដែល គ មិនបានបំពេញលក្ខខណ្ឌលទ្ធកម្មដោយសុចរិតទេ ខ អាចអះអាងពីអាទិភាព ជាម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានដោយផ្អែកតាមមាត្រា ៧៧២។

តើមានវិធីណាដើម្បីការពារ ខ ពីការណ៍ដែល គ ធ្វើលទ្ធកម្មនូវកម្មវត្ថុ? វិធីដែលអាចធ្វើបាន គឺអាចជាការដាក់ជាសញ្ញាសម្គាល់លើឡាននោះ ដើម្បីបង្ហាញថាជាកម្មវត្ថុដោយអនុប្បទាន។ តាមរយៈការធ្វើបែបនេះ ខ អាចធ្វើឱ្យតតិយជនដែលមានបំណងទិញរថយន្តនោះក្លាយជាជនទុច្ចរិត និង មានកំហុស។

##### ៣.៥.១.២. ចលនវត្ថុផ្តុំគ្នា

នៅក្នុងករណីដែលចលនវត្ថុផ្តុំគ្នា អ្នកធានាដោយវត្ថុអាចចាត់ចែងវត្ថុដែលមានគម្រោងនឹងលក់បាន ដោយសេរី យោងតាមមាត្រា ៨៩៤ កថាខណ្ឌទី ២។

**ឧទាហរណ៍ :** នៅក្នុងករណី ក បានជំពាក់បំណុល ខ ក បានធ្វើអនុប្បទានទំនិញក្នុងហាង ដែលជាចលនវត្ថុផ្តុំគ្នាជាប្រាតិភោគ ដោយ ក នៅតែបន្តការកាន់កាប់ដោយចំពោះ។ បន្ទាប់មក ក បានលក់ទំនិញដែលមានគម្រោងនឹង

លក់តាំងពីដំបូងនោះ ទៅឱ្យ គ ដែលបានដឹងអំពីការកើតសិទ្ធិប្រាតិភោគដោយអនុប្បទានដោយ ក។ នៅក្នុងករណីនេះយោងតាមមាត្រា ៨៩៤ កថាខណ្ឌទី ២ ទោះបីជា គ បានដឹងអំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគប្រត្យក្សរបស់ ខ ក៏ដោយ ក៏ គ អាចធ្វើលទ្ធកម្មកម្មសិទ្ធិនៃទំនិញបានដែរ។ នេះក៏ព្រោះតែទំនិញទាំងនោះ នឹងលែងជាផ្នែកនៃចលនវត្ថុផ្តិត្ត នៅពេលដែលនៅក្រៅទីហ៊ានៃចលនវត្ថុផ្តិត្ត។

### ៣.៥.២. ការចាត់ចែងដោយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន

ក្នុងករណីវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវបានចាត់ចែងដោយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានដែលគាត់បានកាន់កាប់ដោយផ្ទាល់ នោះមាត្រា ៨៩៧ ត្រូវយកមកអនុវត្ត។

នៅក្នុងករណីនៃការចាត់ចែងដោយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន វាមានលក្ខណៈស្រដៀងគ្នាទៅនឹងការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយអ្នកធានាដោយវត្ថុ បញ្ហាគឺនៅត្រង់ថាតើតតិយជនបានបំពេញលក្ខខណ្ឌនៃលទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុដែរ ឬ ទេ។ នៅក្នុងករណីខាងលើ ខ បានធ្វើលទ្ធកម្មនូវការកាន់កាប់ទំនិញនៅក្នុងឃ្លាំងពី ក ហើយដោយគ្មានការយល់ព្រមពី ក ខ បានលក់ទំនិញនោះទៅឱ្យ គ។ គ មិនបានដឹងថាវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញនេះ ជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាននោះទេ។ ក្នុងករណីនេះ គ អាចទទួលបាននូវកម្មសិទ្ធិនៃចលនវត្ថុនោះដោយស្របច្បាប់ ដោយ ក គ្រាន់តែអាចទាមទារសំណងពី ខ។ ផ្ទុយទៅវិញ បើសិនជា គ មានកំហុស ឬ ជាជនទុច្ចរិត ក អាចទទួលបាននូវចលនវត្ថុនោះត្រឡប់មកវិញបាន។

### ៣.៦. បញ្ញត្តិពិសេសនៅក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានកាន់កាប់វត្ថុដែលជាកម្មវត្ថុ

មាត្រា ៨៩៦ ចែងថា បញ្ញត្តិនៃមាត្រា ៨២១ (អានុភាពនៃការឃាត់ទុក) មាត្រា ៨២៣ (ករណីយកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ចាំក្នុងការរក្សាទុកនូវវត្ថុបញ្ចាំ) និង មាត្រា ៨២៤ (សិទ្ធិទាមទារឱ្យសងសោហ៊ុយរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ) ត្រូវយកមកអនុវត្តដូចគ្នាចំពោះករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬតតិយជនដែលបានទទួលការបញ្ជាពីម្ចាស់សិទ្ធិនោះ កាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុ។ មូលហេតុ គឺដោយសារទំនាក់ទំនងរវាងម្ចាស់សិទ្ធិ និង វត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន គឺស្រដៀងគ្នានឹងទំនាក់ទំនងរវាងម្ចាស់សិទ្ធិលើការបញ្ចាំ និង វត្ថុដែលជាកម្មវត្ថុ។

## ៤. ការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន

មានវិធីពីរយ៉ាង ក្នុងការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន។ ទី ១ គឺការប្តូរវត្ថុដែលជាកម្មវត្ថុជាប្រាក់ ហើយទី ២ គឺអនុប្បទានជាស្ថាពរ យោងតាមមាត្រា ៨៩៨ កថាខណ្ឌទី ១។

**ឧទាហរណ៍ :** ក គឺជាអ្នកលក់ដុំ ហើយគាត់មានបំណងចង់ខ្ចីប្រាក់ពី ខ។ ខ ទាមទារឱ្យដាក់ប្រាតិភោគទើបខ្លួនព្រមឱ្យខ្ចីប្រាក់។ ក មិនមានអចលនវត្ថុនោះទេ ហេតុដូច្នេះ ក និង ខ បានព្រមព្រៀងគ្នាថា ក ធ្វើអនុប្បទានកម្មសិទ្ធិលើចលនវត្ថុនៅក្នុងឃ្លាំងជាប្រាតិភោគ ហើយ ក បានផ្ទេរការកាន់កាប់ដោយប្រយោលទៅឱ្យ ខ តាមរយៈ

ការប្តូរលក្ខណៈនៃការកាន់កាប់ ដើម្បីពង្រឹងសិទ្ធិប្រាតិភោគដោយអនុប្បទានចំពោះតតិយជន។ ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលត្រូវបានធានាគឺចំនួន ២០០ ដុល្លារ ប៉ុន្តែ ក មិនបានសងនោះទេ។ ខ មានបំណងចង់អនុវត្តសិទ្ធិប្រាតិភោគរបស់ខ្លួន។ ដូចនេះ មានវិធី ២ យ៉ាងដែល ខ អាចជ្រើសរើសបាន។

### ៤.១. ការប្តូរជាប្រាក់

ក្នុងករណីដល់កាលបរិច្ឆេទកំណត់សង តែ ក មិនសងទេនោះ ខ អាចធ្វើការចាត់ចែងវត្ថុដែលជាកម្មវត្ថុនោះជាប្រាក់ដោយខ្លួនគាត់បាន ដោយគ្រាន់តែជូនដំណឹងទៅអ្នកបង្កើតសិទ្ធិប្រាតិភោគ។

### ៤.២. អនុប្បទានជាស្ថាពរ

ក្រៅពីជម្រើសនៃការចាត់ចែងដោយការប្តូរជាប្រាក់ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានអាចប្រើជម្រើសដោយធ្វើអនុប្បទានជាស្ថាពរ មានន័យថាយកវត្ថុដែលជាកម្មវត្ថុជាកម្មសិទ្ធិតែម្តង។

### ៤.៣.ករណីយកិច្ចត្រូវបង់ទឹកប្រាក់ដែលលើស

ផ្អែកតាមមាត្រា ៨៩៨ កថាខណ្ឌទី ៣ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវបង់នូវចំនួនទឹកប្រាក់ដែលលើសពីចំនួនទឹកប្រាក់កាតព្វកិច្ចទៅអ្នកបង្កើតវិញដោយចាត់ទុកជាប្រាក់ជម្រះ។ មានន័យថា ទោះបីជាម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានប្រើជម្រើសណាមួយក៏ដោយ ក៏ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានមានករណីយកិច្ចត្រូវបង់ចំនួនទឹកប្រាក់ដែលលើសដោយចាត់ជាប្រាក់ជម្រះ បើតម្លៃនៃវត្ថុមានចំនួនលើសទឹកប្រាក់នៃកាតព្វកិច្ចដែលត្រូវសង យោងតាមមាត្រា ៨៩៨ កថាខណ្ឌទី៣។

### ៤.៤. សិទ្ធិទទួលយកមកវិញរបស់អ្នកបង្កើត

ជាគោលការណ៍ បើដល់កាលបរិច្ឆេទសងហើយ ប៉ុន្តែនៅមិនទាន់បានទទួលសំណងនោះ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានអាចប្រើជម្រើសណាមួយក៏បាន ដើម្បីអនុវត្ត តែបើអ្នកបង្កើតបានសង ទោះបីជានៅក្រោយពេលកំណត់សងក៏ដោយ ប៉ុន្តែនៅមុនពេលបង់ប្រាក់ដែលលើសនោះ កម្មសិទ្ធិត្រូវផ្ទេរទៅឱ្យអ្នកបង្កើតវិញ។

ក្រោយដល់ពេលកំណត់សង ខ បានជូនដំណឹងទៅ ក ហើយបានយកទំនិញនោះពីក្នុងឃ្លាំងដើម្បីប៉ាន់ស្មានតម្លៃ ហើយលក់ទំនិញទាំងនោះ។ មុនពេលបញ្ចប់ការវាយតម្លៃ ក ពិតជាមានសំណាងដោយមានទឹកប្រាក់គ្រប់គ្រាន់ដើម្បីសងបំណុល ហើយបានទាមទារឱ្យ ខ ប្រគល់ទំនិញនោះត្រឡប់មកវិញ។ ក្នុងករណីនេះ ក អាចមានសិទ្ធិទាមទារបាន។ ប៉ុន្តែបើ ខ លក់ឱ្យ គ ហើយនោះ ក ពុំអាចទាមទារមកវិញទេ តែអាចទាមទារសំណងបាន ពីព្រោះសិទ្ធិទទួលបានមកវិញត្រូវរលត់ ដោយការបញ្ចប់ការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន។

# ឧបសម្ព័ន្ធ ៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០២៥ សហវ.ប្រក

[illegible]

ថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ2010

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០១០

# ប្រកាស

## ស្តីពី

## ការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និង អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៤ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការចាត់តាំងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជានាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/១២០៨/០២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩
- បានឃើញ ក្រឹត្យច្បាប់លេខ ៣៨ ក្រ.ច ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៨៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៨
- បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និង អនុក្រឹត្យលេខ ២០អនក្រ/បក ចុះថ្ងៃទី ២៩ ខែ មិនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងការកែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១៣៤.អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និង រដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៩ លើលិខិតលេខ ១១៦៨ សហវ ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០៩ ស្តីពីការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ
- យោងតាមចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១០ លើលិខិតលេខ ០៨១ សហវ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១០ ស្តីពីការគ្រប់គ្រង ការត្រួតពិនិត្យ និងការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន
- បានឃើញ ប្រកាសលេខ ៥៨៤ សហវ.ប្រក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួល ការរៀបចំ និង ការប្រព្រឹត្តទៅនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

### ប្រការ១: គោលដៅ

ប្រកាសនេះមានគោលដៅអនុវត្តចំពោះប្រតិបត្តិការខ្ចីប្រាក់ដែលមានវត្ថុដាក់ធានាជាទ្រព្យផ្សេងៗ នៅកន្លែងអាជីវកម្មស្របច្បាប់ណាមួយដែលមានទីតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រៅពីគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ដែលស្ថិតនៅក្រោមច្បាប់ស្តីពី គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ។

### ប្រការ២: គោលបំណង

ប្រកាសនេះមានគោលបំណងកំណត់នូវវិធានការជាមូលដ្ឋានគ្រឹះសម្រាប់គ្រប់គ្រងអាជីវកម្មដើម្បី :

-កែលំអ និងតម្រង់ទិសដល់ប្រតិបត្តិការអាជីវកម្ម ឱ្យអនុវត្តបានត្រឹមត្រូវស្របតាមក្រមសីលធម៌វិជ្ជាជីវៈ ។

-ការដាក់បញ្ចាំ ឬដាក់ប្រាតិភោគដោយអនុប្បទានទ្រព្យសម្បត្តិ ឬរបស់របរ ឬទំនិញផ្សេងៗ ធ្វើឡើងតាមរយៈកន្លែងអាជីវកម្មដែលទទួលបានអាជ្ញាប័ណ្ណពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីងាយស្រួលដល់ការគ្រប់គ្រង និង កាត់បន្ថយបាននូវហានិភ័យមួយចំនួនដែលអាចកើតមានឡើងជាយថាហេតុ ។

-សម្រួលដល់វិនិយោគិន និងប្រជាពលរដ្ឋដែលមានបំណងដាក់បញ្ចាំ ឬដាក់ប្រាតិភោគដោយអនុប្បទានទ្រព្យសម្បត្តិ ឬរបស់របរ ឬទំនិញផ្សេងៗឱ្យទទួលបាននូវសេវាល្អប្រសើរ និងតម្លៃមួយសមស្របតាមថ្លៃទីផ្សារ ។

-បង្កើនការគ្រប់គ្រងការពារសន្តិសុខសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គមតាមរយៈការត្រួតពិនិត្យ ការពារអំពើចោរកម្មទ្រព្យសម្បត្តិ ។

-បង្កើនភាពជឿទុកចិត្តដល់អតិថិជន អាជីវករ និងអ្នកទិញទ្រព្យពីកន្លែងអាជីវកម្ម

-ធានាការទូទាត់ និងរក្សាទុកទ្រព្យដែលអាចទទួលយកបានរវាងអតិថិជន និងអាជីវករ

-បង្កើនប្រាក់ចំណូលជាតិតាមរយៈការយកពន្ធអាករ និងការបង់ថ្លៃសេវាផ្សេងៗ

ប្រការ៣: និយមន័យ

- "**ក្រសួង**" សំដៅដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- "**អាជីវកម្ម**" សំដៅដល់អាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ ឬ អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន ។

- "**អាជីវករ**" សំដៅដល់អ្នកទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ ឬអ្នកទទួលប្រាតិភោគដោយអនុប្បទាន ដែលជារូបវន្តបុគ្គល ឬនីតិបុគ្គលសញ្ជាតិខ្មែរដែលបានចុះបញ្ជីពាណិជ្ជកម្មស្របច្បាប់ ដើម្បីប្រកបអាជីវកម្មឱ្យខ្ចីប្រាក់ដោយយកទ្រព្យផ្សេងៗដាក់ធានា ។

- "**បញ្ចាំ**" សំដៅទៅលើការណ៍ដែលអតិថិជនដាក់នូវចលនវត្ថុ ឯកសារបញ្ជាក់សិទ្ធិកាន់កាប់អចលនវត្ថុ ឬឯកសារផ្សេងៗ ជាមួយអាជីវករ ដើម្បីធានាដល់ការទូទាត់សងប្រាក់កម្ចី និងការប្រាក់ ។

- "**ប្រាតិភោគដោយអនុប្បទាន**" សំដៅទៅលើការណ៍ដែលអតិថិជនធ្វើអនុប្បទាននូវចលនវត្ថុរបស់ខ្លួនជាកំណាត់ជាមួយអាជីវករ ដើម្បីធានាដល់ការទូទាត់សងប្រាក់កម្ចី និងការប្រាក់ ។

- "**អតិថិជន**" សំដៅដល់អ្នកដាក់បញ្ចាំ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទានដែលជា រូបវន្តបុគ្គល ឬនីតិបុគ្គលដែលយកទ្រព្យសម្បត្តិ ឬរបស់របរ ឬទំនិញផ្សេងៗទៅដាក់ធានាជាមួយនឹងអាជីវករ ដើម្បីទទួលបានប្រាក់កម្ចី ។

- "**កិច្ចសន្យា**" សំដៅដល់កិច្ចសន្យាបញ្ចាំ ឬកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន ដែលធ្វើឡើងរវាងអតិថិជនជាមួយនឹងអាជីវករលើការដាក់ទ្រព្យធានា ។

- "**កន្លែងអាជីវកម្ម**" សំដៅដល់ហាងទទួលបញ្ចាំ ឬក្រុមហ៊ុនទទួលបញ្ចាំ ឬហាងទទួលប្រាតិភោគដោយអនុប្បទាន ឬក្រុមហ៊ុនទទួលប្រាតិភោគដោយអនុប្បទានរូបភាព : អាគារ លំនៅដ្ឋាន ឃ្លាំង ឬទីកន្លែង អាជីវកម្មផ្សេងៗទៀតដែលត្រូវបានជ្រើសរើសដើម្បីធ្វើជាទីកន្លែងសម្រាប់ធ្វើអាជីវកម្ម ។

- "**ទ្រព្យ**" សំដៅដល់ទ្រព្យបញ្ចាំរួមមានចលនវត្ថុ ឬឯកសារបញ្ជាក់សិទ្ធិកាន់កាប់អចលនវត្ថុ និងឯកសារផ្សេងៗ ដែលជាកម្មវត្ថុយកមកដាក់បញ្ចាំ និង សំដៅដល់ទ្រព្យប្រាតិភោគដោយអនុប្បទានដែលមានចលនវត្ថុជាកម្មវត្ថុយកមកដាក់ធ្វើប្រាតិភោគដោយអនុប្បទាន ។

- "**អាជ្ញាប័ណ្ណ**" សំដៅដល់លិខិតអនុញ្ញាតប្រកបអាជីវកម្មទទួលបញ្ចាំ ឬអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- "**លោះ**" គឺជាការទទួលយកមកវិញនូវទ្រព្យ ដែលបានមកពីការសងប្រាក់កម្ចីរួមទាំងការប្រាក់របស់អតិថិជន ជូនទៅអាជីវករដូចដែលមានចែងនៅក្នុងកិច្ចសន្យា ។

## ប្រការ៤: ការអនុញ្ញាតធ្វើអាជីវកម្ម

គ្មានរូបវន្តបុគ្គល ឬនីតិបុគ្គលណាម្នាក់អាចធ្វើអាជីវកម្មបានទេ ប្រសិនបើគ្មានអាជ្ញាប័ណ្ណពីក្រសួង ។

## ប្រការ៥: ការដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ

រូបវន្តបុគ្គល ឬនីតិបុគ្គលទាំងអស់ដែលកំពុងធ្វើអាជីវកម្ម ឬមានបំណងចង់ធ្វើអាជីវកម្មត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណនៅក្រសួង ។

ពាក្យស្នើសុំអាជ្ញាប័ណ្ណ ត្រូវបានរៀបចំជូនដោយនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ប្រការ៦: ថ្លៃអាជ្ញាប័ណ្ណ

អាជីវករត្រូវបង់ថ្លៃអាជ្ញាប័ណ្ណដូចខាងក្រោម :

សំរាប់អាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ

- អាជ្ញាប័ណ្ណថ្មីចំនួន ២.០០០.០០០ រៀល (ពីរលានរៀល)
- បន្តអាជ្ញាប័ណ្ណចំនួន ២.០០០.០០០ រៀល (ពីរលានរៀល)
- អាជ្ញាប័ណ្ណសាខាចំនួន ១.០០០.០០០ រៀល (មួយលានរៀល)
- បន្តអាជ្ញាប័ណ្ណសាខាចំនួន ១.០០០.០០០ រៀល (មួយលានរៀល)

សំរាប់អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន

- អាជ្ញាប័ណ្ណថ្មីចំនួន ១.០០០.០០០ រៀល (មួយលានរៀល)
- បន្តអាជ្ញាប័ណ្ណចំនួន ១.០០០.០០០ រៀល (មួយលានរៀល)
- អាជ្ញាប័ណ្ណសាខាចំនួន ៥០០.០០០ រៀល (ប្រាំសែនរៀល)
- បន្តអាជ្ញាប័ណ្ណសាខាចំនួន ៥០០.០០០ រៀល (ប្រាំសែនរៀល)

អាជីវករត្រូវបង់ប្រាក់ថ្លៃអាជ្ញាប័ណ្ណដូចមានចែងខាងលើទៅអគ្គនាយកដ្ឋានរតនាគារជាតិ ឬធនាគារជាតិនៃកម្ពុជា តាមដីការអមរបស់នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ប្រការ៧: សុពលភាព និងការបន្តសុពលភាពអាជ្ញាប័ណ្ណ

អាជ្ញាបណ្ណ័មានសុពលភាពរយៈពេល ០១ ឆ្នាំ (មួយឆ្នាំ) គិតចាប់ពីថ្ងៃចុះហត្ថលេខា ។

អ្នកកាន់អាជ្ញាប័ណ្ណត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពឱ្យបាន ៣០ ថ្ងៃ (សាមសិបថ្ងៃ) មុនពេលអាជ្ញាប័ណ្ណនោះអស់សុពលភាព ។

ក្រសួងមានសិទ្ធិបន្តអាជ្ញាប័ណ្ណដោយមានដាក់ ឬមិនមានដាក់លក្ខខណ្ឌ ឬមិនបន្តអាជ្ញាប័ណ្ណប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណមិនបានបំពេញទៅតាមលក្ខខណ្ឌតម្រូវណាមួយដែលក្រសួងបានកំណត់ ។

ក្នុងករណីអ្នកកាន់អាជ្ញាប័ណ្ណមិនបន្តសុពលភាពអាជ្ញាប័ណ្ណ ត្រូវជូនដំណឹងជាលាយល័ក្ខអក្សរដោយភ្ជាប់មកជាមួយ នូវឯកសារពាក់ព័ន្ធព្រមទាំងបញ្ជាក់អំពីមូលហេតុអោយបានត្រឹមត្រូវមកក្រសួងក្នុងរយៈពេល ៣០ ថ្ងៃ (សាមសិបថ្ងៃ) មុន ។

## ប្រការ៨: លក្ខខណ្ឌនៃការផ្តល់អាជ្ញាប័ណ្ណ

ក្រសួងនឹងផ្តល់អាជ្ញាប័ណ្ណ ជូនដល់អាជីវករទាំងឡាយណាដែលបានបំពេញលក្ខខណ្ឌដូចខាងក្រោម :

-ជារូបវន្តបុគ្គលដែលមានសញ្ជាតិខ្មែរ ហើយមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ ឬនីតិបុគ្គលមានសញ្ជាតិខ្មែរដែលបានបំពេញបែបបទ និងចុះបញ្ជីត្រឹមត្រូវតាមច្បាប់

-លិខិតថ្កោលទោស ឬលិខិតបញ្ជាក់កិរិយាមារយាទដែលចេញដោយក្រសួងយុត្តិធម៌ ឬតុលាការពាក់ព័ន្ធ

-បានចុះបញ្ជីពាណិជ្ជកម្មស្របច្បាប់នៅក្រសួងពាណិជ្ជកម្ម

-មានអាស័យដ្ឋានស្នាក់នៅច្បាស់លាស់ក្នុងព្រះរាជាណាចក្រកម្ពុជា

-ត្រូវបង្ហាញពីកន្លែងសុវត្ថិភាពដើម្បីធានាថែរក្សា និងការពារការខូចខាត ឬការបាត់បង់ទ្រព្យ

-សំរាប់អាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំត្រូវមានដើមទុនអាជីវកម្មអប្បបរមាចំនួន ៨០.០០០.០០០ រៀល (ប៉ែតសិបលានរៀល) និងដាក់ប្រាក់តំកល់ចំនួន ១០% នៃដើមទុនអាជីវកម្ម ឬប្រាក់តំកល់អតិបរមាចំនួន ៤០.០០០.០០០ រៀល (សែសិបលានរៀល) នៅក្នុងគណនីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានចែងនៅក្នុងសៀវភៅបន្ទុក ។

-សំរាប់អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន ត្រូវមានដើមទុនអាជីវកម្មអប្បបរមាចំនួន ៤០.០០០.០០០ រៀល (សែសិបលានរៀល) និងដាក់ប្រាក់តំកល់ចំនួន ១០% នៃដើមទុនអាជីវកម្ម ឬប្រាក់តំកល់អតិបរមាចំនួន ៤០.០០០.០០០ រៀល (សែសិបលានរៀល) នៅក្នុងគណនីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានចែងនៅក្នុងសៀវភៅបន្ទុក ។

-អាជីវករអាចដកប្រាក់តំកល់ខាងលើមកវិញបាន លុះត្រាតែមានការអនុញ្ញាតពីក្រសួងដូចដែលមានចែងនៅក្នុងសៀវភៅបន្ទុក ។

-ត្រូវមានលិខិតបញ្ជាក់អាស័យដ្ឋានកន្លែងអាជីវកម្មអោយបានច្បាស់លាស់ពីអាជ្ញាធរមូលដ្ឋាន

-មានកំរិតវប្បធម៌ចាប់ពីថ្នាក់បរិញ្ញាបត្រ ឬប្រហាក់ប្រហែលផ្នែកសេដ្ឋកិច្ច ឬពាណិជ្ជកម្ម ឬនីតិសាស្ត្រ ឬវិញ្ញាបនប័ត្រផ្សេងៗទៀតដែលទាក់ទងនឹងអាជីវកម្ម ឬមានបទពិសោធន៍ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងផ្នែកអាជីវកម្ម ឬធ្លាប់បំរើការងារផ្នែកនេះពីមុន ។

-មានសមត្ថភាពក្នុងការទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពទាំងការនិយាយ ការសរសេរ និងមានសមត្ថភាពក្នុងការរៀបចំរបាយការណ៍ដែលមានទំរង់បែបបទត្រឹមត្រូវ ។

-បង្ហាញពីម្ចាស់ភាគហ៊ុន នាយកក្រុមហ៊ុន អ្នកគ្រប់គ្រងផ្នែកផ្សេងៗ និងឈ្មោះបុគ្គលិកដែលបំរើការងារនៅក្នុងកន្លែងអាជីវកម្មអោយបានច្បាស់លាស់ ។

-បានបង់ថ្លៃអាជ្ញាប័ណ្ណដូចមានចែងក្នុងប្រការ ៦ នៃប្រកាសនេះ

-ភ្ជាប់គំរូស្លាកសញ្ញា និងត្រារបស់កន្លែងអាជីវកម្ម ព្រមទាំងហត្ថលេខារបស់អ្នកកាន់អាជ្ញាប័ណ្ណ

ការកំណត់លក្ខខណ្ឌផ្សេងទៀត អាចនឹងតម្រូវបន្ថែមដោយក្រសួង ។

## ប្រការ៩: លក្ខខណ្ឌនៃការមិនផ្តល់អាជ្ញាប័ណ្ណ

ក្រសួងមិនផ្តល់អាជ្ញាប័ណ្ណប្រកបអាជីវកម្មជូនអ្នកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណទាំងឡាយណាដែលស្ថិតនៅក្នុងលក្ខខណ្ឌដូចខាងក្រោម :

-ផ្តល់ព័ត៌មានមិនពិតចំពោះចំណុចណាមួយដែលមានចែងក្នុងប្រការ ៨ នៃប្រកាសនេះ

-មិនបានផ្តល់ព័ត៌មានដែលខ្វះចន្លោះណាមួយដែលមានចែងក្នុងប្រការ៨ នៃប្រកាសនេះមកអោយក្រសួងក្នុង

រយៈពេល ១៥ថ្ងៃ (ដប់ប្រាំថ្ងៃ) បន្ទាប់ពីការទទួលសំណើសុំជាលាយលក្ខណ៍អក្សរពីក្រសួងដល់អ្នកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ ។

## ប្រការ១០: ភារកិច្ចនៃអាជីវករ (អ្នកកាន់អាជ្ញាប័ណ្ណ)

អ្នកកាន់អាជ្ញាប័ណ្ណមានភារកិច្ចដូចតទៅ :

១-ត្រូវអនុវត្តតាមរាល់បទដ្ឋានផ្សេងៗដែលចេញដោយក្រសួង

២-ត្រូវការពារ និងលើកកំពស់អត្ថប្រយោជន៍អតិថិជនរបស់ខ្លួន ហើយភារកិច្ចតំណាងមួយទៀតគឺមិនត្រូវគេចវេសពីការទទួលខុសត្រូវចំពោះភាគីដទៃទៀតដែលពាក់ព័ន្ធក្នុងកិច្ចការអាជីវកម្មរបស់ខ្លួនឡើយ

៣-ត្រូវមានស្លាកសញ្ញាអាជីវកម្មនៅពីមុខកន្លែងធ្វើអាជីវកម្ម ហើយអាជ្ញាប័ណ្ណត្រូវរក្សានៅក្នុងបការ ឬក្រុមហ៊ុនដែលកំពុងប្រកបអាជីវកម្ម និងត្រូវដាក់តាំងនៅកន្លែងដែលងាយមើលឃើញ

៤-ត្រូវមានសៀវភៅចុះបញ្ជីទ្រព្យ សៀវភៅបោះទ្រព្យ និងសៀវភៅកំណត់ចំណាយប្រចាំខែ និងឯកសារផ្សេងៗដែលពាក់ព័ន្ធ ។ ដោយទំរង់នៃសៀវភៅទាំងនោះនឹងមានបញ្ជាក់នៅក្នុងសៀវភៅបន្ទុក

៥-ត្រូវចេញកិច្ចសន្យាឱ្យទៅអតិថិជន ។ ទំរង់នៃកិច្ចសន្យានឹងមានបញ្ជាក់នៅក្នុងសៀវភៅបន្ទុក

៦-ត្រូវសរសេរជាលាយល័ក្ខអក្សរ ដើម្បីជៀសវាងការយល់ខុសពីគ្នាទៅវិញទៅមកនូវរាល់ការលើកលែងការសន្យា និងការធានាលើសេវាជាក់លាក់ណាមួយចំពោះអតិថិជន

៧-ត្រូវពិនិត្យអោយបានល្អិតល្អន់មុនពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀងណាមួយ ដោយបញ្ជាក់ជូនទៅភាគីម្ខាងទៀតអំពីលក្ខខណ្ឌដែលភាគីនីមួយៗត្រូវទទួលខុសត្រូវ

៨-ត្រូវរក្សាទុកទ្រព្យនៅកន្លែងមានសុវត្ថិភាព និងមិនត្រូវយកទ្រព្យនោះទៅប្រើប្រាស់ឡើយ

៩-អាជីវករត្រូវទទួលខុសត្រូវទាំងស្រុងចំពោះការខូចខាតលើទ្រព្យដែលកើតឡើងក្នុងអំឡុងពេលជាប់កិច្ចសន្យា

១០-ត្រូវផ្តល់ជូនអតិថិជននូវសេវាប្រកបដោយការយកចិត្តទុកដាក់ខ្ពស់

១១-ត្រូវផ្តល់ព័ត៌មានជាបន្ទាន់ឱ្យនគរបាល ឬសមត្ថកិច្ចពាក់ព័ន្ធ ក្នុងករណីមានការសង្ស័យបទល្មើសនៃអតិថិជន ឬទ្រព្យណាមួយ

១២-ត្រូវផ្តល់ព័ត៌មាន ឬរបាយការណ៍អំពីអត្តសញ្ញាណនៃអតិថិជន និងទ្រព្យ (សៀវភៅចុះបញ្ជីទ្រព្យ) ជូនប៉ុស្តិ៍នគរបាលរដ្ឋបាល ឬសមត្ថកិច្ចដែលមានទីតាំងនៅជិតកន្លែងអាជីវកម្មយ៉ាងយូររយៈពេល ០៣ថ្ងៃ (បីថ្ងៃ) បន្ទាប់ពីការបរិច្ឆេទទទួលទ្រព្យ

១៣-ត្រូវតាមដាននូវរាល់សភាពការណ៍ដែលអាចជះឥទ្ធិពលដល់លក្ខខណ្ឌទីផ្សារបច្ចុប្បន្ន ដើម្បីផ្តល់ជាដំបូន្មានដល់អតិថិជនរបស់ខ្លួន និង/ឬដើម្បីជួយអតិថិជនក្នុងលក្ខណៈមួយដែលមានការទទួលខុសត្រូវ

១៤-ត្រូវធានាថារាល់ការព្រមព្រៀងដែលពាក់ព័ន្ធទៅនឹងកិច្ចសន្យា ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរដោយប្រើប្រាស់ពាក្យពេចន៍ច្បាស់ៗ និងងាយយល់ ព្រមទាំងមានការបញ្ជាក់អោយបានច្បាស់លាស់នូវរាល់លក្ខខណ្ឌភារកិច្ច និង រាល់អនុសាសន៍ដែលភាគីពាក់ព័ន្ធបានព្រមព្រៀងគ្នា ។ រាល់កិច្ចសន្យាដែលបានពិនិត្យនិងចុះហត្ថលេខា ត្រូវតែថតចំលងដើម្បីចែកជូនដល់ភាគីដែលពាក់ព័ន្ធ

១៥-ត្រូវធានាថារាល់ការបង្ហាញនៅក្នុងការផ្សាយពាណិជ្ជកម្មគឺជាការពិត ហើយរាល់ការផ្សព្វផ្សាយអំពីទ្រព្យ

សម្បត្តិ ប្រភេទទាំងអស់ត្រូវតែមានបញ្ជាក់ពីអត្តសញ្ញាណរបស់កន្លែងអាជីវកម្ម និងឈ្មោះបុគ្គលដែលទទួលបានអាជ្ញាប័ណ្ណ

១៦-ត្រូវរក្សាទុកអោយបានល្អនូវសៀវភៅកត់ត្រា ឯកសារអាជីវកម្ម និងលិខិតស្នាមផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងប្រតិបត្តិការអាជីវកម្ម

១៧-ត្រូវបិទផ្សាយថ្ងៃ និងពេលវេលាម៉ោងធ្វើការរបស់ខ្លួន នៅនឹងច្រកទ្វារចេញ-ចូលនៃកន្លែងអាជីវកម្មឱ្យបានត្រឹមត្រូវ។ នៅថ្ងៃ ឬម៉ោងដែលប្រកាសបិទមិនធ្វើការនោះ មិនត្រូវទទួលបញ្ចាំ ឬទទួលប្រាតិភោគដោយអនុប្បទាន និងប្រមូលការប្រាក់ឡើយ ។ អាជីវករត្រូវជូនដំណឹងទៅក្រសួងអំពីការផ្លាស់ប្តូរពេលវេលាធ្វើការដែលបានបិទនៅលើច្រកទ្វារចេញ-ចូល

១៨-ត្រូវផ្តល់របាយការណ៍ពីប្រតិបត្តិការអាជីវកម្មដោយភ្ជាប់បញ្ជីទ្រព្យមកក្រសួងរៀងរាល់ខែ និងរៀងរាល់ដំណាច់ឆ្នាំ

១៩-មិនត្រូវផ្តល់ប្រាក់កម្ចីដល់អតិថិជន ០១ នាក់ ឬ ០១ ក្រុម លើសពី ២០% នៃដើមទុនអាជីវកម្មនោះឡើយ

២០-មិនត្រូវផ្តល់ប្រាក់កម្ចីលើសពី ២០.០០០.០០០ រៀល សំរាប់ឯកសារបញ្ជាក់សិទ្ធិកាន់កាប់អចលនវត្ថុ ឬឯកសារផ្សេងៗដែលជាកម្មវត្ថុយកមកដាក់បញ្ចាំ

២១-មិនត្រូវធ្វើអាជីវកម្មខុសពីឈ្មោះ ឬអាស័យដ្ឋានរបស់ខ្លួនដែលបានចុះក្នុងអាជ្ញាប័ណ្ណនោះទេ

២២-មិនត្រូវបង្កវិវាទឬជំពាក់ក្នុងការធ្វើអាជីវកម្មជាមួយអាជីវករដទៃទៀតឡើយ

២៣-មិនត្រូវផ្តល់ព័ត៌មាន ឬលាតត្រដាងអំពីអតិថិជនឬអំពីកិច្ចការនិងទំនាក់ទំនងរបស់ខ្លួនឡើយ

២៤-មិនអាចធ្វើការផ្លាស់ប្តូរទីកន្លែងធ្វើអាជីវកម្ម ដោយគ្មានការជូនដំណឹងជាមុនយ៉ាងតិច ៣០ថ្ងៃ (សាមសិបថ្ងៃ) ទៅក្រសួងបានឡើយ

២៥-មិនត្រូវទទួលយកទ្រព្យអ្វីមួយពីអនីតិជន ឬពីជនណាដែលកំពុងមានជាតិស្រវឹងជោគជាំក្នុងខ្លួន ឬពីជនណាដែលខ្លួនបានសង្ស័យថាជាចោរ ឬអ្នកទទួលផលចោរកម្ម។

២៦-មិនត្រូវឱ្យអតិថិជនផ្តិតមេដៃលើកិច្ចសន្យា ឬកំណត់ត្រាផ្សេងៗដែលមិនទាន់បានបំពេញត្រឹមត្រូវពេញលេញនោះឡើយ

២៧-មិនត្រូវធ្វើអាជីវកម្មដើម្បីបំរើដល់សកម្មភាពសំអាតប្រាក់ ឬបំរើផលប្រយោជន៍ដល់ភេរវករ ឬឧក្រិដ្ឋជនណាមួយឡើយ។ ក្នុងករណីដែលសង្កេតឃើញមានសកម្មភាពនេះ សាមីជនត្រូវរាយការណ៍ជាបន្ទាន់មកក្រសួង ឬអាជ្ញាធរមានសមត្ថកិច្ច

២៨-នៅពេលមានការស្នើសុំអោយផ្តល់យោបល់ ឬវាយតំលៃវត្ថុអ្វីមួយ អាជីវករត្រូវគិត និងធ្វើការវិភាគឱ្យបានល្អិតល្អន់នូវរាល់កត្តាដែលអាចជះឥទ្ធិពលដល់តំលៃវត្ថុត្រូវដាក់បញ្ចាំ ឬដាក់ប្រាតិភោគដោយអនុប្បទាន មុននឹងជំរាបជូនដល់អតិថិជនរបស់ខ្លួន។

## ប្រការ១១: ការផ្ទេរអាជ្ញាប័ណ្ណ

អាជ្ញាប័ណ្ណមិនអាចផ្ទេរទៅអោយអ្នកផ្សេងបានឡើយ លុះត្រាតែមានការអនុញ្ញាតពី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

### ប្រការ១២: ការផ្អាកសកម្មភាពអាជីវកម្ម និងការបញ្ឈប់អាជីវកម្ម

ក្នុងករណីផ្អាក ឬបញ្ឈប់សកម្មភាពអាជីវកម្ម អ្នកកាន់អាជ្ញាប័ណ្ណត្រូវដាក់សំណើជាលាយលក្ខណ៍អក្សរដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ ព្រមទាំងបញ្ជាក់អំពីមូលហេតុអោយបានត្រឹមត្រូវមកក្រសួងក្នុងរយៈពេល ៣០ថ្ងៃ (សាមសិបថ្ងៃ) មុនអាជីវកម្មត្រូវបានផ្អាក ឬបញ្ឈប់សកម្មភាពជាស្ថាពរ ។ ការសំរេចលើការផ្អាក ឬបញ្ឈប់សកម្មភាពអាជីវកម្មជាសិទ្ធិរបស់ក្រសួង ។

ក្រោយពីបញ្ឈប់អាជីវកម្មហើយ អ្នកកាន់អាជ្ញាប័ណ្ណត្រូវប្រគល់អាជ្ញាប័ណ្ណមកក្រសួងវិញ ។

### ប្រការ១៣: ការព្យួរ ឬដកហូតអាជ្ញាប័ណ្ណ

ក្រសួងមានសិទ្ធិព្យួរ ឬដកហូតអាជ្ញាប័ណ្ណមកវិញ នៅពេលដែលអ្នកកាន់អាជ្ញាប័ណ្ណបានប្រព្រឹត្តដូចករណីណាមួយដូចខាងក្រោម :

-ពុំបានអនុវត្តអោយបានត្រឹមត្រូវទៅតាមខ្លឹមសារនៃប្រកាសនេះឬលិខិតបទដ្ឋានផ្សេងៗទៀតដែលចេញដោយក្រសួង

-ក្រោយពីទទួលបានការណែនាំពីក្រសួងគ្រប់ទាំងទទួលពិន័យរដ្ឋបាលហើយ អ្នកកាន់អាជ្ញាប័ណ្ណនៅតែបន្តប្រព្រឹត្តល្មើសទៅនឹងលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងប្រកាសនេះ

-អ្នកកាន់អាជ្ញាប័ណ្ណខកខានមិនបានបំពេញកាតព្វកិច្ចពិនិត្យវត្ថុមាន កាតព្វកិច្ចបង់ពន្ធ និងចំណូលផ្សេងៗជូនរដ្ឋ លើសពី ០២ ខែ (ពីរខែ) ជាប់គ្នា

-ការលើកឡែងអាជីវកម្មក្ស័យធន ឬប្រព្រឹត្តិបទល្មើសក្នុងការធ្វើអាជីវកម្មណាមួយ ក្រសួងនឹងជូនដំណឹងជាលាយលក្ខណ៍អក្សរ ៣០ថ្ងៃ (សាមសិបថ្ងៃ) មុន ចំពោះការឡែងអាជីវកម្មដែលនឹងត្រូវដកហូតអាជ្ញាប័ណ្ណ និងចុះផ្សាយអោយសាធារណៈជនបានជ្រាប ឬអាចស្នើទៅតុលាការដើម្បីរឹបអូស ឬឃាត់ទុកវត្ថុដែលដាក់បញ្ចាំ ឬដាក់ប្រាតិភោគដោយអនុប្បទាន ។

### ប្រការ១៤: ការចាត់ចែងលើទ្រព្យ

-ក្នុងករណីអតិថិជនពុំមានលទ្ធភាពសងប្រាក់កម្ចី និងការប្រាក់តាមការកំណត់នៅពេលកិច្ចសន្យាដល់កាលវសាន្ត ការចាត់ចែងលើទ្រព្យមានដូចខាងក្រោម:

+សំរាប់អាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ ទ្រព្យបញ្ចាំនឹងត្រូវចាត់ចែងតាមនីតិវិធីច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

+សំរាប់អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន ទ្រព្យប្រាតិភោគដោយអនុប្បទាននឹងត្រូវចាត់ចែងតាមលទ្ធភាពជាក់ស្តែង ឬនីតិវិធីច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

-ក្នុងករណីអតិថិជនបានសងប្រាក់កម្ចី និងការប្រាក់គ្រប់ចំនួនដូចមានចែងក្នុងកិច្ចសន្យា នោះអាជីវករត្រូវប្រគល់ទ្រព្យទៅឱ្យអតិថិជនវិញភ្លាម ។

អាជីវករមិនមានសិទ្ធិលក់ ផ្ទេរ ឬប្រគល់សិទ្ធិកាន់កាប់ទ្រព្យអោយទៅអ្នកផ្សេងក្នុងកំឡុងពេលដែលទ្រព្យនេះកំពុងជាប់កិច្ចសន្យា លុះត្រាតែមានការឯកភាពពីអតិថិជន ។

**ប្រការ១៥: ការកំណត់អត្រាការប្រាក់ និង រយៈពេលបញ្ចាំ**

-អត្រាការប្រាក់ត្រូវបានកំណត់តាមការព្រមព្រៀងរវាងអាជីវករ និងអតិថិជន ។ ប៉ុន្តែការព្រមព្រៀងលើអត្រាការប្រាក់នេះមិនត្រូវអោយខ្ពស់ពីច្បាប់កំណត់នោះឡើយ ។

-កិច្ចសន្យាមានរយៈពេលយ៉ាងយូរត្រឹម ០៤ ខែ (បួនខែ) គិតពីថ្ងៃចុះហត្ថលេខានៃការដាក់ទ្រព្យ និងអាចបន្តសុពលភាពបាន ។

**ប្រការ១៦: ការកាត់កិច្ចពន្ធលើអាជីវកម្ម**

អាជីវករត្រូវបង់ពន្ធទៅអគ្គនាយកដ្ឋានពន្ធដារជាតិ តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ១៧: ការបង្កើតសាខា**

អាជីវករអាចបង្កើតសាខាបាន លុះត្រាតែមានការអនុញ្ញាតពីក្រសួង ហើយត្រូវសុំអាជ្ញាប័ណ្ណសម្រាប់សាខាអាជីវកម្មដោយបំពេញលក្ខខណ្ឌទាំងឡាយដូចមានចែងនៅក្នុងប្រការ ៨ នៃប្រកាសនេះ ។

**ប្រការ១៨: របាយការណ៍អាជីវកម្មប្រចាំខែ**

អាជីវករត្រូវផ្តល់ស្ថិតិ និងរបាយការណ៍អាជីវកម្មប្រចាំខែមកក្រសួងមិនអោយលើសពី ១៥ថ្ងៃ នៃខែ បន្ទាប់ ។ ស្ថិតិ និងរបាយការណ៍នោះត្រូវបញ្ជាក់ថាពិត និងត្រឹមត្រូវដោយអ្នកកាន់អាជ្ញាប័ណ្ណ ។

**ប្រការ១៩: របាយការណ៍អាជីវកម្មប្រចាំឆ្នាំ**

ក្នុងរយៈពេល ០៣ ខែ (បីខែ) ក្រោយពីបញ្ចប់ឆ្នាំនីមួយៗ អាជីវករត្រូវផ្តល់ឱ្យក្រសួងនូវរបាយការណ៍អាជីវកម្ម នៃឆ្នាំសារពើពន្ធកន្លងមក ។

**ប្រការ២០: ការត្រួតពិនិត្យបញ្ជី**

ក្រសួងអាចចាត់មន្ត្រីជំនាញ ដើម្បីចុះត្រួតពិនិត្យឯកសារផ្សេងៗដែលពាក់ព័ន្ធទៅនឹងការធ្វើអាជីវកម្មតាមការចាំបាច់ ។ អាជីវករត្រូវសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីរបស់ក្រសួង ។

**ប្រការ២១: ការដាក់ពិន័យរដ្ឋបាល**

អាជីវករទាំងឡាយណាដែលល្មើសទៅនឹងបទប្បញ្ញត្តិ និងលក្ខខណ្ឌនានាដែលមានចែងក្នុងប្រកាសនេះនឹងត្រូវទទួលទណ្ឌកម្មដូចជា ទទួលការដាក់ពិន័យ ការព្យួរ ឬការដកហូតអាជ្ញាប័ណ្ណ ដូចមានចែងនៅក្នុងសៀវភៅបន្ទុក ។ ក្នុងករណីចាំបាច់ក្រសួងមានសិទ្ធិប្តឹងទៅតុលាការដើម្បីអនុវត្តទណ្ឌកម្មខាងលើ ។

**ប្រការ២២: ការអនុវត្តតាមសៀវភៅបន្ទុក**

អ្នកកាន់អាជ្ញាប័ណ្ណត្រូវអនុវត្តរាល់លក្ខខណ្ឌដែលមានចែងនៅក្នុងសៀវភៅបន្ទុក ស្តីពីលក្ខខណ្ឌអនុវត្តអាជ្ញាប័ណ្ណសំរាប់អាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន ។

**ប្រការ២៣: អវសានប្បញ្ញត្តិ**

បទប្បញ្ញត្តិ ឬ លិខិតបទដ្ឋានទាំងឡាយណាដែលផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ២៤: ការអនុវត្តប្រកាស**

អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងប្រធាននាយកដ្ឋាន និងអង្គភាព ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កន្លែងអាជីវកម្ម និងបុគ្គលដែលពាក់ព័ន្ធ ត្រូវអនុវត្ត និងប្រតិបត្តិតាមខ្លឹមសារនៃប្រកាសនេះអោយមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ២៥: សុពលភាពនៃការអនុវត្តប្រកាស**

ប្រកាសនេះមានតំលៃអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ចំលងជូន :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សាលារាជធានី ខេត្ត
  "ដើម្បីជូនជ្រាប និងសហការអនុវត្ត"
- ដូចប្រការ ២៤
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ ៤

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចសន្យាខ្ចីប្រាក់-ដាក់បញ្ចាំ

រវាងខ្ញុំបាទ-នាងខ្ញុំឈ្មោះ...............................អាយុ.........ឆ្នាំ.............កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិ.......លេខ................................ ចុះថ្ងៃទី........ខែ.........ឆ្នាំ.............មានទីលំនៅ ផ្ទះលេខ............ ផ្លូវលេខ........... ក្រុមទី............ ភូមិ.................. ឃុំ/សង្កាត់................ ស្រុក/ខណ្ឌ..................ខេត្ត/ក្រុង/រាជធានី...................... ហៅកាត់ថា ភាគី "ក" ម្ចាស់ប្រាក់។

**និង**

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ................................ អាយុ.........ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិ.......លេខ................................ ចុះថ្ងៃទី........ខែ.........ឆ្នាំ............ មានទីលំនៅ ផ្ទះលេខ............ ផ្លូវលេខ........... ក្រុមទី............ ភូមិ.................. ឃុំ/សង្កាត់................ ស្រុក/ខណ្ឌ...............ខេត្ត/ក្រុង/រាជធានី...................... ហៅកាត់ថា ភាគី "ខ" ជាអ្នកខ្ចីប្រាក់។

*ភាគី "ក" និងភាគី "ខ" បានព្រមព្រៀង តាមប្រការដូចខាងក្រោម៖*

<u>ប្រការ១៖</u> ភាគី "ក" យល់ព្រមឱ្យភាគី "ខ" ខ្ចីប្រាក់ចំនួន...........ដុល្លារ (...............................)

ភាគី "ខ" បានទទួលចំនួនទឹកប្រាក់នេះ នៅពេលចុះកិច្ចសន្យាចំពោះមុខសាក្សី និងមេធាវី។

<u>ប្រការ២៖</u> ភាគី "ខ" យល់ព្រមបង់ការប្រាក់ឱ្យភាគី "ក" ហើយភាគី "ក" យល់ព្រមទទួលការប្រាក់ពីភាគី "ខ" ក្នុងអត្រាព្រមព្រៀង............ភាគរយ ក្នុង១ខែ ស្មើនឹង............................... (...........................) នៃប្រាក់ដែលបានខ្ចី។ រយៈពេល.......................នៃការខ្ចីប្រាក់ គិតចាប់ពីថ្ងៃទី.......ខែ.......... ឆ្នាំ.......... រហូតដល់ថ្ងៃទី.......ខែ..........ឆ្នាំ...........។

<u>ប្រការ៣៖</u> ភាគី "ខ" យល់ព្រមបង់ការប្រាក់ឱ្យ ភាគី "ក" នៅថ្ងៃទី...................ដើមខែនិមួយៗ។ ភាគី "ក" យល់ព្រម ឱ្យភាគី "ខ" បង់សងនូវចំនួនទឹកប្រាក់ខ្ចីទាំងអស់ ឬមួយផ្នែកណានោះ នៃកិច្ចសន្យានៅពេលណាក៏បានក្នុងពេលអនុវត្តកិច្ចសន្យានេះ បើកាលណាភាគី "ខ" មាន បំណងចង់ចេញសងរួមទាំងប្រាក់ដើមនិងការប្រាក់ផង។ ក្នុងករណីភាគី "ខ" ពុំបានបង់ការប្រាក់ ក្នុងរយៈពេល០៣ខែជាប់ៗគ្នា

នោះ ភាគី "ខ" យល់ព្រមឱ្យភាគី "ក" ប្រើសិទ្ធិ របស់ខ្លួនក្នុងការ បញ្ឈប់ ឬបញ្ចប់កិច្ចសន្យានេះបាន ដោយឯកតោភាគី ។

ប្រការ៤៖ យោងកិច្ចសន្យានេះ ដើម្បីធានាលើការបំពេញកាតព្វកិច្ចភាគី "ខ" បានដាក់ចលនទ្រព្យធានា មានដូចជា:

| ល.រ | រាយមុខទ្រព្យសម្បត្តិដាក់បញ្ចាំ |
|---|---|
| ១ | ចលនទ្រព្យទី១............................................ |
| ២ | ចលនទ្រព្យទី២............................................ |

<u>ប្រការ៥៖</u> កិច្ចសន្យានេះធ្វើឡើងជាភាសាខ្មែរចំនួន ០៣ច្បាប់ សម្រាប់ភាគី "ក" និងភាគី "ខ" រក្សាទុក ចំនួន ០១ច្បាប់ម្នាក់ មេធាវី ០១ច្បាប់។

<u>ប្រការ៦៖</u> កិច្ចសន្យានេះធ្វើឡើងរវាងភាគី "ក" និងភាគី "ខ" ដោយគ្មានការបង្ខិតបង្ខំពីភាគីណាមួយ ឡើយ ហើយកិច្ចសន្យានេះមានសុពលភាពនៅពេលដែលចុះហត្ថលេខា និងផ្តិតស្នាមមេដៃស្តាំ ជាកស្តុតាង។

ធ្វើនៅ............., ថ្ងៃទី......... ខែ............. ឆ្នាំ.............

**ភាគី "ខ"** **សាក្សីភាគី "ខ"** **សាក្សីភាគី "ក"** **ភាគី "ក"**

ឈ្មោះ.......................... ឈ្មោះ.......................... ឈ្មោះ.......................... ឈ្មោះ..........................

បានឃើញ និង បញ្ជាក់ថា

ភាគីទាំងពីរបានផ្តិតមេដៃស្តាំ ចំពោះមុខមេធាវី

ប្រាកដមែន ។

ធ្វើនៅ.............ថ្ងៃទី.........ខែ..........ឆ្នាំ.........

**មេធាវី**

# ឧបសម្ព័ន្ធ ៥

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## <u>កិច្ចព្រមព្រៀងប្រាតិភោគ</u>

**ម្ចាស់សិទ្ធិប្រាតិភោគ៖** ឈ្មោះ.........ភេទ... អាយុ... ជនជាតិ... កាន់អត្តសញ្ញាណប័ណ្ណលេខ......... ចុះថ្ងៃទី..... ខែ...... ឆ្នាំ......... មានទីលំនៅបច្ចុប្បន្នផ្ទះលេខ......... ក្រុមទី... ភូមិ........ ឃុំ/សង្កាត់........ ស្រុក/ខណ្ឌ.......... ខេត្ត/រាជធានី............... ជាម្ចាស់បំណុល ហៅកាត់ថា ភាគី "ក" ។

**អ្នកបង្កើតប្រាតិភោគ៖** ឈ្មោះ.........ភេទ... អាយុ... ជនជាតិ... កាន់អត្តសញ្ញាណប័ណ្ណលេខ......... ចុះថ្ងៃទី..... ខែ...... ឆ្នាំ......... មានទីលំនៅបច្ចុប្បន្នផ្ទះលេខ......... ក្រុមទី... ភូមិ........ ឃុំ/សង្កាត់........ស្រុក/ខណ្ឌ..........ខេត្ត/រាជធានី...............ជាកូនបំណុល/អ្នកធានាកាតព្វកិច្ចដោយវត្ថុ ហៅកាត់ថា ភាគី "ខ" ។

**ភាគីទាំងពីរ បានព្រមព្រៀង និងឯកភាពគ្នាដោយសុឆន្ទៈអនុវត្តន៍តាមប្រការដូចខាងក្រោម៖**

**ប្រការ១៖** ភាគី "ក" បានឲ្យភាគី "ខ" ខ្ចីប្រាក់ចំនួន..............................ដុល្លារអាមេរិកគត់។

**ប្រការ២៖** ភាគី "ខ" បានទទួលប្រាក់ចំនួន ......................... ដុល្លាអារមេរិកគត់ ពីភាគី "ក"
នៅថ្ងៃទី... ខែ...... ឆ្នាំ..... សម្រាប់រយៈពេល........... គិតចាប់ពីថ្ងៃចុះកិច្ចសន្យារហូតដល់ ថ្ងៃទី... ខែ....... ឆ្នាំ........... នឹងត្រូវសងប្រាក់ជំពាក់ឲ្យមកភាគី "ក" វិញយ៉ាងយូរត្រឹមថ្ងៃទី..... ខែ........ ឆ្នាំ..........។

**ប្រការ៣៖** ថ្ងៃនេះ ភាគី "ខ" បានផ្ទេរកម្មសិទ្ធិនៃទ្រព្យសម្បត្តិដែលបានរៀបរាប់ខាងក្រោម (ការពណ៌នាពី "លក្ខណៈនៃទ្រព្យសម្បត្តិ") ទៅភាគី "ក" ក្នុងគោលបំណងធានាសិទ្ធិលើបំណុលរបស់ភាគី "ក" សម្រាប់ការទូទាត់សងប្រាក់ពីភាគី "ខ" ដែលបានខ្ចីដោយយោងលើប្រការ១ និង ប្រការ២ នៃកិច្ចសន្យានេះ។

## ការពណ៌នាពីលក្ខណៈនៃទ្រព្យសម្បត្តិ

**ប្រការ៤៖** ថ្ងៃនេះ ភាគី "ខ" បានផ្ទេរការកាន់កាប់នៃទ្រព្យសម្បត្តិទៅភាគី "ក" ដោយការប្តូរលក្ខណៈនៃការ កាន់កាប់។

**ប្រការ៥៖** ភាគី "ក" យល់ព្រម និងបានអនុញ្ញាតឲ្យភាគី "ខ" បន្តការកាន់កាប់ និងប្រើប្រាស់ទ្រព្យសម្បត្តិ នោះ ហើយភាគី "ខ" បានយល់ព្រម។

**ប្រការ៦៖** ភាគី "ខ" ត្រូវចាត់វិធានការសមស្របជូនដំណឹងជាសាធារណៈពីទ្រព្យសម្បត្តិដែលស្ថិតនៅក្រោម សិទ្ធិប្រាតិភោគដោយអនុប្បទានរបស់ភាគី "ក"។ ប្រសិនបើភាគី "ខ" មិនចាត់វិធានការណាមួយទេ នោះភាគី "ក" អាចចាត់វិធានការជំនួសភាគី "ខ" ហើយនៅក្នុងករណីនេះ ភាគី "ក" អាចទាមទារ សំណងនៃការចំណាយក្នុងការចាត់វិធានការនោះពី ភាគី "ខ"។

**ប្រការ៧៖** ក្នុងអំឡុងពេលខ្ចីប្រាក់ ភាគី "ខ" បានយល់ព្រមបង់ការប្រាក់ .......... ស្មើ .....% ក្នុងមួយខែ នៅលើចំនួនទឹកប្រាក់សរុបទៅភាគី "ក" យ៉ាងយូរនៅថ្ងៃទី.... ខែ...... ឆ្នាំ ..........។

**ប្រការ៨៖** ភាគី "ខ" នឹងបាត់បង់ផលប្រយោជន៍នៃការកំណត់ពេលនៅក្នុងករណីដូចខាងក្រោមនេះ៖

(១). ភាគី "ខ" បានផ្ទេរកម្មសិទ្ធិនៃទ្រព្យសម្បត្តិនោះទៅតតិយជនមួយដោយគ្មានការយល់ព្រម ពី ភាគី "ក"។

(២). ភាគី "ខ" ដកយកចេញវិធានការនៃការជូនដំណឹងតាមប្រការ៦ នៃកិច្ចសន្យានេះ។

**ប្រការ៩៖** ការកែប្រែណាមួយនៃកិច្ចសន្យា ឬបន្ថែមខ្លឹមសារផ្សេងៗអាចធ្វើទៅបាន លុះត្រាតែមានការយល់ ព្រម និងកិច្ចព្រមព្រៀងពីភាគីទាំងសងខាង។

# ឧបសម្ព័ន្ធ ៦

# ទទួលបញ្ចាំកាតគ្រឿងយាន

# គ្រប់ប្រភេទ



សេវាកម្មរហ័សទាន់ចិត្ត

ទំនាក់ទំនង070 80 60 40/ 011 80 60 40